ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# ប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុ

## ចក្ខុវិស័យឆ្នាំ ២០៣៨

ប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុ ចក្ខុវិស័យឆ្នាំ ២០៣៨

រៀបចំដោយ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

បោះពុម្ពផ្សាយលើកទី១

ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥, ខែកញ្ញា ឆ្នាំ២០២១

# ប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុ

## ចក្ខុវិស័យឆ្នាំ២០៣៨

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

លេខ: ០៤៥ សសរ

**សេចក្តីសម្រេច**

**ស្តីពី**

**ការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុ**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអស្សាមិករណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់

អាសយដ្ឋាន: ពិឡូត៍លេខ ២០០៩ ផ្លូវលេខ ៣០៧ សង្កាត់ឬស្សីកែវ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ (855) 23 886 999 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា២ និងមាត្រា៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានឃើញអនុក្រឹត្យលេខ៧៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការរៀបចំដែនដីខេត្តព្រះសីហនុ
- បានឃើញសេចក្តីសម្រេចលេខ០៤១ សសរ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ
- យោងតាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុនិងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តព្រះសីហនុ

**សម្រេច**

**ប្រការ១.-**

ត្រូវបានដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុ ដែលមានចក្ខុវិស័យដល់ឆ្នាំ២០៣៥ ដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយសេចក្តីសម្រេចនេះ។

**ប្រការ២.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តព្រះសីហនុ និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងព្រះសីហនុត្រូវរៀបចំផែនការសម្រាប់អនុវត្តប្លង់គោលប្រើប្រាស់ដីខាងលើនេះឱ្យមានប្រសិទ្ធភាព និងត្រូវរាយការណ៍អំពីវឌ្ឍនភាពជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៣.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងព្រះសីហនុ ត្រូវធ្វើបច្ចុប្បន្នភាពប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុក្នុងរយៈពេល៥(ប្រាំ)ឆ្នាំម្តង តាមករណីចាំបាច់នៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ ការកែសម្រួលប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុមុនពេលកំណត់ អាចប្រព្រឹត្តទៅបានក្នុងករណីដែលមានតម្រូវការចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈឬផលប្រយោជន៍ជាតិ។

ការកែសម្រួលប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុ ត្រូវអនុវត្តតាមនីតិវិធីដែលមានចែងនៅក្នុងសេចក្តីសម្រេចលេខ០៤១ សសរ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៥.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុនិងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តព្រះសីហនុ និងអភិបាលនៃគណៈអភិបាលក្រុងព្រះសីហនុនិងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងព្រះសីហនុ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] [illegible] ខែ[illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

**ជា សុផារ៉ា**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃសេចក្ដីសម្រេចលេខ ០៤៥ សសរ ចុះថ្ងៃ សុក្រ ១៥កើត ខែកត្ដិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ត្រូវនឹងថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ២០២១

ស្ដីពីការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុ

# ប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុ

## ចក្ខុវិស័យឆ្នាំ២០៣៨

# មាតិកា

ទំព័រ


១-សេចក្តីផ្តើម ---------- ១

២-ក្របខណ្ឌសង្គម-សេដ្ឋកិច្ច និងចក្ខុវិស័យ ---------- ២

២.១-ក្របខណ្ឌសង្គម-សេដ្ឋកិច្ច ---------- ២

២.២-ចក្ខុវិស័យ ---------- ៣

៣-គោលបំណងនិងគោលដៅ ---------- ៤

៣.១-គោលបំណង ---------- ៤

៣.២-គោលដៅ ---------- ៤

៤-យុទ្ធសាស្ត្រអភិវឌ្ឍនិងអភិរក្សក្រុងព្រះសីហនុ ---------- ៤

៤.១-យុទ្ធសាស្ត្រអភិវឌ្ឍនិងអភិរក្សនគរូបនីយកម្ម ---------- ៥

៤.១.១-យុទ្ធសាស្ត្រអភិវឌ្ឍនិងទិសដៅនគរូបនីយកម្ម ---------- ៥

៤.១.២-យុទ្ធសាស្ត្រអភិរក្សនិងអភិវឌ្ឍនគរូបនីយកម្មតំបន់ឆ្នេរសមុទ្រ ---------- ៧

៤.១.៣-យុទ្ធសាស្ត្រអភិរក្សនិងអភិវឌ្ឍកោះ ---------- ២៣

៤.១.៤-យុទ្ធសាស្ត្រអភិវឌ្ឍក្រុងព្រះសីហនុជាទីក្រុងឆ្លាត មានចីរភាព និងប្រកបដោយបរិយាបន្ន- ២៤

៤.២-យុទ្ធសាស្ត្រគ្រប់គ្រងនិងប្រើប្រាស់ដីប្រកបដោយចីរភាព ---------- ២៥

៤.២.១-ប្រភេទដីអាចសាងសង់បាន ---------- ២៥

៤.២.២-ប្រភេទដីកម្រិតការសាងសង់ ---------- ៤៧

៤.៣-យុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ---------- ៥១

៤.៣.១-អ័ក្សនៃការអភិវឌ្ឍភស្តុភារកម្ម ទេសចរណ៍ និងពាណិជ្ជកម្មតាមផ្លូវជាតិ ---------- ៥២

៤.៣.២-អ័ក្សនៃការអភិវឌ្ឍភស្តុភារកម្មនិងឧស្សាហកម្មតាមផ្លូវអេយស្វ័យយានតភ្ជាប់រវាងក្រុង ព្រះសីហនុ និងរាជធានីភ្នំពេញ ---------- ៥២

៤.៣.៣-ផ្លូវថ្នល់និងសេវាដឹកជញ្ជូនសាធារណៈ ---------- ៥៣

៤.៣.៤-ផ្លូវដែក ---------- ៥៥

៤.៣.៥-ផ្លូវទឹកនិងកំពង់ផែ ---------- ៥៥

៤.៣.៦-អាកាសចរស៊ីវិល ---------- ៥៧

៤.៣.៧-ការផ្គត់ផ្គង់ថាមពលនិងអគ្គិសនី ---------- ៥៨

៤.៣.៨-ការផ្គត់ផ្គង់ទឹកស្អាតនិងធនធានទឹក ---------- ៥៨

៤.៣.៩-សមាហរណកម្មហេដ្ឋារចនាសម្ព័ន្ធ ---------- ៥៩

៤.៤-យុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ច ---------- ៥៩

៤.៤.១-យុទ្ធសាស្ត្រអភិវឌ្ឍវិស័យទេសចរណ៍ ---------- ៥៩

៤.៤.២-យុទ្ធសាស្ត្រអភិវឌ្ឍវិស័យឧស្សាហកម្ម ---------- ៦២

៤.៤.៣-យុទ្ធសាស្ត្រអភិវឌ្ឍវិស័យកសិកម្ម ---------- ៦៥

**៤.៥-យុទ្ធសាស្ត្រអភិវឌ្ឍសង្គមកិច្ច ---------- ៦៦**
៤.៥.១-វិស័យអប់រំ ---------- ៦៦
៤.៥.២-វិស័យសុខាភិបាល ---------- ៦៧
៤.៥.៣-ទីក្រុងតំរូវក្នុងការគ្រប់គ្រងនិងអភិបាលកិច្ចល្អប្រកបដោយសេវាទីក្រុង ហេដ្ឋារចនាសម្ព័ន្ធ ទីក្រុង បរិក្ខារទីក្រុង និងផ្តល់ការងារសម្បូរបែប ---------- ៦៧
៤.៥.៤-លម្ហសាធារណៈ សួនច្បារ និងខ្សែក្រវាត់តំបន់បៃតង ---------- ៦៧
៤.៥.៥-បរិក្ខាររូបវន្តនិងវប្បធម៌ ---------- ៦៨
៤.៥.៦-ការអភិវឌ្ឍសង្គមកិច្ច ---------- ៦៨
**៤.៦-យុទ្ធសាស្ត្រការពារបរិស្ថាននិងគ្រប់គ្រងសំណល់ ---------- ៦៩**
៤.៦.១-យុទ្ធសាស្ត្រគ្រប់គ្រងសំណល់រឹង ---------- ៦៩
៤.៦.២-យុទ្ធសាស្ត្រគ្រប់គ្រងសំណល់រាវ ---------- ៧០
៤.៦.៣-ការបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថាន ---------- ៧១
៤.៦.៤-វិធានការចាំបាច់ក្នុងការការពារតំបន់សំខាន់ៗ ---------- ៧២
**៤.៧-យុទ្ធសាស្ត្របង្ការទប់ស្កាត់គ្រោះមហន្តរាយ ---------- ៧២**
៤.៧.១-វិធានការបង្ការគ្រោះមហន្តរាយពីព្រែក អូរ ប្រឡាយ និងផ្លូវទឹកសំខាន់ៗ ---------- ៧២
៤.៧.២-វិធានការការពារការស្ទះផ្លូវទឹកហូរ ---------- ៧២
៤.៧.៣-វិធានការការពារការរាំងស្ទះខ្សែទឹកហូរដោយសារការអភិវឌ្ឍថ្មីៗ ---------- ៧៣
៤.៧.៤-វិធានការបង្ការគ្រោះមហន្តរាយនៅទីចំណោត ---------- ៧៤
៤.៧.៥-វិធានការបង្ការគ្រោះមហន្តរាយតាមតំបន់ឆ្នេរសមុទ្រ ---------- ៧៥
**៤.៨-យុទ្ធសាស្ត្រពង្រឹងអភិបាលកិច្ចល្អ គ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុនៅមូលដ្ឋាន ---------- ៧៧**
**៥-ផែនការសកម្មភាព ---------- ៧៧**
**៥.១-ការអភិរក្សនិងការអភិវឌ្ឍតំបន់នគរូបនីយកម្ម ---------- ៧៧**
**៥.២-ការគ្រប់គ្រងនិងការប្រើប្រាស់ដីប្រកបដោយចីរភាព ---------- ៧៨**
៥.២.១-ការគ្រប់គ្រងការអភិវឌ្ឍលើប្រភេទដីអាចសាងសង់បាននិងប្រភេទដីកម្រិតការសាងសង់- ៧៨
៥.២.២-ការអភិវឌ្ឍលំនៅឋាន ---------- ៧៩
**៥.៣-ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ---------- ៨០**
៥.៣.១-ផ្លូវថ្នល់និងសេវាដឹកជញ្ជូនសាធារណៈ ---------- ៨០
៥.៣.២-ផ្លូវដែក ---------- ៨០
៥.៣.៣-ផ្លូវទឹកនិងកំពង់ផែ ---------- ៨០
៥.៣.៤-អាកាសចរស៊ីវិល ---------- ៨១
៥.៣.៥-ការផ្គត់ផ្គង់ថាមពលនិងអគ្គិសនី ---------- ៨១
៥.៣.៦-ការផ្គត់ផ្គង់ទឹកស្អាតនិងធនធានទឹក ---------- ៨១

**៥.៤-ការអភិវឌ្ឍសេដ្ឋកិច្ច** ---------- ៩២

៥.៤.១-ការអភិវឌ្ឍវិស័យទេសចរណ៍ ---------- ៩២

៥.៤.២-ការអភិវឌ្ឍវិស័យឧស្សាហកម្ម ---------- ៩៤

៥.៤.៣-ការអភិវឌ្ឍវិស័យកសិកម្ម ---------- ៩៧

**៥.៥-ការអភិវឌ្ឍសង្គមកិច្ច** ---------- ៩៨

៥.៥.១-វិស័យអប់រំ ---------- ៩៨

៥.៥.២-វិស័យសុខាភិបាល ---------- ៩៨

៥.៥.៣-ទីក្រុងគំរូក្នុងការគ្រប់គ្រងនិងអភិបាលកិច្ចល្អប្រកបដោយសេវាទីក្រុង ហេដ្ឋារចនាសម្ព័ន្ធទីក្រុង បរិក្ខារទីក្រុង និងផ្តល់ការងារសម្បូរបែប ---------- ៩៩

៥.៥.៤-លម្ហសាធារណៈ សួនច្បារ និងខ្សែក្រវាត់តំបន់បៃតង ---------- ៩៩

៥.៥.៥-បរិក្ខាររូបវត្ថុនិងវប្បធម៌ ---------- ១០០

៥.៥.៦-ការអភិវឌ្ឍសង្គមកិច្ច ---------- ១០០

**៥.៦-ការការពារបរិស្ថាននិងការគ្រប់គ្រងសំណល់** ---------- ១០០

៥.៦.១-ការគ្រប់គ្រងសំណល់រឹង ---------- ១០០

៥.៦.២-ការគ្រប់គ្រងសំណល់រាវ ---------- ១០១

៥.៦.៣-ការបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថាន ---------- ១០៣

៥.៦.៤-វិធានការចាំបាច់ក្នុងការការពារតំបន់សំខាន់ៗ ---------- ១០៣

**៥.៧-ការបង្ការទប់ស្កាត់គ្រោះមហន្តរាយ** ---------- ១០៣

៥.៧.១-ការបង្ការគ្រោះមហន្តរាយពីព្រែក អូរ ប្រឡាយ និងផ្លូវទឹកសំខាន់ៗ ---------- ១០៣

៥.៧.២-ការការពារការស្ទះផ្លូវទឹកហូរ ---------- ១០៤

៥.៧.៣-ការការពារការរាំងស្ទះខ្សែទឹកហូរដោយសារការអភិវឌ្ឍថ្មីៗ ---------- ១០៤

៥.៧.៤-ការបង្ការគ្រោះមហន្តរាយនៅទីចំណោត ---------- ១០៤

៥.៧.៥-ការបង្ការគ្រោះមហន្តរាយតាមតំបន់ឆ្នេរសមុទ្រ ---------- ១០៤

**៦-គម្រោងអាទិភាព** ---------- ១០៥

**៦.១-ការអភិរក្សនិងការអភិវឌ្ឍតំបន់នគរូបនីយកម្ម** ---------- ១០៥

**៦.២-ការគ្រប់គ្រងនិងការប្រើប្រាស់ដីប្រកបដោយចីរភាព** ---------- ១០៥

៦.២.១-ការគ្រប់គ្រងការអភិវឌ្ឍលើប្រភេទដីអាចសាងសង់បាននិងប្រភេទដីកម្រិតការសាងសង់ ១០៥

៦.២.២-ការអភិវឌ្ឍលំនៅឋាន ---------- ១០៦

**៦.៣-ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ** ---------- ១០៦

៦.៣.១-ផ្លូវថ្នល់ សេវាដឹកជញ្ជូនសាធារណៈ និងថាមពល ---------- ១០៦

៦.៣.២-ការផ្គត់ផ្គង់ទឹកស្អាត ---------- ១០៧

**៦.៤-ការអភិវឌ្ឍសេដ្ឋកិច្ច** ---------- ១០៧

៦.៤.១-ការអភិវឌ្ឍវិស័យទេសចរណ៍ ---------- ១០៧

៦.៤.២-ការអភិវឌ្ឍវិស័យឧស្សាហកម្ម ---------- ១០៩

៦.៤.៣-ការអភិវឌ្ឍវិស័យកសិកម្ម ---------- ១១០

**៦.៥-ការអភិវឌ្ឍសង្គមកិច្ច** ---------- ១១១

៦.៥.១-វិស័យអប់រំ ---------- ១១១

៦.៥.២-វិស័យសុខាភិបាល ---------- ១១១

៦.៥.៣-ទីក្រុងតំរូវក្នុងការគ្រប់គ្រងនិងអភិបាលកិច្ចល្អប្រកបដោយសេវាទីក្រុង ហេដ្ឋារចនាសម្ព័ន្ធទីក្រុង បរិក្ខារទីក្រុង និងផ្តល់ការងារសម្បូរបែប ---------- ១១១

៦.៥.៤-លម្ហសាធារណៈ សួនច្បារ និងខ្សែក្រវាត់តំបន់បៃតង ---------- ១១១

៦.៥.៥-បរិក្ខាររូបវន្តនិងវប្បធម៌ ---------- ១១២

៦.៥.៦-ការអភិវឌ្ឍសង្គមកិច្ច ---------- ១១២

**៦.៦-ការការពារបរិស្ថាននិងការគ្រប់គ្រងសំណល់** ---------- ១១២

៦.៦.១-ការគ្រប់គ្រងសំណល់រឹង ---------- ១១២

៦.៦.២-ការគ្រប់គ្រងសំណល់រាវ ---------- ១១២

**៦.៧-ការបង្ការទប់ស្កាត់គ្រោះមហន្តរាយ** ---------- ១១៣

៦.៧.១-ការបង្ការគ្រោះមហន្តរាយពីព្រែក អូរ ប្រឡាយ និងផ្លូវទឹកសំខាន់ៗ ---------- ១១៣

៦.៧.២-ការការពារការស្ទះផ្លូវទឹកហូរ ---------- ១១៣

៦.៧.៣-ការការពារការរាំងស្ទះខ្សែទឹកហូរដោយសារការអភិវឌ្ឍថ្មីៗ ---------- ១១៣

៦.៧.៤-ការបង្ការគ្រោះមហន្តរាយនៅទីចំណោត ---------- ១១៣

៦.៧.៥-ការបង្ការគ្រោះមហន្តរាយតាមតំបន់ឆ្នេរសមុទ្រ ---------- ១១៣

**៧-ផែនការហិរញ្ញវត្ថុ** ---------- ១១៤

**៨-ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ** ---------- ១១៤

**៨.១-យន្តការ** ---------- ១១៤

**៨.២-ច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត** ---------- ១១៤

**៨.៣-ភារកិច្ច នីតិវិធី និងគោលការណ៍** ---------- ១១៥

**៩-សេចក្តីសន្និដ្ឋាន** ---------- ១១៥

**អនុសាសន៍** ---------- ១១៧

**សទ្ទានុក្រម** ---------- ១១៨

**ឯកសារឧបសម្ព័ន្ធ** ---------- ១២៣

**១-សេចក្តីផ្តើម**

ស្ថិតក្នុងបរិការណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ ស្ថេរភាពនយោបាយរឹងមាំ ការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្សនៅក្រោមដំបូលរដ្ឋធម្មនុញ្ញនិងច្បាប់ រាជរដ្ឋាភិបាលបានធានាជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខនៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលបានបន្តជំរុញការកែទម្រង់ស្ថាប័នឱ្យមានសន្ទុះថ្មី មុតស្រួច និងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែក និងគ្រប់វិស័យក្នុងគោលដៅបង្កើន និងកែលម្អការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព និងសក្តិសិទ្ធភាព។

ផ្អែកតាមយុទ្ធសាស្ត្រចតុកោណនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជាសំដៅធានាថាដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជាត្រូវបានគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍតាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្ត្ររៀបចំដែនដីនិងការធ្វើឱ្យប្រសើរនូវវិធាននិងឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយភាពសុខដុមរមនានៅតាមតំបន់ភូមិសាស្ត្រនីមួយៗ។

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ក្នុងមុំទី៣ នៃចតុកោណទី៤ បានផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម និងការអភិវឌ្ឍទីក្រុងតាមរយៈការជំរុញអភិវឌ្ឍនិងពង្រឹងការអនុវត្តគោលនយោបាយ ច្បាប់ និងបទដ្ឋានពាក់ព័ន្ធរួមជាមួយនឹងគោលការណ៍ទីក្រុងឆ្លាតចីរភាព និងបរិយាបន្នសំដៅសម្រេចបានចក្ខុវិស័យកម្ពុជានៅឆ្នាំ២០៣០ ក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ និងនៅឆ្នាំ២០៥០ ក្លាយជាប្រទេសមានចំណូលខ្ពស់។

ក្នុងគោលបំណងធានាការគ្រប់គ្រង ការពារ អភិរក្ស និងអភិវឌ្ឍនគរូបនីយកម្ម ការគ្រប់គ្រងការប្រើប្រាស់ដី និងធនធានធម្មជាតិ ព្រមទាំងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រខេត្តព្រះសីហនុ ប្រកបដោយភាពឆ្លាតចីរភាព និងបរិយាបន្ន គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិដឹកនាំដោយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់បានគាំទ្របច្ចេកទេសកសាងប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុចក្ខុវិស័យឆ្នាំ២០៣៥ ដែលមានវិសាលភាពគ្របដណ្តប់ក្រុងព្រះសីហនុ ផ្នែកខ្លះនៃឃុំបិតត្រាំងនិងឃុំរាម ស្រុកព្រៃនប់ និងផ្នែកខ្លះនៃឃុំកំពេញ ឃុំទំនប់រលក និងឃុំអូរត្រេះ ស្រុកស្ទឹងហាវ ក្នុងគោលដៅតម្រង់ទិសការគ្រប់គ្រងនិងការអភិវឌ្ឍដែនដីក្រុងព្រះសីហនុស្របតាមចក្ខុវិស័យនៃផែនការរៀបចំដែនដីខេត្តព្រះសីហនុចក្ខុវិស័យឆ្នាំ២០៣០ ដោយផ្អែកលើសក្តានុពលទីតាំងភូមិសាស្ត្រនិងអនុលោមតាមគោលនយោបាយដីធ្លី "សៀវភៅសដីធ្លី" គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយជាតិស្តីពីលំនៅឋាន គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍទេសចរណ៍ បើពិនិត្យលើផ្នែកគតិយុត្តសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងការរៀបចំដែនដីនិងនគរូបនីយកម្មនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដូចជាច្បាប់ស្តីពីសំណង់ ច្បាប់ស្តីពីភូមិបាល ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីអស្សាមិករណ៍ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត

ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ អនុក្រឹត្យស្តីពីតំបន់ទេសចរណ៍ពិសិដ្ឋ អនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ សារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេចស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំអភិវឌ្ឍន៍រមណីយដ្ឋានឆ្នេរសមុទ្រ ប្រកាសអន្តរក្រសួងស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងឆ្នេរខ្សាច់កម្សាន្ត និងសេចក្តីសម្រេចស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌជាដើម។

ដោយមើលឃើញថាសក្តានុពលតំបន់ឆ្នេរសមុទ្រមានសារៈសំខាន់ដល់សេដ្ឋកិច្ច រាជរដ្ឋាភិបាលកម្ពុជាបានកែលម្អនិងពង្រីកកំពង់ផែស្វយ័តក្រុងព្រះសីហនុឱ្យក្លាយទៅជាកំពង់ផែទំនើប និងពង្រីកអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុឱ្យមានប្រសិទ្ធភាពខ្ពស់ដែលជាច្រកទ្វារសម្រាប់ការដឹកជញ្ជូន ធ្វើដំណើរ ទេសចរណ៍ និងពាណិជ្ជកម្មជាអន្តរជាតិ។

ចក្ខុវិស័យនៃប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុ មានលក្ខណៈទូលំទូលាយគ្របដណ្តប់ទាំងទិដ្ឋភាពគតិយុត្តនិងបច្ចេកទេសសម្រាប់ធ្វើការសម្របសម្រួលរវាងវិស័យនានា ដែលជាកម្លាំងចលករសេដ្ឋកិច្ច សំដៅធ្វើការតម្រង់ទិសការអភិវឌ្ឍប្រកបដោយភាពឆ្លាត ចីរភាព និងបរិយាបន្ន ឆ្លើយតបទៅនឹងកំណើនប្រជាសាស្ត្រនិងតម្រូវការប្រើប្រាស់ដីសម្រាប់ការអភិវឌ្ឍនគរូបនីយកម្ម រូបវន្ត សង្គម សេដ្ឋកិច្ច ពាណិជ្ជកម្ម សេវាកម្ម ទេសចរណ៍ ស័ក្តិសមជាតំបន់សេដ្ឋកិច្ចពិសេសតំរុយពហុបំណង ដោយធានាបាននូវការការពារធនធានដី ប្រព័ន្ធអេកូឡូស៊ី បរិស្ថាន និងធនធានធម្មជាតិ ដែលអាចរងការបំផ្លាញដោយសារសកម្មភាពអភិវឌ្ឍឬដោយសារការប្រែប្រួលអាកាសធាតុ ដូចជាការបំភាយឧស្ម័នផ្ទះកញ្ចក់ ការកើនឡើងនៃកម្តៅក្នុងទីក្រុង របបទឹកភ្លៀងមិនទៀងទាត់ ទឹកជំនន់ ភាពរាំងស្ងួត ខ្យល់ព្យុះជាដើម។

## ២-ក្របខណ្ឌសង្គម-សេដ្ឋកិច្ច និងចក្ខុវិស័យ

### ២.១-ក្របខណ្ឌសង្គម-សេដ្ឋកិច្ច

ប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុ ចក្ខុវិស័យឆ្នាំ២០៣៥ ត្រូវបានរៀបចំឡើងដោយបានប្រមូល សិក្សា និងវិភាគទិន្នន័យរូបវន្ត ទិន្នន័យសេដ្ឋកិច្ច ទិន្នន័យសង្គម ទិន្នន័យបរិស្ថាន ទិន្នន័យប្រជាសាស្ត្រ និងការស្រង់មតិ សមស្របតាមគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយដីធ្លី "សៀវភៅសដីធ្លី" អនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងសេចក្តីសម្រេចស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

ដើម្បីកំណត់ចក្ខុវិស័យដល់ឆ្នាំ២០៣៥ ប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុ ត្រូវបានសិក្សាក្របខណ្ឌសង្គម-សេដ្ឋកិច្ច ដោយផ្អែកលើសក្តានុពលសេដ្ឋកិច្ច ទីតាំងភូមិសាស្ត្រតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ក្របខណ្ឌជាតិ តំបន់ និងអន្តរជាតិ ព្រមទាំងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ គោលនយោបាយដីធ្លី "សៀវភៅសដីធ្លី" គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយតាមវិស័យសំខាន់ៗជាច្រើនទៀតរបស់រាជរដ្ឋាភិបាល លទ្ធផលនៃជំរឿនទូទៅនូវប្រជាសាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨ និងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩។ វិសាលភាពនៃការសិក្សាប្លង់គោលប្រើ

ប្រាស់ដីក្រុងព្រះសីហនុនិងតំបន់ជុំវិញមានផ្ទៃដី២៧៩,៣៤គីឡូម៉ែត្រក្រឡា ដែលក្នុងនោះគ្របដណ្តប់លើក្រុងព្រះសីហនុមានផ្ទៃដី៨៣,៤០គីឡូម៉ែត្រក្រឡា គ្របដណ្តប់លើស្រុកព្រៃនប់មានផ្ទៃដី១០០,៨២គីឡូម៉ែត្រក្រឡា និងគ្របដណ្តប់លើស្រុកស្ទឹងហាវមានផ្ទៃដី៩៥,១២គីឡូម៉ែត្រក្រឡា។ សូចនាករសំខាន់ៗសម្រាប់ការអភិវឌ្ឍក្រុងព្រះសីហនុនិងតំបន់ជុំវិញដែលបានធ្វើការព្យាករណ៍និងគ្រោងសម្រេចបានត្រឹមឆ្នាំ២០៣៨ មាន៖

- ប្រជាជនសម្រាប់ក្រុងព្រះសីហនុនិងតំបន់ជុំវិញនៅឆ្នាំ២០១៩ មានចំនួន១៧៨ ២៩១នាក់នឹងកើនឡើងដល់ចំនួន២៣២ ១២១នាក់នៅឆ្នាំ២០៣៨
- ភ្ញៀវទេសចរអន្តរជាតិនៅឆ្នាំ២០១៨ មានចំនួន៨៨១ ០០០នាក់នឹងកើនឡើងដល់ចំនួន២ ៥០០ ០០០នាក់នៅឆ្នាំ២០៣៨។ ភ្ញៀវទេសចរជាតិនៅឆ្នាំ២០១៨ មានចំនួនប្រមាណ១ លាននាក់នឹងកើនឡើងដល់ចំនួនប្រមាណ៥ លាននាក់នៅឆ្នាំ២០៣៨
- ហេដ្ឋារចនាសម្ព័ន្ធក្នុងក្រុងព្រះសីហនុនិងតំបន់ជុំវិញ៖
  - ផ្លូវក្រាលកៅស៊ូឬបេតុងនៅឆ្នាំ២០១៨ មានចំនួន២០,៥%នឹងកើនឡើងដល់ចំនួន១០០% នៅឆ្នាំ២០៣៨
  - ការផ្គត់ផ្គង់ទឹកស្អាតនៅឆ្នាំ២០១៨ មានចំនួន៣២,០%នឹងកើនឡើងដល់ចំនួន១០០% នៅឆ្នាំ២០៣៨។
- ភស្តុភារកម្មនៅឆ្នាំ២០១៨ មានចំនួន៤,៩លានតោននឹងកើនឡើងដល់ចំនួន៣៧,២លានតោននៅឆ្នាំ២០៣៨
- តំបន់លំនៅឋាននៅឆ្នាំ២០១៩ មានផ្ទៃដី១ ៦៣១ហិកតានឹងកើនឡើងដល់ផ្ទៃដី៥ ៩០៤,៧៦ហិកតានៅឆ្នាំ២០៣៨
- តំបន់ឧស្សាហកម្មនៅឆ្នាំ២០១៩ មានផ្ទៃដី៨២៩ហិកតានឹងកើនឡើងដល់ផ្ទៃដី១ ៦០២,១៤ហិកតានៅឆ្នាំ២០៣៨
- តំបន់លម្ហសាធារណៈនិងផ្ទៃបៃតងសម្រាប់មនុស្សម្នាក់នៅឆ្នាំ២០១៩ មានផ្ទៃដី០,៥១ម៉ែត្រក្រឡាសម្រាប់មនុស្សម្នាក់នឹងកើនឡើងដល់ផ្ទៃដី១០ម៉ែត្រក្រឡាសម្រាប់មនុស្សម្នាក់នៅឆ្នាំ២០៣៨។

### ២.២-ចក្ខុវិស័យ

ចក្ខុវិស័យដល់ឆ្នាំ២០៣៨ នៃប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុ គឺសំដៅរៀបចំនិងអភិវឌ្ឍ “**ក្រុងព្រះសីហនុជាទីក្រុងស្នូលនៃប៉ូលអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាពនៅតំបន់ឆ្នេរសមុទ្រកម្ពុជាក្នុងការជំរុញកំណើនសេដ្ឋកិច្ច អភិវឌ្ឍន៍ធុរកិច្ច ពាណិជ្ជកម្ម និងទេសចរណ៍ប្រកបដោយភាពរស់រវើក ឆ្លាត និងបរិយាបន្ន**” តាមរយៈការអភិវឌ្ឍ៖ ១)ទីក្រុងទំនើបបៃតងប្រកបដោយភាពច្នៃប្រឌិតរស់រវើកនិងបរិស្ថានរស់នៅល្អប្រសើរបំផុត ២)តំបន់សេដ្ឋកិច្ចពិសេសពហុបំណង មជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិ និងមជ្ឈមណ្ឌលកំណើនថ្មី ៣)រមណីយដ្ឋានឆ្នេរសមុទ្រនិងកោះដែលស្អាតបំផុតលើសកលលោកសម្រាប់ការស្នាក់នៅ លម្ហែកាយ និងការកម្សាន្ត ៤)មជ្ឈមណ្ឌលគាំទ្រឧស្សាហកម្មផលិតកម្មបែបបច្ចេកវិទ្យាទំនើប នវានុវត្តន៍ ៥)ច្រកចេញចូលអន្តរជាតិនិងភស្តុភារកម្មជាតិដែលមានទំនាក់ទំនងជាមួយទីផ្សារអាស៊ាននិងសកលលោក ៦)ទីក្រុងឆ្លាតវៃក្នុងការគ្រប់គ្រងនិងអភិបាលកិច្ចល្អប្រកបដោយសេវាទីក្រុង ហេដ្ឋារចនាសម្ព័ន្ធទីក្រុង បរិក្ខារទីក្រុង និងផ្តល់ការងារសម្បូរបែប។

## ៣-គោលបំណងនិងគោលដៅ

ដើម្បីសម្រេចចក្ខុវិស័យខាងលើ ប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុ មានគោលបំណងនិងគោលដៅដូចខាងក្រោម៖

### ៣.១-គោលបំណង

ប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុ មានគោលបំណងផ្តល់ក្របខណ្ឌនិងទិសដៅសម្រាប់ការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍក្រុងព្រះសីហនុប្រកបដោយភាពរស់រវើក ភាពឆ្លាត និងបរិយាបន្ន។

### ៣.២-គោលដៅ

ប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុ មានគោលដៅ៖

- កំណត់យុទ្ធសាស្ត្រគ្រប់គ្រងនគរូបនីយកម្ម និងការប្រើប្រាស់ដី ប្រកបដោយប្រសិទ្ធភាព ចីរភាព ភាពឆ្លាត បរិយាបន្ន និងសមាហរណកម្ម
- ជំរុញកំណើនសេដ្ឋកិច្ច អភិវឌ្ឍធុរកិច្ច តំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ទាក់ទាញគាំទ្រដល់ការវិនិយោគសាធារណៈនិងឯកជនដើម្បីសមធម៌សង្គមនិងផ្តល់ការងារ
- លើកកម្ពស់ឧស្សាហកម្ម កសិកម្ម និងពាណិជ្ជកម្មជាតិនិងអន្តរជាតិ
- លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការគ្រប់គ្រង ការកែលម្អ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឱ្យមានតុល្យភាពទាំងនៅក្នុងទីក្រុងនិងនៅតំបន់ជុំវិញ
- ការពារ អភិរក្ស និងប្រើប្រាស់ធនធានធម្មជាតិ បេតិកភណ្ឌវប្បធម៌ ការអភិវឌ្ឍបៃតង និងបង្ការទប់ស្កាត់គ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព
- លើកកម្ពស់ការរៀបចំនិងការគ្រប់គ្រងផ្ទៃបៃតង លម្ហសាធារណៈ និងទេសភាពទីក្រុងប្រកបដោយភាពទាក់ទាញ និងបរិយាកាសល្អប្រសើរសម្រាប់ការរស់នៅប្រកបដោយសុខដុមរមនានិងការកម្សាន្តប្រកបដោយបរិយាកាសរីករាយ
- លើកកម្ពស់ការរៀបចំបរិក្ខារបម្រើដល់វិស័យទេសចរណ៍និងបង្កើតខ្សែច្រវាក់ទេសចរណ៍ធនធានធម្មជាតិនិងឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោកដើម្បីប្រែក្លាយទៅជាទីក្រុងទេសចរណ៍កម្រិតអន្តរជាតិ
- គិតគូរនិងពង្រីកតំបន់លំនៅឋានឱ្យឆ្លើយតបទៅនឹងកំណើនប្រជាសាស្ត្រនិងការអភិវឌ្ឍ និងលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាពនិងប្រសិទ្ធភាព
- ធ្វើសមាហរណកម្មផែនការរូបវន្ត សេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន និងផែនការតាមវិស័យដើម្បីធានាភាពសុខដុមរមនាសង្គមនិងការអភិវឌ្ឍប្រកបដោយចីរភាព
- ដោះស្រាយនិងឆ្លើយតបបានល្អប្រសើរតាមតម្រូវការរបស់ប្រជាជន។

## ៤-យុទ្ធសាស្ត្រអភិវឌ្ឍនិងអភិរក្សក្រុងព្រះសីហនុ

ដើម្បីសម្រេចបានចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើ ប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុត្រូវបានកំណត់យុទ្ធសាស្ត្រ ដូចខាងក្រោម៖

## ៤.១-យុទ្ធសាស្ត្រអភិវឌ្ឍនិងអភិក្រមនគរូបនីយកម្ម

### ៤.១.១-យុទ្ធសាស្ត្រអភិវឌ្ឍនិងទិសដៅនគរូបនីយកម្ម

#### ក-តំបន់នគរូបនីយកម្មបច្ចុប្បន្ន

- កំណត់តំបន់កែលម្អនិងអភិវឌ្ឍទីក្រុងឱ្យមានសកម្មភាពនិងសោភណភាពរស់រវើក សណ្តាប់ធ្នាប់ល្អ និងបរិស្ថានរស់នៅប្រកបដោយផាសុកភាពសម្រាប់មនុស្សទាំងអស់គ្នា ដោយកែលម្អនិងរៀបចំពង្រីកកំណាត់ផ្លូវជាតិលេខ៤ភ្ជាប់ជាមួយផ្លូវល្បឿនលឿន និងសាងសង់មហាវិថីច្រកចូលក្រុងតភ្ជាប់ទៅនឹងវិថី អនុវិថី ផ្លូវបម្រើឱ្យការដឹកជញ្ជូនសំខាន់ៗ ផ្លូវថ្មើរជើង ផ្លូវជិះកង់ ផ្លូវជនមានពិការភាព ការកែលម្អឆ្នេរខ្សាច់កម្សាន្ត សួនសាធារណៈ បន្ទប់ទឹកសាធារណៈ សួនកុមារ ទីលានកីឡា កន្លែងកម្សាន្ត លម្ហសាធារណៈ ការអភិវឌ្ឍថ្មៃបៃតង ចំណតសាធារណៈ ផ្លាក តំនូស ភ្លើងបំភ្លឺ និងភ្លើងសញ្ញាចរាចរណ៍ និងដាំដើមឈើនិងផ្កាតាមប្រភេទតាមដងផ្លូវជាបណ្តាញបៃតង តាមរយៈការអនុវត្តគម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវក្រុងចំនួន៣៤ខ្សែ ប្រវែង៨៤ ៥០៥ម៉ែត្រ ក្នុងចក្ខុវិស័យផ្លូវមិនត្រឹមតែសម្រាប់ធ្វើដំណើរប្រកបដោយប្រសិទ្ធភាពប៉ុណ្ណោះទេ ថែមទាំង ១)ផ្លូវជាលម្ហសាធារណៈប្រកបដោយមេត្រីភាព សុវត្ថិភាព និងសមធម៌ ២)ផ្លូវដើម្បីកំណើនសេដ្ឋកិច្ចនិងអភិវឌ្ឍធុរកិច្ច ៣)ផ្លូវដើម្បីលើកកម្ពស់គុណភាពនគរូបនីយកម្ម ភាពធន់នឹងអាកាសធាតុ និងបរិស្ថានប្រកបដោយចីរភាព ដោយបានផ្តោតការសិក្សាកំណត់បែងចែកឋានានុក្រមផ្លូវជាបីប្រភេទ រួមមានមហាវិថី វិថី និងអនុវិថី ស្របតាមតំបន់នគរូបនីយកម្មក្នុងទីក្រុង
- កំណត់តំបន់អាទិភាពនិងរៀបចំប្លង់លម្អិតនគរូបនីយកម្មតាមតំបន់នីមួយៗស្របតាមទីតាំងភូមិសាស្ត្រ តំបន់ឆ្នេរសមុទ្រ តំបន់កណ្តាលក្រុង តំបន់ពាណិជ្ជកម្ម សេវាកម្ម ទេសចរណ៍ និងលំនៅឋានជាដើម ដើម្បីកែលម្អហេដ្ឋារចនាសម្ព័ន្ធ សេវាកម្មទីក្រុង បង្កើនគុណភាពនគរូបនីយកម្ម លើកកម្ពស់គុណភាពបរិស្ថាននៃការរស់នៅ អភិវឌ្ឍធុរកិច្ច និងទាក់ទាញការវិនិយោគ
- កំណត់បទប្បញ្ញត្តិនគរូបនីយកម្ម សម្រាប់កែលម្អសោភណភាពទីក្រុង ផ្លាកសញ្ញាផ្សាយពាណិជ្ជកម្មតាមដងផ្លូវឱ្យមានសណ្តាប់ធ្នាប់និងសោភណភាពល្អ និងស្ថាបត្យកម្មឱ្យមានរចនាបទខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន។

#### ខ-ទិសដៅនគរូបនីយកម្ម

- កំណត់ទិន្នាការនគរូបនីយកម្មឆ្ពោះទៅទិសខាងជើងនិងទិសខាងកើត និងការអភិវឌ្ឍសំណង់ខ្ពស់ៗ ស្របតាមបទប្បញ្ញត្តិប្រើប្រាស់ដី
- កំណត់តំបន់អភិវឌ្ឍទីក្រុងនិងគម្រោងអភិវឌ្ឍទីក្រុងតាមទិន្នាការនគរូបនីយកម្ម
- កំណត់ប្រភេទដី តំបន់ប្រើប្រាស់ដី និងបទប្បញ្ញត្តិប្រើប្រាស់ដី ស្របតាមទីតាំងភូមិសាស្ត្រនិងសមាហរណកម្មទៅនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ សេវាកម្ម និងបរិក្ខារទីក្រុង
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឡើងវិញ បណ្តាញផ្លូវ បណ្តាញលូទឹកភ្លៀង លូទឹកកខ្វក់ ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ សួនសាធារណៈ សួនកុមារ ទីលានកីឡា កន្លែងកម្សាន្ត លម្ហសាធារណៈ បណ្តាញបៃតង ដាំដើមឈើនិងផ្កាតាមប្រភេទ ភ្លើងបំភ្លឺ ផ្លាកនិងតំនូសសញ្ញាចរាចរណ៍តាមដងផ្លូវ

- កំណត់ទីតាំងនិងរៀបចំចំណតរថយន្តសាធារណៈគ្រប់ប្រភេទ សម្រាប់រថយន្តទេសចរណ៍ រថយន្តដឹកអ្នកដំណើរ និងរថយន្តដឹកទំនិញ និងលើកទឹកចិត្តការវិនិយោគសាងសង់អគារចំណតរថយន្ត និងទីតាំងចតរថយន្តពីផ្ទែកឯកជន
- កំណត់តំបន់និងបទប្បញ្ញត្តិសម្រាប់ការគ្រប់គ្រងការអភិវឌ្ឍនិងការអភិរក្សតំបន់ការពារធនធានធម្មជាតិ និងទីជម្រាល តំបន់ការពារទេសភាពទីក្រុង និងតំបន់វប្បធម៌ប្រវត្តិសាស្ត្រ ប្រកបដោយប្រសិទ្ធភាព និងចីរភាព
- រៀបចំនិងអភិវឌ្ឍក្រុងព្រះសីហនុនិងតំបន់ជុំវិញ ជាតំបន់ខ្សែក្រវាត់ដឹកជញ្ជូនដែលមានទំនាក់ទំនងរាងជាត្រីកោណរវាងតំបន់ស្នូលក្រុងព្រះសីហនុ ស្រុកស្ទឹងហាវដែលមានកំពង់ផែ និងស្រុកព្រៃនប់ដែលមានតំបន់សេដ្ឋកិច្ចពិសេសបិតត្រាំងនិងអាកាសយានដ្ឋានអន្តរជាតិ
- លើកកម្ពស់ការគ្រប់គ្រងការអភិវឌ្ឍទីក្រុងឆ្លាត និងធ្វើសមាហរណកម្មការអភិវឌ្ឍទីក្រុងនិងតំបន់ជុំវិញជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ដោយធានាបានអត្តសញ្ញាណវប្បធម៌ជាតិ ប្រកបដោយប្រសិទ្ធភាព ចីរភាព និងបរិយាបន្ន ស្របតាមបទប្បញ្ញត្តិរៀបចំដែនដីនិងនគរូបនីយកម្ម
- រៀបចំនិងកំណត់រចនាបថអគារ ពណ៌អគារ និងកំណត់ផ្លាកផ្សព្វផ្សាយពាណិជ្ជកម្មតាមដងផ្លូវនិងតាមតំបន់នានានីមួយៗឱ្យមានសណ្ដាប់ធ្នាប់និងសោភណភាពល្អស្របតាមទីតាំងភូមិសាស្ត្រជាក់ស្តែង
- ពង្រឹងការគ្រប់គ្រងការអភិវឌ្ឍដីស្របតាមលក្ខខណ្ឌបច្ចេកទេសសម្រាប់ការអភិវឌ្ឍដីដែលបានកំណត់នៅក្នុងប្រកាសស្តីពីការអភិវឌ្ឍដីដើម្បីធានាបាននូវហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លំហសាធារណៈ ផ្ទៃបៃតង និងបរិក្ខារសាធារណៈសមស្របសម្រាប់មនុស្សទាំងអស់គ្នា រួមទាំងជនមានពិការភាព ជនងាយរងគ្រោះ ចាស់ជរា និងកុមារ
- ជំរុញលទ្ធភាពរៀបចំបណ្ដាញអគ្គិសនី ឬបណ្ដាញបញ្ជូនអគ្គិសនី បណ្ដាញទូរគមនាគមន៍ ខ្សែកាប្លិ៍គ្រប់ប្រភេទ កប់ក្នុងដី ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពនិងរក្សាដល់សោភណភាពទីក្រុង
- រៀបចំផែនការប្រើប្រាស់ដីដោយកំណត់បទប្បញ្ញត្តិនៃការប្រើប្រាស់ដី ការអភិវឌ្ឍដី ការសាងសង់និងប្លង់លម្អិតនគរូបនីយកម្មតាមតំបន់នីមួយៗស្របតាមទីតាំងភូមិសាស្ត្រជាក់ស្តែង
- ជំរុញការរៀបចំនិងការអភិវឌ្ឍតំបន់កំពង់ផែដែលជាច្រកចេញចូលអន្តរជាតិនិងតំបន់សុវត្ថិភាពសម្រាប់កំពង់ផែពាណិជ្ជកម្មនិងកំពង់ផែទេសចរណ៍
- គ្រប់គ្រងនិងថែរក្សាតំបន់ឧទ្យាន ភ្នំ ទេសភាព និងតំបន់បៃតងជាយក្រុង និងអភិវឌ្ឍបណ្ដាញបៃតងសមាហរណកម្មតភ្ជាប់ទីប្រជុំជន តំបន់ជុំវិញ និងតំបន់ជនបទ
- ពង្រឹងសមត្ថភាព ស្ថាប័នធ្វើផែនការអភិវឌ្ឍនិងគ្រប់គ្រងការអភិវឌ្ឍ ពិសេសប្រសិទ្ធភាពនៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តព្រះសីហនុនិងក្រុងព្រះសីហនុដែលមានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុនិងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលនៃរដ្ឋបាលក្រុងព្រះសីហនុជាសេនាធិការ។

### ៤.១.២- យុទ្ធសាស្ត្រអភិរក្សនិងអភិវឌ្ឍនគូបនីយកម្មតំបន់ឆ្នេរសមុទ្រ

#### ក- គោលការណ៍ណែនាំអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា

ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានដាក់បញ្ចូលជាសមាជិកក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោកកាលពីថ្ងៃទី២៥-២៦ ខែឧសភា ឆ្នាំ២០១១ នៅទីក្រុងទូបាតូតាប្រទេសសេណេហ្គាល់ដោយក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោកដោយសារភាពសម្បូរបែបនៃជីវចម្រុះ ភាពល្អប្រណីតនៃបរិស្ថានធម្មជាតិ តម្លៃអេកូឡូស៊ី សេដ្ឋកិច្ចសង្គម វប្បធម៌ និងប្រពៃណីក្នុងតំបន់ ព្រមទាំងភាពទាក់ទាញផ្នែកទេសចរណ៍។

យោងតាមសារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ឆ្នេរសមុទ្រត្រូវកំណត់ចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតនៃទឹកសមុទ្រឡើងមកលើរហូតដល់ខ្សែបន្ទាត់ហាមឃាត់ការកាន់កាប់ ឬសាងសង់នានាជាថ្មី ដីឬខ្សាច់ដែលបានកំណត់ទុកជាតំបន់សម្រាប់ប្រើប្រាស់ជាសាធារណៈនិងត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ។

#### ក.១- ឆ្នេរសមុទ្រ

– ឆ្នេរជម្រាលត្រូវកំណត់យ៉ាងតិចមានប្រវែង៣០ម៉ែត្រចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតទៅខាងដីគោក

– ឆ្នេរចោតត្រូវកំណត់យ៉ាងតិចមានប្រវែង២០ម៉ែត្រចាប់ពីចំណុចកំពូលនៃផ្ទៃចោតមកខាងដីគោក។

ក្នុងករណីដែលស្ថានភាពទីតាំងជាក់ស្តែងនៃឆ្នេរជម្រាលមិនអាចកំណត់តាមទំហំខាងលើបាន ទំហំឆ្នេរសមុទ្រត្រូវកែច្នៃឬពង្រីកបន្ថែមដើម្បីបង្កើតជាឆ្នេរសម្រាប់ដើរលេងកម្សាន្តប្រសិនបើអាចធ្វើទៅបាន។

#### ក.២- ដីចំណីឆ្នេរសមុទ្រ

ដីចំណីឆ្នេរសមុទ្រគឺជាផ្ទៃដីដែលចាប់រាប់ពីខ្សែបន្ទាត់ឆ្នេរខាងលើមកទិសខាងដីគោក។ ដីចំណីឆ្នេរសមុទ្រជាដីសាធារណៈរបស់រដ្ឋ លើកលែងតែមានការកាន់កាប់ស្របច្បាប់។

ប្រវែងឬទំហំដីចំណីឆ្នេរសមុទ្រត្រូវកំណត់ដូចខាងក្រោម៖

– ប្រវែងទទឹងដីចំណីឆ្នេរសមុទ្រត្រូវកំណត់យ៉ាងតិច៥០ម៉ែត្រគិតពីខ្សែបន្ទាត់ឆ្នេរខាងលើទៅខាងដីគោក

– ក្នុងករណីដែលតាមបណ្តោយឆ្នេរសមុទ្រមានផ្លូវសាធារណៈរួចហើយ ដីចំណីឆ្នេរសមុទ្រអាចកំណត់មកទល់នឹងផ្លូវសាធារណៈនេះ។

#### ក.៣- ផ្លូវសាធារណៈតាមបណ្តោយដីចំណីឆ្នេរសមុទ្រ ផ្លូវថ្មើរជើង និងផ្លូវជិះកង់

ផ្លូវសាធារណៈតាមបណ្តោយដីចំណីឆ្នេរសមុទ្រគឺជាផ្លូវដែលសាងសង់ឡើងនៅជាប់ខ្សែបន្ទាត់ខាងក្រៅនៃដីចំណីឆ្នេរសមុទ្រដែលខណ្ឌចែកដីចំណីឆ្នេរសមុទ្រជាមួយតំបន់រណប។ ផ្លូវនេះជារបាំងទប់ស្កាត់ការរំលោភបំពានកាន់កាប់ដីចំណីឆ្នេរសមុទ្រ។ ផ្លូវនេះត្រូវមានចំណីផ្លូវទំហំយ៉ាងតិច១៥ម៉ែត្រពីសងខាងអ័ក្សផ្លូវ និងត្រូវកំណត់ល្បឿនសម្រាប់ចរាចរណ៍២០គីឡូម៉ែត្រក្នុងមួយម៉ោង។

ផ្លូវថ្មើរជើងនិងផ្លូវជិះកង់នៅលើដីចំណីផ្លូវសាធារណៈតាមបណ្តោយឆ្នេរសមុទ្រដែលត្រូវកំណត់ទំហំយ៉ាងតិច៦ម៉ែត្រឬស្របតាមស្ថានភាពជាក់ស្តែង។ ការសាងសង់ផ្លូវថ្មើរជើងនិងផ្លូវជិះកង់ត្រូវគោរពតាមសេចក្តីសម្រេចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់លេខ០៣៩សសរ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់ស្ថាបត្យកម្ម ចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង និងគន្លងផ្លូវទោចក្រយានសម្រាប់ប្រជាជន និងជនមានពិការភាព។

### ក.៤-តំបន់រណបតាមបណ្ដោយផ្លូវសាធារណៈ

តំបន់រណបគឺជាតំបន់មួយប្លុកស្ថិតនៅចន្លោះផ្លូវសាធារណៈតាមបណ្ដោយឆ្នេរសមុទ្រនិងផ្លូវស្របបន្ទាប់មួយទៀតដែលស្ថិតក្នុងទិសខាងជើងគោក។

ការអភិវឌ្ឍនិងការសាងសង់សំណង់នានាក្នុងតំបន់ឆ្នេរសមុទ្រក្រុងព្រះសីហនុត្រូវគោរពតាមប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីក្រុងព្រះសីហនុនិងសារាចរណែនាំលេខ០១សរណន ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ស្ដីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងបទប្បញ្ញត្តិជាធរមាន។

### ខ-ឆ្នេរសមុទ្រនៅក្រុងព្រះសីហនុ

ក្រុងព្រះសីហនុនិងតំបន់ជុំវិញមានឆ្នេរសមុទ្រប្រវែងសរុប២៧ ៥២០ម៉ែត្រក្នុងនេះមានឆ្នេរខ្សាច់ប្រវែង១៩ ៤៥០ម៉ែត្រនិងឆ្នេរថ្ម (ពាមសមុទ្រ) ប្រវែង៨ ០៧០ម៉ែត្រ។ ប្រភេទ ឈ្មោះ និងប្រវែងឆ្នេរសមុទ្រនីមួយៗមានដូចខាងក្រោម៖

#### ខ.១-ឆ្នេរខ្សាច់កម្សាន្ត

- ឆ្នេរខ្សាច់ម្ហូបជ្រៃមានប្រវែង៩០០ម៉ែត្រ
- ឆ្នេរខ្សាច់កោះពស់មានប្រវែង៨០០ម៉ែត្រ
- ឆ្នេរខ្សាច់ឯករាជ្យមានប្រវែង១ ០០០ម៉ែត្រ
- ឆ្នេរខ្សាច់សុខាមានប្រវែង១ ២០០ម៉ែត្រ
- ឆ្នេរខ្សាច់អូរឈើទាលមានប្រវែង៣ ២០០ម៉ែត្រ
- ឆ្នេរខ្សាច់អូរត្រេះមានប្រវែង៣ ៧០០ម៉ែត្រ
- ឆ្នេរខ្សាច់ជីទាវម៉ៅមានប្រវែង៥ ៧០០ម៉ែត្រ
- ឆ្នេរខ្សាច់ព្រៃកព្រែងមានប្រវែង២ ៩៥០ម៉ែត្រ។

#### ខ.២-ឆ្នេរថ្មឬពាមសមុទ្រ

- ឆ្នេរពាមជ័យជំនះមានប្រវែង១៩០ម៉ែត្រ
- ឆ្នេរពាមឯករាជ្យមានប្រវែង១ ៥០០ម៉ែត្រ
- ឆ្នេរពាមកំពេញមានប្រវែង១ ៨៥០ម៉ែត្រ
- ឆ្នេរពាមតាមួងមានប្រវែង៧៥០ម៉ែត្រ
- ឆ្នេរពាមព្រែកអូរឈើទាល (ភ្នំ៣៩) មានប្រវែង៤៤០ម៉ែត្រ
- ឆ្នេរពាមព្រែកត្រែងមានប្រវែង៤៨០ម៉ែត្រ
- ឆ្នេរពាមទំនប់រលកមានប្រវែង២ ៨៦០ម៉ែត្រ។

គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា បានកែលម្អ អភិវឌ្ឍ និងធ្វើសមាហរណកម្មតភ្ជាប់ឆ្នេរសមុទ្រសំខាន់ៗតាមរយៈការអភិវឌ្ឍមហាវិថីនិងវិថីថ្មី ដើម្បីតភ្ជាប់ឆ្នេរសមុទ្រក្រុងព្រះសីហនុ និងតំបន់ជុំវិញសំខាន់ៗ មានការតភ្ជាប់ឆ្នេរខ្សាច់សុខាភ្ជាប់ទៅឆ្នេរខ្សាច់អូរឈើទាលតាមរយៈគម្រោងអភិវឌ្ឍវិថីពេជ្រប្រវែង១ ០៣៤ម៉ែត្រ, ការតភ្ជាប់ឆ្នេរខ្សាច់អូរឈើទាលភ្ជាប់ទៅឆ្នេរខ្សាច់អូរត្រេះតាមរយៈគម្រោងអភិវឌ្ឍ

វិថីពយអូរឈើទាលប្រវែង២៥០ម៉ែត្រ, ការតភ្ជាប់ឆ្នេរខ្សាច់អូរត្រេះភ្ជាប់ទៅឆ្នេរខ្សាច់ជិតាវម៉ៅតាមរយៈគម្រោងអភិវឌ្ឍស្ពានសែនត្រជាក់ចិត្តប្រវែង៤៥ម៉ែត្រនិងវិថីឆ្នេរពយជិតាវម៉ៅប្រវែង១ ៨៥០ម៉ែត្រ, និងការតភ្ជាប់ឆ្នេរខ្សាច់ជិតាវម៉ៅភ្ជាប់ទៅឆ្នេររាមតាមរយៈគម្រោងអភិវឌ្ឍមហាវិថីជិតាវម៉ៅប្រវែង៨ ៨៩០ម៉ែត្រភ្ជាប់ជាមួយនឹងមហាវិថីឆ្នេររាមប្រវែង៤ ៩៥០ម៉ែត្រ រង្វង់មូលព្រះថោងព្រះនាងនាគអង្កត់ផ្ចិត៩៩ម៉ែត្រ ស្ពានព្រះថោងប្រវែង៣០ម៉ែត្រ ស្ពានព្រះសិរៈប្រវែង៥០ម៉ែត្រ រង្វង់មូលព្រះឧមាហេស្វរៈអង្កត់ផ្ចិត៩៩ម៉ែត្រ និងមហាវិថីរាមប្រវែង៧ ០២៨ម៉ែត្រ ភ្ជាប់ទៅអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុនិងផ្លូវជាតិលេខ៤។ គម្រោងកែលម្អនិងអភិវឌ្ឍការតភ្ជាប់និងធ្វើសមាហរណកម្មនេះមានស្ថានភាពភូមិសាស្ត្រនិងកម្រិតកម្ពស់ដីខុសៗគ្នាជាច្រើន ដែលត្រូវកាត់សម្រុតកម្ពស់ទីទួលកន្លែងខ្លះពីរយៈកម្ពស់៧៦ម៉ែត្រមក១៦ម៉ែត្រត្រង់ចំណុចភ្នំជិតាវម៉ៅ ដើម្បីរក្សាជម្រាលផ្លូវត្រឹម៦,៥% និងធានាបាននូវសុវត្ថិភាពចរាចរណ៍ស្របតាមបទដ្ឋានបច្ចេកទេស។

ជាមួយគ្នានេះ គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជានិងរដ្ឋបាលខេត្តព្រះសីហនុបានរុះរើសំណង់អនាធិបតេយ្យចំនួន១៥៦ទីតាំងនៅឆ្នេរអូរត្រេះ ចំនួន១២៦ទីតាំងនៅឆ្នេរអូរឈើទាល II និងចំនួន១២ទីតាំងទៀតនៅឆ្នេរលំហែកាយ និងបានរៀបចំកែលម្អឆ្នេរអូរត្រេះ ឆ្នេរអូរឈើទាល II ឆ្នេរលំហែកាយភ្ជាប់ជាមួយនឹងឆ្នេរទាំងអស់ រួមជាមួយការរៀបចំកន្លែងកម្សាន្តនិងតំបន់ទេសភាព "ខ្មែរធ្វើបាន" "ដើមឈើចាំស្នេហ៍" "សិលាចាំស្នេហ៍" ពយអូរឈើទាល និងវិថីតេជោ រៀបចំចំណតរថយន្តសាធារណៈតាមបណ្តោយឆ្នេរសមុទ្រចំនួន៨០០ចំណត សាងសង់បង្គន់សាធារណៈតាមបណ្តោយឆ្នេរសមុទ្រចំនួន១១ទីតាំង និងដាំដើមឈើនិងបណ្តាញបៃតង ប្រកបដោយសោភណភាពនិងភាពទាក់ទាញភ្ញៀវទេសចរនិងសាធារណជន។

ក្នុងការកែលម្អតំបន់ឆ្នេរសមុទ្រក្រុងព្រះសីហនុ គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជាបានសាងសង់ខ្លោងទ្វារចូលឆ្នេរសមុទ្រចំនួន១១ទីតាំង និងសាងសង់ប៉ាណូផ្សព្វផ្សាយពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ស្របតាមសារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជាចំនួន៥៤ប៉ាណូ។

**គ-គោលការណ៍ណែនាំអភិវឌ្ឍតំបន់រមណីយដ្ឋានឆ្នេរសមុទ្រ**

- ថែរក្សាបាននូវបូរណភាពនៃធម្មជាតិតំបន់ឆ្នេរសមុទ្រ
- ផ្តល់បទពិសោធន៍ប្រកបដោយគុណភាពខ្ពស់សម្រាប់ភ្ញៀវទេសចរមកកាន់ឆ្នេរសមុទ្រតាមរយៈការផ្តល់សេវាកម្មនិងហេដ្ឋារចនាសម្ព័ន្ធប្រកបដោយគុណភាព
- ធានាបាននូវបរិស្ថានប្រកបដោយសុវត្ថិភាពសម្រាប់អ្នកប្រើប្រាស់ឆ្នេរសមុទ្រក្នុងសកម្មភាពកម្សាន្ត
- គាំពារការអភិវឌ្ឍនិងពិពិធភាពនៃសកម្មភាពតំបន់ឆ្នេរសមុទ្រប្រកបដោយការទទួលខុសត្រូវ
- បង្កើតទិសដៅអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនាពេលអនាគត
- បង្កើតផែនការគ្រប់គ្រងនិងការពារតំបន់ឆ្នេរសមុទ្រ
- បង្កើតគោលការណ៍ណែនាំអភិវឌ្ឍតំបន់ឆ្នេរសមុទ្រឱ្យបានច្បាស់លាស់ដោយផ្អែកលើការកំណត់ប្រវែងឆ្នេរសមុទ្រនិងទិសដៅនៃការអភិវឌ្ឍ
- កំណត់បទប្បញ្ញត្តិ កម្ពស់អគារ សន្ទស្សន៍ប្រើប្រាស់ដី ផលធៀបផ្ទៃក្រឡាជាន់សំណង់ធៀបនឹងផ្ទៃដីឡូត៍ ជួរតម្រង់អគារ និងដង់ស៊ីតេនៅតំបន់ឆ្នេរសមុទ្រដើម្បីការពារនិងអភិរក្សបរិស្ថានធម្មជាតិនៅតំបន់ឆ្នេរសមុទ្រ

- កំណត់គោលការណ៍លម្អិតសម្រាប់ការសាងសង់ដូចជាទិសនៃអគារដែលបែរមុខទៅ គម្លាតអគារចេញពីដីឡូត៍កាន់កាប់ស្របច្បាប់ និងលម្ហបៃតងក្នុងដីឡូត៍
- ពង្រឹងការប្រើប្រាស់និងការថែរក្សាសោភណភាពឆ្នេរសមុទ្រឱ្យបានល្អប្រសើរប្រកបដោយបរិស្ថានធម្មជាតិល្អដែលជាធនធានទេសចរណ៍ដ៏មានតម្លៃ
- បទប្បញ្ញត្តិឧត្តមបនីយកម្មសម្រាប់ការអភិរក្សនិងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា នឹងត្រូវកំណត់ដោយគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ដើម្បីធានាការអភិវឌ្ឍប្រកបដោយចីរភាព។

**ឃ-ការកំណត់ចំណាត់ថ្នាក់រមណីយដ្ឋានឆ្នេរសមុទ្រ**

ដោយផ្អែកតាមសេចក្តីសម្រេចលេខ១៣១សសរ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំអភិវឌ្ឍន៍រមណីយដ្ឋានឆ្នេរសមុទ្ររបស់រាជរដ្ឋាភិបាលកម្ពុជា ឆ្នេរសមុទ្រក្រុងព្រះសីហនុ និងតំបន់ជុំវិញត្រូវបានកំណត់បែងចែកដូចខាងក្រោម៖

- ប្រភេទទី១និងទី២ រមណីយដ្ឋានឆ្នេរអភិរក្សស្ងួលនិងអេកូទេសចរណ៍៖ ឆ្នេរពាមជីតាវម៉ៅ ឆ្នេរពាមព្រែកអូរឈើទាល និងឆ្នេរពាមតាមូង
- ប្រភេទទី៣ រមណីយដ្ឋានឆ្នេរកម្សាន្តប្រណីត៖ ឆ្នេរខ្សាច់សុខា ឆ្នេរពាមកំពេញ ឆ្នេរពាមឯករាជ្យ និងឆ្នេរពាមជីយជិន៖
- ប្រភេទទី៤ រមណីយដ្ឋានឆ្នេរកម្សាន្តសាធារណៈកម្រិតខ្ពស់៖ ឆ្នេរខ្សាច់អូរត្រេះនិងឆ្នេរខ្សាច់អូរឈើទាល
- ប្រភេទទី៥ រមណីយដ្ឋានឆ្នេរកម្សាន្តសាធារណៈកម្រិតមធ្យម៖ ឆ្នេរខ្សាច់ម្លប់ជ្រៃ ឆ្នេរខ្សាច់កោះពស់ និងឆ្នេរខ្សាច់ព្រែកត្រែង។

**ង-បទប្បញ្ញត្តិសម្រាប់ការអភិរក្សនិងការអភិវឌ្ឍតំបន់រមណីយដ្ឋានឆ្នេរសមុទ្រ**

**ង.១-ការបែងចែកតំបន់ប្រើប្រាស់ដី**

ការបែងចែកតំបន់នៅទីតាំងរមណីយដ្ឋានឆ្នេរកម្សាន្តត្រូវបានធ្វើការបែងចែកដូចខាងក្រោម៖

- ឆ្នេរខ្សាច់ជាតំបន់ត្រូវថែរក្សា ការពារ និងត្រូវកំណត់ប្រវែងទទឹងយ៉ាងតិច៣០ម៉ែត្រចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតទៅខាងដីគោក
- ដីចំណីឆ្នេរសមុទ្រជាតំបន់ការពារដីសាធារណៈរបស់រដ្ឋនិងត្រូវកំណត់ប្រវែងទទឹងយ៉ាងតិច៥០ម៉ែត្រគិតពីខ្សែបន្ទាត់ឆ្នេរខាងលើទៅទិសខាងដីគោក។ ក្នុងករណីដែលនៅតាមបណ្តោយឆ្នេរសមុទ្រមានផ្លូវសាធារណៈរួចហើយនោះដីចំណីឆ្នេរសមុទ្រត្រូវកំណត់មកទល់នឹងផ្លូវសាធារណៈដែលមានស្រាប់
- តំបន់រណបជាតំបន់មួយប្លុកដែលមានប្រវែងទទឹង៣០០ម៉ែត្រដែលគិតចាប់ពីផ្លូវសាធារណៈតាមបណ្តោយឆ្នេរសមុទ្រឆ្ពោះទៅទិសខាងដីគោកឬស្របតាមស្ថានភាពជាក់ស្តែង។ តំបន់រណបត្រូវធ្វើការបែងចែកជា៣តំបន់ទៀតដូចខាងក្រោម៖

- តំបន់ការពារទេសភាពជាតំបន់មួយប្លុកដែលមានប្រវែងទទឹង១០០ម៉ែត្រដែលគិតចាប់ពីផ្លូវសាធារណៈតាមបណ្តោយឆ្នេរសមុទ្រឆ្ពោះទៅទិសខាងដីគោកឬស្របតាមស្ថានភាពជាក់ស្តែង។ ការអភិវឌ្ឍនិងការសាងសង់នៅក្នុងតំបន់ការពារទេសភាពត្រូវកំណត់សន្ទស្សន៍ប្រើប្រាស់ដីទាបដូចមានកំណត់ក្នុងបទប្បញ្ញត្តិប្រើប្រាស់ដី
- តំបន់អភិវឌ្ឍន៍ប្រកបដោយចីរភាពជាតំបន់មួយប្លុកដែលមានប្រវែងទទឹង១០០ម៉ែត្រដែលគិតចាប់បន្តពីតំបន់ការពារទេសភាពឆ្ពោះទៅទិសខាងដីគោកឬស្របតាមស្ថានភាពជាក់ស្តែង។ ការអភិវឌ្ឍនិងការសាងសង់នៅក្នុងតំបន់អភិវឌ្ឍន៍ប្រកបដោយចីរភាពត្រូវកំណត់សន្ទស្សន៍ប្រើប្រាស់ដីមធ្យមកម្រិតទាបដូចមានកំណត់ក្នុងបទប្បញ្ញត្តិប្រើប្រាស់ដី
- តំបន់អភិវឌ្ឍន៍សមាហរណកម្មជាតំបន់មួយប្លុកដែលមានប្រវែងទទឹង១០០ម៉ែត្រដែលគិតចាប់បន្តពីតំបន់អភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្ពោះទៅទិសខាងដីគោកឬស្របតាមស្ថានភាពជាក់ស្តែង។ ការអភិវឌ្ឍនិងការសាងសង់នៅក្នុងតំបន់អភិវឌ្ឍន៍សមាហរណកម្មត្រូវកំណត់សន្ទស្សន៍ប្រើប្រាស់ដីកម្រិតខ្ពស់មធ្យមដូចមានកំណត់ក្នុងបទប្បញ្ញត្តិប្រើប្រាស់ដី។

### ៤.២-ការកំណត់បទប្បញ្ញត្តិប្រើប្រាស់ដី

តំបន់រមណីយដ្ឋានឆ្នេរកម្សាន្តត្រូវធ្វើការរៀបចំនិងកំណត់បទប្បញ្ញត្តិប្រើប្រាស់ដីសម្រាប់ការអភិរក្ស ការអភិវឌ្ឍ ការសាងសង់ សកម្មភាពដែលអាចអនុញ្ញាតនិងសកម្មភាពដែលត្រូវហាមឃាត់ដើម្បីរក្សាសោភណភាពនិងទេសភាពតំបន់ទីក្រុងមាត់ទឹកដូចខាងក្រោម៖

#### ១-ឆ្នេរខ្សាច់

រាល់សកម្មភាពនៅលើឆ្នេរខ្សាច់ត្រូវអនុវត្តបទប្បញ្ញត្តិការពារនិងអភិរក្សឱ្យបានគង់វង្សដើម្បីរក្សាបានទេសភាពឆ្នេរសមុទ្រនិងបរិស្ថានធម្មជាតិឆ្នេរសមុទ្រស្អាតបំផុតលើសកលលោក។ ឆ្នេរខ្សាច់ត្រូវប្រើប្រាស់សម្រាប់ជាកន្លែងសម្រាកលំហែកាយ ការកម្សាន្ត និងសម្បទាទេសចរណ៍តែប៉ុណ្ណោះ។ ការសាងសង់សំណង់រឹងមាំ សកម្មភាពអាជីវកម្ម និងពាណិជ្ជកម្មផ្សេងៗនៅក្នុងតំបន់នេះនឹងមិនត្រូវបានអនុញ្ញាតនោះទេ។

តារាងទី១៖ សកម្មភាពលំហែកម្សាន្តនិងសម្បទាទេសចរណ៍ដែលអនុញ្ញាតនិងហាមឃាត់នៅលើឆ្នេរខ្សាច់

| ការអនុញ្ញាត | | ការហាមឃាត់ |
|---|---|---|
| សកម្មភាព | សម្បទាទេសចរណ៍ | |
| • ការហែលទឹក<br>• ការដើរ<br>• ការស្ងួតថ្ងៃ<br>• កីឡាលើខ្សាច់ | • ឥដ់កីឡា<br>• បរិក្ខារកីឡា<br>• ប៉មឆ្មាំឆ្នេរសមុទ្រសម្រាប់សង្គ្រោះ<br>• សម្បទាបន្ទាប់បន្សំ តុ កៅអី ឆ័ត្រ ផ្លាកសញ្ញា។ល។ | • រាល់ការសាងសង់សំណង់រឹងមាំ<br>• អាជីវកម្ម និងពាណិជ្ជកម្ម |

## ២-ដីចំណីឆ្នេរសមុទ្រ

តារាងទី២៖ សកម្មភាពនិងសម្បទាទេសចរណ៍ដែលអនុញ្ញាតនិងការហាមឃាត់នៅលើដីចំណីឆ្នេរសមុទ្រ

| ការអនុញ្ញាត | | ការហាមឃាត់ |
|---|---|---|
| **សកម្មភាព** | **សម្បទាទេសចរណ៍** | |
| • ការដើរ<br>• ការទទួលទានអាហារ<br>• ការអង្គុយលម្ហែ<br>• ការងូតទឹកសាប<br>• ការកម្សាន្តលក្ខណៈគ្រួសារ<br>• ការអប់រំនិងការសិក្សា | • សំណង់មិនរឹងមាំនិងសំណង់តូបតូចៗសម្រាប់បម្រើផលស់សេវាកម្មទេសចរណ៍។ សំណង់តូបតូចៗនេះត្រូវរៀបចំឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសនិងមានច្រកដើរចេញចូលច្បាស់លាស់ដើម្បីចៀសវាងផលប៉ះពាល់ដល់សួនច្បារនិងទេសភាពបៃតង<br>• ចំណតយានយន្ត<br>• មណ្ឌលព័ត៌មានទេសចរណ៍<br>• វេជ្ជបាលគ្រប់គ្រង<br>• អាហារដ្ឋាន<br>• តូបលម្ហែ<br>• បុកអនាម័យ (បង្គន់អនាម័យនិងបន្ទប់ទឹក)<br>• កន្លែងក្មេងលេង<br>• សម្បទាការងារសង្គ្រោះ<br>• សារមន្ទីរធនធានសមុទ្រខ្នាតតូច<br>• អាងប្រព្រឹត្តកម្មទឹកកខ្វក់ខ្នាតតូច<br>• សម្បទាបន្ទាប់បន្សំ កៅអី រូបសំណាក ផ្លាកសញ្ញា បង្គោលភ្លើងបំភ្លឺ ធុងសំរាម។ល ។ | • រាល់ការសាងសង់សំណង់រឹងមាំ |

### ៣-តំបន់រណប

តំបន់រណបត្រូវបានអនុញ្ញាតឱ្យមានការអភិវឌ្ឍនិងការសាងសង់សំណង់រឹងមាំដែលបម្រើផលដល់ការស្នាក់នៅ សេវាកម្ម សកម្មភាពទេសចរណ៍ ការទទួលទានអាហារ ការទិញទំនិញ និងសកម្មភាពវប្បធម៌មានដូចជាសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋានឬហាងកាហ្វេ ហាងលក់ទំនិញរាយ សាលពិព័រណ៍សិល្បៈ ចំណតយានយន្ត សួនកុមារ ។ល។ ដើម្បីលើកកម្ពស់សោភណភាព បរិស្ថានធម្មជាតិ និងសំណង់ ការអភិវឌ្ឍនិងការសាងសង់ក្នុងតំបន់រណបដែលមានតំបន់ការពារទេសភាព តំបន់អភិវឌ្ឍន៍ប្រកបដោយចីរភាព និងតំបន់អភិវឌ្ឍន៍សមាហរណកម្មត្រូវគោរពតាមគោលការណ៍ដូចមានកំណត់ក្នុងតារាងខាងក្រោម៖

តារាងទី៣៖ ការកំណត់បទប្បញ្ញត្តិប្រើប្រាស់ដីនៅតំបន់ការពារទេសភាព

| ប្រភេទ | បទប្បញ្ញត្តិ |
|---|---|
| **ផ្លាតម្លាត** | - ផ្លាតម្លាតផ្លូវខាងមុខយ៉ាងតិច៦ម៉ែត្រ<br>- ផ្លាតម្លាតផ្លូវខាងក្រោយយ៉ាងតិច៦ម៉ែត្រ (ត្រូវបើកចំហសម្រាប់ជាផ្លូវថ្មើរជើង កន្លែងពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍)<br>- ផ្លាតម្លាតសងខាងយ៉ាងតិច៣ម៉ែត្រ ក្នុងករណីជាប់នឹងផ្លូវត្រូវរក្សាគម្លាតយ៉ាងតិច៦ម៉ែត្រ<br>(ដូចមានបង្ហាញលម្អិតក្នុងរូបភាពទី១) |

| | |
|---|---|
| **កម្ពស់និងដង់ស៊ីតេ** | - កម្ពស់អតិបរមា១៨ម៉ែត្រ<br>- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូតិ៍៥០%<br>- សន្ទស្សន៍ប្រើប្រាស់ដីផ្ទៃការ១,៥<br>(ដូចមានបង្ហាញលម្អិតក្នុងរូបភាពទី១) |
| **សំណង់និងការប្រើប្រាស់** | - បរិក្ខារបម្រើឱ្យការស្នាក់នៅតាមឆ្នេរ អគារពាណិជ្ជកម្ម (ហាងកាហ្វេ ហាងស្រា ភោជនីយដ្ឋាន និងកន្លែងលក់ដូរ) សារមន្ទីរ ការកម្សាន្ត និងបរិក្ខារសាធារណៈ<br>- ជាន់ខាងក្រោមនៃអគារប្រើប្រាស់សម្រាប់បំពាក់បរិក្ខារសាធារណៈឬជាកន្លែងពាណិជ្ជកម្ម |
| **ចំណតរថយន្ត** | - ភោជនីយដ្ឋាន២០ម៉ $^2$ មានចំណត១, កន្លែងលក់ដូរ៣០ម៉ $^2$ មានចំណត១ និងអគារពាណិជ្ជកម្ម៥០ម៉ $^2$ មានចំណត១<br>- សណ្ឋាគារមានចំណត១សម្រាប់៥បន្ទប់ |

តារាងទី៤៖ ការកំណត់បទប្បញ្ញត្តិប្រើប្រាស់ដីនៅតំបន់អភិវឌ្ឍន៍ប្រកបដោយចីរភាព

| ប្រភេទ | បទប្បញ្ញត្តិ |
|---|---|
| **ថ្នាតម្លាត** | - ថ្នាតម្លាតផ្លូវខាងមុខយ៉ាងតិច៦ម៉ែត្រ<br>- ថ្នាតម្លាតផ្លូវខាងក្រោយយ៉ាងតិច៦ម៉ែត្រ (ត្រូវបើកចំហសម្រាប់ជាផ្លូវថ្មើរជើង កន្លែងពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍)<br>- ថ្នាតម្លាតសងខាងយ៉ាងតិច៣ម៉ែត្រ ក្នុងករណីជាប់នឹងផ្លូវត្រូវរក្សាតម្លាតយ៉ាងតិច៦ម៉ែត្រ<br>(ដូចមានបង្ហាញលម្អិតក្នុងរូបភាពទី១) |
| **កម្ពស់និងដង់ស៊ីតេ** | - កម្ពស់អតិបរមា២៧ម៉ែត្រ<br>- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូតិ៍៥០%<br>- សន្ទស្សន៍ប្រើប្រាស់ដីផ្ទៃការ២,៥<br>(ដូចមានបង្ហាញលម្អិតក្នុងរូបភាពទី១) |
| **សំណង់និងការប្រើប្រាស់** | - បរិក្ខារបម្រើឱ្យការស្នាក់នៅតាមឆ្នេរ អគារពាណិជ្ជកម្ម (ហាងកាហ្វេ ហាងស្រា ភោជនីយដ្ឋាន និងកន្លែងលក់ដូរ) អគារស្នាក់នៅ (សណ្ឋាគារ វីឡា និងផ្ទះសំណាក់) ការិយាល័យ សារមន្ទីរ កន្លែងកម្សាន្ត និងបរិក្ខារសាធារណៈ<br>- ជាន់ខាងក្រោមនៃអគារប្រើប្រាស់ជាកន្លែងពាណិជ្ជកម្ម |

| | |
|---|---|
| **ចំណតរថយន្ត** | - ភោជនីយដ្ឋាន២០ម$^{២}$ មានចំណត១, កន្លែងលក់ស្រា៣០ម$^{២}$ មានចំណត១, អគារពាណិជ្ជកម្ម៥០ម$^{២}$ មានចំណត១, អគារស្នាក់នៅ១០០ម$^{២}$ មានចំណត១ និងអគារសាធារណៈ១០០ម$^{២}$ មានចំណត១<br>- សណ្ឋាគារមានចំណត១សម្រាប់៥បន្ទប់ |

តារាងទី៥៖ ការកំណត់បទប្បញ្ញត្តិប្រើប្រាស់ដីនៅតំបន់អភិវឌ្ឍន៍សមាហរណកម្ម

| ប្រភេទ | បទប្បញ្ញត្តិ |
|---|---|
| **ថ្នាតម្លាត** | - ថ្នាតម្លាតផ្លូវខាងមុខយ៉ាងតិច៦ម៉ែត្រ<br>- ថ្នាតម្លាតផ្លូវខាងក្រោយយ៉ាងតិច៦ម៉ែត្រ (ត្រូវបើកចំហសម្រាប់ជាផ្លូវថ្មើរជើង កន្លែងពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍)<br>- ថ្នាតម្លាតសងខាងយ៉ាងតិច៣ម៉ែត្រ ក្នុងករណីជាប់នឹងផ្លូវត្រូវរក្សាតម្លាតយ៉ាងតិច៦ម៉ែត្រ<br>(ដូចមានបង្ហាញលម្អិតក្នុងរូបភាពទី១) |
| **កម្ពស់និងដង់ស៊ីតេ** | - កម្ពស់អតិបរមា៣៦ម៉ែត្រ<br>- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូតិ៍៥០%<br>- សន្ទស្សន៍ប្រើប្រាស់ដីផ្លូវការ៣,៥<br>(ដូចមានបង្ហាញលម្អិតក្នុងរូបភាពទី១) |
| **សំណង់និងការប្រើប្រាស់** | - បរិក្ខារបម្រើឱ្យការស្នាក់នៅតាមឆ្នេរ អគារពាណិជ្ជកម្ម (ហាងកាហ្វេ ហាងស្រា ភោជនីយដ្ឋាន និងកន្លែងលក់ស្រា) អគារស្នាក់នៅ (សណ្ឋាគារ វីឡា និងផ្ទះសំណាក់) ការិយាល័យ សារមន្ទីរ កន្លែងកម្សាន្ត និងបរិក្ខារសាធារណៈ<br>- ជាន់ខាងក្រោមនៃអគារប្រើប្រាស់ជាកន្លែងពាណិជ្ជកម្ម |
| **ចំណតរថយន្ត** | - ភោជនីយដ្ឋាន២០ម$^{២}$ មានចំណត១, កន្លែងលក់ស្រា៣០ម$^{២}$ មានចំណត១, អាគារពាណិជ្ជកម្ម៥០ម$^{២}$ មានចំណត១, អគារស្នាក់នៅ១០០ម$^{២}$មានចំណត១ និងអគារសាធារណៈ១០០ម$^{២}$ មានចំណត១<br>- សណ្ឋាគារមានចំណត១សម្រាប់៥បន្ទប់ |
| ការលើកទឹកចិត្តចំពោះការវិនិយោគការអភិវឌ្ឍ និងការសាងសង់ចំណតយានយន្តសម្រាប់បម្រើសេវាសាធារណៈ | អាជ្ញាធរមានសមត្ថកិច្ចអាចលើកទឹកចិត្តដល់អ្នកវិនិយោគដែលអភិវឌ្ឍនិងសាងសង់ចំណតយានយន្តបម្រើសេវាសាធារណៈដោយផ្តល់បន្ថែមនូវសន្ទស្សន៍ប្រើប្រាស់ដីស្មើ ២ដងនៃចំនួនផ្ទៃក្រឡាដែលអភិវឌ្ឍសម្រាប់ចំណត |

### ៥.៣-ប្លង់កម្ពស់

ប្លង់កម្ពស់អគារត្រូវរៀបចំនិងកំណត់ក្នុងគោលបំណងរក្សានូវគំហើញទេសភាពនិងសោភណភាពតំបន់ទីក្រុងមាត់ទឹកនៅតាមបណ្ដោយឆ្នេរសមុទ្រ។ ប្លង់កម្ពស់អគារត្រូវរៀបចំឡើងកំណត់កម្ពស់អគារពីកម្ពស់ទាបទៅខ្ពស់ដោយកម្ពស់ទាបគិតចាប់ចេញពីតំបន់ការពារទេសភាពនិងខ្ពស់បន្តិចម្ដងៗឆ្ពោះទៅកាន់ទិសខាងនិគោក។ ប្លង់កម្ពស់អគារតំបន់រមណីយដ្ឋានឆ្នេរកម្សាន្តត្រូវបានកំណត់ដោយភ្ជាប់បង្ហាញគំនូរប្លង់ដូចខាងក្រោម៖

- តំបន់ការពារទេសភាព៖ កម្ពស់អតិបរមាត្រូវបានកំណត់១៨ម៉ែត្រដើម្បីរក្សាគំហើញទេសភាពនិងសោភណភាពឆ្នេរសមុទ្រ។ ចំពោះអគារនៅជាន់ក្រោមត្រូវប្រើប្រាស់សម្រាប់សកម្មភាពពាណិជ្ជកម្មនិងរៀបចំបំពាក់បរិក្ខារដែលមានមុខងារច្រើនយ៉ាងនិងអាចប្រើប្រាស់ទាំងពេលថ្ងៃនិងពេលយប់បានដើម្បីបម្រើឱ្យវិស័យទេសចរណ៍
- តំបន់អភិវឌ្ឍន៍ប្រកបដោយចីរភាព៖ កម្ពស់អតិបរមាត្រូវបានកំណត់២៧ម៉ែត្រដើម្បីរក្សាគំហើញទេសភាពនិងសោភណភាពឆ្ពោះទៅទិសខាងមាត់សមុទ្រ
- តំបន់អភិវឌ្ឍន៍សមាហរណកម្ម៖ កម្ពស់អតិបរមាត្រូវបានកំណត់៣៦ម៉ែត្រដើម្បីរក្សាគំហើញទេសភាពនិងសោភណភាពឆ្ពោះទៅទិសខាងមាត់សមុទ្រ។

## បទបញ្ញត្តិគតុបនីយកម្មសម្រាប់ការអភិវឌ្ឍ និងការអភិរក្សតំបន់ឆ្នេរសមុទ្រកម្ពុជា




រូបភាពទី១៖ ស្ទៃនៃការកំណត់បទបញ្ញត្តិគតុបនីយកម្មសម្រាប់ការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ

## ៦.៤-ការរៀបចំប្លង់លម្អិតនគរូបនីយកម្ម គំហើញ និងទេសភាពតាមដងផ្លូវ

ការគិតគូរដោយហ្មត់ចត់ទៅលើប្លង់លម្អិតនគរូបនីយកម្មនឹងផ្តល់ផលល្អសម្រាប់គំហើញខ្សែភ្នែក ការត្រជាក់ដោយប្រយោល និងការរស់នៅប្រកបដោយសុខុមាលភាព ព្រមទាំងលើកកម្ពស់ដល់សោភណភាពនៅតាមដងផ្លូវ។ គោលការណ៍សំខាន់ៗសម្រាប់ការរៀបចំប្លង់លម្អិតនគរូបនីយកម្ម គំហើញ និងទេសភាពតាមដងផ្លូវត្រូវបានកំណត់ដូចខាងក្រោម៖

- រាល់ការអភិវឌ្ឍនិងការសាងសង់ត្រូវគោរពតាមខ្សែរយៈកម្ពស់ដីដែលត្រូវអភិវឌ្ឍនិងសាងសង់តាមតំបន់នីមួយៗដែលបានកំណត់ដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ខេត្ត។ ការកំណត់ខ្សែរយៈកម្ពស់ដីដែលត្រូវអភិវឌ្ឍនិងសាងសង់ត្រូវផ្អែកទៅលើហេដ្ឋារចនាសម្ព័ន្ធផ្លូវនិងប្រព័ន្ធលូបង្ហូរស្របតាមទីតាំងភូមិសាស្ត្រនៃតំបន់នីមួយៗ
- ត្រូវរៀបចំសំណង់ដោយប្រើប្រាស់ប្រព័ន្ធខ្យល់ធម្មជាតិឱ្យបានច្រើននិងមានពន្លឺគ្រប់គ្រាន់ចូលដល់ក្នុងអគារ
- ត្រូវគិតគូរពីទីតាំង ការរចនាបង្អួច និងទិសសំណង់ដើម្បីសម្រួលដល់ការឆ្លងកាត់របស់ខ្យល់ធម្មជាតិ
- ត្រូវរចនាសំណង់ដោយរក្សាបាននូវគំហើញទៅកាន់ឆ្នេរសមុទ្រដោយ៖
  - ដំបូលមានមុំសមស្រប
  - រចនាគម្រោងប្លង់ស្ថាបត្យកម្មតាមទម្រង់ឆ្លាស់គ្នា
  - សាងសង់សំណង់តាមសណ្ឋានដីធម្មជាតិដោយចៀសវាងការកាត់ដី ជីកដី ឬចាក់បំពេញដីលើសពីការកំណត់ ដើម្បីរក្សាទេសភាពភូមិសាស្ត្រធម្មជាតិ។
- ត្រូវរៀបចំសំណង់និងទីតាំងឱ្យមានទំនាក់ទំនងល្អជាមួយផ្លូវនិងមានច្រកចូលដែលងាយស្រួលក្នុងការប្រើប្រាស់
- ដើម្បីរក្សាបានភាពទាក់ទាញនៃសំណង់និងលើកកម្ពស់ទេសភាពតាមដងផ្លូវត្រូវ៖
  - ប្រើប្រាស់ពណ៌លើសំណង់ឱ្យស៊ីសង្វាក់គ្នានឹងទេសភាពតាមដងផ្លូវ
  - មានរបងដែលមានកម្ពស់ទាបល្មមនិងប្រើប្រាស់សម្ភារៈសំណង់កម្រិតមធ្យមនិងស្រាល
  - មានបំពាក់និងដាំរុក្ខជាតិលម្អនៅលើរានហាលនិងជញ្ជាំងអគារ
  - មានរានហាលដែលមានបង្កាន់ដៃនិងប្រើសម្ភារៈមានពណ៌ស្រាល។
- សំណង់ដែលមានទីតាំងនៅផ្លូវកែងត្រូវរៀបចំមានលក្ខណៈដូចខាងក្រោម៖
  - សំណង់ត្រូវមានពណ៌សមស្រប
  - សំណង់ត្រូវមានរូបភាពគំហើញនិងសោភណភាពដែលទាក់ទាញពីផ្លូវកែង
  - គំហើញសំណង់នៅតាមព្រំដីដែលមានប្រវែងវែងត្រូវរចនាឱ្យមានបង្អួចវែងៗ រានហាល និងផ្លាកម្លាតជញ្ជាំង។

## ៦.៥-ការបង្កើតលម្ហសាធារណៈ

គោលបំណងសំខាន់នៃការបង្កើតលម្ហសាធារណៈនៅក្នុងតំបន់ ដោយផ្អែកលើការសិក្សា ការគិតគូរអំពីបរិស្ថានក្នុងតំបន់និងផ្លូវនៅជុំវិញដើម្បីធានាបាននូវលម្ហសាធារណៈ គុណភាពខ្យល់ ផ្ទៃជម្រៀសនៅក្នុងតំបន់ និងបង្កើតតំបន់លម្ហសាធារណៈក្នុងតំបន់ដែលមិនទាន់មានដើម្បីលើកកម្ពស់បរិស្ថានទីក្រុង។ គោលការណ៍ណែនាំអនុវត្តសំខាន់ៗសម្រាប់ការបង្កើតលម្ហសាធារណៈមានដូចខាងក្រោម៖

– រៀបចំផ្ទៃបៃតងនិងលម្ហសាធារណៈនៅលើផ្លូវប្រសព្វធំនៅត្រង់ចំណុចកែងលើផ្លូវប្រសព្វដែលនៅជាប់នឹងផ្លូវ២ឬច្រើន
– ក្នុងករណីដែលមានផ្លូវកាត់គ្នាច្រើនជាង១ត្រូវរៀបចំលម្ហសាធារណៈនៅចំហៀងផ្លូវ
– រៀបចំតំបន់លម្ហសាធារណៈឱ្យបានច្រើនដែលបែងចែកប្រភេទតំបន់លម្ហសាធារណៈសម្រាប់អ្នកថ្មើរជើងនិងសម្រាប់សាធារណជនទូទៅប្រើប្រាស់ទៅតាមស្ថានភាពរបស់តំបន់ជាក់ស្តែង
– កំណត់ផ្លាតម្លាតសំណង់យ៉ាងតិច៦ម៉ែត្រនៅខាងមុខលម្ហសាធារណៈសម្រាប់ថ្មើរជើងហើយតុបតែងដោយគ្រឿងសង្ហារឹមនិងដើមរុក្ខជាតិតាមចិញ្ចើមផ្លូវសម្រាប់បរិស្ថានផ្លូវល្អប្រសើរ
– រៀបចំនិងជ្រើសរើសប្រភេទសម្ភារៈសម្រាប់រៀបចំចិញ្ចើមផ្លូវដែលមានលក្ខណៈសម្គាល់អត្តសញ្ញាណក្នុងតំបន់និងមានតំរូវដូចគ្នាដោយរក្សាបរិស្ថានបៃតង
– ធ្វើការរៀបចំចិញ្ចើមផ្លូវដោយមិនឱ្យមានឧបសគ្គឬការរាំងដល់ថ្មើរជើងធ្វើដំណើរ
– ក្នុងករណីដែលលម្ហសាធារណៈនៅជិតនឹងតំបន់បៃតងសាធារណៈដទៃទៀតត្រូវធ្វើការរៀបចំភ្ជាប់ទំនាក់ទំនងតភ្ជាប់ទៅនឹងតំបន់បៃតងនិងលម្ហសាធារណៈនោះ
– លើកទឹកចិត្តក្នុងការផ្តល់សន្ទស្សន៍ប្រើប្រាស់ដីចំពោះម្ចាស់កម្មសិទ្ធិករដែលបានចូលរួមរៀបចំនិងអភិវឌ្ឍផ្លូវថ្មើរជើងនិងលម្ហសាធារណៈដោយរក្សាប្រវែងតម្លាតខាងក្រោយយ៉ាងតិច៦ម៉ែត្រសម្រាប់សេវាកម្មពាណិជ្ជកម្មនិងទេសចរណ៍។ ទំហំដីដែលត្រូវបើកចំហសម្រាប់ការអភិវឌ្ឍផ្លូវថ្មើរជើងនិងលម្ហសាធារណៈសម្រាប់សេវាកម្មពាណិជ្ជកម្មនិងទេសចរណ៍មានប្រវែងតម្លាតខាងក្រោយ៦ម៉ែត្រគុណនឹងប្រវែងទទឹងដីកាន់កាប់ជាក់ស្តែងដោយរក្សាកម្មសិទ្ធិដីនៅដដែលនិងម្ចាស់ដីទទួលបាននូវការប្រើប្រាស់ទីតាំងនេះសម្រាប់សេវាកម្មពាណិជ្ជកម្មនិងត្រូវបើកចំហជាផ្លូវថ្មើរជើងសម្រាប់សាធារណជនចេញចូលនិងធ្វើដំណើរបានគ្រប់ពេលយ៉ាងតិច៤ម៉ែត្រ ដោយក្បាលដីមួយខាងចូលរួមរៀបចំផ្លូវថ្មើរជើងយ៉ាងតិច២ម៉ែត្រ ដូចមានគំនូរប្លង់ខាងក្រោម។



រូបភាពទី២៖ គំរូនៃការរៀបចំតំបន់លម្ហសាធារណៈ

## ៥.៦-ការរៀបចំផ្លូវថ្មើរជើង ផ្លូវជនមានពិការភាព និងផ្លូវជិះកង់សាធារណៈ

ដើម្បីធានាសោភណភាពសាធារណៈ សុវត្ថិភាព សុខុមាលភាព និងភាពងាយស្រួលដល់អ្នកថ្មើរជើង ជនមានពិការភាព និងអ្នកជិះកង់ធ្វើដំណើរទៅកាន់ឆ្នេរសមុទ្រ ការរៀបចំផ្លូវថ្មើរជើង ផ្លូវជនមានពិការភាព និងផ្លូវជិះកង់សាធារណៈនៅតំបន់ឆ្នេរសមុទ្រ ត្រូវអនុវត្តតាមគោលការណ៍សំខាន់ៗដូចខាងក្រោម៖

- រៀបចំផ្លូវថ្មើរជើង ផ្លូវជនមានពិការភាព និងផ្លូវជិះកង់សាធារណៈតាមបទដ្ឋានបច្ចេកទេស ដើម្បីធ្វើដំណើរទៅកាន់ឆ្នេរសមុទ្រដោយភ្ជាប់ទៅនឹងបណ្តាញបៃតងដូចជាឆ្នេរសមុទ្រ សួនច្បារនិងឧទ្យានជាដើម
- រៀបចំរចនាសម្ព័ន្ធដែលផ្តល់អាទិភាពដល់ផ្លូវថ្មើរជើង ផ្លូវជនមានពិការភាព និងផ្លូវជិះកង់នៅកន្លែងដែលប្រសព្វរវាងផ្លូវនេះនិងផ្លូវធ្វើដំណើរទូទៅ
- មិនអនុញ្ញាតឱ្យមានការសាងសង់ឬការរៀបចំនៅលើផ្លូវថ្មើរជើង ផ្លូវជនមានពិការភាព និងផ្លូវជិះកង់ដែលប៉ះពាល់ឬរំខានដល់ការធ្វើដំណើរជាសាធារណៈ
- រៀបចំកម្ពស់ផ្លូវឱ្យស្មើគ្នាទាំងផ្លូវថ្មើរជើងនិងផ្លូវដែលតភ្ជាប់ជាមួយនឹងផ្លូវថ្មើរជើង
- ត្រូវរៀបចំសាងសង់ជម្រាលសម្រាប់សម្រួលដល់ថ្មើរជើងនិងជណ្តើរសម្រាប់ជនមានពិការភាពក្នុងករណីដែលកម្រិតកម្ពស់ផ្លូវនៅចុងសងខាងខុសគ្នា
- កាត់បន្ថយការប្រើប្រាស់ផ្ទៃមិនជ្រាបទឹកនិងបង្កើនផ្ទៃជ្រាបទឹកសម្រាប់ផ្លូវថ្មើរជើងដើម្បីឱ្យទឹកជ្រាបចូលក្នុងដីបានច្រើននិងចៀសវាងទឹកហូរច្រោះដោយប្រើប្រាស់សម្ភារៈសាងសង់ផ្លូវដែលមានលក្ខណៈសមស្របនឹងបរិស្ថានឆ្នេរខ្សាច់
- រាល់ការរៀបចំផ្លូវថ្មើរជើង ផ្លូវជនមានពិការភាព និងផ្លូវជិះកង់ត្រូវគោរពតាមសេចក្តីសម្រេចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់លេខ០៣៩សសរ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់ស្តាបត្យកម្មចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង និងគន្លងផ្លូវទោចក្រយានសម្រាប់សាធារណជននិងជនមានពិការភាព។




រូបភាពទី៣៖ គំរូនៃការរៀបចំផ្លូវថ្មើរជើងនិងការភ្ជាប់ទៅនឹងផ្ទៃបៃតង

## ៦.៧- ការគ្រប់គ្រងនិងការកំណត់ផ្លាតម្លាតអគារ

ដើម្បីរក្សាបរិស្ថានរស់នៅល្អប្រសើរ បង្កើនផ្ទៃបៃតង រក្សាលម្ហសម្រាប់ការពារនិងកាត់បន្ថយសំឡេងតាមដងផ្លូវសាធារណៈ ការកំណត់ផ្លាតម្លាតអគារនៅតំបន់ឆ្នេរសមុទ្រត្រូវអនុវត្តតាមគោលការណ៍ណែនាំដូចខាងក្រោម៖

- ហាមសាងសង់ជញ្ជាំងអគារលើសពីប្លង់ផ្លាតម្លាតដែលបានកំណត់
- ហាមដាក់តាំងឬបំពាក់សម្ភារៈបរិក្ខារដែលរំខានដល់ថ្មើរជើងដូចជាផ្ទាំង របង និងយានយន្តនៅកន្លែងដែលបានកំណត់តាមគោលការណ៍នគរូបនីយកម្មសម្រាប់ផ្លូវថ្មើរជើង
- អនុវត្តតាមប្លង់ផ្លាតម្លាតអគារពីព្រំប្រទល់ដីកាន់កាប់ស្របច្បាប់ ដូចដែលបានកំណត់នៅក្នុងតំបន់ការពារទេសភាព តំបន់អភិវឌ្ឍន៍ប្រកបដោយចីរភាព តំបន់អភិវឌ្ឍន៍សមាហរណកម្ម និងប្រើប្រាស់លម្ហផ្លាតម្លាតនេះភ្ជាប់ជាមួយនឹងលម្ហដែលមានស្រាប់សម្រាប់សកម្មភាពពាណិជ្ជកម្ម ទេសចរណ៍ ការកម្សាន្តនៅឆ្នេរសមុទ្រ និងផ្លូវថ្មើរជើង
- ហាមសាងសង់ភានហាលនៅជាន់ខាងលើលើសពីការកំណត់ដោយបទប្បញ្ញត្តិនគរូបនីយកម្មនិងលិខិតអនុញ្ញាតសាងសង់។




រូបភាពទី៨៖ គោលការណ៍ណែនាំនៃការកំណត់ព្រំប្រទល់អគារ

## ៦.៨- ការរៀបចំរបងនៅតំបន់ឆ្នេរសមុទ្រ

ដើម្បីរក្សាសោភណភាព ការពារបរិស្ថានធម្មជាតិ និងតំហើញទេសភាព ត្រូវគោរពតាមមុខងារតំបន់ប្រើប្រាស់ដីនៃទីក្រុងមាត់ទឹកនិងឆ្នេរសមុទ្រ ការរៀបចំបទដ្ឋានសម្រាប់ការសាងសង់របងនៅតំបន់ឆ្នេរសមុទ្រ ត្រូវអនុវត្តតាមគោលការណ៍ណែនាំដូចខាងក្រោម៖

- កំណត់ការសាងសង់របងនៅផ្នែកខាងមុខនៃអគារតាមផ្លូវស្របតាមបណ្ដោយឆ្នេរសមុទ្រនិងផ្លូវឆ្ពោះទៅឆ្នេរសមុទ្រ ស្របតាមតំបន់ប្រើប្រាស់ដីនីមួយៗនៃទីក្រុង
- ហាមសាងសង់របងនៅក្នុងតំបន់ពាណិជ្ជកម្ម តំបន់ទេសចរណ៍ និងនៅផ្នែកខាងមុខនៃតំបន់លម្ហសាធារណៈនិងតំបន់ចំណតចេញចូល។ ក្នុងករណីចាំបាច់ដែលត្រូវសាងសង់របងដោយមិនអាចចៀសវាងបានត្រូវសាងសង់របងទាបនិងអាចមើលធ្លុះបានដើម្បីរក្សាគំហើញទេសភាពឆ្នេរសមុទ្រ
- រចនាស្ថាបត្យកម្មនិងប្រើប្រាស់សម្ភារៈសំណង់របងដែលស្ថិតនៅតាមផ្លូវតែមួយឱ្យមានសោភណភាពសណ្ដាប់ធ្នាប់សាធារណៈ និងសុខដុមរមនា
- លើកទឹកចិត្តដល់ការសាងសង់របងដែលធ្វើអំពីរុក្ខជាតិបៃតងនិងមានលក្ខណៈសមស្របទៅនឹងបរិស្ថានរបស់តំបន់ឆ្នេរសមុទ្រ
- រៀបចំប្លង់ស្ថាបត្យកម្មស្របតាមបទប្បញ្ញត្តិនគរូបនីយកម្ម ដើម្បីស្នើសុំលិខិតអនុញ្ញាតសាងសង់របងពីអាជ្ញាធរមានសមត្ថកិច្ច។

### ៤.៩-ការគ្រប់គ្រងច្រកចេញចូលយានយន្ត

ដើម្បីគ្រប់គ្រងចរាចរណ៍និងបញ្ចៀសការកកស្ទះចរាចរណ៍ដោយធ្វើការគិតគូរទៅលើស្ថានភាពតំបន់ហ៊ានុក្រមផ្លូវ និងមុខងារនៃអគារដែលបែរមុខមកផ្លូវ និងដើម្បីផ្ដល់អាទិភាពសម្រាប់ថ្មើរជើងធ្វើដំណើរ ប្រកបដោយសុវត្ថិភាពនិងមានភាពងាយស្រួល ការគ្រប់គ្រងច្រកចេញចូលយានយន្តនៅតំបន់ឆ្នេរសមុទ្រ ត្រូវអនុវត្តតាមគោលការណ៍សំខាន់ៗដូចខាងក្រោម៖

- កំណត់ច្រកចេញចូលរបស់យានយន្តក្នុងដីឡូត៍នៅតាមដងផ្លូវដែលមិនមែនជាផ្លូវមេ និងមិនឱ្យជាប់នឹងផ្លូវប្រសព្វគ្នាដោយផ្អែកទៅលើស្ថានភាពជាក់ស្ដែងរបស់ផ្លូវនិងតំបន់
- ហាមរៀបចំច្រកយានយន្តចេញចូលក្នុងដីឡូត៍ក្នុងចម្ងាយ៣០ម៉ែត្រពីចំណុចប្រសព្វផ្លូវមេនិងក្នុងចម្ងាយ១០ម៉ែត្រពីចំណុចប្រសព្វអនុវិថី
- ហាមរៀបចំច្រកយានយន្តចេញចូលក្នុងដីឡូត៍ក្នុងចម្ងាយ១០ម៉ែត្រពីផ្លូវប្រសព្វនៅក្នុងតំបន់ទេសចរណ៍
- ហាមរៀបចំច្រកចេញចូលយានយន្តក្នុងដីឡូត៍ចេញទៅផ្លូវសំខាន់ៗនិងមានភាពមមាញឹកខ្លាំង លើកលែងក្នុងករណីចាំបាច់ដែលមិនអាចចៀសវាងបាន។



រូបភាពទី៥៖ ផែនការរៀបចំសម្រាប់ការគ្រប់គ្រងការចេញចូលយានយន្ត

តារាងទី៦៖ ការកំណត់ចរាចរណ៍របស់យានយន្តនៅតំបន់ឆ្នេរសមុទ្រ

| ចំណតរថយន្តក្រុង ផ្លូវថ្មើរជើងឆ្លងកាត់ កន្លែងឆ្លងកាត់ | ផ្លូវថ្មើរជើងនិងផ្លូវក្នុងសួនឧទ្យាន |
|---|---|
| - មិនអនុញ្ញាតឱ្យមានច្រកចេញចូលយានយន្តក្នុងចម្ងាយ៣០ ម៉ែត្រនៅពីមុខនិងពីក្រោយចំណតរថយន្តក្រុង<br>- មិនអនុញ្ញាតឱ្យមានច្រកចេញចូលយានយន្តក្នុងចម្ងាយ១០ ម៉ែត្រនៅពីមុខនិងពីក្រោយផ្លូវថ្មើរជើងឆ្លងកាត់និងស្ពានអាកាស។ | - មិនអនុញ្ញាតឱ្យមានច្រកយានយន្តចេញចូលក្នុងជិឡូត៍និងចរាចរណ៍នៅលើផ្លូវថ្មើរជើងនិងផ្លូវក្នុងសួនឧទ្យានឡើយ លើកលែងតែរថយន្តសង្គ្រោះបន្ទាន់។ |

### ៤.១០-ចំណតកង់និងយានយន្តសាធារណៈ

ចំណតកង់និងយានយន្តសាធារណៈត្រូវមានចំណុះសមាមាត្រទៅនឹងកម្រិតនៃការប្រើប្រាស់តំបន់កម្សាន្ត មានទីតាំងសមស្រប និងរក្សាបាននូវតម្លៃអភិរក្សរុក្ខជាតិនិងធម្មជាតិនៅក្នុងតំបន់។ គោលការណ៍សំខាន់ៗសម្រាប់ការរៀបចំចំណតយានយន្តសាធារណៈមានដូចខាងក្រោម៖

- សាងសង់ឱ្យមានចំណតសម្រាប់រថយន្តក្រុង រថយន្តទេសចរណ៍ កង់ និងយានយន្ត សម្រាប់មនុស្សទាំងអស់ក្នុងរួមទាំងជនមានពិការភាព
- រៀបចំកន្លែងដាច់ដោយឡែកសម្រាប់ចំណតរថយន្តឈ្នួល រថយន្តក្រុង និងយានយន្តដឹកទំនិញ
- រៀបចំចំណតសម្រាប់រថយន្តសង្គ្រោះបន្ទាន់ រថយន្តពន្លត់អគ្គីភ័យ ក្នុងករណីមានគ្រោះអាសន្នបន្ទាន់។

### ៤.១.២- ការគ្រប់គ្រងសកម្មភាពនៅតំបន់ឆ្នេរសមុទ្រទៅតាមពេលវេលា

គោលបំណងសំខាន់នៃការរៀបចំផែនការគ្រប់គ្រងសកម្មភាពនៅតំបន់ឆ្នេរសមុទ្រទៅតាមពេលវេលា ដើម្បីធ្វើការគ្រប់គ្រងចរាចរណ៍នៅលើផ្លូវតាមបណ្តោយឆ្នេរសមុទ្រនិងផ្លូវដែលភ្ជាប់ទៅនឹងតំបន់ពាណិជ្ជកម្មនៃតំបន់ឆ្នេរសមុទ្រនាចុងសប្តាហ៍និងអំឡុងពេលមានព្រឹត្តិការណ៍សំខាន់ៗនិងធ្វើការសម្របសម្រួលរៀបចំកម្មវិធីទេសចរណ៍ឱ្យមានលក្ខណៈពិសេសផ្សេងៗគ្នារវាងថ្ងៃធម្មតានិងថ្ងៃដែលមានព្រឹត្តិការណ៍សំខាន់ៗដែលជាការលើកកម្ពស់ការប្រើប្រាស់ទីតាំងឱ្យមានប្រសិទ្ធភាព។ ការគ្រប់គ្រងសកម្មភាពនៅតំបន់ឆ្នេរសមុទ្រទៅតាមពេលវេលាត្រូវបានកំណត់ក្នុងតារាងដូចខាងក្រោម៖

តារាងទី៧៖ ការគ្រប់គ្រងសកម្មភាពទេសចរណ៍ទៅតាមពេលវេលា

| ចំណាត់ថ្នាក់ | បទប្បញ្ញត្តិ |
|---|---|
| **ពាក់កណ្តាលយប់ -ពេលព្រឹក<br>រៀងរាល់ថ្ងៃ<br>ម៉ោង២៤:០០-៥:០០** | ▪ ការឆ្លងកាត់របស់យានយន្តត្រូវបានអនុញ្ញាតដូចជារថយន្តដឹកទំនិញនិងដឹកជញ្ជូនសាធារណៈនៅក្នុងតំបន់ពាណិជ្ជកម្មក្បែរនោះ<br>▪ បង្កើតកន្លែងសម្រាប់ទេសចរនាពេលថ្ងៃដោយគិតគូរថែរក្សាទេសភាពទីក្រុង<br>▪ អាចអនុញ្ញាតឱ្យសកម្មភាពទេសចរនិងការចរាចរណ៍យានជំនិះនៅម៉ោង៧ ឬក្រោយម៉ោង៧។ |
| **ពេលថ្ងៃ<br>ថ្ងៃធ្វើការធម្មតា<br>ម៉ោង៥:០០-១៨:០០** | ▪ គ្រប់គ្រងការឆ្លងកាត់នៃយានយន្តទៅលើកលែងតែមធ្យោបាយធ្វើដំណើរសាធារណៈ រថយន្តសង្គ្រោះបន្ទាន់ និងមធ្យោបាយដឹកជញ្ជូនផ្សេងៗ<br>▪ សម្របសម្រួលកម្មវិធីទេសចរណ៍ដោយប្រើប្រាស់ទីធ្លាផ្លូវមួយចំនួនជាកន្លែងសម្រាប់កម្សាន្តនិងសម្រាប់ភ្ញៀវទេសចរទទួលទានអាហារ។ |
| **ពេលល្ងាច<br>ថ្ងៃធ្វើការធម្មតា<br>ម៉ោង១៨:០០-២៤:០០** | ▪ គ្រប់គ្រងការឆ្លងកាត់នៃយានយន្តទៅលើកលែងតែមធ្យោបាយធ្វើដំណើរសាធារណៈ រថយន្តសង្គ្រោះបន្ទាន់<br>▪ សម្របសម្រួលកម្មវិធីទេសចរណ៍ដោយប្រើប្រាស់ទីធ្លាផ្លូវមួយចំនួនជាកន្លែងសម្រាប់កម្សាន្តនិងសម្រាប់ភ្ញៀវទេសចរទទួលទានអាហារ។ |

### ៤.១.៣- យុទ្ធសាស្ត្រអភិរក្សនិងអភិវឌ្ឍកោះ

ក្រុងព្រះសីហនុជាតំបន់ជាប់នឹងសមុទ្រ មានប្រជុំកោះ និងកោះសំខាន់ៗដូចជាកោះព្រាប កោះពស់ កោះថាស កោះដែកគោល កោះត្រែះជាដើម ហើយប្រជុំកោះនិងកោះទាំងនេះជាគោលដៅទេសចរណ៍ដ៏សំខាន់សម្រាប់ក្រុងព្រះសីហនុនិងខេត្តព្រះសីហនុ ក៏ដូចជាប្រទេសកម្ពុជាផងដែរ។ រាល់ការអភិវឌ្ឍកោះត្រូវអនុវត្តតាមបទប្បញ្ញត្តិកំណត់ក្នុងផែនការរៀបចំដែនដីខេត្តព្រះសីហនុនិងសារាចរណែនាំលេខ០១សរណន ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ស្របតាមស្ថានភាពជាក់ស្តែង និងគោរពតាមគោលការណ៍ដូចខាងក្រោម៖

- ត្រូវរក្សានិងការពារធនធានធម្មជាតិនិងព្រៃឈើដែលមានស្រាប់ឱ្យបានយ៉ាងតិច៦០%
- ការអភិវឌ្ឍដីនៅលើកោះត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើ១,៥ ដងធៀបផ្ទៃក្រឡាកម្រាលសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៣៥% ហើយផ្ទៃដីដែលនៅសល់ត្រូវរៀបចំដាំដើមឈើនិងធ្វើជាសួនបៃតងយ៉ាងតិច៥០% និងកម្ពស់អគារអតិបរមា៣ជាន់ឬកម្ពស់ពិតជាក់ស្តែងអតិបរមា១២ម៉ែត្រ
- ត្រូវសាងសង់សំណង់ដែលមានលក្ខណៈជាខ្មែរ

- ត្រូវរៀបចំឱ្យមានលម្ហសាធារណៈនិងតំបន់កម្សាន្តនានាឱ្យបានច្រើនជាអតិបរមាដើម្បីជំរុញការមកលេងកម្សាន្តរបស់សាធារណជននិងទេសចរ
- ត្រូវរៀបចំឱ្យមានកំពង់ផែនាវាចម្លងខ្នាតតូចឬកំពង់ផែទេសចរណ៍ដែលអាចអនុញ្ញាតឱ្យសាធារណជនឬទេសចរចេញចូលបានដោយសេរី
- ត្រូវរៀបចំឱ្យមានតំបន់កម្សាន្តនានាក្នុងករណីមានឆ្នេរខ្សាច់និងរៀបចំកសាងផ្លូវសាធារណៈនៅក្បែរឆ្នេរសមុទ្រស្របតាមស្ថានភាពនៃទីតាំងរបស់កោះ។ ក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធត្រូវផ្តួចផ្តើមរៀបចំគម្រោងកសាងផ្លូវនេះ និងដាក់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដើម្បីពិនិត្យភាពសមស្របតាមគោលនយោបាយនិងបទដ្ឋានបច្ចេកទេសរៀបចំដែនដីនិងនគរូបនីយកម្ម។ ផ្លូវសាធារណៈត្រូវមានទំហំសមស្របតាមបទដ្ឋានបច្ចេកទេសនិងតម្រូវការនៃការប្រើប្រាស់យូរអង្វែង
- ត្រូវរៀបចំឱ្យមានការគ្រប់គ្រងសំណល់រឹងនិងរាវតាមបទដ្ឋានបច្ចេកទេសដើម្បីចៀសវាងការប៉ះពាល់ដល់បរិស្ថាន
- ត្រូវថែរក្សា ការពារ កែច្នៃ និងប្រើប្រាស់ធនធានសមុទ្រ ប្រព័ន្ធអេកូឡូស៊ី និងជីវចម្រុះគ្រប់ប្រភេទដូចជាផ្កាថ្ម ត្រី និងរុក្ខជាតិសមុទ្រជាដើមដែលមាននៅជុំវិញកោះសម្រាប់គោលដៅទេសចរណ៍
- បទប្បញ្ញត្តិនគរូបនីយកម្មសម្រាប់ការអភិរក្សនិងការអភិវឌ្ឍកោះនឹងត្រូវកំណត់ដោយគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ដើម្បីធានាការអភិវឌ្ឍប្រកបដោយចីរភាព។

### ៤.១.៤- យុទ្ធសាស្ត្រអភិវឌ្ឍក្រុងព្រះសីហនុជាទីក្រុងឆ្លាត មានចីរភាព និងប្រកបដោយបរិយាបន្ន

#### ក- ទីក្រុងឆ្លាត

ទីក្រុងឆ្លាតត្រូវបានឱ្យអត្ថន័យផ្សេងៗគ្នាទៅតាមស្ថានភាព តម្រូវការ និងលក្ខខណ្ឌនៃប្រទេសឬស្ថាប័នដែលកំពុងអនុវត្តទីក្រុងឆ្លាត។ ការឱ្យអត្ថន័យនេះគឺមានលក្ខណៈប្រហាក់ប្រហែលគ្នាទោះបីជាមានការប្រើប្រាស់ពាក្យពេជន៍ផ្សេងៗគ្នាយ៉ាងណាក្តីមានដូចជា៖

- ធនាគារពិភពលោកឆ្នាំ២០១៦ បានឱ្យអត្ថន័យទីក្រុងឆ្លាតជាទីក្រុងដែលប្រើប្រាស់ទំនាក់ទំនង និងបច្ចេកវិទ្យាចុងក្រោយបំផុតក្នុងការធ្វើសេចក្តីសម្រេចចិត្តឱ្យបានល្អប្រសើរ ដើម្បីសម្រេចបាននូវសេចក្តីប្រាថ្នារបស់ប្រជាជនដែលរស់នៅក្នុងទីក្រុង
- ចក្រភពអង់គ្លេស បានឱ្យអត្ថន័យទីក្រុងឆ្លាតជាទីក្រុងដែលមានសមាហរណកម្មនៃប្រព័ន្ធរូបវន្ត ឌីជីថល និងមនុស្សប្រកបដោយប្រសិទ្ធភាពក្នុងការកសាងនិងការរៀបចំទីក្រុងប្រកបដោយបរិយាបន្នភាពរុងរឿង និងនិរន្តរភាពនាពេលអនាគតសម្រាប់ប្រជាជនដែលរស់នៅក្នុងទីក្រុង
- ប្រទេសកូរ៉េខាងត្បូងតាមរយៈច្បាប់ស្តីពីទីក្រុងឆ្លាតបានឱ្យអត្ថន័យទីក្រុងឆ្លាតជាទីក្រុង ដែលប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន សារគមនាគមន៍ និងបច្ចេកវិទ្យាបៃតងដើម្បីផ្តល់សេវាទីក្រុងផ្សេងៗ ដូចជារដ្ឋបាល ការដឹកជញ្ជូន ភស្តុភារកម្ម ការការពារគ្រោះមហន្តរាយនិងឧក្រិដ្ឋកម្ម ថាមពល បរិស្ថាន ការគ្រប់គ្រងទឹក លំនៅឋាន និងសុខុមាលភាពដើម្បីលើកស្ទួយគុណភាពជីវិតរស់នៅរបស់ប្រជាជន

- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នៃប្រទេសកម្ពុជាបានឱ្យអត្ថន័យទីក្រុងឆ្លាតជា **ទីក្រុងដែលត្រូវបានគ្រប់គ្រង ដឹកនាំ និងអភិវឌ្ឍឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃដំណើរការប្រតិបត្តិ ការផ្តល់សេវាកម្ម និងការអភិវឌ្ឍទីក្រុង សម្រាប់លើកកម្ពស់គុណភាពនៃជីវិត បង្កើតមុខរបរ និងបង្កើនប្រាក់ចំណូល តាមរយៈការប្រើប្រាស់ឬបំពាក់នូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ទូរគមនាគមន៍ និងបច្ចេកវិទ្យាទំនើបដទៃទៀត ដែលអាចឆ្លើយតបទៅនឹងតម្រូវការនាពេលបច្ចុប្បន្ននិងអនាគត ប្រកបដោយចីរភាពនិងបរិយាបន្នដែលមានជាអាទិ៍សន្តិសុខ សុវត្ថិភាព នគរូបនីយកម្ម សំណង់ ស៊ីវិលយោធី ហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធចរាចរណ៍ ដឹកជញ្ជូន ទូរគមនាគមន៍ សេដ្ឋកិច្ច ធុរកិច្ច ពាណិជ្ជកម្ម ទេសចរណ៍ ឧស្សាហកម្ម នវានុវត្តន៍ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល សេវាសាធារណៈ ពន្ធដារ សេវាសង្គម ប្រជាជន លំនៅឋាន សុខុមាលភាព អប់រំ ថាមពល ធនធានទឹក ការគ្រប់គ្រងបរិស្ថាន សំណល់រឹង សំណល់រាវ ការការពារគ្រោះមហន្តរាយ ឧក្រិដ្ឋកម្ម និងវិស័យអាទិភាពផ្សេងៗទៀតរបស់ទីក្រុង។**

ទីក្រុងព្រះសីហនុកំពុងមានការអភិវឌ្ឍលើគ្រប់វិស័យ។ ដើម្បីជំរុញការអភិវឌ្ឍទីក្រុងប្រកបដោយភាពឆ្លាត ចីរភាព និងបរិយាបន្ន គោលការណ៍និងទស្សនទាននៃទីក្រុងឆ្លាតខាងលើនេះនឹងត្រូវបានអនុវត្តសម្រាប់ការអភិវឌ្ឍទីក្រុងឆ្លាតនៅក្រុងព្រះសីហនុ។

**ខ-បណ្តាញទីក្រុងឆ្លាតអាស៊ាន**

នៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៣២ នាថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៨ ថ្នាក់ដឹកនាំបណ្តាប្រទេសអាស៊ានបានបង្កើតបណ្តាញទីក្រុងឆ្លាតអាស៊ានសំដៅឆ្ពោះទៅរកគោលដៅរួមមួយនៃការអភិវឌ្ឍទីក្រុងប្រកបដោយនិរន្តរភាពនិងឆ្លាត។ គម្រោងសាកល្បងនៃការអនុវត្តទីក្រុងឆ្លាតនៃប្រទេសអាស៊ានមានចំនួន២៦ទីក្រុងក្នុងនោះប្រទេសកម្ពុជាក៏ជាសមាជិកនៃបណ្តាញទីក្រុងឆ្លាតអាស៊ានដែលមានក្រុងចំនួន៣ ត្រូវបានដាក់បញ្ចូលនៅក្នុងគម្រោងសាកល្បងនេះមាន **រាជធានីភ្នំពេញ ក្រុងសៀមរាប និងក្រុងបាត់ដំបង។**

បណ្តាញទីក្រុងឆ្លាតអាស៊ានត្រូវបានបង្កើតឡើងក្នុងគោលបំណងសំខាន់ៗចំនួន៣ រួមមាន៖

- ធ្វើការសម្របសម្រួលអំពីការអភិវឌ្ឍទីក្រុងឆ្លាត៖ សមាជិកនៃបណ្តាញទីក្រុងឆ្លាតទាំងអស់នឹងសហការធ្វើការជាមួយគ្នាដើម្បីរកនូវសក្តានុពលសំខាន់ៗសម្រាប់ទីក្រុងឆ្លាត ចែករំលែកនូវបទពិសោធន៍ និងអនុវត្តផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍទីក្រុងឆ្លាតរបស់ខ្លួនសម្រាប់ឆ្នាំ២០១៨ ដល់ឆ្នាំ២០២៥ និងធ្វើសេចក្តីព្រាងក្របខណ្ឌសម្រាប់អភិវឌ្ឍទីក្រុងឆ្លាតដែលមានលក្ខណៈពិសេសចំពោះអាស៊ាន
- ជំរុញការអនុវត្តគម្រោងជាមួយវិស័យឯកជនដែលអាចទាញយកប្រាក់ចំណេញបានច្រើន៖ សមាជិកទាំងអស់ភ្ជាប់ទំនាក់ទំនងជាមួយនឹងអ្នកផ្តល់ប្រឹក្សាឯកជនលើដំណោះស្រាយទីក្រុងដើម្បីចាប់ផ្តើមគម្រោងដែលអាចអនុវត្តបាននិងចំណេញផ្នែកសេដ្ឋកិច្ចពីការអភិវឌ្ឍទីក្រុងឆ្លាត
- ថែរក្សាសុវត្ថិភាពនៃការផ្តល់មូលនិធិនិងការគាំទ្រដៃគូពីខាងក្រៅក្នុងការអភិវឌ្ឍទីក្រុងឆ្លាត៖ សមាជិកទីក្រុងឆ្លាតនឹងចាប់ដៃគូពីខាងក្រៅដោយឈរលើមូលដ្ឋានស្ម័គ្រចិត្តនិង[illegible]ភាពជាដៃគូដោយផ្តល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមកដើម្បីអភិវឌ្ឍទីក្រុងឆ្លាត។

ជាទស្សនទាន ការអនុវត្តគម្រោងទីក្រុងឆ្លាតនៅក្នុងបណ្តាប្រទេសអាស៊ាន[illegible]សំខាន់មួយឬច្រើនដែលឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជននិងទីក្រុង។ ប្រធានបទដែលជាគោលដៅសម្រាប់ការអភិវឌ្ឍទីក្រុងឆ្លាតនៃបណ្តាប្រទេសអាស៊ានរួមមាន៖

- ប្រជាជននិងសង្គម
- សុខភាពនិងសុខុមាលភាព
- សុវត្ថិភាពនិងសន្តិសុខ
- គុណភាពបរិស្ថាន
- ហេដ្ឋារចនាសម្ព័ន្ធ
- នវានុវត្តន៍និងសហគ្រិនភាព ឧស្សាហកម្មនិងនវានុវត្តន៍។

ដូច្នេះយោងតាមលក្ខណៈសម្បត្តិ សក្តានុពល និងការអភិវឌ្ឍក្រុងព្រះសីហនុមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ក្រុងព្រះសីហនុគួរស្នើដាក់បញ្ចូលក្នុងបណ្តាញទីក្រុងឆ្លាតអាស៊ាន។

**គ-ការអភិវឌ្ឍក្រុងព្រះសីហនុជាទីក្រុងឆ្លាត**

ផ្អែកតាមចក្ខុវិស័យផែនការរៀបចំដែនដីខេត្តព្រះសីហនុ ដែលត្រូវបានរាជរដ្ឋាភិបាលសម្រេចដាក់ឱ្យអនុវត្តតាមរយៈអនុក្រឹត្យលេខ៨១អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ និងគម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវក្រុងក្នុងខេត្តព្រះសីហនុ ដែលត្រូវបានសម្ពោធបើកការដ្ឋាន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៩ និងបានបំពេញការសាងសង់ចប់ជាស្ថាពរក្នុងឆ្នាំ២០២១ ក្រុងព្រះសីហនុតាមរយៈប្លង់គោលប្រើប្រាស់ដីចក្ខុវិស័យឆ្នាំ២០៣៨ បានដាក់ចេញនូវយុទ្ធសាស្ត្រអភិវឌ្ឍទីក្រុងឆ្លាត ដើម្បីលើកកម្ពស់ដល់គុណភាពនៃការដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍឱ្យប្រសើរឡើងនូវគុណភាពនៃជីវិត ប្រសិទ្ធភាព និងការប្រកួតប្រជែងនៃដំណើរការប្រតិបត្តិការ ការផ្តល់សេវាកម្ម និងការអភិវឌ្ឍទីក្រុង ឆ្លើយតបទៅនឹងតម្រូវការនាពេលបច្ចុប្បន្ននិងអនាគតប្រកបដោយចីរភាពនិងបរិយាបន្នតាមរយៈការតភ្ជាប់និងបំពាក់នូវហេដ្ឋារចនាសម្ព័ន្ធ បរិក្ខារ និងសេវាកម្មសម្រាប់ទីក្រុងឆ្លាត ដូចខាងក្រោម៖

**គ.១-ការអភិវឌ្ឍទីក្រុងប្រកបដោយភាពឆ្លាត**

**គ.១.១-វិស័យទូរគមនាគមន៍**

ទី១-សេវាអ៊ីនធឺណិតសាធារណៈ៖
- ផ្តល់ការប្រើប្រាស់សេវាអ៊ីនធឺណិតសាធារណៈដល់សាធារណជនទូទៅក្នុងកន្លែងសាធារណៈ ដូចជា ស្ថានីយរថភ្លើង សួនកម្សាន្ត តំបន់ទេសចរណ៍ តំបន់វប្បធម៌ និងមហាវិថីធំៗដែលផ្តល់ដោយស្ថាប័នផ្គត់ផ្គង់សេវាទូរគមនាគមន៍ដោយមានការគាំទ្រពីរាជរដ្ឋាភិបាល
- អនុញ្ញាតឱ្យភ្ជាប់ជាមួយនឹងឧបករណ៍ផ្សេងៗរួមទាំងទូរស័ព្ទដៃទំនើប
- ផ្តល់ផែនទីបង្ហាញសេវាអ៊ីនធឺណិតសាធារណៈដើម្បីផ្សព្វផ្សាយដល់អ្នកប្រើប្រាស់។

ទី២-មជ្ឈមណ្ឌលទិន្នន័យសាធារណៈ៖
- សិក្សានិងកសាងមជ្ឈមណ្ឌលទិន្នន័យសម្រាប់គម្រោងទីក្រុងឆ្លាត ដែលអាចគ្រប់គ្រងនិងប្រមូលទិន្នន័យបច្ចុប្បន្នភាពក្នុងទីក្រុង
- ដំណើរការប្រព័ន្ធទិន្នន័យរបស់រាជរដ្ឋាភិបាលនៅក្នុងតំបន់ ដែលអាចជួយសម្រួលនិងដំណើរការនូវគេហទំព័រសេវាកម្មដល់ប្រជាពលរដ្ឋ ការងាររដ្ឋបាល និងជាប្រភពទិន្នន័យសម្រាប់ប្រព័ន្ធការងាររដ្ឋបាលអន្តរជាតិ
- វិភាគនិងដោះស្រាយបញ្ហារបស់ទីក្រុងបានទាន់ហេតុការណ៍សម្រាប់ក្រុងព្រះសីហនុ។

ទី៣- ប្រព័ន្ធសេវាផ្តល់សេចក្តីជូនដំណឹងពីព័ត៌មានស្តីពីសេវាសាធារណៈក្នុងទីក្រុងដល់ប្រជាពលរដ្ឋ៖

- រៀបចំប្រព័ន្ធសេវាផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋឱ្យបានទៀងទាត់និងទាន់ហេតុការណ៍ដូចជាសន្តិសុខចរាចរណ៍ សុខាភិបាល រដ្ឋបាល បរិស្ថាន សេដ្ឋកិច្ច និងវប្បធម៌ជាដើម។

### គ.១.២-វិស័យហេដ្ឋារចនាសម្ព័ន្ធនិងដឹកជញ្ជូន

ទី១- កសាងប្រព័ន្ធដឹកជញ្ជូនឆ្លាតសាធារណៈតាមរយៈ៖

- ការបង្កើតប្រព័ន្ធគ្រប់គ្រងចរាចរណ៍តាមបែបសមាហរណកម្ម
- ការប្រើប្រាស់ប្រព័ន្ធដឹកជញ្ជូនឆ្លាត សន្សំសំចៃ និងមិនប៉ះពាល់ដល់បរិស្ថាន
- ការបង្កើតប្រព័ន្ធទំនាក់ទំនងសម្រាប់មធ្យោបាយដឹកជញ្ជូនសាធារណៈ
- ការប្រើប្រាស់គំនូសផ្លូវឆ្លាតដោយប្រើប្រាស់ទឹកថ្នាំគំនូសផ្លូវដែលមានចំណាំងផ្លាតនិងភ្លឺនៅក្នុងពេលធ្វើចរាចរណ៍នៅពេលយប់
- ការបំពាក់អំពូលឆ្លាតនៅតាមដងផ្លូវដែលជាប្រភេទអំពូលដែលមានការសន្សំសំចៃខ្ពស់និងគ្រប់គ្រងថាមពលដោយស្វ័យប្រវត្តិ
- ការបំពាក់ប្រព័ន្ធឆ្លាតនិងកាមេរ៉ាសុវត្ថិភាពលើដងផ្លូវនិងទីប្រជុំជនសំខាន់ៗនៅក្នុងក្រុងព្រះសីហនុដើម្បីត្រួតពិនិត្យចរាចរណ៍ជាទូទៅនៅតាមដងផ្លូវ ក៏ដូចជាទីសាធារណៈនានាដើម្បីធានាសុវត្ថិភាពជូនប្រជាជននិងបង្ក្រាបនូវរាល់សកម្មភាពអវិជ្ជមានដែលកើតមានឱ្យបានទាន់ពេលវេលានិងមានប្រសិទ្ធភាពនិងពន្លឿនការស្រាវជ្រាវរកមុខសញ្ញាចំពោះករណីណាដែលកើតមានឡើងតាមដងផ្លូវនិងទីសាធារណៈ
- ការបង្កើតប្រព័ន្ធគ្រប់គ្រងល្បឿន។

ទី២- កសាងផ្លូវដឹកជញ្ជូនសាធារណៈនិងការផ្តល់ព័ត៌មាននៃពេលវេលាមកដល់៖

- បង្កើតប្រព័ន្ធព័ត៌មាននៃការដឹកជញ្ជូនសាធារណៈដល់អ្នកដំណើរ
- ផ្តល់ការពិនិត្យព័ត៌មានអំពីពេលវេលានៃការធ្វើដំណើរនិងចរាចរណ៍ដល់សាធារណជន ដូចជាតាមរយៈទូរស័ព្ទដៃទំនើប។

ទី៣- កសាងប្រព័ន្ធចតយានយន្តឆ្លាត៖

- កសាងសុវត្ថិភាពនិងបែងចែកចំណតសម្រាប់ចតយានយន្ត
- ផ្តល់ព័ត៌មានជាក់លាក់និងទាន់ពេលវេលាអំពីកន្លែងចតយានយន្ត។

### គ.១.៣-ការប្រើប្រាស់ថាមពល

- រៀបចំការសន្សំសំចៃថាមពលដោយផ្តួចផ្តើមការប្រើប្រាស់ថាមពលកកើតឡើងវិញនៅតាមការិយាល័យនិងស្ថាប័នរដ្ឋ
- តាមស្ថានភាពនៅក្រុងព្រះសីហនុអាចធ្វើការផ្គត់ផ្គង់ថាមពលកកើតឡើងវិញ ដោយប្រើប្រាស់ធនធានសមុទ្រនិងព្រះអាទិត្យ
- លើកទឹកចិត្តនិងជំរុញការប្រើប្រាស់ប្រព័ន្ធថាមពលព្រះអាទិត្យ តាមរយៈការបំពាក់ឧបករណ៍បង្កើតថាមពលពន្លឺព្រះអាទិត្យនៅលើដំបូលអគារស្នាក់នៅ អគាររដ្ឋបាល និងកន្លែងចតយានយន្តជាដើម។

### គ.១.៤-ការគ្រប់គ្រងធនធានទឹក

- អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងនិងប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាពនិងសន្សំសំចៃ
- រៀបចំផែនការគ្រប់គ្រងនិងប្រើប្រាស់ទឹកដែលមានប្រភពមកពីទឹកភ្លៀងតាមរយៈការបង្កើនប្រសិទ្ធភាពអាងស្តុកទឹកភ្លៀងនិងការគ្រប់គ្រងទឹកជម្រាល។

### គ.១.៥-ការបង្ការគ្រោះមហន្តរាយ

- រៀបចំប្រព័ន្ធឆ្លាតនិងផ្លូវសុវត្ថិភាពក្នុងការជម្លៀសចេញពីគ្រោះមហន្តរាយ
- រៀបចំប្រព័ន្ធតាមដាននិងផ្តល់ព័ត៌មានអំពីគ្រោះមហន្តរាយឱ្យទាន់ពេលវេលាដើម្បីជូនដំណឹងដល់សាធារណជននៅពេលដែលមានគ្រោះអាសន្ននានាកើតឡើងតាមរយៈទូរស័ព្ទឬតាមបណ្តាញសង្គមនានាឱ្យបានឆាប់រហ័សដែលអាចធានាសុវត្ថិភាពប្រជាជននិងទ្រព្យសម្បត្តិ
- រៀបចំជម្រកបណ្តោះអាសន្ននិងនីតិវិធីជម្លៀសជនរងគ្រោះក្នុងពេលដែលមានអាសន្ននិងត្រូវរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការជម្លៀសខ្លួនដល់សាធារណជន សាលារៀន និងស្ថាប័ននានា។

### គ.១.៦-ការគ្រប់គ្រងបរិស្ថាន

- អភិវឌ្ឍប្រព័ន្ធឆ្លាតសម្រាប់ការគ្រប់គ្រងសំណល់រាវ ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ និងបណ្តាញលូ
- អភិវឌ្ឍប្រព័ន្ធឆ្លាតសម្រាប់ការគ្រប់គ្រងសំណល់រឹង
- រៀបចំដំណើរការមជ្ឈមណ្ឌលគ្រប់គ្រងបរិស្ថានទីក្រុងតាមបែបសមាហរណកម្ម។

### គ.១.៧-នគរូបនីយកម្ម

- ប្រើប្រាស់បច្ចេកវិទ្យាឆ្លាតក្នុងការគ្រប់គ្រងទីក្រុង ការអភិវឌ្ឍទីក្រុង ការគ្រប់គ្រងដី ការប្រើប្រាស់ដី ការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ តាមរយៈការគ្រប់គ្រងនិងលើកទឹកចិត្តដល់ការអភិវឌ្ឍសំណង់បៃតង ហេដ្ឋារចនាសម្ព័ន្ធបៃតង និងសេវាដឹកជញ្ជូនឆ្លាតដែលដំណើរការដោយបច្ចេកវិទ្យាទូរគមនាគមន៍ទំនើប
- ប្រព័ន្ធការពារធនធានធម្មជាតិនិងបរិស្ថាន សមាហរណកម្ម និងលម្អនគរូបនីយកម្ម ប្រកបដោយភាពសុខដុមរមនាជាមួយផ្ទៃទឹកនិងផ្ទៃបៃតង
- ប្រើប្រាស់បច្ចេកវិទ្យាឆ្លាតក្នុងដំណើរការផលិត កែច្នៃ និងដឹកជញ្ជូនផលិតផលកសិកម្ម ឧស្សាហកម្មកែច្នៃ ពាណិជ្ជកម្ម និងទេសចរណ៍ដើម្បីបង្កើនគុណភាពនិងបរិមាណសម្រាប់ការផ្គត់ផ្គង់តម្រូវការដល់ប្រជាជនក្នុងនិងក្រៅក្រុងឱ្យបានសមស្របនិងមានចីរភាព
- ជំរុញលើកស្ទួយដល់ការប្រកួតប្រជែងរបស់ទីក្រុងតាមរយៈការជំរុញលើកទឹកចិត្តដល់វិស័យឧស្សាហកម្មកែច្នៃនិងទេសចរណ៍ឱ្យប្រើប្រាស់បច្ចេកវិទ្យាឆ្លាត
- ជំរុញការប្រើប្រាស់បច្ចេកវិទ្យាឆ្លាតក្នុងការរចនា ការរៀបចំ ការអភិវឌ្ឍដែនដី និងការការពារបរិស្ថាននិងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព ចីរភាព និងការប្រកួតប្រជែង
- ជំរុញនិងលើកទឹកចិត្តដល់ការប្រើប្រាស់បច្ចេកវិទ្យាឆ្លាតនៅក្នុងវិស័យអប់រំ សុខាភិបាល សន្តិសុខ និងសណ្តាប់ធ្នាប់ជាដើម ជាពិសេសការគ្រប់គ្រងនិងផ្តល់សេវាកម្មផ្សេងៗដល់ពលរដ្ឋនិងធុរជន។

### គ.២- ការអភិវឌ្ឍទីក្រុងប្រកបដោយចីរភាព

- ត្រូវធានានូវរាល់ការអភិវឌ្ឍនិងអភិរក្សទីក្រុងឱ្យទទួលបានចីរភាពខាងសេដ្ឋកិច្ច សង្គម បរិស្ថាន វប្បធម៌ សន្តិសុខស្បៀង និងការពារសន្តិភាព
- ជំរុញនិងលើកទឹកចិត្តចំពោះការប្រើប្រាស់ប្រព័ន្ធដំណើរការថាមពលឆ្លាតដោយប្រើប្រាស់ថាមពលកកើតឡើងវិញដូចជាថាមពលពន្លឺព្រះអាទិត្យនិងថាមពលបានពីការកែច្នៃសំណល់រឹងរាវ ក្នុងគោលបំណងកាត់បន្ថយជាអតិបរមាដល់ការប្រើប្រាស់ថាមពលដែលបានមកពីការប្រើប្រាស់ធនធានធម្មជាតិ
- ជំរុញនិងលើកទឹកចិត្តដល់ការរចនា រៀបចំ និងអនុវត្តគម្រោងសាងសង់និងគម្រោងអភិវឌ្ឍនិងអភិរក្សទីក្រុងតាមគោលការណ៍អភិវឌ្ឍប្រកបដោយចីរភាព
- ជំរុញការគ្រប់គ្រង ការផ្គត់ផ្គង់ទឹកស្អាត និងការកសាងប្រព័ន្ធកែច្នៃការប្រើប្រាស់ទឹកឡើងវិញ។

### គ.៣- ការអភិវឌ្ឍទីក្រុងប្រកបដោយបរិយាបន្ន

- ត្រូវធានារាល់ការអភិវឌ្ឍនិងការអភិរក្សទីក្រុងសម្រាប់មនុស្សទាំងអស់គ្នាអាចទទួលបាននូវផលប្រយោជន៍ប្រកបដោយសមធម៌រួមទាំងជនមានពិការភាពនិងជនងាយរងគ្រោះ
- កែលម្អបរិស្ថានទីក្រុងសម្រាប់ការរស់នៅប្រកបដោយសុវត្ថិភាពពីគ្រោះមហន្តរាយផ្សេងៗ តាមរយៈការប្រើប្រាស់ប្រព័ន្ធបង្ការគ្រោះមហន្តរាយឆ្លាតនិងការកសាងផ្លូវនិងលម្ហសម្រាប់ការជម្លៀសចេញពីគ្រោះមហន្តរាយ
- ជំរុញការគ្រប់គ្រងទីក្រុងប្រកបដោយប្រសិទ្ធភាពនិងមានការចូលរួមតាមរយៈការកសាងមជ្ឈមណ្ឌលប្រតិបត្តិដំណើរការសមាហរណកម្មមុខងាររបស់ទីក្រុង។

## ៤.២- យុទ្ធសាស្ត្រគ្រប់គ្រងនិងប្រើប្រាស់ដីប្រកបដោយចីរភាព

វិសាលភាពសិក្សាប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុ ចក្ខុវិស័យឆ្នាំ២០៣៨ គ្របដណ្តប់លើផ្ទៃដីប្រមាណ២៧ ៩៣៤,៣៥ហិកតាដោយគ្របដណ្តប់លើក្រុងព្រះសីហនុ ផ្នែកខ្លះនៃឃុំបិតត្រាំងនិងឃុំរាម ស្រុកព្រៃនប់ និងផ្នែកខ្លះនៃឃុំកំពេញ ឃុំទំនប់រលក និងឃុំអូរត្រេះ ស្រុកស្ទឹងហាវ និងត្រូវបានកំណត់ការប្រើប្រាស់ដីជា២ប្រភេទគឺប្រភេទដីអាចសាងសង់បាននិងប្រភេទដីកម្រិតការសាងសង់។ ប្រភេទដីអាចសាងសង់បានមានផ្ទៃដីប្រមាណ១៥ ៧០១,៩៧ហិកតាស្មើនឹង៥៦,២១%និងប្រភេទដីកម្រិតការសាងសង់មានផ្ទៃដីប្រមាណ១២ ២៣២,៣៨ហិកតាស្មើនឹង៤៣,៧៩% នៅឆ្នាំ២០៣៨ ធៀបនឹងតំបន់សិក្សាទាំងមូល។

រាល់ការអភិវឌ្ឍនិងការសាងសង់ត្រូវគោរពតាមខ្សែរយៈកម្ពស់ដី ដែលត្រូវអភិវឌ្ឍនិងសាងសង់តាមតំបន់នៃទីតាំងភូមិសាស្ត្រនីមួយៗ ដែលបានកំណត់ដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ខេត្ត។ ការកំណត់ខ្សែរយៈកម្ពស់ដីដែលត្រូវអភិវឌ្ឍនិងសាងសង់ត្រូវផ្អែកទៅលើហេដ្ឋារចនាសម្ព័ន្ធផ្លូវនិងប្រព័ន្ធលូបង្ហូរស្របតាមទីតាំងភូមិសាស្ត្រនៃតំបន់នីមួយៗ។

### ៤.២.១- ប្រភេទដីអាចសាងសង់បាន

ប្រភេទដីអាចសាងសង់បានត្រូវបានកំណត់ជា១១តំបន់ ដូចមាននិយាមក័ណ៌ក្នុងផែនទីប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុ ចក្ខុវិស័យឆ្នាំ២០៣៨ ជាឧបសម្ព័ន្ធភ្ជាប់មកជាមួយ។ មាតិកាញត្តិនៃការប្រើប្រាស់ដីមានជាអាទិ៍ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ ក្លាតម្លាតអគារ សន្ទស្សន៍ប្រើប្រាស់ដី កម្ពស់អគារ

ចំណតរថយន្ត ជួរតម្រង់អគារ ផ្ទៃដីសួនច្បារជ្រាបទឹក ការដាំដើមឈើ អាងបង្អន់អនាម័យ អាងប្រព្រឹត្តកម្មទឹកកខ្វក់ ពណ៌អគារ សោភណភាពអគារ និងរចនាបទស្ថាបត្យកម្មត្រឹមត្រូវស្របតាមបទប្បញ្ញត្តិជាធរមាន។

ការកំណត់តំបន់និងបទប្បញ្ញត្តិនគរូបនីយកម្មនៃតំបន់នីមួយៗត្រូវកំណត់ដូចខាងក្រោម៖

**ក- តំបន់លំនៅឋាន**

តំបន់លំនៅឋានមានផ្ទៃដីប្រមាណ៥ ៩០៤,៧៦ហិកតាស្មើនឹង៤០,២៤% នៃប្រភេទដីអាចសាងសង់បាន និងត្រូវបានកំណត់បែងចែកជា៣ប្រភេទ៖

**ក.១- តំបន់លំនៅឋានកម្ពស់ទាប**មានផ្ទៃដីប្រមាណ៤ ៦០៤,៦៣ហិកតាស្មើនឹង៣១,៩៦% នៃប្រភេទដីអាចសាងសង់បាន។ តំបន់នេះមានមុខងារសម្រាប់សាងសង់អគារលំនៅឋានដាច់ពីគ្នាឬជាប់គ្នាមួយចំហៀងដែលមានកម្ពស់ទាបដូចជាភូមិគ្រឹះទោល ភូមិគ្រឹះភ្លោះ ផ្ទះក្នុងដីឡូត៍ដែលមានធ្លាគម្លាតជុំវិញ អគារស្នាក់នៅនិងអគារលំនៅឋានសហកម្មសិទ្ធិ និងត្រូវបានកំណត់៖

- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៤០%
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា០,៨ និងសន្ទស្សន៍ប្រើប្រាស់ដីបន្ថែមអតិបរមាសម្រាប់ការលើកទឹកចិត្ត០,៧
- កម្ពស់អគារអតិបរមាស្របតាមសន្ទស្សន៍ប្រើប្រាស់ដី
- ធ្លាគម្លាតអគារខាងមុខយ៉ាងតិច៤ម៉ែត្រនិងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច២ម៉ែត្រ
- សោភណភាពនិងពណ៌សមស្រប
- ស្ថាបត្យកម្មត្រូវមានរចនាបទខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន
- អាងបង្អន់អនាម័យស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០%
- ផ្ទៃដីឡូត៍១០០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិផ្សេងពីនេះ
- ផ្ទៃក្រឡាកម្រាលសំណង់៥០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តចំនួន១។

**ក.២-តំបន់លំនៅឋានកម្ពស់មធ្យម**មានផ្ទៃដីប្រមាណ១ ១៨៤,៣៦ហិកតាស្មើនឹង៧,៦៣% នៃប្រភេទដីអាចសាងសង់បាន។ តំបន់នេះមានមុខងារសម្រាប់សាងសង់អគារលំនៅឋានដែលមានកម្ពស់មធ្យមដូចជាភូមិគ្រឹះទោល ភូមិគ្រឹះភ្លោះ អគារស្នាក់នៅ និងអគារលំនៅឋានសហកម្មសិទ្ធិ និងត្រូវបានកំណត់៖

- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៥០%
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា១,៥ និងសន្ទស្សន៍ប្រើប្រាស់ដីបន្ថែមអតិបរមាសម្រាប់ការលើកទឹកចិត្ត១,០
- កម្ពស់អគារអតិបរមាស្របតាមសន្ទស្សន៍ប្រើប្រាស់ដី
- ធ្លាគម្លាតអគារ៖

▪ អគារកម្ពស់ពី៤ដល់៨ជាន់ត្រូវកំណត់ថ្នាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច៥ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច២,៥ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់

▪ អគារកម្ពស់ពី៩ដល់១១ជាន់ត្រូវកំណត់ថ្នាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច៦ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច៣ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់។

– សោភណភាពនិងពណ៌សមស្រប

– ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន

– អាងបង្គន់អនាម័យស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន

– ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០%

– ផ្ទៃដីឡូត៍១០០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិផ្សេងពីនេះ

– ផ្ទៃក្រឡាកម្រាលសំណង់១០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១។

**ក.៣- តំបន់លំនៅឋានកម្ពស់ខ្ពស់**មានផ្ទៃដីប្រមាណ១០១,៧៧ហិកតាស្មើនឹង២០,៦៥% នៃប្រភេទដីអាចសាងសង់បាន។ តំបន់នេះមានមុខងារសម្រាប់សាងសង់អគារលំនៅឋានដែលមានកម្ពស់ខ្ពស់ដូចជាអគារស្នាក់នៅនិងអគារលំនៅឋានសហកម្មសិទ្ធិ និងត្រូវបានកំណត់៖

– ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%

– សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា២,៥ និងសន្ទស្សន៍ប្រើប្រាស់ដីបន្ថែមអតិបរមាសម្រាប់ការលើកទឹកចិត្ត១,៥

– កម្ពស់អគារអតិបរមាស្របតាមសន្ទស្សន៍ប្រើប្រាស់ដី

– ថ្នាតម្លាតអគារ៖

▪ អគារកម្ពស់ពី១២ដល់២០ជាន់ ត្រូវកំណត់ថ្នាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច៦,៥ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច៣,២៥ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់

▪ អគារកម្ពស់ពី២១ដល់៣០ជាន់ត្រូវកំណត់ថ្នាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច៨ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច៤ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់

▪ អគារកម្ពស់ពី៣១ជាន់ឡើងទៅត្រូវកំណត់ថ្នាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច១០ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច៥ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់។

– សោភណភាពនិងពណ៌សមស្រប

– ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន

– អាងបង្គន់អនាម័យស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន

– ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០%

– ផ្ទៃដីឡូត៍១០០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិផ្សេងពីនេះ

– ផ្ទៃក្រឡាកម្រាលសំណង់១០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១។

**ខ-តំបន់ពាណិជ្ជកម្ម**

តំបន់ពាណិជ្ជកម្មមានផ្ទៃដីប្រមាណ៦០៥,០៩ហិកតាស្មើនឹង៣,៨៥% នៃប្រភេទដីអាចសាងសង់បាន។ តំបន់នេះមានមុខងារសម្រាប់សាងសង់អគារដែលបម្រើដល់វិស័យពាណិជ្ជកម្ម ធុរកិច្ច និងសេវាកម្មដូចជាអគារការិយាល័យ ធនាគារ ហាងកុន ហាងល្ខោន ភោជនីយដ្ឋាន ហាងលក់ដូរ ទីផ្សារ និងដេប៉ូចែកចាយទំនិញជាដើម និងត្រូវបានកំណត់បែងចែកជា២ប្រភេទ៖

**ខ.១-តំបន់ពាណិជ្ជកម្ម**មានផ្ទៃដីប្រមាណ៣០៤,៤៣ហិកតាស្មើនឹង១,៩៥% នៃប្រភេទដីអាចសាងសង់បាន និងត្រូវបានកំណត់៖

- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៨០%
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៥,៥ និងសន្ទស្សន៍ប្រើប្រាស់ដីបន្ថែមអតិបរមាសម្រាប់ការលើកទឹកចិត្ត៥,៥
- កម្ពស់អគារអតិបរមាស្របតាមសន្ទស្សន៍ប្រើប្រាស់ដី
- ថ្នាតម្លាតអគារ៖
  - អគារកម្ពស់ពី១ដល់៣ជាន់ត្រូវកំណត់ថ្នាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច៤ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច២ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
  - អគារកម្ពស់ពី៤ដល់៨ជាន់ត្រូវកំណត់ថ្នាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច៥ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច២,៥ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
  - អគារកម្ពស់ពី៩ដល់១១ជាន់ត្រូវកំណត់ថ្នាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច៦ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច៣ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
  - អគារកម្ពស់ពី១២ដល់២០ជាន់ ត្រូវកំណត់ថ្នាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច៦,៥ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច៣,២៥ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
  - អគារកម្ពស់ពី២១ដល់៣០ជាន់ត្រូវកំណត់ថ្នាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច៨ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច៤ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
  - អគារកម្ពស់ពី៣១ជាន់ឡើងទៅត្រូវកំណត់ថ្នាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច១០ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច៥ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់។
- ក្នុងករណីចាំបាច់នៃតំបន់ពាណិជ្ជកម្មនេះ និងក្នុងករណីសំណង់គ្មានជញ្ជាំងនិងមានតែសសរ ហើយជាន់ផ្ទាល់ដីត្រូវបានប្រើប្រាស់សម្រាប់ធ្វើរបៀងសាធារណៈ ថ្នាតម្លាតអគារអប្បបរមាផ្នែកខាងមុខត្រូវកំណត់យ៉ាងតិចស្មើនឹងពីរភាគបី នៃតម្លាតខាងមុខដែលបានកំណត់ខាងលើសម្រាប់អគារដែលមានកម្ពស់ខ្ពស់
- អាជ្ញាធរមានសមត្ថកិច្ចអាចតម្រូវឱ្យរៀបចំឱ្យមានច្រកផ្លូវដើរដែលមានដំបូលសមស្រប ឬក្នុងអគារសម្រាប់សាធារណជនដែលមានទំហំទទឹងយ៉ាងតិច២,៥ម៉ែត្រដើម្បីលើកទឹកចិត្តដល់ថ្មើរជើង
- សោភណភាពនិងពណ៌សមស្រប
- ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន

- អាងបង្គន់អនាម័យស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- អាងប្រព្រឹត្តកម្មទឹកកខ្វក់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០%
- ផ្ទៃដីឡូត៍១០០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
- ចំណតរថយន្តៈ
  - ភោជនីយដ្ឋាននិងភេសជ្ជដ្ឋាន ផ្ទៃក្រឡាកម្រាលសំណង់១៥ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១ និងក្លឹបកម្សាន្ត ផ្ទៃក្រឡាកម្រាលសំណង់កន្លែងភ្ញៀវ១ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១
  - ផ្សារទំនើប ផ្ទៃក្រឡាកម្រាលសំណង់២៥ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១
  - ផ្សារឬកន្លែងលក់ដូរ ផ្ទៃក្រឡាកម្រាលសំណង់៥០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១
  - អគារពាណិជ្ជកម្មផ្សេងៗ ផ្ទៃក្រឡាកម្រាលសំណង់៥០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១។

**១.២-តំបន់ពាណិជ្ជកម្មចម្រុះ**មានផ្ទៃដីប្រមាណ៣០០,៦៦ហិកតាស្មើនឹង១,៩១%នៃប្រភេទដីអាចសាងសង់បាន និងត្រូវបានកំណត់ៈ

- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៧០%
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៤,៥ និងសន្ទស្សន៍ប្រើប្រាស់ដីបន្ថែមអតិបរមាសម្រាប់ការលើកទឹកចិត្ត៤,៥
- កម្ពស់អគារអតិបរមាស្របតាមសន្ទស្សន៍ប្រើប្រាស់ដី
- ថ្លាតម្លាតអគារៈ
  - អគារកម្ពស់ពី១ដល់៣ជាន់ត្រូវកំណត់ថ្លាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច៤ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច២ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
  - អគារកម្ពស់ពី៤ដល់៨ជាន់ត្រូវកំណត់ថ្លាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច៥ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច២,៥ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
  - អគារកម្ពស់ពី៩ដល់១១ជាន់ត្រូវកំណត់ថ្លាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច៦ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច៣ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
  - អគារកម្ពស់ពី១២ដល់២០ជាន់ ត្រូវកំណត់ថ្លាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច៦,៥ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច៣,២៥ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
  - អគារកម្ពស់ពី២១ដល់៣០ជាន់ត្រូវកំណត់ថ្លាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច៨ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច៤ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
  - អគារកម្ពស់ពី៣១ជាន់ឡើងទៅត្រូវកំណត់ថ្លាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច១០ម៉ែត្រនិងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច៥ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់។

- ក្នុងករណីចាំបាច់នៃតំបន់ពាណិជ្ជកម្មចម្រុះនេះ និងក្នុងករណីសំណង់គ្មានជញ្ជាំងនិងមានតែសសរ ហើយជាន់ផ្ទាល់ដីត្រូវបានប្រើប្រាស់សម្រាប់ថ្មើរជើងសាធារណៈ ឆ្លាតម្លាតអគារអប្បបរមាផ្នែកខាងមុខត្រូវកំណត់យ៉ាងតិចស្មើនឹងពីរភាគបី នៃគម្លាតខាងមុខដែលបានកំណត់ខាងលើសម្រាប់អគារដែលមានកម្ពស់ខ្ពស់
- អាជ្ញាធរមានសមត្ថកិច្ចអាចតម្រូវឱ្យរៀបចំឱ្យមានច្រកផ្លូវដើរដែលមានដំបូលសមស្រប ឬក្នុងអគារសម្រាប់សាធារណជនដែលមានទំហំទទឹងយ៉ាងតិច២ម៉ែត្រដើម្បីលើកទឹកចិត្តដល់ថ្មើរជើង
- សោភណភាពនិងពណ៌សមស្រប
- ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន
- អាងបង្គន់អនាម័យស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- អាងប្រព្រឹត្តកម្មទឹកកខ្វក់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០%
- ផ្ទៃដីឡូត៍១០០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិថែងផ្សេងពីនេះ
- ចំណតរថយន្ត៖
  - ភោជនីយដ្ឋាននិងភេសជ្ជដ្ឋាន ផ្ទៃក្រឡាកម្រាលសំណង់១៥ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១ និងក្លិបកម្សាន្ត ផ្ទៃក្រឡាកម្រាលសំណង់កន្លែងរាំ១ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១
  - ផ្សារទំនើប ផ្ទៃក្រឡាកម្រាលសំណង់២៥ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១
  - ផ្សារឬកន្លែងលក់ដូរ ផ្ទៃក្រឡាកម្រាលសំណង់៥០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១
  - អគារពាណិជ្ជកម្មផ្សេងៗ ផ្ទៃក្រឡាកម្រាលសំណង់៥០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១។

**គ-តំបន់ឧស្សាហកម្ម**

តំបន់ឧស្សាហកម្មមានផ្ទៃដីប្រមាណ១ ៦០២,១៤ហិកតាស្មើនឹង១០,២០%នៃប្រភេទដីអាចសាងសង់បាន។ តំបន់នេះត្រូវបានកំណត់បែងចែកជា៣ប្រភេទមានតំបន់ឧស្សាហកម្ម តំបន់ឧស្សាហកម្មស្រាល និងតំបន់ឧស្សាហកម្មចម្រុះ ដោយផ្អែកតាមកម្រិតនៃហេតុប៉ះពាល់បរិស្ថាននិងសង្គម។

**គ.១- តំបន់ឧស្សាហកម្ម**មានផ្ទៃដីប្រមាណ១៨៩,០១ហិកតាស្មើនឹង១,២០%នៃប្រភេទដីអាចសាងសង់បាន និងត្រូវបានកំណត់៖

- ប្រភេទរោងចក្រដែលមានហេតុប៉ះពាល់បរិស្ថាននិងសង្គមកម្រិតខ្ពស់
- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៥០%
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា១,៥ និងសន្ទស្សន៍ប្រើប្រាស់ដីបន្ថែមអតិបរមាសម្រាប់ការលើកទឹកចិត្ត១,៥
- កម្ពស់អគារអតិបរមាស្របតាមសន្ទស្សន៍ប្រើប្រាស់ដី

- ឆ្លាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច២៥ម៉ែត្រចំពោះមិនមែនផ្លូវជាតិនិងយ៉ាងតិច៥០ម៉ែត្រចំពោះផ្លូវជាតិសម្រាប់រៀបចំចំណតរថយន្តដឹកទំនិញនិងកម្មករនិងឆ្លាតម្លាតអគារផ្នែកខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច៨ម៉ែត្រពីព្រំដីឡូត៍កាត់កាប់ស្របច្បាប់
- សោភណភាពនិងពណ៌សមស្រប
- ស្ថាបត្យកម្មត្រូវមានរចនាបថ អត្តសញ្ញាណវប្បធម៌សមស្រប និងលក្ខណៈធម្មជាតិនិងបរិស្ថាន
- អាងប្រព្រឹត្តកម្មទឹកកខ្វក់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០%
- ផ្ទៃដីឡូត៍១០០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិខុសផ្សេងពីនេះ
- ចំណតរថយន្ត៖
  - អគាររោងចក្រ ផ្ទៃក្រឡាកម្រាលសំណង់២៥០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១ និងផ្ទៃក្រឡាកម្រាលសំណង់១ ២៥០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តធំចំនួន១ និងចំណតកង់ ម៉ូតូសមស្រប
  - អគារឃ្លាំងផ្ទុកទំនិញផ្ទាល់ខ្លួន ផ្ទៃក្រឡាកម្រាលសំណង់៤០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១ និងផ្ទៃក្រឡាកម្រាលសំណង់២ ០០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តធំចំនួន១ និងចំណតកង់ ម៉ូតូសមស្រប។

**គ.២-តំបន់ឧស្សាហកម្មស្រាល**មានផ្ទៃដីប្រមាណ៥៤៧,៩០ហិកតាស្មើនឹង៣,៤៩% នៃប្រភេទដីអាចសាងសង់បាន និងត្រូវបានកំណត់៖

- ប្រភេទរោងចក្រឬសិប្បកម្មដែលមានហេតុប៉ះពាល់បរិស្ថាននិងសង្គមកម្រិតទាប
- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា២,៥ និងសន្ទស្សន៍ប្រើប្រាស់ដីបន្ថែមអតិបរមាសម្រាប់ការលើកទឹកចិត្ត០,៥
- កម្ពស់អគារអតិបរមាស្របតាមសន្ទស្សន៍ប្រើប្រាស់ដី
- ឆ្លាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច១២ម៉ែត្រចំពោះមិនមែនផ្លូវជាតិនិងយ៉ាងតិច២១ម៉ែត្រចំពោះផ្លូវជាតិសម្រាប់រៀបចំចំណតរថយន្តដឹកទំនិញនិងកម្មករនិងឆ្លាតម្លាតអគារផ្នែកខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច៦ម៉ែត្រពីព្រំដីឡូត៍កាត់កាប់ស្របច្បាប់
- សោភណភាពនិងពណ៌សមស្រប
- ស្ថាបត្យកម្មត្រូវមានរចនាបថ អត្តសញ្ញាណវប្បធម៌សមស្រប និងលក្ខណៈធម្មជាតិនិងបរិស្ថាន
- អាងប្រព្រឹត្តកម្មទឹកកខ្វក់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០%
- ផ្ទៃដីឡូត៍១០០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិខុសផ្សេងពីនេះ

– ចំណតរថយន្ត៖

- អគាររោងចក្រ ផ្ទៃក្រឡាកម្រាលសំណង់២៥០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១ និងផ្ទៃក្រឡាកម្រាលសំណង់១ ២៥០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តធំចំនួន១ និងចំណតកង់ ម៉ូតូសមស្រប
- អគារឃ្លាំងស្តុកទំនិញផ្ទាល់ខ្លួន ផ្ទៃក្រឡាកម្រាលសំណង់៤០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១ និងផ្ទៃក្រឡាកម្រាលសំណង់២ ០០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តធំចំនួន១ និងចំណតកង់ ម៉ូតូសមស្រប។

**គ.៣- តំបន់ឧស្សាហកម្មចម្រុះ**មានផ្ទៃដីប្រមាណ៨៦៥,២៣ហិកតាស្មើនឹង៥,៩១% នៃប្រភេទដីអាចសាងសង់បាន និងត្រូវបានកំណត់៖

– ប្រភេទរោងចក្រឬសិប្បកម្មដែលមានហេតុប៉ះពាល់បរិស្ថាននិងសង្គមកម្រិតមធ្យម
– ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%
– សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា២,០ និងសន្ទស្សន៍ប្រើប្រាស់ដីបន្ថែមអតិបរមាសម្រាប់ការលើកទឹកចិត្ត១,០
– កម្ពស់អគារអតិបរមាស្របតាមសន្ទស្សន៍ប្រើប្រាស់ដី
– ថ្នាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច២១ម៉ែត្រចំពោះមិនមែនផ្លូវជាតិនិងយ៉ាងតិច៣៣ម៉ែត្រចំពោះផ្លូវជាតិសម្រាប់រៀបចំចំណតរថយន្តដឹកទំនិញនិងកម្មករនិងថ្នាតម្លាតអគារផ្នែកខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច៧ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
– សោភណភាពនិងពណ៌សមស្រប
– ស្ថាបត្យកម្មត្រូវមានរចនាបទ អត្តសញ្ញាណវប្បធម៌សមស្រប និងលក្ខណៈធម្មជាតិនិងបរិស្ថាន
– អាងប្រព្រឹត្តកម្មទឹកកខ្វក់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
– ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០%
– ផ្ទៃដីឡូត៍១០០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិផ្សេងពីនេះ
– ចំណតរថយន្ត៖

- អគាររោងចក្រ ផ្ទៃក្រឡាកម្រាលសំណង់២៥០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១ និងផ្ទៃក្រឡាកម្រាលសំណង់១ ២៥០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តធំចំនួន១ និងចំណតកង់ ម៉ូតូសមស្រប
- អគារឃ្លាំងស្តុកទំនិញផ្ទាល់ខ្លួន ផ្ទៃក្រឡាកម្រាលសំណង់៤០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១ និងផ្ទៃក្រឡាកម្រាលសំណង់២ ០០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តធំចំនួន១ និងចំណតកង់ ម៉ូតូសមស្រប។

**ឃ- តំបន់ចម្រុះ**

តំបន់ចម្រុះមានផ្ទៃដីប្រមាណ២ ២៦៩,៩៣ហិកតាស្មើនឹង១៤,៨៦% នៃប្រភេទដីអាចសាងសង់បាន។ តំបន់នេះមានមុខងារសម្រាប់សាងសង់អគារពហុមុខងារសម្រាប់លំនៅឋាន ពាណិជ្ជកម្ម និងសេវាកម្ម ដោយធានាបានបរិស្ថានរស់នៅនិងបង្កើនភាពងាយស្រួលដល់ការស្នាក់នៅ ការប្រកបការងារ ការសិក្សា ការកម្សាន្ត និងសេវាកម្ម។ តំបន់នេះត្រូវបានកំណត់បែងចែកជា៣ប្រភេទ៖

**ឃ.១-តំបន់ចម្រុះកម្ពស់ទាប**មានផ្ទៃដីប្រមាណ៣៦៣,២៣ហិកតាស្មើនឹង២,៣១% នៃប្រភេទដីអាចសាងសង់បាន និងត្រូវបានកំណត់៖

- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៥០%
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា២,០ និងសន្ទស្សន៍ប្រើប្រាស់ដីបន្ថែមអតិបរមាសម្រាប់ការលើកទឹកចិត្ត១,០
- កម្ពស់អគារអតិបរមាស្របតាមសន្ទស្សន៍ប្រើប្រាស់ដី
- ថ្នាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច៤ម៉ែត្រនិងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច២ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
- ក្នុងករណីចាំបាច់នៃតំបន់ចម្រុះកម្ពស់ទាបនេះនិងក្នុងករណីសំណង់គ្មានជញ្ជាំងនិងមានតែសសរ ហើយជាន់ផ្ទាល់ដីត្រូវបានប្រើប្រាស់សម្រាប់ថ្មើរជើងសាធារណៈ ថ្នាតម្លាតអគារអប្បបរមាផ្នែកខាងមុខត្រូវកំណត់យ៉ាងតិចស្មើនឹងមួយភាគពីរ នៃគម្លាតខាងមុខដែលបានកំណត់ខាងលើសម្រាប់អគារដែលមានកម្ពស់ទាប
- អាជ្ញាធរមានសមត្ថកិច្ចអាចតម្រូវឱ្យរៀបចំឱ្យមានច្រកផ្លូវដើរដែលមានទំហំសមស្រប ឬក្នុងអគារសម្រាប់សាធារណជនដែលមានទំហំទទឹងយ៉ាងតិច២ម៉ែត្រដើម្បីលើកទឹកចិត្តដល់ថ្មើរជើង
- សោភណភាពនិងពណ៌សមស្រប
- ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន
- អាងបង្គន់អនាម័យស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- អាងប្រព្រឹត្តកម្មទឹកកខ្វក់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០%
- ផ្ទៃដីឡូត៍១០០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
- ចំណតរថយន្តត្រូវកំណត់ទៅតាមការកំណត់ចំនួនចំណតរថយន្តរបស់ប្រភេទអគារនីមួយៗ ដែលបានកំណត់នៅក្នុងតំបន់ប្រើប្រាស់ដីនីមួយៗ។

**ឃ.២-តំបន់ចម្រុះកម្ពស់មធ្យម**មានផ្ទៃដីប្រមាណ១ ០៧១,៦២ហិកតាស្មើនឹង៦,៨២% នៃប្រភេទដីអាចសាងសង់បាន និងត្រូវបានកំណត់៖

- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៣,០ និងសន្ទស្សន៍ប្រើប្រាស់ដីបន្ថែមអតិបរមាសម្រាប់ការលើកទឹកចិត្ត២,០
- កម្ពស់អគារអតិបរមាស្របតាមសន្ទស្សន៍ប្រើប្រាស់ដី
- ថ្នាតម្លាតអគារ៖
  - អគារកម្ពស់ពី៤ដល់៨ជាន់ត្រូវកំណត់ថ្នាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច៥ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច២,៥ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
  - អគារកម្ពស់ពី៩ដល់១១ជាន់ត្រូវកំណត់ថ្នាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច៦ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច៣ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់។

- ក្នុងករណីចាំបាច់នៃតំបន់ចម្រុះកម្ពស់មធ្យមនេះ និងក្នុងករណីសំណង់គ្មានជញ្ជាំងនិងមានតែសរសរ ហើយជាន់ផ្ទាល់ដីត្រូវបានប្រើប្រាស់សម្រាប់ថ្មើរជើងសាធារណៈ ថ្នាតម្លាតអគារអប្បបរមាផ្នែកខាងមុខត្រូវកំណត់យ៉ាងតិចស្មើនឹងមួយភាគពីរ នៃតម្លាតខាងមុខដែលបានកំណត់ខាងលើសម្រាប់អគារដែលមានកម្ពស់មធ្យម
- អាជ្ញាធរមានសមត្ថកិច្ចអាចតម្រូវឱ្យរៀបចំឱ្យមានច្រកផ្លូវដើរដែលមានដំបូលសមស្រប ឬក្នុងអគារសម្រាប់សាធារណជនដែលមានទំហំទទឹងយ៉ាងតិច២ម៉ែត្រដើម្បីលើកទឹកចិត្តដល់ថ្មើរជើង
- សោភណភាពនិងពណ៌សមស្រប
- ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន
- អាងបង្គន់អនាម័យស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- អាងប្រព្រឹត្តកម្មទឹកកខ្វក់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០%
- ផ្ទៃដីឡូត៍១០០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិផ្សេងពីនេះ
- ចំណតរថយន្តត្រូវកំណត់ទៅតាមការកំណត់ចំនួនចំណតរថយន្តរបស់ប្រភេទអគារនីមួយៗដែលបានកំណត់នៅក្នុងតំបន់ប្រើប្រាស់ដីនីមួយៗ។

**ឃ.៣- តំបន់ចម្រុះកម្ពស់ខ្ពស់**មានផ្ទៃដីប្រមាណ៨៣៥,០៧ហិកតាស្មើនឹង៥,៣២% នៃប្រភេទដីអាចសាងសង់បាន និងត្រូវបានកំណត់៖

- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៨០%
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៦,០ និងសន្ទស្សន៍ប្រើប្រាស់ដីបន្ថែមអតិបរមាសម្រាប់ការលើកទឹកចិត្ត៣,០
- កម្ពស់អគារអតិបរមាស្របតាមសន្ទស្សន៍ប្រើប្រាស់ដី
- ថ្នាតម្លាតអគារ៖
  - អគារកម្ពស់ពី១២ដល់២០ជាន់ ត្រូវកំណត់ថ្នាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច៦,៥ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច៣,២៥ម៉ែត្រពីព្រំដីឡូត៍កាត់កាប់ស្របច្បាប់
  - អគារកម្ពស់ពី២១ដល់៣០ជាន់ត្រូវកំណត់ថ្នាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច៨ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច៤ម៉ែត្រពីព្រំដីឡូត៍កាត់កាប់ស្របច្បាប់
  - អគារកម្ពស់ចាប់ពី៣១ជាន់ឡើងទៅ ត្រូវកំណត់ថ្នាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច១០ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច៥ម៉ែត្រពីព្រំដីឡូត៍កាត់កាប់ស្របច្បាប់។
- ក្នុងករណីចាំបាច់នៃតំបន់ចម្រុះកម្ពស់ខ្ពស់នេះ និងក្នុងករណីសំណង់គ្មានជញ្ជាំងនិងមានតែសរសរ ហើយជាន់ផ្ទាល់ដីត្រូវបានប្រើប្រាស់សម្រាប់ថ្មើរជើងសាធារណៈ ថ្នាតម្លាតអគារអប្បបរមាផ្នែកខាងមុខត្រូវកំណត់យ៉ាងតិចស្មើនឹងពីរភាគបី នៃតម្លាតខាងមុខដែលបានកំណត់ខាងលើសម្រាប់អគារដែលមានកម្ពស់ខ្ពស់

- អាជ្ញាធរមានសមត្ថកិច្ចអាចតម្រូវឱ្យរៀបចំឱ្យមានច្រកផ្លូវដើរដែលមានដំបូលសមស្រប ឬក្នុងអគារសម្រាប់សាធារណជនដែលមានទំហំទទឹងយ៉ាងតិច២,៥ម៉ែត្រដើម្បីលើកទឹកចិត្តដល់ថ្មើរជើង
- សោភណភាពនិងពណ៌សមស្រប
- ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន
- អាងបង្គន់អនាម័យស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- អាងប្រព្រឹត្តកម្មទឹកកខ្វក់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០%
- ផ្ទៃដីឡូត៍១០០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
- ចំណតរថយន្តត្រូវកំណត់ទៅតាមការកំណត់ចំនួនចំណតរថយន្តរបស់ប្រភេទអគារនីមួយៗដែលបានកំណត់នៅក្នុងតំបន់ប្រើប្រាស់ដីនីមួយៗ។

**ង-តំបន់ដឹកជញ្ជូន**

តំបន់ដឹកជញ្ជូនមានផ្ទៃដីប្រមាណ៩៤៣,៧៥ហិកតាស្មើនឹង៦,០១% នៃប្រភេទដីអាចសាងសង់បាន។ តំបន់នេះមានមុខងារចម្បងសម្រាប់សាងសង់អគារហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្មបម្រើដល់វិស័យដឹកជញ្ជូននិងគមនាគមន៍មានជាអាទិ៍ស្ថានីយរថភ្លើង ព្រលានយន្តហោះ ស្ថានីយរថយន្ត កំពង់ចម្លង កំពង់ផែ កំពង់ផែស្ងួត ឃ្លាំង មជ្ឈមណ្ឌលចែកចាយទំនិញ ភស្តុភារកម្ម និងចំណតរថយន្តជាដើម និងត្រូវបានកំណត់៖

- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា២,០ និងសន្ទស្សន៍ប្រើប្រាស់ដីបន្ថែមអតិបរមាសម្រាប់ការលើកទឹកចិត្ត១,០
- កម្ពស់អគារអតិបរមាស្របតាមសន្ទស្សន៍ប្រើប្រាស់ដី
- ថ្នាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច៤ម៉ែត្រនិងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច២ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
- សោភណភាពនិងពណ៌សមស្រប
- ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន
- អាងប្រព្រឹត្តកម្មទឹកកខ្វក់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០%
- ផ្ទៃដីឡូត៍១០០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
- ផ្ទៃក្រឡាកម្រាលសំណង់១០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តចំនួន១។

**ច-តំបន់ទេសចរណ៍**

តំបន់ទេសចរណ៍មានផ្ទៃដីប្រមាណ១ ៦២៥,៤០ហិកតាស្មើនឹង៧,៧២%នៃប្រភេទដីអាចសាងសង់បាន។ តំបន់នេះមានមុខងារសម្រាប់សាងសង់អគារបម្រើដល់វិស័យទេសចរណ៍និងកម្សាន្ត មានជាអាទិ៍ សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន កន្លែងកម្សាន្តជាដើម និងត្រូវបានកំណត់៖

- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៣,០ និងសន្ទស្សន៍ប្រើប្រាស់ដីបន្ថែមអតិបរមាសម្រាប់ការលើកទឹកចិត្ត១,៥
- កម្ពស់អគារអតិបរមាស្របតាមសន្ទស្សន៍ប្រើប្រាស់ដី
- ថ្លាតម្លាតអគារ៖
  - អគារកម្ពស់ពី១ដល់៣ជាន់ត្រូវកំណត់ថ្លាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច៤ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច២,៥ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
  - អគារកម្ពស់ពី៤ដល់៨ជាន់ត្រូវកំណត់ថ្លាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច៥ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច២,៥ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
  - អគារកម្ពស់ពី៩ដល់១១ជាន់ត្រូវកំណត់ថ្លាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច៦ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច៣ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់។
- សោភណភាពនិងពណ៌សមស្រប
- ស្ថាបត្យកម្មត្រូវមានរចនាបទខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន
- អាងបង្គន់អនាម័យស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- អាងប្រព្រឹត្តកម្មទឹកកខ្វក់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០%
- ផ្ទៃដីឡូត៍១០០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
- ចំណតរថយន្ត៖
  - អគារសណ្ឋាគារ ចំនួនបន្ទប់៥បន្ទប់ត្រូវមានចំណតរថយន្តតូចចំនួន១ និងចំនួនបន្ទប់៣០បន្ទប់ត្រូវមានចំណតរថយន្តធំចំនួន១
  - អគារផ្ទះសំណាក់ ចំនួនបន្ទប់១០បន្ទប់ត្រូវមានចំណតរថយន្តតូចចំនួន១ និងចំនួនបន្ទប់៣០បន្ទប់ត្រូវមានចំណតរថយន្តធំចំនួន១
  - អគារការិយាល័យជួលជញ្ជូន ផ្ទៃក្រឡាកម្រាលសំណង់១០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១ និងផ្ទៃក្រឡាកម្រាលសំណង់៥០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តធំចំនួន១
  - អគារពាណិជ្ជកម្មផ្សេងៗ ផ្ទៃក្រឡាកម្រាលសំណង់៥០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១។

**ង-តំបន់រដ្ឋបាលនិងសេវាសាធារណៈ**

តំបន់រដ្ឋបាលនិងសេវាសាធារណៈមានផ្ទៃដីប្រមាណ១៩៤,៧៣ហិកតាស្មើនឹង១,២៤% នៃផ្ទៃដីអាចសាងសង់បាន។ តំបន់នេះមានមុខងារចម្បងសម្រាប់សាងសង់អគារដែលបម្រើសេវារដ្ឋបាលនិងសេវាសាធារណៈមានជាអាទិ៍អគារស្ថាប័ន មន្ទីរ អង្គភាព សាលាខេត្ត សាលាក្រុង សាលាស្រុក សាលាឃុំ សាលាសង្កាត់ សាលារៀន មន្ទីរពេទ្យ បណ្ណាល័យ មណ្ឌលសុខភាព ប្រៃសណីយ៍ជាដើម និងត្រូវបានកំណត់៖

- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៤,០ និងសន្ទស្សន៍ប្រើប្រាស់ដីបន្ថែមអតិបរមាសម្រាប់ការលើកទឹកចិត្ត១,០
- កម្ពស់អគារអតិបរមាស្របតាមសន្ទស្សន៍ប្រើប្រាស់ដី
- ថ្នាតម្លាតអគារ៖
  - អគារកម្ពស់ពី១ដល់៣ជាន់ត្រូវកំណត់ថ្នាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច៤ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច២,០ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
  - អគារកម្ពស់ពី៤ដល់៨ជាន់ត្រូវកំណត់ថ្នាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច៥ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច២,៥ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
  - អគារកម្ពស់ពី៩ដល់១១ជាន់ត្រូវកំណត់ថ្នាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច៦ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច៣ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់។
- សោភណភាពនិងពណ៌សមស្រប
- ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន
- អាងបង្គន់អនាម័យស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- អាងប្រព្រឹត្តកម្មទឹកកខ្វក់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០%
- ផ្ទៃដីឡូត៍១០០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
- ចំណតរថយន្ត៖
  - អគារគ្រឹះស្ថានឧត្តមសិក្សា ផ្ទៃក្រឡាកម្រាលសំណង់១០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១
  - អគារគ្រឹះស្ថានមធ្យមសិក្សា ផ្ទៃក្រឡាកម្រាលសំណង់២០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១
  - អគារគ្រឹះស្ថានបឋមសិក្សា ផ្ទៃក្រឡាកម្រាលសំណង់៣០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១
  - អគារមជ្ឈមណ្ឌលកីឡា ផ្ទៃក្រឡាកម្រាលសំណង់១០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១
  - អគារមន្ទីរពេទ្យ ផ្ទៃក្រឡាកម្រាលសំណង់១០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១
  - អគារគ្លីនិកព្យាបាលនិងសុខភាព ផ្ទៃក្រឡាកម្រាលសំណង់១២០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១
  - អគាររដ្ឋបាលនិងការិយាល័យផ្សេងៗ ផ្ទៃក្រឡាកម្រាលសំណង់១០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១។

### ផ- តំបន់លម្ហសាធារណៈនិងផ្ទៃបៃតង

តំបន់លម្ហសាធារណៈនិងផ្ទៃបៃតងមានផ្ទៃដីប្រមាណ២២០,១០ហិកតាស្មើនឹង១,៤០% នៃប្រភេទដីអាចសាងសង់បាន។ តំបន់នេះមានមុខងារសម្រាប់បម្រើដល់ការសម្រាក ការលម្ហែ ការកម្សាន្ត និងពិធីសាធារណៈ មានដូចជាឧទ្យាន សួនច្បារ សួនសត្វ សួនកុមារ កន្លែងក្មេងលេង សួនយុវជន សួនមនុស្សចាស់ជាដើម ដែលត្រូវបានរៀបចំនិងសាងសង់សម្រាប់បម្រើដល់សាធារណជន និងត្រូវបានកំណត់៖

- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៥%
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា០,១
- កម្ពស់អគារអតិបរមា២ជាន់
- ឆ្លាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច៤ម៉ែត្រនិងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច២ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
- សោភណភាពនិងពណ៌សមស្រប
- ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន
- អាងបង្ហូរទឹកមានម៉ែត្របេឡាតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- ផ្ទៃដីដែលនៅសល់ពីការសាងសង់ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹក
- ផ្ទៃដីឡូត៍៥០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិផ្សេងពីនេះ
- ចំណតរថយន្តក្រុង ចំណតរថយន្តទេសចរណ៍ ចំណតយានយន្ត និងចំណតកង់ត្រូវមានចំនួនសមស្រប។

### ឈ- តំបន់វប្បធម៌និងសាសនា

តំបន់វប្បធម៌និងសាសនាមានផ្ទៃដីប្រមាណ៣៣,៥២ហិកតាស្មើនឹង០,២១%នៃប្រភេទដីអាចសាងសង់បាន។ តំបន់នេះមានមុខងារចម្បងសម្រាប់សាងសង់អគារដែលបម្រើដល់វិស័យប្រវត្តិសាស្ត្រ សិល្បៈ វប្បធម៌ និងសាសនា មានដូចជាប្រាសាទ វត្តអារាម វិហារសាសនា សាលារៀន សារមន្ទីរ ទីលានកីឡា កន្លែងសិប្បកម្មចម្លាក់ សាលាឆទាន ពុទ្ធិសាកលវិទ្យាល័យជាដើម និងត្រូវបានកំណត់៖

- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៥០%
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា២,០
- កម្ពស់អគារអតិបរមាស្របតាមសន្ទស្សន៍ប្រើប្រាស់ដី
- ឆ្លាតម្លាតអគារ៖
    - អគារកម្ពស់ពី១ដល់៣ជាន់ត្រូវកំណត់ឆ្លាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច៤ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច២,៥ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
    - អគារកម្ពស់ពី៤ដល់៥ជាន់ត្រូវកំណត់ឆ្លាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច៥ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច២,៥ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់។
- សោភណភាពនិងពណ៌សមស្រប
- ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន

- អាងបង្ហូរទឹកអនាម័យស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០%
- ផ្ទៃដីឡូត៍១០០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិខុសផ្សេងពីនេះ
- ផ្ទៃក្រឡាកម្រាលសំណង់១០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១។

**ញ- តំបន់សេដ្ឋកិច្ចពិសេស**

តំបន់សេដ្ឋកិច្ចពិសេសក្នុងវិសាលភាពសិក្សានេះមានផ្ទៃដីប្រមាណ២៣០២,៥៦ហិកតាស្មើនឹង១៤,៦៦% នៃប្រភេទដីអាចសាងសង់បាន មានជាអាទិ៍ **តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ (SIHANOUKVILLE SEZ)** មានផ្ទៃដី១ ១១៣,៣៩ហិកតា (១១ ១៣៣ ៩០០ម៉ែត្រក្រឡា) ស្ថិតនៅភូមិថ្មីធៀង សង្កាត់បិតត្រាំង និងភូមិស្ទឹងចំផែន សង្កាត់រាម ក្រុងព្រះសីហនុ ដែលបានបង្កើតឡើងតាមរយៈអនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបង្កើតតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ, **តំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ (SIHANOUKVILLE PORT SEZ)** មានផ្ទៃដី៦៧,៤៦ហិកតា (៦៧៤ ៦០០ម៉ែត្រក្រឡា) ស្ថិតនៅភូមិ៣ សង្កាត់លេខ៣ និងភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ដែលបានបង្កើតឡើងតាមរយៈអនុក្រឹត្យលេខ១៤៧ អនក្រ.បក ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីការបង្កើតតំបន់សេដ្ឋកិច្ចកំពង់ផែក្រុងព្រះសីហនុជាដើម។

ការបង្កើតតំបន់សេដ្ឋកិច្ចពិសេសត្រូវអនុលោមតាមអនុក្រឹត្យលេខ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើតនិងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស អនុក្រឹត្យលេខ២៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលលើមាត្រា៤ ចំណុច៤.១ នៃអនុក្រឹត្យលេខ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើតនិងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស និងអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការកែសម្រួលលើមាត្រា៤ ចំណុច៤.១ និងចំណុច៤.៣ នៃអនុក្រឹត្យលេខ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើតនិងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស ព្រមទាំងត្រូវមានការវាយតម្លៃហេតុផលប៉ះពាល់នៃការរៀបចំដែនដីនិងនគរូបនីយកម្មស្របតាមបទប្បញ្ញត្តិជាធរមាន។

បទប្បញ្ញត្តិនគរូបនីយកម្មនិងប្រើប្រាស់ដីសម្រាប់តំបន់សេដ្ឋកិច្ចពិសេសត្រូវបានកំណត់៖

- បទប្បញ្ញត្តិនគរូបនីយកម្ម៖
  - ឆ្លាតម្លាតអគារផ្នែកខាងមុខនៃតំបន់សេដ្ឋកិច្ចពិសេសត្រូវកំណត់យ៉ាងតិច២៥ម៉ែត្រចំពោះមិនមែនផ្លូវជាតិនិងយ៉ាងតិច៥០ម៉ែត្រចំពោះផ្លូវជាតិសម្រាប់រៀបចំលម្ហសាធារណៈ លម្ហសង្គម ចំណតរថយន្តដឹកទំនិញនិងកម្មករ និងឆ្លាតម្លាតអគារផ្នែកខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច១២ម៉ែត្រពីព្រំដីឡូត៍កាត់កាប់ស្របច្បាប់
  - ហេដ្ឋារចនាសម្ព័ន្ធរួបវន្តមានជាអាទិ៍បណ្តាញផ្លូវ បរិក្ខារ បណ្តាញអគ្គិសនី បណ្តាញទូរគមនាគមន៍ ប្រព័ន្ធគ្រប់គ្រងសំណល់រឹងនិងរាវ និងប្រព័ន្ធគ្រប់គ្រងអគ្គីភ័យ និងបរិក្ខារផ្សេងៗ ត្រូវកំណត់យ៉ាងតិច២៥%នៃផ្ទៃដីតំបន់សេដ្ឋកិច្ចពិសេស និងបណ្តាញផ្លូវមេត្រូវធ្វើសមាហរណកម្មជាមួយនឹងបណ្តាញផ្លូវមេក្នុងទីក្រុង
  - សួនច្បារសាធារណៈ កន្លែងក្មេងលេង កន្លែងហាត់ប្រាណ ទីលានកីឡា និងទីលានសម្រាកត្រូវកំណត់យ៉ាងតិច១០%នៃផ្ទៃដីតំបន់សេដ្ឋកិច្ចពិសេស

- ស្ថាបត្យកម្មខ្លោងទ្វារត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន និងមានសោភណភាពនិងពណ៌សមស្រប
- ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- សំណង់សម្រាប់ផ្តល់សេវាជូនសាធារណជនត្រូវរៀបចំឱ្យបានសមស្របតាមតម្រូវការបច្ចេកទេស
- ផែនការអភិវឌ្ឍបៃតង ផែនការបន្សាំនិងកាត់បន្ថយការប្រែប្រួលអាកាសធាតុ ផែនការទីតាំងដែលងាយបង្កឱ្យមានគ្រោះអគ្គិភ័យនិងមហន្តរាយផ្សេងៗជាយថាហេតុ ត្រូវកំណត់ឱ្យបានច្បាស់លាស់ ដើម្បីធានាសន្តិសុខ សុវត្ថិភាព សុខុមាលភាពសាធារណៈ និងការពារបរិស្ថាន។

– បទប្បញ្ញត្តិប្រើប្រាស់ដី៖ ត្រូវកំណត់អនុវត្តតាមតំបន់ប្រើប្រាស់ដីនីមួយៗដែលបានកំណត់ខាងលើ និងហេតុប៉ះពាល់បរិស្ថាននិងសង្គមមានជាអាទិ៍ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា កម្ពស់អគារអតិបរមា ថ្នាតម្លាតអគារចំណតរថយន្ត សួនច្បារជ្រាបទឹក ការដាំដើមឈើនិងការអភិវឌ្ឍបៃតង សោភណភាពនិងពណ៌សមស្រប ស្ថាបត្យកម្មត្រូវមានរចនាបថ អត្តសញ្ញាណវប្បធម៌សមស្រប និងលក្ខណៈធម្មជាតិនិងបរិស្ថានជាដើម

– បទប្បញ្ញត្តិជាធរមាន។

**៥- តំបន់អភិវឌ្ឍទីក្រុងថ្មី (គម្រោងអភិវឌ្ឍទីក្រុងរាម)**

រាជរដ្ឋាភិបាលកម្ពុជាបានកំណត់តំបន់អភិវឌ្ឍទីក្រុងថ្មី ដោយការពង្រីកចូលទៅក្នុងផ្ទៃទឹកសមុទ្រនៃតំបន់ឆ្នេរសមុទ្ររាមមានផ្ទៃដីប្រមាណ៩៣៤ហិកតា តាមរយៈលិខិតលេខ៥២ សជណ.ជប ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ និងអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ មានផ្ទៃដីទំហំ៤០៧ហិកតា និងលិខិតលេខ៣៩៣ សជណ.ជប ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ និងអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ មានផ្ទៃដីទំហំ៤២៧ហិកតា ព្រមទាំងលិខិតលេខ១៤០ សជណ.ជប ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០២១ និងអនុក្រឹត្យលេខ៣១ អនក្រ.បក ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០២១ មានផ្ទៃដីទំហំ១០០ហិកតា។ បទប្បញ្ញត្តិប្រើប្រាស់ដីនៃតំបន់អភិវឌ្ឍទីក្រុងថ្មីត្រូវអនុលោមតាមអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងប្រកាសលេខ០៨៧ដ.ន.ស.ប្រក/នីក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការអភិវឌ្ឍដី ដូចខាងក្រោម៖

– ផ្ទៃដីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបន្តត្រូវកំណត់យ៉ាងតិច២៥ %នៃតំបន់អភិវឌ្ឍទីក្រុងថ្មី មានដូចជា៖

- បណ្តាញផ្លូវសាធារណៈ ផ្លូវបេតុង ផ្លូវថ្មើរជើង ផ្លូវជនមានពិការភាព ការដាំដើមឈើនិងបណ្តាញបៃតង បំពាក់ភ្លើងបំភ្លឺផ្លូវ ភ្លើងសញ្ញាចរាចរណ៍ គំនូសសញ្ញាចរាចរណ៍ ស្របតាមបទប្បញ្ញត្តិជាធរមាន
- បរិក្ខារសាធារណៈ មានជាអាទិ៍ ប្រព័ន្ធទឹកស្អាត ប្រព័ន្ធលូបង្ហូរទឹកកខ្វក់ ទឹកភ្លៀង បណ្តាញអគ្គិសនី បណ្តាញទូរគមនាគមន៍ ស្របតាមបទប្បញ្ញត្តិជាធរមាន
- ប្រព័ន្ធគ្រប់គ្រងសំណល់រឹងនិងរាវ មានជាអាទិ៍ ទីលានចាក់សំរាម រោងចក្រកែច្នៃសំរាម ប្រព័ន្ធលូ ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ ស្របតាមបទប្បញ្ញត្តិជាធរមាន
- ប្រព័ន្ធគ្រប់គ្រងអគ្គិភ័យនិងមហន្តរាយផ្សេងៗ ស្របតាមបទប្បញ្ញត្តិជាធរមាន។

- ផ្ទៃដីអភិវឌ្ឍលំហសាធារណៈនិងផ្ទៃបៃតងត្រូវកំណត់យ៉ាងតិច១០%នៃតំបន់អភិវឌ្ឍទីក្រុងថ្មី ឬ ១០ ម៉ែត្រក្រឡាសម្រាប់មនុស្សម្នាក់ មានដូចជា សួនច្បារសាធារណៈ កន្លែងក្មេងលេង កន្លែងហាត់ប្រាណ ទីលានកីឡា និងទីលានកម្សាន្ត
- ផ្ទៃដីអភិវឌ្ឍសំណង់សម្រាប់ផ្តល់សេវាជូនសាធារណជន ត្រូវកំណត់ឱ្យបានសមស្របទៅតាមតម្រូវការនៃគម្រោងអភិវឌ្ឍនីមួយៗ មានដូចជា សាលារៀន មណ្ឌលសុខភាព អគាររដ្ឋបាល ផ្សារ ដើម្បីធានាការផ្តល់សេវាសាធារណៈ ប្រកបដោយប្រសិទ្ធភាពនិងសមធម៌
- ការអភិវឌ្ឍបៃតង ផែនការបន្សាំនិងកាត់បន្ថយការប្រែប្រួលអាកាសធាតុ ត្រូវកំណត់ឱ្យបានច្បាស់អំពីទីតាំងដែលងាយបង្កឱ្យមានគ្រោះអគ្គិភ័យនិងហានិភ័យផ្សេងៗជាយថាហេតុ ដើម្បីធានាសន្តិសុខ សុវត្ថិភាព និងសុខុមាលភាពសាធារណៈ ការពារបរិស្ថាន និងលើកកម្ពស់តម្លៃវប្បធម៌និងអត្តសញ្ញាណជាតិ
- ឆ្នេរសមុទ្រ ដីចំណីឆ្នេរសមុទ្រ តំបន់រណប និងផ្លូវស្របតាមបណ្តោយឆ្នេរសមុទ្រក្នុងតំបន់ចម្រុះ និងតំបន់ពាណិជ្ជកម្ម ត្រូវកំណត់អភិវឌ្ឍស្របតាមសារាចរណែនាំលេខ០១សរណន ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា
- ប្លង់លម្អិតនគរូបនីយកម្មសម្រាប់តំបន់អភិវឌ្ឍទីក្រុងថ្មី ត្រូវរៀបចំនិងស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដី ពីអាជ្ញាធរមានសមត្ថកិច្ច។

ផ្ទៃដីតំបន់អភិវឌ្ឍទីក្រុងថ្មីដែលនៅសល់ពីការអភិវឌ្ឍខាងលើ ត្រូវបានកំណត់ជាតំបន់អភិវឌ្ឍដែលមានសន្ទស្សន៍ប្រើប្រាស់ដីទាប តំបន់អភិវឌ្ឍដែលមានសន្ទស្សន៍ប្រើប្រាស់ដីមធ្យម និងតំបន់អភិវឌ្ឍដែលមានសន្ទស្សន៍ប្រើប្រាស់ដីខ្ពស់ តាមបទប្បញ្ញត្តិដូចខាងក្រោម៖

**៥.១- តំបន់អភិវឌ្ឍដែលមានសន្ទស្សន៍ប្រើប្រាស់ដីទាប** ត្រូវបានកំណត់៖

- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៥០%
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា២,០ និងសន្ទស្សន៍ប្រើប្រាស់ដីបន្ថែមអតិបរមាសម្រាប់ការលើកទឹកចិត្ត១,០
- កម្ពស់អគារអតិបរមាស្របតាមបទប្បញ្ញត្តិសុវត្ថិភាពផ្លូវហោះហើររបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ធ្លាតម្កាតអគារផ្នែកខាងមុខយ៉ាងតិច៤ម៉ែត្រនិងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច២ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
- ត្រូវរៀបចំឱ្យមានច្រកផ្លូវដើរដែលមានដំបូលសមស្រប ឬក្នុងអគារសម្រាប់សាធារណជនដែលមានទំហំទទឹងយ៉ាងតិច២ម៉ែត្រដើម្បីលើកទឹកចិត្តដល់ថ្មើរជើង ក្នុងករណីតំបន់ចម្រុះឬតំបន់ពាណិជ្ជកម្ម
- សោភណភាពនិងពណ៌សមស្រប
- ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈចម្រុះនិងបរិស្ថាន
- អាងបង្គន់អនាម័យស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- អាងប្រព្រឹត្តកម្មទឹកកខ្វក់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន

- ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០%
- ផ្ទៃដីឡូត៍១០០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិផ្សេងពីនេះ
- ចំណតរថយន្តត្រូវកំណត់ទៅតាមការកំណត់ចំនួនចំណតរថយន្តរបស់ប្រភេទអគារនីមួយៗ ដែលបានកំណត់នៅក្នុងតំបន់ប្រើប្រាស់ដីនីមួយៗ។

**៥.២- តំបន់អភិវឌ្ឍដែលមានសន្ទស្សន៍ប្រើប្រាស់ដីមធ្យម** ត្រូវបានកំណត់៖

- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៣,០ និងសន្ទស្សន៍ប្រើប្រាស់ដីបន្ថែមអតិបរមាសម្រាប់ការលើកទឹកចិត្ត២,០
- កម្ពស់អគារអតិបរមាស្របតាមបទប្បញ្ញត្តិសុវត្ថិភាពផ្លូវហោះហើររបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ថ្នាក់គម្លាតអគារ៖
  - អគារកម្ពស់ពី៤ដល់៨ជាន់ត្រូវកំណត់ថ្នាក់គម្លាតអគារផ្នែកខាងមុខយ៉ាងតិច៥ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច២,៥ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
  - អគារកម្ពស់ពី៩ដល់១១ជាន់ត្រូវកំណត់ថ្នាក់គម្លាតអគារផ្នែកខាងមុខយ៉ាងតិច៦ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច៣ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់។
- ត្រូវរៀបចំឱ្យមានច្រកផ្លូវដើរដែលមានដំបូលសមស្រប ឬក្នុងអគារសម្រាប់សាធារណជនដែលមានទំហំទទឹងយ៉ាងតិច២ម៉ែត្រដើម្បីលើកទឹកចិត្តដល់ថ្មើរជើង ក្នុងករណីតំបន់ពង្រុះឬតំបន់ពាណិជ្ជកម្ម
- សោភណភាពនិងពណ៌សមស្រប
- ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន
- អាងបង្គន់អនាម័យស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- អាងប្រព្រឹត្តកម្មទឹកកខ្វក់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០%
- ផ្ទៃដីឡូត៍១០០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិផ្សេងពីនេះ
- ចំណតរថយន្តត្រូវកំណត់ទៅតាមការកំណត់ចំនួនចំណតរថយន្តរបស់ប្រភេទអគារនីមួយៗ ដែលបានកំណត់នៅក្នុងតំបន់ប្រើប្រាស់ដីនីមួយៗ។

**៥.៣- តំបន់អភិវឌ្ឍដែលមានសន្ទស្សន៍ប្រើប្រាស់ដីខ្ពស់** ត្រូវបានកំណត់៖

- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៥០%
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៦,០ និងសន្ទស្សន៍ប្រើប្រាស់ដីបន្ថែមអតិបរមាសម្រាប់ការលើកទឹកចិត្ត៣,០
- កម្ពស់អគារអតិបរមាស្របតាមបទប្បញ្ញត្តិសុវត្ថិភាពផ្លូវហោះហើររបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

- ថ្លាតម្លាតអគារ៖
  - អគារកម្ពស់ពី១២ដល់២០ជាន់ ត្រូវកំណត់ថ្លាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច៦,៥ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច៣,២៥ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
  - អគារកម្ពស់ពី២១ដល់៣០ជាន់ត្រូវកំណត់ថ្លាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច៨ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច៤ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
  - អគារកម្ពស់ចាប់ពី៣១ជាន់ឡើងទៅ ត្រូវកំណត់ថ្លាតម្លាតអគារផ្នែកខាងមុខយ៉ាងតិច១០ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច៥ម៉ែត្រពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់។
- ត្រូវរៀបចំឱ្យមានច្រកផ្លូវដើរដែលមានដំបូលសមស្រប ឬក្នុងអគារសម្រាប់សាធារណជនដែលមានទំហំទទឹងយ៉ាងតិច២,៥ម៉ែត្រដើម្បីលើកទឹកចិត្តដល់ថ្មើរជើង ក្នុងករណីតំបន់ចម្រុះឬតំបន់ពាណិជ្ជកម្ម
- សោភណភាពនិងពណ៌សមស្រប
- ស្ថាបត្យកម្មត្រូវមានរចនាបទខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន
- អាងបង្គន់អនាម័យស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- អាងប្រព្រឹត្តកម្មទឹកកខ្វក់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០%
- ផ្ទៃដីឡូត៍១០០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
- ចំណតរថយន្តត្រូវកំណត់ទៅតាមការកំណត់ចំនួនចំណតរថយន្តរបស់ប្រភេទអគារនីមួយៗដែលបានកំណត់នៅក្នុងតំបន់ប្រើប្រាស់ដីនីមួយៗ។

### ៤.២.២-ប្រភេទដីកម្រិតការសាងសង់

ផ្អែកតាមច្បាប់ស្តីពីតំបន់ការពារធនធានធម្មជាតិចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១០ អនុក្រឹត្យលេខ១៣៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ស្តីពីតំបន់ការពារធម្មជាតិ សារាចរណែនាំលេខ០១សរណន ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា អនុក្រឹត្យលេខ៤២អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន អនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការរៀបចំដែនដីខេត្តព្រះសីហនុ ច្បាប់និងបទដ្ឋានគតិយុត្តជាធរមាន ប្រភេទដីកម្រិតការសាងសង់ត្រូវបានកំណត់ជា៥តំបន់ដូចមាននិយាមកាកំណត់ក្នុងផែនទីប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុ ចក្ខុវិស័យឆ្នាំ២០៣៨ ជាឧបសម្ព័ន្ធភ្ជាប់មកជាមួយ។ រាល់ការអភិវឌ្ឍនិងការសាងសង់នៅលើប្រភេទដីកម្រិតការសាងសង់ ត្រូវគោរពតាមខ្សែរយៈកម្ពស់ដីដែលត្រូវអភិវឌ្ឍនិងសាងសង់តាមតំបន់នីមួយៗ ដែលបានកំណត់ដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ខេត្ត។ ការកំណត់ខ្សែរយៈកម្ពស់ដីដែលត្រូវអភិវឌ្ឍនិងសាងសង់ត្រូវផ្អែកទៅលើហេដ្ឋារចនាសម្ព័ន្ធផ្លូវនិងប្រព័ន្ធលូបង្ហូរ ស្របតាមទីតាំងភូមិសាស្ត្រនៃតំបន់នីមួយៗ។

**ក- តំបន់កសិកម្ម**

តំបន់កសិកម្មមានផ្ទៃដីប្រមាណ៣២០,៧៨ហិកតាស្មើនឹង២,៦២% នៃប្រភេទដីកម្រិតការសាងសង់។ តំបន់នេះត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការការពារសម្រាប់ផលិតកម្មកសិកម្មដោយតំបន់នេះមានលក្ខណៈអំណោយផល និងសក្ដានុពលខ្ពស់សម្រាប់ដំណាំផ្សេងៗដូចជាដំណាំស្រូវ កៅស៊ូ ស្វាយ ម្រេច ដូង និងវារីវប្បកម្មជាដើម។ បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍនិងសាងសង់ក្នុងតំបន់កសិកម្មត្រូវបានកំណត់ដូចខាងក្រោម៖

- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា២០%
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា០,៤
- ផលធៀបផ្ទៃក្រឡាបាតសួនជ្រាបទឹកធៀបនឹងផ្ទៃដីឡូត៍អប្បបរមា៦០%
- កម្ពស់អគារអតិបរមាស្របតាមសន្ទស្សន៍ប្រើប្រាស់ដី
- ឆ្លាតម្លាតអគារខាងមុខយ៉ាងតិច១២ម៉ែត្រពីព្រំដីចំណីផ្លូវនិងឆ្លាតម្លាតផ្នែកខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច៦ម៉ែត្រពីព្រំដី
- សោភណភាពនិងពណ៌សមស្រប
- ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន
- អាងបង្គន់អនាម័យស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- អាងប្រព្រឹត្តកម្មទឹកកខ្វក់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- ផ្ទៃដីឡូត៍៥០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិផ្សេងពីនេះ
- ចំណតរថយន្តត្រូវមានគ្រប់គ្រាន់តាមតម្រូវការតាមប្រភេទអគារនីមួយៗ។

រាល់ការអភិវឌ្ឍនិងសាងសង់នៅតំបន់កសិកម្មតម្រូវឱ្យមានលិខិតអនុញ្ញាតអភិវឌ្ឍដីជាមុនស្របតាមអនុក្រឹត្យលេខ៤២អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងប្រកាសលេខ០៨៧ដ.ន.ស.ប្រក/ នីក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីការអភិវឌ្ឍដី។ មានតែតំបន់កសិកម្មប៉ុណ្ណោះដែលអាចអនុញ្ញាតឱ្យសាងសង់លំនៅឋានផ្ទាល់ខ្លួនបានដែលមិនមានលក្ខណៈអាជីវកម្មនិងអាចសាងសង់រោងសិប្បកម្មសម្រាប់គោលដៅកសិកម្មបានដោយមិនបាច់ធ្វើការកែប្រែទៅជាប្រភេទដីអាចសាងសង់បាន លើកលែងតែតំបន់ណាដែលមានបទដ្ឋានគតិយុត្តកំណត់ដោយឡែក។

**ខ- តំបន់ព្រៃឈើ**

តំបន់ព្រៃឈើមានផ្ទៃដីប្រមាណ៤ ៦៥៦,៣៧ហិកតាស្មើនឹង៣៨,០៧% នៃប្រភេទដីកម្រិតការសាងសង់ រួមមានព្រៃឈើនិងព្រៃកោងកាងដ៏ស្រស់ស្អាតដែលជាជម្រកដ៏សំខាន់សម្រាប់ជីវចម្រុះធម្មជាតិគ្រប់ប្រភេទនិងមានសក្ដានុពលសម្រាប់គោលដៅទេសចរណ៍ធម្មជាតិស្ថិតនៅតំបន់ភ្នំ ពពកវិលឬវាលវៀន តាមបណ្ដោយព្រែកអូរដើមទាល ព្រែកអូរព្រេះ ជុំវិញបឹងធំកង្កែប និងតំបន់ស្រុកស្ទឹងហាវនិងស្រុកព្រៃនប់។ តំបន់នេះត្រូវការពារនិងអភិរក្សដោយទប់ស្កាត់ការកាប់បំផ្លាញនិងការប្តូរប្រភេទដីដើម្បីធានានូវចីរភាពបរិស្ថាននិងធនធានធម្មជាតិនៅតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា។

រាល់ការអភិវឌ្ឍនិងការសាងសង់លើដីសាធារណៈរបស់រដ្ឋក្នុងតំបន់ព្រៃឈើត្រូវមានគោលការណ៍សម្រេចពីរាជរដ្ឋាភិបាលដោយអនុក្រឹត្យស្របតាមបទដ្ឋានគតិយុត្តនិងនីតិវិធីជាធរមាន។ បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍនិងការសាងសង់ក្នុងតំបន់ព្រៃឈើត្រូវបានកំណត់ដូចខាងក្រោម៖

- ត្រូវការពារធនធានធម្មជាតិនិងរក្សាគម្របព្រៃឈើដែលមានស្រាប់ធៀបនឹងផ្ទៃដីឡូត៍ឱ្យបានយ៉ាងតិច ៦០%
- ផលធៀបផ្ទៃក្រឡាបាតសួនបៃតងជ្រាបទឹកធៀបនឹងផ្ទៃដីឡូត៍អប្បបរមា២០%
- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា២០%
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា០,៤
- កម្ពស់អគារអតិបរមាស្របតាមសន្ទស្សន៍ប្រើប្រាស់ដី
- ថ្នាតម្លាតអគារខាងមុខយ៉ាងតិច១២ម៉ែត្រពីព្រំដីចំណីផ្លូវនិងថ្នាតម្លាតផ្នែកខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច៦ម៉ែត្រពីព្រំដី
- សោភណភាពនិងពណ៌សមស្រប
- ស្ថាបត្យកម្មត្រូវមានរចនាបទខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន
- អាងបង្គន់អនាម័យស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- អាងប្រព្រឹត្តកម្មទឹកកខ្វក់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- ផ្ទៃដីឡូត៍៥០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិផ្សេងពីនេះ
- ចំណតរថយន្តត្រូវមានគ្រប់គ្រាន់តាមតម្រូវការតាមប្រភេទអគារនីមួយៗ។

**គ- តំបន់ធនធានទឹក**

តំបន់ធនធានទឹកមានផ្ទៃទឹកប្រមាណ៥៦៦,០៥ហិកតាស្មើនឹង៤,៦៣% នៃប្រភេទដីកម្រិតការសាងសង់ក្នុងនោះមានបឹងធំកង្កែប ព្រែកអូរឈើទាល ព្រែកអូរព្រះ អូរ ប្រឡាយ ទំនប់ទឹក និងបណ្តាញផ្លូវទឹកផ្សេងៗទៀតដែលមានប្រភពភ្ជាប់ទៅសមុទ្រនិងតំបន់ភ្នំដែលជាសក្តានុពលដ៏សំខាន់ដែលត្រូវស្តារនិងការពារថែរក្សា។

ខ្សែទឹកដែលហូរពីលើចុះមកក្រោមត្រូវបានទទួលរងផលប៉ះពាល់ទាំងបរិមាណនិងគុណភាពពីទម្រង់នៃការប្រើប្រាស់ដីធ្លីក្នុងតំបន់ទីជម្រាលដែលស្ថិតនៅខាងលើតាមបណ្តោយខ្សែទឹកហូរនោះ។ ការហូរច្រោះដីនិងការរងនូវការកកដីល្បាប់នៅក្នុងតំបន់ផ្ទៃទឹកនិងខ្សែទឹកហូរគឺទាក់ទងយ៉ាងខ្លាំងទៅនឹងការគ្រប់គ្រងគម្របព្រៃឈើ។ គុណភាពទឹកគឺពឹងផ្អែកយ៉ាងខ្លាំងទៅលើទម្រង់នៃការប្រើប្រាស់ដីដូចជាការធ្វើកសិកម្ម ការប្រើប្រាស់ជីនិងថ្នាំសំលាប់សត្វល្អិត និងសកម្មភាពកម្សាន្តទេសចរណ៍ជាដើម។ ដើម្បីថែរក្សាប្រភពទឹកនិងគុណភាពទឹក គោលការណ៍សំខាន់ៗដែលត្រូវអនុវត្តរួមមាន៖

- ទប់ស្កាត់ការប្រើប្រាស់ ការសាយភាយ និងការហូរចូលទៅក្នុងប្រភពទឹកនៃផលិតផលគីមី និងសារធាតុគីមីដែលមានគ្រោះថ្នាក់ដល់គុណភាពទឹក សុខភាពមនុស្សនិងសត្វ និងត្រូវធ្វើការពង្រឹងនិងអនុវត្តទៅតាមបទដ្ឋានគតិយុត្តជាធរមាននិងសេចក្តីណែនាំរបស់ក្រសួងបរិស្ថានឱ្យបានតឹងរ៉ឹងទៅលើការប្រើប្រាស់ជាតិពុលនិងផលិតផលដែលមានគ្រោះថ្នាក់

- ថែរក្សាតម្រងទឹកនិងគ្រប់គ្រងការប្រើប្រាស់ដីកសិកម្មនៅតាមតំបន់ជាប់ផ្លូវទឹកធម្មជាតិរួមមានស្ទឹង ព្រែក អូរ បឹងជាដើម ដើម្បីការពារការសឹករិចរឹលដី ការបាក់ដី ឬការហូរច្រោះដីចូលទៅក្នុងប្រភពទឹកដែលអាចប៉ះពាល់ដល់គុណភាពទឹក សុខភាពមនុស្ស និងសត្វ
- រៀបចំផែនការដាំឬការពារព្រៃឈើតាមរយៈគម្រោងអេកូទេសចរណ៍
- ធ្វើការថែរក្សាតម្រងទឹកអចិន្ត្រៃយ៍
- ត្រួតពិនិត្យឱ្យបានតឹងរ៉ឹងលើការប្រើប្រាស់ជាតិពុលនិងផលិតផលហាមឃាត់។

**ឃ-តំបន់ការពារឆ្នេរសមុទ្រ**

ដោយផ្អែកតាមសារាចរណែនាំលេខ០១សរណន ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ តំបន់ឆ្នេរសមុទ្រត្រូវបានកំណត់ ថែរក្សា និងការពារឆ្នេរសមុទ្រឱ្យបានទំហំទទឹងយ៉ាងតិច៣០ម៉ែត្រ ដីចំណីឆ្នេរសមុទ្រយ៉ាងតិច៥០ម៉ែត្រ និងដីចំណីផ្លូវសាធារណៈតាមបណ្តោយឆ្នេរសមុទ្រយ៉ាងតិច៣០ម៉ែត្រ។ សរុបតំបន់ឆ្នេរសមុទ្រមានប្រវែងទទឹងយ៉ាងតិច១១០ម៉ែត្រជាដីសាធារណៈរបស់រដ្ឋនិងតំបន់រណប ដែលមានប្រវែងទទឹងយ៉ាងតិច៣០០ម៉ែត្រឬស្របតាមស្ថានភាពទីតាំងជាក់ស្តែងសម្រាប់គោលដៅការពារទេសភាព ការអភិវឌ្ឍប្រកបដោយចីរភាព និងការធ្វើសមាហរណកម្មជាមួយតំបន់នគរូបនីយកម្ម។ យោងតាមការកំណត់ខាងលើ ឆ្នេរសមុទ្រនិងដីចំណីឆ្នេរសមុទ្រមានផ្ទៃដីប្រមាណ១ ១៦៩,១៨ហិកតាស្មើនឹង៩,៥៦%នៃប្រភេទដីអាចសាងសង់បាននិងត្រូវបានកំណត់និយាមកាក្នុងផែនទីប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុ ចក្ខុវិស័យឆ្នាំ២០៣៨ ដូចមានឧបសម្ព័ន្ធភ្ជាប់មកជាមួយ។ បទប្បញ្ញត្តិនៃការការពារ និងការអភិរក្ស ព្រមទាំងការអភិវឌ្ឍនិងការសាងសង់នៅតំបន់ឆ្នេរសមុទ្រត្រូវបានកំណត់នៅក្នុងចំណុច៤.១.២-ស្តីពីយុទ្ធសាស្ត្រអភិរក្សនិងអភិវឌ្ឍនគរូបនីយកម្មតំបន់ឆ្នេរសមុទ្រ។

**ង-តំបន់ប្រើប្រាស់ច្រើនយ៉ាងព្រែកទឹកសាបក្បាលឆាយ**

តំបន់ប្រើប្រាស់ច្រើនយ៉ាងព្រែកទឹកសាបក្បាលឆាយត្រូវបានបង្កើតឡើងតាមរយៈអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ និងត្រូវបានធ្វើការកែសម្រួលឡើងវិញតាមរយៈអនុក្រឹត្យលេខ១១៦អនក្រ.បក ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា១នៃអនុក្រឹត្យលេខ៧៨អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦។ ផ្អែកតាមអនុក្រឹត្យខាងលើនេះ តំបន់ប្រើប្រាស់ច្រើនយ៉ាងព្រែកទឹកសាបក្បាលឆាយមានផ្ទៃដី៥ ៥២០,០០ហិកតាស្មើនឹង៤៥,១៣% នៃប្រភេទដីកម្រិតការសាងសង់ដែលស្ថិតនៅក្នុងភូមិសាស្ត្រតំបន់សិក្សា។ តំបន់ប្រើប្រាស់ច្រើនយ៉ាងព្រែកទឹកសាបក្បាលឆាយគឺជាប្រភពទឹកដ៏សំខាន់សម្រាប់ក្រុងព្រះសីហនុនិងតំបន់ជុំវិញ ជាតំបន់ព្រៃចំតែមួយគត់នៅក្នុងតំបន់និងជារមណីយដ្ឋានទេសចរណ៍ធម្មជាតិដ៏សំខាន់ផងដែរ។ ដូច្នេះតំបន់នេះត្រូវយកចិត្តទុកដាក់ខ្ពស់សម្រាប់ការថែរក្សា ការពារ និងអភិរក្សតាមរយៈគោលការណ៍ណែនាំសំខាន់ៗដូចខាងក្រោម៖

- ការពារនិងថែរក្សាព្រៃតំបន់ប្រើប្រាស់ច្រើនយ៉ាងព្រែកទឹកសាបក្បាលឆាយនិងព្រៃក្នុងតំបន់ទីជម្រាល ដើម្បីធានាការគ្រប់គ្រងបរិស្ថានទឹកប្រកបដោយចីរភាព
- ដាំដើមឈើនិងបង្កើតក្រវាត់បៃតងជុំវិញតំបន់នេះ
- ពង្រឹងនូវព្រំប្រទល់ខាងក្រៅដោយដាក់បង្គោលបេតុង

- កំណត់នូវតំបន់ប្រតិបត្តិការនិងធ្វើការបែងចែកជាតំបន់គ្រប់គ្រងចំនួន៤ផ្សេងគ្នារួមមានតំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ដោយយោងតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨
- គ្រប់គ្រងធនធានព្រៃឈើដោយសហគមន៍នៅក្នុងតំបន់ការពារតាមរយៈកិច្ចព្រមព្រៀងមួយដែលបានកំណត់តាមនីតិវិធីដែលទទួលស្គាល់និងមានការឯកភាពពីក្រសួងបរិស្ថាន
- ធ្វើការត្រួតពិនិត្យឱ្យបានតឹងរឹងចំពោះការបង្ហូរទឹកកខ្វក់ចូលក្នុងតំបន់ព្រែកទឹកសាបនេះនិងការប្រើប្រាស់សារធាតុពុលនិងផលិតផលហាមឃាត់នៅក្នុងតំបន់នេះ។

រាល់ការអភិវឌ្ឍនិងការសាងសង់លើដីសាធារណៈរបស់រដ្ឋក្នុងតំបន់ការពារធនធានធម្មជាតិត្រូវមានគោលការណ៍សម្រេចពីរាជរដ្ឋាភិបាលដោយអនុក្រឹត្យស្របតាមនីតិវិធីជាធរមាន។ បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍនិងសាងសង់ក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនិងតំបន់សហគមន៍នៃតំបន់ការពារធម្មជាតិត្រូវបានកំណត់ ដូចខាងក្រោម៖

- ត្រូវការពារធនធានធម្មជាតិនិងរក្សាគម្របព្រៃឈើដែលមានស្រាប់ធៀបនឹងផ្ទៃដីឡូត៍ឱ្យបានយ៉ាងតិច៦០%
- ផលធៀបផ្ទៃក្រឡាបាតស្នូនបៃតងជ្រាបទឹកធៀបនឹងផ្ទៃដីឡូត៍អប្បបរមា២០%
- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា២០%
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា០,៤
- កម្ពស់អគារអតិបរមាស្របតាមសន្ទស្សន៍ប្រើប្រាស់ដី
- ថ្លាគម្លាតអគារខាងមុខយ៉ាងតិច១២ម៉ែត្រពីព្រំដីចំណីផ្លូវនិងថ្លាគម្លាតផ្នែកខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច៦ម៉ែត្រពីព្រំដី
- សោភណភាពនិងពណ៌សមស្រប
- ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន
- អាងបង្គន់អនាម័យស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- អាងប្រព្រឹត្តកម្មទឹកកខ្វក់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- ផ្ទៃដីឡូត៍៥០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិផ្សេងពីនេះ
- ចំណតរថយន្តត្រូវមានគ្រប់គ្រាន់តាមតម្រូវការតាមប្រភេទអគារនីមួយៗ។

### ៤.៣-យុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ

ផ្លូវជាតិលេខ៤ដែលជាផ្លូវយុទ្ធសាស្ត្រដ៏សំខាន់សម្រាប់ការដឹកជញ្ជូនរវាងរាជធានីភ្នំពេញ និងខេត្តព្រះសីហនុកាន់តែមានភាពមមាញឹក និងមិនអាចឆ្លើយតបទៅនឹងកំណើននៃការដឹកជញ្ជូនដែលមានការកើនឡើងជាលំដាប់ដោយសារការអភិវឌ្ឍយ៉ាងគំហុកនៅខេត្តព្រះសីហនុ ការអភិវឌ្ឍកំពង់ផែស្វយ័តក្រុងព្រះសីហនុ ការអភិវឌ្ឍអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ ការអភិវឌ្ឍកំពង់ផែស្ទឹងហាវ និងការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសព្រះសីហនុ។

ជាមួយគ្នានេះ បណ្ដាញផ្លូវជាតិ ផ្លូវខេត្ត ផ្លូវដែលមានតួនាទីជាផ្លូវវាងក្រុង និងផ្លូវដែលបំបែកចេញពីផ្លូវជាតិលេខ៤ចូលក្រុង និងផ្លូវក្នុងក្រុងបានទទួលរងការខូចខាតយ៉ាងខ្លាំងដោយសារការអភិវឌ្ឍយ៉ាងគំហុកនៃវិស័យអចលនទ្រព្យ ការដឹកជញ្ជូនលើសចំណុះ បញ្ហាជំនន់ទឹកភ្លៀង និងកត្តាកកស្ទះចរាចរណ៍ជាប្រចាំ។

រាជរដ្ឋាភិបាលបានសម្រេចអនុវត្តគម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវក្រុងក្នុងខេត្តព្រះសីហនុ គម្រោងអភិវឌ្ឍផ្លូវល្បឿនលឿន និងគម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជាច្រើនទៀតដើម្បីសម្រេចចក្ខុវិស័យនៃការអភិវឌ្ឍខេត្តព្រះសីហនុជាប៉ូលអភិវឌ្ឍជាតិប្រកបដោយចីរភាពនៅតំបន់ឆ្នេរសមុទ្រកម្ពុជា និងជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ស្របតាមផែនការរៀបចំដែនដីខេត្តព្រះសីហនុ គោលនយោបាយជាតិស្ដីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ព្រមទាំងផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យពាក់ព័ន្ធ។ យុទ្ធសាស្ត្រសំខាន់សម្រាប់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេសមានដូចខាងក្រោម៖

### ៤.៣.១-អ័ក្សនៃការអភិវឌ្ឍកសិកម្ម ទេសចរណ៍ និងពាណិជ្ជកម្មតាមផ្លូវជាតិ

- កសាងផ្លូវល្បឿនលឿនសម្រាប់ការធ្វើដំណើរនិងការដឹកជញ្ជូនប្រកបដោយប្រសិទ្ធភាពនិងសុវត្ថិភាពរវាងក្រុងព្រះសីហនុនិងរាជធានីភ្នំពេញ
- ពង្រីកទទឹងទ្រូងផ្លូវជាតិលេខ៤ ជាផ្លូវជាតិដ៏សំខាន់ដែលមានតួនាទីជាអ័ក្សអភិវឌ្ឍកសិកម្ម-ឧស្សាហកម្មដើម្បីសម្រួលចរាចរណ៍ឆ្លើយតបទៅនឹងតម្រូវការនៃការដឹកជញ្ជូនដែលកំពុងតែមានការកើនឡើង
- ពង្រីកកំណាត់ផ្លូវជាតិលេខ៤ចាប់ពីរង្វង់មូលអាកាសយានដ្ឋានអន្តរជាតិដើម្បីភ្ជាប់ជាមួយផ្លូវល្បឿនលឿនចូលមកក្រុងនិងអាកាសយានដ្ឋានអន្តរជាតិឱ្យបានចំនួន៦គន្លងពីចំនួនពាគន្លងទៅ និងចំនួនពាគន្លងមកដើម្បីសម្រួលចរាចរណ៍
- លើកកម្ពស់ប្រសិទ្ធភាពចរន្តការបរិមាណដឹកជញ្ជូននិងការដឹកជញ្ជូនកសិកម្មនាពេលអនាគតតាមរយៈការជំរុញការសាងសង់មូលដ្ឋានកសិកម្មក្នុងតំបន់និងអភិវឌ្ឍមជ្ឈមណ្ឌលចែកចាយ។

### ៤.៣.២-អ័ក្សនៃការអភិវឌ្ឍកសិកម្មនិងឧស្សាហកម្មតាមផ្លូវដែកស្វ័យយានតភ្ជាប់រវាងក្រុងព្រះសីហនុ និងរាជធានីភ្នំពេញ

ផ្លូវដែកស្វ័យយានដែលតភ្ជាប់ពីកំពង់ផែស្វយ័តក្រុងព្រះសីហនុទៅរាជធានីភ្នំពេញគួរធ្វើទំនើបកម្មបន្ថែមដើម្បីក្លាយជាមធ្យោបាយដ៏ល្អប្រសើរសម្រួលនិងជំនួសឱ្យការដឹកជញ្ជូនតាមរថយន្តដឹកអ្នកដំណើរ ទេសចរ និងទំនិញប្រកបដោយប្រសិទ្ធភាពនិងចូលរួមកាត់បន្ថយផលប៉ះពាល់ដល់បរិស្ថាន ការចំណាយ ពេលវេលា និងគ្រោះថ្នាក់ចរាចរណ៍។

យោងតាមផែនការរយៈពេលមធ្យម គោលដៅឆ្នាំ២០៣០ ដែលមានក្នុងផែនការមេផ្លូវដែកប្រទេសកម្ពុជាដែលសិក្សាដោយភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េកាលពីឆ្នាំ២០១៣ ផែនការកែលម្អនិងជួសជុលផ្លូវដែកស្វ័យយានមានដូចខាងក្រោម៖

- រៀបចំផែនការសម្រាប់ប្រវែងផ្លូវដែកស្វ័យយាន២៦០គីឡូម៉ែត្រនៅភាគខាងត្បូងដោយមានស្ថានីយស្វ័យយានចំនួន១៣កន្លែងដែលដំណើរការដោយស្វ័យយានមានល្បឿន១២០គីឡូម៉ែត្រក្នុងមួយម៉ោង
- កាត់បន្ថយប្រវែងផ្លូវដែកស្វ័យយានប្រមាណ៥០គីឡូម៉ែត្រតាមរយៈការកែសម្រួលផ្លូវនៅតំបន់វាលរេញនិងក្រុងព្រះសីហនុ។

### ៤.៣.៣- ផ្លូវថ្នល់និងសេវាទឹកជញ្ជូនសាធារណៈ

#### ក- ផ្លូវថ្នល់

នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចឱ្យគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា អនុវត្តគម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវក្រុងចំនួន៣៤ខ្សែមានប្រវែង ៨៤ ៥០៥ម៉ែត្រចែកចេញជាបីប្រភេទ រួមមានមហាវិថី វិថី និងអនុវិថីស្របតាមតំបន់គោលបំណងក្នុងក្រុង តំបន់ជាយក្រុង តំបន់លំនៅឋាន តំបន់ពាណិជ្ជកម្ម និងតំបន់ទេសចរណ៍ ដោយមានលក្ខណៈបច្ចេកទេសដូចខាងក្រោម៖

- មហាវិថីមានចំនួន៣ខ្សែមានប្រវែង២២ ៧៣១ម៉ែត្រ មានទទឹង៥០ម៉ែត្រ ទ្រូងផ្លូវមានគន្លងផ្លូវរថយន្ត ៦គន្លង និងគន្លងផ្លូវមោចក្រយានយន្ត២គន្លង
- វិថីមានចំនួន១៦ខ្សែមានប្រវែង៤៩ ៩៥៧ម៉ែត្រ មានទទឹងពី២០ទៅ៤០ម៉ែត្រ ទ្រូងផ្លូវមានគន្លងផ្លូវរថយន្ត២ទៅ៤គន្លង និងគន្លងផ្លូវមោចក្រយានយន្ត២គន្លង
- អនុវិថីមានចំនួន១៥ខ្សែមានប្រវែង១១ ៨១៧ម៉ែត្រ មានទទឹងពី១៥ទៅ៤៥ម៉ែត្រ ទ្រូងផ្លូវមានគន្លងផ្លូវរថយន្ត២គន្លង និងគន្លងផ្លូវមោចក្រយានយន្ត២គន្លង
- ស្ពានមានចំនួន៨ទីតាំងមានប្រវែង២៧២ម៉ែត្រ សម្រាប់តភ្ជាប់មហាវិថីនិងវិថី
- រង្វង់មូលមានចំនួន៥ទីតាំងមានរង្វង់មូលព្រះថោងព្រះនាងនាគអង្កត់ផ្ចិត៩៩ម៉ែត្រ រង្វង់មូលព្រះនុមាហេស្វរៈអង្កត់ផ្ចិត៩៩ម៉ែត្រ រង្វង់មូល (ត្រីកោណផ្លូវប្រសព្វ) សីហរាជមុខបី រង្វង់មូល (ត្រីកោណផ្លូវប្រសព្វ) ព្រះស្តុន្មទ្រង់ក្លោក និងកែលម្អរង្វង់មូលនាគកងកេង
- ទ្រូងផ្លូវត្រូវបានសាងសង់ដោយមានគ្រឹះថ្មមាកដាមរឹងមាំ ក្រាលបេតុងសរសៃដែក (RC) កម្រាស់ ០,២៥ម៉ែត្រ និងក្រាលកៅស៊ូ (AC) កម្រាស់០,០៧ម៉ែត្រ មានគំនូសចរាចរណ៍ និងមានខឿនសួនចែកទ្រូងផ្លូវនៅតាមមហាវិថី
- ចិញ្ចើមផ្លូវនិងហេដ្ឋារចនាសម្ព័ន្ធផ្លូវក្រុងរួមមានចិញ្ចើមផ្លូវមានគ្រឹះបេតុងនិងក្រាលថ្មក្រានិតមានផ្ទៃ ៥៣២ ៦២៦,៨៨ម៉ែត្រក្រឡា ខឿនគែមផ្លូវអំពីថ្មក្រានិតមានផ្ទៃ២១១ ៩៤៧,២៤ម៉ែត្រសម្រាប់ជាផ្លូវថ្មើរជើង ផ្លូវជនមានពិការភាព ផ្លូវជិះកង់ និងបណ្តាញបៃតងដោយដាំដើមឈើចំនួន១២ ៦១៨ដើមមានដើមចារ ដើមធ្នង់ ដើមប្ញក្រើក្ស ដើមឥន្ទនេល ដើមរាជព្រឹក្ស ដើមនាងនួន ដើមរំដួល និងដើមក្លោក
- បង្គោលភ្លើងបំភ្លឺផ្លូវចំនួន៤ ៦២៨ដើម ភ្លើងស្តុបចរាចរណ៍ចំនួន៣៤ទីតាំងមាន១៣៤បង្គោល ផ្លាកសញ្ញាចរាចរណ៍១ ៣២៨ផ្លាក និងប្រព័ន្ធឆ្លាតនិងសុវត្ថិភាពចរាចរណ៍ដោយពាក់កាមេរ៉ាសុវត្ថិភាពចំនួន៥៣៦គ្រឿង និងរៀបចំមជ្ឈមណ្ឌលទិន្នន័យសម្រាប់ការគ្រប់គ្រង
- បណ្តាញលូទំនើបដោយញែកដាច់ពីគ្នារវាងទឹកកខ្វក់និងទឹកភ្លៀងនៅសងខាងផ្លូវ ដែលក្នុងនេះលូទឹកកខ្វក់មុខកាត់១ម៉ែត្រចំនួន៧៤ ៩២៣,៦៣ម៉ែត្រ និងលូទឹកភ្លៀងមុខកាត់១ម៉ែត្រចំនួន៨២ ៥៥៦,៥៦ម៉ែត្រ ដើម្បីឆ្លើយតបនឹងដំណោះស្រាយនូវបញ្ហាទឹកជំនន់និងការជន់លិចក្រុង

- កន្លែងកម្សាន្តនិងតំបន់ទេសភាពចំនួន៥កន្លែងមាន "ខ្មែរធ្វើបាន" "ដើមឈើចាំស្នេហ៍" "សិលាចាំស្នេហ៍" ពយអូរឈើទាល និងវិថីតេជោ
- ចំណតរថយន្តសាធារណៈតាមបណ្តោយឆ្នេរសមុទ្របានសាងសង់ហើយចំនួន៨០០ចំណត និងកំពុងរៀបចំជាបន្តបន្ទាប់បន្ថែមនៅឆ្នេរអូរឈើទាលនិងឆ្នេរពយជិតរម៉ៅ
- បង្គន់សាធារណៈតាមបណ្តោយឆ្នេរសមុទ្របានសាងសង់ហើយចំនួន១១ទីតាំងនិងកំពុងរៀបចំជាបន្តបន្ទាប់បន្ថែមស្របតាមតម្រូវការ។

បន្ថែមលើនេះ រាជរដ្ឋាភិបាលបានសម្រេចឱ្យសាងសង់វិថីថ្មីចំនួន៣ខ្សែបន្ថែម ប្រវែង៣ ១៣៤ម៉ែត្រ ដើម្បីតភ្ជាប់ឆ្នេរសមុទ្ររួមមានវិថីតេជោ ប្រវែង១ ០៣៤ម៉ែត្រ វិថីពយអូរឈើទាល ប្រវែង២៥០ម៉ែត្រ និងវិថីឆ្នេរពយជិតរម៉ៅប្រវែង១ ៨៥០ម៉ែត្រ។

ទន្ទឹមនឹងនេះដើម្បីបំពេញបន្ថែមហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅក្នុងក្រុងព្រះសីហនុ រាជរដ្ឋាភិបាលក៏បានសម្រេចឱ្យក្រសួងសាធារណការនិងដឹកជញ្ជូននិងរដ្ឋបាលខេត្តព្រះសីហនុបន្តអនុវត្តគម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ក្នុងក្រុងព្រះសីហនុចំនួន១១ខ្សែ ប្រវែង៥៩ ១៦២ម៉ែត្រដែលក្នុងនេះមានកំណាត់ផ្លូវជាតិលេខ៤ វិថី និងអនុវិថីដូចជាផ្លូវលេខ១៤៦បេ វិថី៧មករាលេខ២០០ អនុវិថីលេខ១០៤ និងអនុវិថីក្នុងក្រុងចំនួន៧ខ្សែផ្សេងទៀតដូចមាននៅក្នុងផែនទីយុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្រុងព្រះសីហនុ ដូចមានឧបសម្ព័ន្ធភ្ជាប់មកជាមួយ។ ការសិក្សាក៏បានបង្ហាញពីគម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ផ្លូវជាយុទ្ធសាស្ត្រជាច្រើនទៀតដើម្បីសម្រេចចក្ខុវិស័យខេត្តព្រះសីហនុជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណងនិងជាប៉ូលអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាព។

រាល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវក្រុង ត្រូវជិះញ្ញលទ្ធភាពរៀបចំបណ្តាញអគ្គិសនី ឬបណ្តាញបញ្ជូនអគ្គិសនី ខ្សែកាប្លិ៍គ្រប់ប្រភេទ កប់ក្នុងដី ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពនិងរក្សាផល់សោភណភាពទីក្រុង។

**ខ-សេវាដឹកជញ្ជូនសាធារណៈ**

ការមិនមានប្រព័ន្ធសេវាដឹកជញ្ជូនសាធារណៈដោយរថយន្តក្រុងដំណើរការនៅក្នុងក្រុងគឺជាមូលហេតុមួយដ៏ចម្បងដែលនាំឱ្យមានការកកស្ទះចរាចរណ៍ ពិសេសនៅត្រង់ផ្លូវប្រសព្វគ្នានិងផ្លូវបំបែកនៅក្នុងក្រុង។ ដើម្បីសម្រួលនិងដោះស្រាយបញ្ហាចរាចរណ៍នៅក្នុងក្រុង ចាំបាច់ត្រូវកសាងផែនការនិងរៀបចំនូវប្រព័ន្ធដឹកជញ្ជូនសាធារណៈដោយរថយន្តក្រុងសម្រាប់ក្នុងក្រុង តំបន់ជុំវិញនិងចេញក្រៅក្រុងទៅកាន់ក្រុងនិងខេត្តផ្សេងៗ។ សម្រាប់ក្រុងព្រះសីហនុ ផែនការនិងទិសដៅសម្រាប់ប្រព័ន្ធដឹកជញ្ជូនសាធារណៈមានដូចខាងក្រោម៖

- សិក្សានិងបង្កើតប្រព័ន្ធដឹកជញ្ជូនសាធារណៈនៅក្នុងក្រុងដើម្បីជួយដោះស្រាយការកកស្ទះចរាចរណ៍រវាងទីប្រជុំជន តំបន់ជុំវិញ និងចរាចរណ៍ទៅកាន់បណ្តាខេត្តនិងក្រុងផ្សេងៗ
- សិក្សាខ្សែដឹកជញ្ជូនសាធារណៈដោយគិតគូរអំពីការភ្ជាប់ទំនាក់ទំនងរវាងតំបន់នៃសកម្មភាពសំខាន់ៗនៅក្នុងក្រុង តំបន់កម្សាន្តមាត់សមុទ្រ តំបន់បេតិកភណ្ឌវប្បធម៌ និងតំបន់ដឹកជញ្ជូនមានជាអាទិ៍ ស្ថានីយអយស្ម័យយាននិងអាកាសយានដ្ឋានអន្តរជាតិ
- រៀបចំបង្កើតខ្សែផ្លូវរថយន្តក្រុងដូចបានកំណត់នៅក្នុងផែនទីយុទ្ធសាស្ត្រអភិវឌ្ឍវិស័យសេវាដឹកជញ្ជូនសាធារណៈដូចមានឧបសម្ព័ន្ធភ្ជាប់មកជាមួយ។

តារាងទី៨៖ គម្រោងខ្សែរថយន្តក្រុងនៅក្រុងព្រះសីហនុនិងតំបន់ជុំវិញ

| ប្រភេទនិងខ្សែរថយន្តក្រុង | | ផែនការបណ្ដាញផ្លូវ |
|---|---|---|
| ខ្សែរថយន្តក្រុងទៅកាន់រាជធានី ខេត្ត ក្រុង | ខ្សែទី១ | តំបន់ក្រុង ⇔ ផ្លូវល្បឿនលឿនភ្នំពេញ-សីហនុ ⇔ ភ្នំពេញទៅភាគខាងជើងប្រទេសកម្ពុជា |
| | ខ្សែទី២ | ផ្លូវជាតិលេខ៤ (ផ្លូវជាតិលេខ៤ ⇔ អាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ ⇔ ភាគខាងត្បូងប្រទេសកម្ពុជានិងប្រទេសវៀតណាម) |
| ខ្សែរថយន្តក្រុងនៅខាងត្បូងនិងខាងជើង (ក្នុងក្រុងនិងតំបន់ជុំវិញ) | | តំបន់ក្រុង ⇔ កំពង់ផែស្វយ័តក្រុងព្រះសីហនុ ⇔ ស្ថានីយប្រេង ⇔ តំបន់សេដ្ឋកិច្ចពិសេសស្ទឹងហាវ ⇔ វាលរេញ |
| ខ្សែរថយន្តក្រុងនៅខាងលិចនិងខាងកើត | ខ្សែទី១ | តំបន់ក្រុង ⇔ ផ្លូវជាតិលេខ៤ (ផ្លូវជាតិលេខ៤ ⇔ តំបន់សេដ្ឋកិច្ចពិសេសព្រះសីហនុ ⇔ អាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ ⇔ វាលរេញ) |
| | ខ្សែទី២ | តំបន់ក្រុង ⇔ តំបន់ទេសចរណ៍មាត់សមុទ្រ (កន្លែងកម្សាន្ត ⇔ ទេសចរណ៍ក្បាលនាគ ⇔ វាលរេញ) |
| ខ្សែរថយន្តក្រុងជុំវិញក្រុង | ខ្សែទី១ | តំបន់ក្រុង ⇔ ផ្លូវកម្មករ ⇔ ផ្លូវមិត្តភាព ⇔ ផ្លូវជាតិលេខ៤ ⇔ តំបន់ក្រុង |
| | ខ្សែទី២ | តំបន់ក្រុង ⇔ ផ្លូវឯករាជ្យ ⇔ សាលាប៉ុនប្ញស្ស ⇔ ក្បាលឆាយ ⇔ ស្ថានីយប្រេង ⇔ កំពង់ផែស្វយ័តក្រុងព្រះសីហនុ ⇔ តំបន់ក្រុង |

### ៤.៣.៤-ផ្លូវដែក

ផ្លូវដែកជាមធ្យោបាយដ៏ល្អប្រសើរជំនួសឱ្យការដឹកជញ្ជូនតាមផ្លូវថ្នល់ដូចជារថយន្តដឹកអ្នកដំណើរ រថយន្តទេសចរណ៍ និងរថយន្តដឹកទំនិញប្រកបដោយប្រសិទ្ធភាពនិងចូលរួមកាត់បន្ថយផលប៉ះពាល់ដល់បរិស្ថាន។ យុទ្ធសាស្ត្រអភិវឌ្ឍផ្លូវដែកតភ្ជាប់ទៅក្រុងព្រះសីហនុមានដូចខាងក្រោម៖

- បង្កើតស្ថានីយអយស្ម័យយានក្នុងក្រុងដោយភ្ជាប់ជាមួយនឹងបរិក្ខារសេវាកម្មផ្សេងៗ អគារពាណិជ្ជកម្ម អគារបម្រើសេវាដឹកជញ្ជូន និងភ្ជាប់ជាមួយនឹងសេវាដឹកជញ្ជូនផ្សេងៗទៀតដូចជារថយន្តក្រុង យានយន្តឯកជន និងយានយន្តដឹកអ្នកដំណើរផ្សេងៗទៀត
- បង្កើនប្រសិទ្ធភាពនៃការដឹកទំនិញចេញពីកំពង់ផែតាមរយៈការតភ្ជាប់ផ្លូវដែកទៅកាន់កំពង់ផែ
- កសាងស្ថានីយអយស្ម័យយាននៅថ្មរាប ដូចដែលមាននៅក្នុងផែនការមេផ្លូវដែកប្រទេសកម្ពុជាដែលនឹងជួយជំរុញដល់មុខងារភស្តុភារកម្ម និងជំរុញការអភិវឌ្ឍនៅតំបន់សេដ្ឋកិច្ចពិសេសស្ទឹងហាវនិងស្ទឹងហាវទាំងមូល។

### ៤.៣.៥-ផ្លូវទឹកនិងកំពង់ផែ

#### ក-កំពង់ផែស្វយ័តក្រុងព្រះសីហនុ

សមុទ្រដើរតួយ៉ាងសំខាន់ក្នុងវិស័យដឹកជញ្ជូនតាមផ្លូវទឹកនៅព្រះរាជាណាចក្រកម្ពុជា និងជាច្រកទ្វារសម្រាប់ការធ្វើពាណិជ្ជកម្មជាអន្តរជាតិនៅលើពិភពលោក។ ជាក់ស្ដែង ខេត្តព្រះសីហនុជាខេត្តដែលមានកំពង់ផែសមុទ្រទឹកជ្រៅតែមួយគត់របស់ប្រទេសកម្ពុជាគឺកំពង់ផែស្វយ័តក្រុងព្រះសីហនុបានដើរតួយ៉ាងសំខាន់ក្នុងការចរាចរណ៍ទំនិញតាមផ្លូវទឹក។ ដោយសេដ្ឋកិច្ចប្រទេសកម្ពុជាមានការរីកចម្រើនយ៉ាងឆាប់រហ័ស បរិមាណទំនិញដែលចរាចរណ៍តាមផ្លូវទឹកនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុមានការកើនឡើងយ៉ាងឆាប់រហ័សដែលបានដាក់សម្ពាធនិងជំរុញឱ្យមានការយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍមុខងាររបស់កំពង់ផែដើម្បីឆ្លើយតបទៅនឹងបរិមាណទំនិញដែលកំពុងតែមានការកើនឡើងនិងត្រូវចរាចរណ៍តាមរយៈកំពង់ផែនេះ។

យោងតាមស្ថិតិពីកំពង់ផែស្វយ័តក្រុងព្រះសីហនុ ឆ្នាំ២០១៧ គម្រោងពង្រីកនិងអភិវឌ្ឍកំពង់ផែនឹងចែកចេញជា៖

- ផែនការអភិវឌ្ឍន៍រយៈពេលខ្លីដល់ឆ្នាំ២០២៣
- ផែនការអភិវឌ្ឍន៍រយៈពេលមធ្យមដល់ឆ្នាំ២០៣០
- ផែនការអភិវឌ្ឍន៍រយៈពេលវែងដល់ឆ្នាំ២០៤០ និងផែនការបន្ត។

តារាងទី៩៖ គម្រោងអភិវឌ្ឍកំពង់ផែស្វយ័តក្រុងព្រះសីហនុតាមដំណាក់កាល

| **ចំណាត់ថ្នាក់តាមដំណាក់កាល** | **ផែនការអភិវឌ្ឍន៍** |
|---|---|
| **រយៈពេលខ្លីដល់ឆ្នាំ២០២៣** | សាងសង់សំណង់ថ្មីដែលមានមុខងារច្រើនយ៉ាង ពង្រីកមុខងារចែកចាយ និងបំពាក់បរិក្ខារសម្រាប់ការចរាចរណ៍ទំនិញ |
| **រយៈពេលមធ្យមដល់ឆ្នាំ២០៣០** | កសាងស្ថានីយថ្មីសម្រាប់កុងតឺន័រដំណាក់កាលទី១ |
| **រយៈពេលវែងដល់ឆ្នាំ២០៤០** | កសាងស្ថានីយថ្មីសម្រាប់កុងតឺន័រដំណាក់កាលទី២ និងទី៣ |
| **បន្ទាប់ពីឆ្នាំ២០៤០** | អភិវឌ្ឍផ្នែកខាងក្នុងនៃទំនប់ទឹកដែលមានស្រាប់ដំណាក់កាលទី១<br>អភិវឌ្ឍផ្នែកខាងក្រៅទំនប់ទឹកដែលមានស្រាប់ដំណាក់កាលទី២ |

ប្រភព៖ កំពង់ផែស្វយ័តក្រុងព្រះសីហនុ ឆ្នាំ២០១៧

### ខ-កំពង់ផែស្ទឹងហាវ

កំពង់ផែស្ទឹងហាវស្ថិតនៅចម្ងាយប្រមាណ១៥គីឡូម៉ែត្រភាគខាងជើងនៃក្រុងព្រះសីហនុដែលផ្តល់សេវាកម្មសម្រាប់ចរាចរណ៍ទំនិញទូទៅ។ យោងតាមផែនការមេសម្រាប់ការអភិវឌ្ឍកំពង់ផែស្ទឹងហាវនិងតំបន់សេដ្ឋកិច្ចពិសេស គម្រោងផែនការសម្រាប់អភិវឌ្ឍន៍កំពង់ផែស្ទឹងហាវនិងតំបន់សេដ្ឋកិច្ចពិសេសមានដូចក្នុងតារាងខាងក្រោម៖

តារាងទី១០៖ ផែនការអភិវឌ្ឍន៍កំពង់ផែស្ទឹងហាវនិងតំបន់សេដ្ឋកិច្ចពិសេស

| **ចំណាត់ថ្នាក់ (ប្រភេទ)** | **ព័ត៌មានលម្អិត** |
|---|---|
| **ស្ថានភាពអនុវត្ត** | ការអនុញ្ញាតរបស់រាជរដ្ឋាភិបាលនិងការរៀបចំតំបន់សេដ្ឋកិច្ចពិសេសសម្រាប់ដំណើរការកំពង់ផែ |
| **ទំហំ** | ផ្ទៃដី១ ១២០ហិកតាសម្រាប់កំពង់ផែនិងតំបន់សេដ្ឋកិច្ចពិសេស |
| **ហេដ្ឋារចនាសម្ព័ន្ធ** | ស្ថានីយប្រេងឥន្ធនៈ សំណង់រោងចក្រឡុងចក្រ និងកំពុងដំណើរការសាងសង់សំណង់ផ្សេងៗ |
| **ផែនការអភិវឌ្ឍន៍** | ស្ថិតក្នុងប្លង់គោលប្រើប្រាស់ដីស្រុកស្ទឹងហាវគឺកំពង់ផែស្ទឹងហាវត្រូវពង្រីក |
| **បញ្ហាសំខាន់ៗ** | ជាកំពង់ផែសមុទ្រទឹកជ្រៅដែលទីតាំងមានភាពងាយស្រួលភ្ជាប់ទៅនឹងផ្លូវដែកមានស្រាប់និងផ្លូវល្បឿនលឿនថ្មី |

ប្រភព៖ ផែនការមេសម្រាប់ការអភិវឌ្ឍកំពង់ផែស្ទឹងហាវនិងតំបន់សេដ្ឋកិច្ចពិសេស

- គម្រោងអភិវឌ្ឍកែលម្អផ្លូវអយស្ម័យយានខ្សែភាគខាងត្បូងដោយឆ្លងកាត់កំពង់ផែស្ទឹងហាវ និងផ្លូវល្បឿនលឿនរាជធានីភ្នំពេញ-ខេត្តព្រះសីហនុត្រូវបានសាងសង់រួចរាល់ពិតជាមានភាពល្អប្រសើរខ្លាំងណាស់សម្រាប់ភ្ជាប់ជាមួយនឹងកំពង់ផែស្ទឹងហាវនិងតំបន់ទីក្រុង
- គម្រោងអភិវឌ្ឍកំពង់ផែស្ទឹងហាវដើម្បីសម្រួលនិងឆ្លើយតបទៅនឹងបរិមាណទំនិញដែលកំពុងតែមានការកើនឡើងនៅខេត្តព្រះសីហនុ ក៏ដូចជាប្រទេសកម្ពុជាទាំងមូល ដូច្នេះការចរាចរណ៍បរិមាណទំនិញដ៏ច្រើននៅខេត្តព្រះសីហនុត្រូវធ្វើការសម្របសម្រួលតាមរយៈការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនទាំងផ្លូវថ្នល់និងផ្លូវទឹករវាងទីក្រុងនិងតំបន់ជុំវិញក្រុង។

### គ-កំពង់ផែទេសចរណ៍

តំបន់ឆ្នេរសមុទ្រខេត្តព្រះសីហនុត្រូវកំណត់ទីតាំងនិងរៀបចំឱ្យមានផែទេសចរណ៍ (ម៉ារីណា) សម្រាប់អ្នកដំណើរនិងភ្ញៀវទេសចរ នៅទីតាំងដែលមិនប៉ះពាល់ដល់ឆ្នេរខ្សាច់កម្សាន្តសាធារណៈនិងទីតាំងហាមឃាត់ស្របតាមបទប្បញ្ញត្តិអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា និងត្រូវមានលិខិតអនុញ្ញាតពីគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ឬគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល ដើម្បីធានាបាននូវកិច្ចការពារបរិស្ថាននិងសុវត្ថិភាពតំបន់ឆ្នេរខ្សាច់កម្សាន្តប្រកបដោយចីរភាព។

### ៤.៣.៦-អាកាសចរស៊ីវិល

ដោយមានការកើនឡើងយ៉ាងឆាប់រហ័សនូវចំនួនអ្នកធ្វើដំណើរនៅអាកាសយានដ្ឋានអន្តរជាតិ គឺជាការបញ្ជាក់អំពីកំណើននៃការអភិវឌ្ឍយ៉ាងឆាប់រហ័សនៅខេត្តព្រះសីហនុ។ ក្នុងឆ្នាំ២០១៧ មានអ្នកដំណើរប្រមាណ ៣៣៨ ០០០នាក់ ហើយចំនួននេះមានការកើនឡើងចំនួនពីរដងរហូតដល់៦៥១ ០០០នាក់នៅឆ្នាំ២០១៨។

ដើម្បីឆ្លើយតបទៅនឹងកំណើនអ្នកធ្វើដំណើរមកកាន់ខេត្តព្រះសីហនុរួមគ្នាជាមួយការដឹកជញ្ជូនភស្តុភារសម្រាប់គោលដៅឆ្នាំ២០៣៨ ក្រុមហ៊ុន Cambodia Airports (VINCI) ដែលជាក្រុមហ៊ុនដំណើរការអាកាសយានដ្ឋានអនុវត្តផែនការសម្រាប់ការអភិវឌ្ឍវិស័យអាកាសចរស៊ីវិលដូចខាងក្រោម៖

– ក្នុងខែមិថុនា ឆ្នាំ២០១៨ ក្រុមហ៊ុន Cambodia Airports (VINCI) បានបញ្ចប់ការកែលម្អបរិក្ខារនៅអាកាសយានដ្ឋានដែលអាចទទួលអ្នកដំណើរចំនួន៥០០ ០០០នាក់ក្នុងមួយឆ្នាំតាមរយៈការពង្រីកស្ថានីយអ្នកដំណើរដែលមានស្រាប់ គម្រោងកែលម្អបរិក្ខារនៅអាកាសយានដ្ឋាន គម្រោងពង្រីកផ្លូវយន្តហោះពី២ ៥០០ម៉ែត្រទៅ៣ ២០០ម៉ែត្រនិងគម្រោងកែលម្អផ្លូវបត់យន្តហោះហោះហើរ
– ក្រុមហ៊ុន Cambodia Airports (VINCI) មានគម្រោងពង្រីកស្ថានីយអ្នកដំណើរទៅទិសខាងត្បូងនៃស្ថានីយអ្នកដំណើរដែលមានស្រាប់ ដូចនេះនឹងអាចបំពេញមុខងារជាអាកាសយានដ្ឋានអន្តរជាតិដែលឆ្លើយតបទៅនឹងចំនួនអ្នកដំណើរដែលត្រូវបានរំពឹងទុកថានឹងមានការកើនឡើងនាពេលអនាគត
– ទន្ទឹមនឹងនេះដើម្បីធ្វើឱ្យផែនការកែលម្អអាកាសយានដ្ឋានអន្តរជាតិកាន់តែមានភាពប្រសើរឡើងក្រុមហ៊ុន ក៏គិតគូរអំពីគម្រោងកសាងសេវាដឹកជញ្ជូនសាធារណៈភ្ជាប់ពីអាកាសយានដ្ឋានអន្តរជាតិទៅកាន់ក្រុងព្រះសីហនុនាពេលអនាគតដើម្បីសម្រួលការធ្វើដំណើររវាងទីក្រុង និងអាកាសយានដ្ឋានអន្តរជាតិនេះ។

| | ២០១៨ | ២០២០ និងឆ្នាំបន្ទាប់ |
|---|---|---|
| គម្រោងកែលម្អ | តាមរយៈការពង្រីកស្ថានីយអ្នកដំណើរដែលមានស្រាប់ គម្រោងកែលម្អបរិក្ខារនៅអាកាសយានដ្ឋាន (បញ្ចប់ខែមិថុនា ឆ្នាំ២០១៨) កែលម្អ ជួសជុល និងធ្វើឱ្យប្រសើរប្រព័ន្ធភ្លើងនិងលូបង្ហូរទឹក | ផ្លូវរថយន្តឈ្នួលថ្មី ចំណតយន្តហោះថ្មី ស្ថានីយអ្នកដំណើរថ្មី ចំណតរថយន្តថ្មី និងបរិក្ខារថ្មីៗ |
| ផែនការ |  |  |

រូបភាពទី៦៖ គម្រោងកែលម្អអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុរបស់ក្រុមហ៊ុន Cambodia Airports (VINCI)

ប្រភព៖ ផែនការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធប្រទេសកម្ពុជា ដោយ KOICA ឆ្នាំ២០១៨

### ៤.៣.៧-ការផ្គត់ផ្គង់ថាមពលនិងអគ្គិសនី

យុទ្ធសាស្ត្រអភិវឌ្ឍវិស័យថាមពលនិងអគ្គិសនីនៅក្រុងព្រះសីហនុមានដូចខាងក្រោម៖

- ជំរុញ ស្តារ និងអភិវឌ្ឍថាមពលនិងអគ្គិសនីដើម្បីគាំទ្រដល់ការអភិវឌ្ឍឧស្សាហកម្ម ទេសចរណ៍ សេដ្ឋកិច្ច និងពាណិជ្ជកម្មដោយធានាបាននូវគុណភាពបរិស្ថានរស់នៅល្អ
- ពង្រីកបន្ថែមបណ្តាញអគ្គិសនីឱ្យដល់គ្រប់ភូមិនិងគ្រប់លំនៅឋាន
- ជំរុញលទ្ធភាពរៀបចំបណ្តាញអគ្គិសនី ឬបណ្តាញបញ្ជូនអគ្គិសនី ខ្សែកាប្លិ៍គ្រប់ប្រភេទ កប់ក្នុងដី ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពនិងរក្សាដល់សោភណភាពទីក្រុង
- បន្តជំរុញលើកទឹកចិត្តឱ្យប្រើប្រាស់អគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យនិងថាមពលធម្មជាតិ
- ជំរុញលើកទឹកចិត្តឱ្យប្រើប្រាស់ប្រព័ន្ធថាមពលឆ្លាត ដូចជាយានយន្តប្រើអាគុយ អំពូលឆ្លាត និងឧបករណ៍អគ្គិសនីនិងសម្ភារៈឆ្លាត។

### ៤.៣.៨-ការផ្គត់ផ្គង់ទឹកស្អាតនិងធនធានទឹក

រោងចក្រផលិតទឹកស្អាតប្រើប្រាស់នៅក្នុងក្រុងព្រះសីហនុបានកសាងឡើងដោយបារាំងនៅក្នុងឆ្នាំ១៩៥៨ ហើយត្រូវបានធ្វើការកែលម្អឡើងវិញដោយរុស្ស៊ីនៅក្នុងឆ្នាំ១៩៨៩ និងក្រោយមកទៀតត្រូវបានពង្រីកបន្ថែមទាំងរោងចក្រផលិតទឹកស្អាត និងតំបន់ទទួលបានទឹកស្អាតប្រើប្រាស់ដោយធនាគារពិភពលោក និងអង្គការ UNDP នៅក្នុងឆ្នាំ២០០៣។

បច្ចុប្បន្នខេត្តព្រះសីហនុកំពុងដំណើការរោងចក្រផលិតទឹកស្អាតរដ្ឋដែលមានលទ្ធភាពអាចផលិតបានប្រមាណ៧ ៦០០ម៉ែត្រគូបក្នុងមួយថ្ងៃនិងរោងចក្រផលិតទឹកស្អាតឯកជនដែលមានលទ្ធភាពអាចផលិតបានប្រមាណ១០ ០០០ម៉ែត្រគូបក្នុងមួយថ្ងៃនិងបានបំពាក់បណ្តាញទុយោរទៅដល់ទីតាំងអ្នកប្រើប្រាស់នៅក្នុងក្រុងព្រះសីហនុ។ សរុបបរិមាណទឹកស្អាតដែលអាចផលិតសម្រាប់ក្រុងព្រះសីហនុគឺ១៧ ៦០០ម៉ែត្រគូបក្នុងមួយថ្ងៃ។

ដោយមានការអភិវឌ្ឍសំខាន់ៗនិងការរីកចម្រើនវិស័យទេសចរណ៍នៅក្នុងក្រុងព្រះសីហនុ តម្រូវការប្រើប្រាស់ទឹកនឹងមានការកើនឡើងដល់២៥% នៅក្នុងឆ្នាំ២០៣៨ ដែលក្នុងនោះនឹងមានការកើនឡើងការប្រើប្រាស់ទឹកសម្រាប់កំណើនទេសចរណ៍ដែលប្រើប្រាស់សម្រាប់សណ្ឋាគារសុខានិងផ្ទះសំណាក់នៅជុំវិញប្រមាណ៦៥០ម៉ែត្រគូបក្នុងមួយថ្ងៃ ការប្រើប្រាស់សម្រាប់រោងចក្រផលិតស្រាបៀរអង្គរ ភេសជ្ជៈ Pepsi និង 7-Up ប្រមាណ ១ ៨០០ម៉ែត្រគូបក្នុងមួយថ្ងៃ ការប្រើប្រាស់សម្រាប់កំពង់ផែស្វយ័តក្រុងព្រះសីហនុ និងរោងចក្រនានានៅជុំវិញប្រមាណ២ ១៥០ម៉ែត្រគូបក្នុងមួយថ្ងៃ និងសម្រាប់តំបន់សេដ្ឋកិច្ចពិសេសនាពេលអនាគតប្រមាណ៦ ០០០ម៉ែត្រគូបក្នុងមួយថ្ងៃ។

ដើម្បីឆ្លើយតបទៅនឹងកំណើននៃការប្រើប្រាស់ទឹកស្អាតនាពេលអនាគត ប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុបានដាក់ចេញនូវយុទ្ធសាស្ត្រសំខាន់ៗសម្រាប់ការផ្គត់ផ្គង់ទឹកស្អាតដូចខាងក្រោម៖

- សិក្សាពីជលសាស្ត្រនិងត្រួតពិនិត្យតាមដានការផ្គត់ផ្គង់និងការប្រើប្រាស់ទឹកដើម្បីធានានូវបរិមាណទឹកស្អាតប្រើប្រាស់ឱ្យបានគ្រប់គ្រាន់និងមានប្រសិទ្ធភាព
- សិក្សាប្រភពទឹកផ្សេងៗដើម្បីផ្គត់ផ្គង់ទឹកស្អាតសម្រាប់តំបន់កណ្តាលក្រុងនិងតំបន់ជាយក្រុង
- រៀបចំបទប្បញ្ញត្តិនិងចាត់វិធានការផ្សេងៗដើម្បីការពារប្រភពផ្គត់ផ្គង់ទឹកក្នុងក្រុងនិងតំបន់ជុំវិញ
- ស្តារឡើងវិញនិងដោះដូរបំពង់ទឹកចាស់ៗដើម្បីកាត់បន្ថយការលេចធ្លាយនិងបង្កើនគុណភាពទឹក

- រក្សា កំណត់ ការពារ និងពង្រីកបន្ថែមទីតាំងប្រភពទឹកស្អាតដើម្បីធានាការផ្គត់ផ្គង់ទឹកស្អាតរួមមានតំបន់ប្រើប្រាស់ច្រើនយ៉ាងក្បាលឆាយ អាងស្តុកទឹកថ្មដា អាងស្តុកទឹកឃុំព្រៃនប់ ឃុំសំរុង ឃុំអណ្តូងថ្ម អាងស្តុកទឹកចង្កេះភ្នំបូកគោ អាងស្តុកទឹកទំនប់រលក អាងស្តុកទឹកទំនប់បង្កៀរឃុំអូរត្រេះ អាងស្តុកទឹករោងចក្រប្រេងកាតឃុំអូរត្រេះ អាងស្តុកទឹកឃុំកែវផុស ប្រភពទឹកស្អាតស្ទឹងអ៊ីនៃឃុំកំពង់សីលា អាងស្តុកទឹកបឹងកង្កែប និងអាងស្តុកទឹកមួយចំនួនទៀតនៅក្នុងខេត្តព្រះសីហនុ
- បន្តពង្រឹងសមត្ថភាពនិងគ្រប់គ្រងដំណើរការថែទាំ ជួសជុល និងការពារបណ្តាញចែកចាយទឹកស្អាតស្របតាមបទដ្ឋានបច្ចេកទេស
- ការពារនិងថែរក្សាប្រភពទឹកធម្មជាតិពីតំបន់ប្រើប្រាស់ច្រើនយ៉ាងព្រែកទឹកសាបក្បាលឆាយដែលជាប្រភពទឹកមានស្ថេរភាពបំផុតទាំងរដូវប្រាំងនិងវស្សាក្នុងការផ្គត់ផ្គង់ទឹកនៅក្រុងព្រះសីហនុនិងតំបន់ជុំវិញ។ នៅក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងព្រែកទឹកសាបក្បាលឆាយកំពុងធ្វើការសាងសង់ទំនប់ទឹកមានមុខងារច្រើនយ៉ាង និងមានសមត្ថភាពស្តុកទឹកប្រមាណ៩ ៣៧៥ ៥០០ម៉ែត្រគូបប្រកបដោយស្ថេរភាពទោះបីជានៅក្នុងរដូវប្រាំងក៏ដោយ។

### ៤.៣.៩- សមាហរណកម្មហេដ្ឋារចនាសម្ព័ន្ធ

យុទ្ធសាស្ត្រអភិវឌ្ឍនិងសមាហរណកម្មហេដ្ឋារចនាសម្ព័ន្ធនៅក្រុងព្រះសីហនុមានដូចខាងក្រោម៖

- ធ្វើសមាហរណកម្មហេដ្ឋារចនាសម្ព័ន្ធបរិស្ថាន សេដ្ឋកិច្ច សង្គម វប្បធម៌ បច្ចេកទេស និងសេវាកម្ម
- ធ្វើសមាហរណកម្មប្រព័ន្ធដឹកជញ្ជូននិងមធ្យោបាយដឹកជញ្ជូនផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស និងទូរគមនាគមន៍
- អាជ្ញាធរមានសមត្ថកិច្ចត្រូវយកចិត្តលើការងារសម្របសម្រួលនិងគ្រប់គ្រងសមាហរណកម្មនេះ។

## ៤.៤- យុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ច

### ៤.៤.១- យុទ្ធសាស្ត្រអភិវឌ្ឍវិស័យទេសចរណ៍

តំបន់ឆ្នេរសមុទ្រដែលស្ថិតនៅក្នុងច្រករបៀងទេសចរណ៍ភាគខាងត្បូងជាតារាងនាទិសនិរតីនៃប្រទេសកម្ពុជារួមមានខេត្តកែប ខេត្តកំពត ខេត្តព្រះសីហនុ និងខេត្តកោះកុងដែលជាប៉ូលទេសចរណ៍ដ៏មានសារៈសំខាន់។ បច្ចុប្បន្នខេត្តព្រះសីហនុបានបំពេញតួនាទីស្នូលក្នុងការជំរុញការអភិវឌ្ឍទេសចរណ៍តំបន់ឆ្នេរសមុទ្រដោយមានការចូលរួមពីគ្រប់វិស័យពាក់ព័ន្ធ។

ក្រុងព្រះសីហនុមានសក្តានុពលទីតាំងភូមិសាស្ត្រ ធនធានធម្មជាតិ ឆ្នេរសមុទ្រ កោះ និងវប្បធម៌ប្រពៃណីដ៏ល្អឯក ដែលជាដើមទុនក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយភាពទាក់ទាញ សម្រាប់ភ្ញៀវទេសចរអន្តរជាតិ មកសម្រាកកម្សាន្តរយៈពេលវែងគ្រប់រដូវកាល។ យុទ្ធសាស្ត្រអភិវឌ្ឍវិស័យទេសចរណ៍ក្រុងព្រះសីហនុផ្តល់ជាសំខាន់លើ៖

#### ក- តំបន់សំណង់ស្ថាបត្យកម្មបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ

ព្រះរាជដំណាក់ជាតំបន់សំណង់ស្ថាបត្យកម្មបេតិកភណ្ឌនិងវប្បធម៌ប្រវត្តិសាស្ត្រដ៏មានតម្លៃនៅក្នុងក្រុងព្រះសីហនុដែលត្រូវធ្វើការការពារនិងអភិរក្សសម្រាប់មនុស្សជំនាន់ក្រោយ។ ការរៀបចំព្រះរាជដំណាក់និងតំបន់ជុំវិញ អាចរក្សាបាននូវអត្តសញ្ញាណនិងបង្កើតជាផលិតផលទេសចរណ៍វប្បធម៌តែមួយគត់សម្រាប់ក្រុងព្រះសីហនុ។ យុទ្ធសាស្ត្រសំខាន់ៗសម្រាប់អភិរក្សនិងអភិវឌ្ឍព្រះរាជដំណាក់និងតំបន់ជុំវិញ មានដូចខាងក្រោម៖

- ការពារសំណង់និងទ្រព្យសម្បត្តិដែលមានស្រាប់នៅក្នុងព្រះរាជដំណាក់
- រៀបចំផែនការគ្រប់គ្រងច្បាស់លាស់និងធ្វើការជួសជុល កែលម្អ និងរៀបចំសោភណភាពឡើងវិញ ដោយរក្សានូវទ្រង់ទ្រាយដើម
- កំណត់និងធ្វើផែនការប្រើប្រាស់ដីលម្អិតតំបន់ជុំវិញព្រះរាជដំណាក់ ដោយបែងចែកជាតំបន់ស្នូល និងតំបន់ទ្រនាប់ក្នុងកាំរង្វង់៥០០ម៉ែត្រនិងត្រូវសិក្សាពីការហាមឃាត់ ការការពារ និងការកែលម្អ
- រៀបចំផែនការអភិវឌ្ឍទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រព្រះរាជដំណាក់ ដោយចាប់ផ្តើមពីយន្តការ និងការគ្រប់គ្រងរហូតដល់ការបង្កើតហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍គាំទ្រ និងការផ្សព្វផ្សាយដល់ភ្ញៀវទេសចរជាតិនិងអន្តរជាតិ
- រៀបចំបង្កើតឱ្យមានក្រុមតន្ត្រីនិងក្រុមរបាំប្រពៃណី ដើម្បីសម្តែងជូនភ្ញៀវទេសចរទស្សនា។

**ខ-តំបន់ទេសចរណ៍ធម្មជាតិ**

យុទ្ធសាស្ត្រអភិវឌ្ឍតំបន់ទេសចរណ៍ធម្មជាតិនៅក្រុងព្រះសីហនុមានដូចខាងក្រោម៖

- ជំរុញរៀបចំកែលម្អ និងគ្រប់គ្រងឆ្នេរសមុទ្រស្របតាមស្តង់ដារបច្ចេកទេសទាំងនៅលើដីគោក និងលើដីកោះ ដើម្បីទាក់ទាញភ្ញៀវទេសចរគ្រប់ប្រភេទ និងគ្រប់ជាតិសាសន៍មកសម្រាកកម្សាន្ត
- ជំរុញកំណត់តំបន់ប្រើប្រាស់ដីឱ្យបានច្បាស់លាស់ នៅឆ្នេរខ្សាច់ ព្រៃក អូរ ព្រៃកោងកាង ព្រៃលិចទឹក តំបន់ឧទ្យានជាតិ និងតំបន់ប្រជុំកោះនានា ដើម្បីមានជាមូលដ្ឋានរឹងមាំគាំទ្រដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍សម្រាប់បង្កើតនិងអភិវឌ្ឍផលិតផលទេសចរណ៍ប្រកបដោយភាពទាក់ទាញ
- រៀបចំចងក្រងនិងបង្កើតសហគមន៍ទេសចរណ៍ដើម្បីជាយន្តការប្រកបដោយប្រសិទ្ធភាព ក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍមូលដ្ឋាន។

**គ-ការអភិវឌ្ឍផលិតផលទេសចរណ៍**

យុទ្ធសាស្ត្រអភិវឌ្ឍផលិតផលទេសចរណ៍នៅខេត្តព្រះសីហនុនិងក្រុងព្រះសីហនុមានដូចខាងក្រោម៖

- ជំរុញអភិវឌ្ឍផលិតផលទេសចរណ៍ឆ្នេរខ្សាច់ សមុទ្រ និងកោះ ក្នុងនោះរួមទាំងការអភិវឌ្ឍទេសចរណ៍ក្រោមទឹកសមុទ្រ និងមុជទឹកសមុទ្រ ព្រមទាំងទេសចរណ៍ធម្មជាតិ ដូចកំណត់ក្នុងចំណុច (ខ)
- ជំរុញអភិវឌ្ឍផលិតផលទេសចរណ៍កីឡាលើទឹកសមុទ្រ ពិសេសហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ការរៀបចំព្រឹត្តិការណ៍កីឡាទេសចរណ៍លើទឹកសមុទ្រ
- ជំរុញលើកទឹកចិត្តដល់ការវិនិយោគអភិវឌ្ឍទេសចរណ៍ផ្ទះទី២ និងទេសចរណ៍សុខភាព
- ជំរុញកែលម្អនិងអភិវឌ្ឍកំពង់ផែទេសចរណ៍ខ្នាតអន្តរជាតិ ដែលអាចទទួលកប៉ាល់ប្រវែងលើសពី ១០០ម៉ែត្រ ចំណតយន្តហោះលើទឹក និងម៉ារីណាទេសចរណ៍ស្របតាមស្តង់ដារអន្តរជាតិ ដើម្បីទាក់ទាញភ្ញៀវទេសចរតាមកប៉ាល់និងតាមទូកឯកជន
- ជំរុញនិងលើកទឹកចិត្តដល់ការអភិវឌ្ឍបង្កើតតំបន់ទេសចរណ៍ពិសិដ្ឋស្របតាមអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៩
- រៀបចំផលិតផលកសិ-ទេសចរណ៍ ពិសេសការដាំដុះបន្លែ ផ្លែឈើសុវត្ថិភាពតាមបែបកំណើត និងការចិញ្ចឹមសត្វសម្រាប់ផ្គត់ផ្គង់ភ្ញៀវទេសចរ ដើម្បីចូលរួមកាត់បន្ថយការផ្ទេរឆ្លងសេដ្ឋកិច្ចក្នុងវិស័យទេសចរណ៍

- ជំរុញអភិវឌ្ឍផលិតផលទេសចរណ៍កម្រិតខ្ពស់ មានដូចជាទេសចរណ៍វាយកូនហ្គោល និងប្រភេទទេសចរណ៍ MICE ជាដើម
- ជំរុញដល់ការរៀបចំព្រឹត្តិការណ៍ទេសចរណ៍ជាតិនិងអន្តរជាតិ
- រៀបចំផែនការអភិវឌ្ឍតំបន់រមណីយដ្ឋានទេសចរណ៍សំខាន់ៗដែលមានស្រាប់ក្នុងក្រុងព្រះសីហនុ
- ជំរុញក្រុមហ៊ុនវិនិយោគដែលទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលឱ្យពន្លឿនការអភិវឌ្ឍរបស់ខ្លួនតាមផែនការមេដែលបានអនុម័ត។

**ឃ-ខ្សែទស្សនកិច្ចទេសចរណ៍និងហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍**

យុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍខ្សែទស្សនកិច្ចទេសចរណ៍និងហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ នៅក្រុងព្រះសីហនុមានដូចខាងក្រោម៖

- ជំរុញដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍គាំទ្រដល់ការអភិវឌ្ឍផលិតផលទេសចរណ៍និងការតភ្ជាប់ជាកញ្ចប់ទស្សនកិច្ចទេសចរណ៍ពីតំបន់កម្សាន្តមួយទៅតំបន់កម្សាន្តមួយ
- ជំរុញដល់ការកំណត់ និងបង្កើតតំបន់ដែលអាចអភិវឌ្ឍចំណតរថយន្តទូទៅ និងចំណតសម្រាប់រថយន្តការ៉ាវ៉ាន់
- ជំរុញការតភ្ជាប់ច្រករបៀងទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជា និងភាគខាងត្បូងតំបន់អាស៊ានតាមផ្លូវសមុទ្រ
- ជំរុញការធ្វើទំនើបកម្មបណ្តាញតភ្ជាប់ផ្លូវដែកពីក្រុងព្រះសីហនុ ទៅខេត្តតំបន់ឆ្នេរសមុទ្រផ្សេងៗទៀត និងភ្ជាប់ទៅរាជធានីភ្នំពេញ។

**ង-ការសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍**

ដើម្បីជំរុញការទាក់ទាញទេសចរណ៍ជាតិនិងអន្តរជាតិមកទស្សនានៅតំបន់ឆ្នេរសមុទ្រ "តារារះនាទិសនិរតី" ពិសេសឆ្នេរសមុទ្រក្រុងព្រះសីហនុឱ្យកាន់តែមានសន្ទុះរីកចម្រើនថែមទៀត យុទ្ធសាស្ត្រសំខាន់ៗមួយចំនួនត្រូវអនុវត្តមានដូចខាងក្រោម៖

- ជំរុញការសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍ឱ្យបានសកម្ម សហការជាមួយផ្នែកឯកជនក្នុងការផលិតឯកសារផ្សព្វផ្សាយនិងសកម្មភាពផ្សព្វផ្សាយទាំងក្នុងនិងក្រៅប្រទេស
- រៀបចំមជ្ឈមណ្ឌលផ្សព្វផ្សាយ មណ្ឌលព័ត៌មានទេសចរណ៍ គេហទំព័រតំបន់ឆ្នេរសមុទ្រ និងចាំបាច់ត្រូវតភ្ជាប់ជាមួយគេហទំព័ររបស់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល អនុតំបន់ និងតំបន់។ល។
- ជំរុញអភិវឌ្ឍទីផ្សារទេសចរណ៍បៃតងនិងបង្កើតឱ្យមានផ្សាររាត្រី
- ជំរុញកិច្ចសហការជាមួយវិស័យពាក់ព័ន្ធលើការរៀបចំខ្សែទស្សនកិច្ចនៅក្នុងតំបន់ឆ្នេរសមុទ្រកម្ពុជាតភ្ជាប់ទៅប្រទេសជិតខាងនិងជំរុញការផ្សព្វផ្សាយកម្មវិធីនេះ
- ជំរុញកិច្ចសហការជាមួយក្រុមហ៊ុនភាពយន្តនិងក្រុមហ៊ុនផ្សាយពាណិជ្ជកម្មដើម្បីរៀបចំព្រឹត្តិការណ៍ទេសចរណ៍នានានៅក្នុងក្រុង
- ជំរុញការឃោសនាផ្សព្វផ្សាយនិងទាក់ទាញឱ្យមានការបោះបើរត្រង់និងតារាតារាទេសចរណ៍មកក្រុងព្រះសីហនុឱ្យបានច្រើន។

**ច-សុវត្ថិភាពទេសចរណ៍**

សុវត្ថិភាពទេសចរណ៍គឺជាកត្តាដ៏សំខាន់ក្នុងការផ្តល់ទំនុកចិត្តនិងភាពកក់ក្តៅដើម្បីទាក់ទាញភ្ញៀវទេសចរមកកម្សាន្តនៅក្រុងព្រះសីហនុ។ យុទ្ធសាស្ត្រសម្រាប់ពង្រឹងសុវត្ថិភាពទេសចរណ៍ មានដូចខាងក្រោម៖

- បន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយគ្រប់ភាគីពាក់ព័ន្ធ ដើម្បីពង្រឹងសន្តិសុខ និងសុវត្ថិភាពនៅក្នុងទីក្រុងក៏ដូចជាគោលដៅកម្សាន្តនានាទាំងនៅលើដីគោក និងនៅលើទឹក ដោយមានយន្តការបង្ការ និងឆ្លើយតបទាន់ពេលវេលា
- បន្តពង្រឹងដល់សុវត្ថិភាពចំណីអាហារ និងអនាម័យនៅតាមបណ្តាភោជនីយដ្ឋាន និងអាហារដ្ឋាន
- បន្តពង្រឹងការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ឱ្យបានម៉ឺងម៉ាត់នៅគ្រប់គោលដៅកម្សាន្ត និងគ្រប់មូលដ្ឋានអាជីវកម្មទេសចរណ៍។

**ឆ-ការអភិវឌ្ឍធនធានមនុស្ស**

ការអភិវឌ្ឍធនធានមនុស្ស ជាកត្តាសំខាន់និងកត្តាអាទិភាពបំផុត ដើម្បីគាំទ្រដល់ការរីកចម្រើនវិស័យទេសចរណ៍នៅក្រុងព្រះសីហនុទាំងកម្រិតគ្រប់គ្រងនិងកម្រិតជំនាញ។ យុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍធនធានមនុស្ស មានដូចខាងក្រោម៖

- ជំរុញនិងលើកទឹកចិត្តដល់ការបង្កើតមហាវិទ្យាល័យទេសចរណ៍ស្តង់ដាអន្តរជាតិ សម្រាប់ការបណ្តុះបណ្តាលកម្រិតឧត្តមសិក្សានិងក្រោយឧត្តមសិក្សា
- ជំរុញដល់ការបង្កើតសាលាជំនាញវិជ្ជាជីវៈទេសចរណ៍តំបន់ឆ្នេរសមុទ្រគ្រប់ជំនាញ ដោយផ្សារភ្ជាប់ទ្រឹស្តីជាមួយនឹងការអនុវត្តជំនាញផ្ទាល់
- លើកទឹកចិត្តដល់មូលដ្ឋានអាជីវកម្មទេសចរណ៍ដើម្បីផ្តល់ឱកាសដល់បុគ្គលិកក្នុងការបណ្តុះបណ្តាលបន្ថែមពង្រឹងនិងអភិវឌ្ឍសមត្ថភាពជំនាញជាប្រចាំតាមរយៈអនឡាញនិងការបណ្តុះបណ្តាលផ្ទាល់
- ជំរុញនិងពង្រឹងដល់ការសិក្សាជំនាញវិជ្ជាជីវៈទេសចរណ៍នៅតាមវិទ្យាល័យ។

### ៤.៤.២-យុទ្ធសាស្ត្រអភិវឌ្ឍវិស័យឧស្សាហកម្ម

វិស័យឧស្សាហកម្មគឺជាវិស័យដ៏សំខាន់ដែលចូលរួមដល់ការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងខេត្តព្រះសីហនុ។ ក្នុងឆ្នាំ២០១៨ តំបន់ឧស្សាហកម្មនៅក្នុងក្រុងព្រះសីហនុនិងតំបន់ជុំវិញគ្របដណ្តប់លើផ្ទៃដីប្រមាណ៨២៩ហិកតា។ សម្រាប់ប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុនិងតំបន់ជុំវិញ ចក្ខុវិស័យឆ្នាំ២០៣៨ តំបន់ឧស្សាហម្មត្រូវបានធ្វើការព្យាករណ៍និងកំណត់ទំហំ១ ៦០២,១៤ហិកតាស្មើនឹង១០,២០% នៃប្រភេទដីអាចសាងសង់បាន។ យុទ្ធសាស្ត្រសំខាន់ៗសម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្មក្រុងព្រះសីហនុត្រូវបានកំណត់ដូចខាងក្រោម៖

**ក-លើកកម្ពស់ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសនិងវិស័យឧស្សាហកម្មបច្ចេកវិទ្យាទំនើបសម្រាប់ការនាំចេញ**

- លើកកម្ពស់និងជំរុញការកែលម្អនិងការពង្រឹងគម្រោងតំបន់សេដ្ឋកិច្ចពិសេស
- ជំរុញលើកទឹកចិត្តនិងគាំទ្រដល់ការជ្រើសរើសយកប្រភេទនៃឧស្សាហកម្មដែលមានសក្តានុពលសម្រាប់ទិសដៅនាំចេញ

- លើកកម្ពស់ការប្រកួតប្រជែងរវាងតំបន់សេដ្ឋកិច្ចពិសេសនិងតំបន់ឧស្សាហកម្មនានានៅក្នុងខេត្តដោយសិក្សានូវស្ថានភាពការស្នូលសម្រាប់វាស់ស្ទង់សមិទ្ធិកម្មនៃកិច្ចដំណើរការនៃតំបន់សេដ្ឋកិច្ចពិសេសនិងឧស្សាហកម្មទាំងនោះសម្រាប់ជាលក្ខណៈវិនិច្ឆ័យក្នុងការផ្តល់ការលើកទឹកចិត្ត
- គាំទ្រដល់ការសិក្សាបង្កើតសួនឧស្សាហកម្មសម្រាប់សហគ្រាសធុនតូចនិងមធ្យមសំដៅជំរុញការតភ្ជាប់រវាងសហគ្រាសធំបរទេសនិងសហគ្រាសក្នុងស្រុក ពិសេសការចូលរួមក្នុងខ្សែច្រវាក់តម្លៃនិងច្រវាក់ផលិតកម្ម។

**ខ-លើកកម្ពស់ការអភិវឌ្ឍវិស័យឧស្សាហកម្មកែច្នៃផលិតផលក្នុងស្រុកនិងពង្រីកហេដ្ឋារចនាសម្ព័ន្ធដើម្បីបង្កើនចំណូលដល់អ្នកនៅជនបទ**

- ជំរុញនិងគាំទ្រការបង្កើតបង្កើនបណ្តាញទំនាក់ទំនងរវាងតំបន់ឧស្សាហនីយកម្ម ពង្រីកបច្ចេកវិទ្យាហេដ្ឋារចនាសម្ព័ន្ធ និងផលិតផលកសិកម្មសម្រាប់ធ្វើការកែច្នៃនិងចែកចាយ
- ធ្វើការសម្របសម្រួលការវិនិយោគនៅក្នុងច្រវាក់ផលិតកម្មនិងការផ្គត់ផ្គង់ដំណាំឧស្សាហកម្មដែលមានតម្លៃខ្ពស់និងវិនិយោគទៅលើផលិតផលនិងធនធាននៅតាមតំបន់តាមរយៈឧស្សាហកម្មកែច្នៃចំណីអាហារ
- ជំរុញ គាំទ្រ និងលើកទឹកចិត្តចំពោះការកាត់បន្ថយការលក់ផលិតផលដើមដូចជាស្រូវទៅកាន់ប្រទេសជិតខាងដែលប្រទេសទាំងនោះធ្វើការកែច្នៃនិងនាំចេញទៅប្រទេសទីបីដោយប្តូរមកធ្វើការអភិវឌ្ឍនូវឧស្សាហកម្មកែច្នៃអាហារសម្រាប់ផលិតផលកសិកម្មនិងផលិតកម្មផ្សេងៗនិងការបន្ថែមតម្លៃបន្ថែមលើផលិតផលដើម្បីពង្រឹងការប្រកួតប្រជែងសម្រាប់ការនាំចេញ
- ជំរុញ គាំទ្រ លើកទឹកចិត្ត និងពិនិត្យលទ្ធភាពបង្កើតនូវតំបន់កែច្នៃកសិផលដូចជាតំបន់កែច្នៃផលិតសង្ហារឹម តំបន់កែច្នៃផលិតម្ហូបអាហារពីសមុទ្រ តំបន់កែច្នៃចំណីអាហារសម្រាប់គោលដៅប្រើប្រាស់ក្នុងស្រុកផងនិងនាំចេញផងដោយប្រើប្រាស់យន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន ព្រមទាំងផ្តល់ការលើកទឹកចិត្តចំពោះក្រុមហ៊ុនណាដែលបោះទីតាំងក្នុងតំបន់ទាំងនោះ
- គាំទ្រការបង្កើតមូលនិធិសម្រាប់ជំរុញការអភិវឌ្ឍផលិតផល បច្ចេកទេសកែច្នៃកសិផល និងអភិវឌ្ឍបច្ចេកទេសដោយភ្ជាប់ទៅនឹងសក្តានុពលនាំចេញ
- សិក្សាកំណត់នូវមុខទំនិញអាទិភាពដែលមានសក្តានុពលកែច្នៃសម្រាប់នាំចេញ ហើយរៀបចំផែនការសកម្មភាពដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយដោយផ្អែកលើខ្សែច្រវាក់តម្លៃដើម្បីកំណត់មូលដ្ឋានគាំទ្រជាក់លាក់ដល់ការអភិវឌ្ឍវិស័យទាំងនោះ
- រៀបចំនូវយន្តការសម្រួលដល់ការនាំចេញកសិផលកែច្នៃ ដោយដោះស្រាយបញ្ហាភស្តុភារកម្ម និងកែលម្អការសម្រួលពាណិជ្ជកម្ម
- ជំរុញ គាំទ្រ និងលើកទឹកចិត្តចំពោះការភ្ជាប់ទំនាក់ទំនងដោយផ្ទាល់រវាងអ្នកលក់និងអ្នកទិញ។

**គ-ពង្រឹងនិងលើកស្ទួយរចនាសម្ព័ន្ធឧស្សាហកម្មនិងតម្លៃបន្ថែមលើផលិតកម្ម**

- ជំរុញ គាំទ្រ និងលើកទឹកចិត្តចំពោះការរៀបចំតំបន់រោងចក្រដែលមានស្រាប់ឡើងវិញដោយធ្វើការកែប្រែទៅជាឧស្សាហកម្មដែលបន្ថែមតម្លៃបន្ថែមខ្ពស់លើផលិតផលតាមរយៈការពង្រឹងនិងកែលម្អឡើងវិញនូវរចនាសម្ព័ន្ធឧស្សាហកម្មដែលមានស្រាប់

- ឧស្សាហកម្មកាត់ដេរនិងវាយនភណ្ឌ បានចូលរួមយ៉ាងសំខាន់នៅក្នុងកំណើនសេដ្ឋកិច្ចប្រទេសកម្ពុជា ប៉ុន្តែវិស័យនេះពឹងផ្អែកទៅលើការនាំចូលនូវវត្ថុធាតុដើមដែលជាកត្តាដែលនាំឱ្យមានផលប៉ះពាល់ដល់សេដ្ឋកិច្ចនៅក្នុងតំបន់។ ដូច្នេះគឺមានសារសំខាន់ណាស់ក្នុងការពង្រឹងការប្រកួតប្រជែងផ្នែកវាយនភណ្ឌតាមរយៈការពង្រឹងបច្ចេកវិទ្យានៃការផលិតនិងការប្រើប្រាស់វត្ថុធាតុដើមនៅក្នុងស្រុក
- ពង្រឹងការទាក់ទាញការវិនិយោគទាំងក្នុងស្រុកនិងក្រៅប្រទេសចូលមកវិនិយោគ ជាពិសេសនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ដើម្បីទាញយកនូវបច្ចេកវិទ្យាទំនើបនិងការគ្រប់គ្រងតាមបែបបច្ចេកវិទ្យាទំនើប។

## ឃ- ថែទាំនិងពង្រីកហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្មនិងអភិវឌ្ឍប្រព័ន្ធភស្តុភារកម្ម

- ជំរុញការរៀបចំនិងអនុវត្តផែនការមេសម្រាប់ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូននិងភស្តុភារកម្មក្នុងគោលដៅបង្កើតប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយនិងប្រព័ន្ធភស្តុភារកម្មដែលមានសមាហរណកម្មនិងប្រសិទ្ធភាពខ្ពស់ ពិសេសផ្តោតលើការតភ្ជាប់ប៉ូលអភិវឌ្ឍនិងអ័ក្សនៃការអភិវឌ្ឍភ្នំពេញ-ព្រះសីហនុឱ្យក្លាយទៅជាអ័ក្សនៃការអភិវឌ្ឍគន្លឹះរបស់ជាតិតាមរយៈការកសាងផ្លូវល្បឿនលឿន និងការបង្កើតប្រព័ន្ធភស្តុភារកម្មប្រកបដោយប្រសិទ្ធភាព
- ជំរុញគាំទ្រកសាងប្លង់មេភស្តុភារកម្មដឹកជញ្ជូន
  - កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដូចជាផ្លូវនិងស្ពាន
  - កសាងប្រព័ន្ធភស្តុភារកម្មតាមរយៈការតភ្ជាប់និងសមាហរណកម្មជាមួយនឹងបរិក្ខារដែលមានស្រាប់។
- ជំរុញ គាំទ្រ និងលើកកម្ពស់តម្រង់ទិសការផ្គត់ផ្គង់អគ្គិសនីនិងទឹកស្អាតទៅកាន់តំបន់ឧស្សាហកម្មនិងផលិតកម្មសំខាន់ៗនៅក្នុងក្រុងនិងខេត្តដោយធានាឱ្យបានតាមតម្រូវការនិងស្មើរភាពជាមួយតម្លៃសមរម្យដែលអនុញ្ញាតឱ្យរោងចក្រអាចដំណើរការផលិតកម្មរបស់ខ្លួនដោយប្រសិទ្ធភាព
- ជំរុញ គាំទ្រ និងលើកកម្ពស់ចំពោះផែនការបញ្ចុះថ្លៃអគ្គិសនីសម្រាប់វិស័យឧស្សាហកម្មនិងពាណិជ្ជកម្មរួមទាំងការពង្រឹងភាពទុកចិត្តនិងការពង្រីកវិសាលភាពគ្របដណ្តប់នៃការផ្គត់ផ្គង់អគ្គិសនី
- លើកកម្ពស់ការពង្រីកបណ្តាញបច្ចេកវិទ្យាព័ត៌មាន ទូរគមនាគមន៍ និងបច្ចេកវិទ្យាទំនើបដទៃទៀត (ICT)ដើម្បីត្រៀមឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មទី៤
- កំពង់ផែស្វយ័តក្រុងព្រះសីហនុជាកំពង់ផែទឹកជ្រៅដែលជាច្រកសំខាន់បំផុតសម្រាប់ការនាំចេញនាំចូលទំនិញក្នុងប្រទេស។ ដូច្នេះត្រូវធ្វើការពង្រឹងមុខងារនៃការដឹកជញ្ជូនរបស់កំពង់ផែនេះនិងពង្រឹងការប្រកួតប្រជែងជាមួយនឹងកំពង់ផែអន្តរជាតិនៃប្រទេសជិតខាង
- លើកកម្ពស់ការអភិវឌ្ឍនិងកែលម្អប្រព័ន្ធដឹកជញ្ជូនផ្លូវថ្នល់ ផ្លូវដែក ផ្លូវអាកាស និងភ្ជាប់ទំនាក់ទំនងសមាហរណកម្មផ្លូវទាំងអស់ជាមួយគ្នានិងភ្ជាប់ទៅតំបន់សំខាន់ដទៃទៀត មានកំពង់ផែក្រុងព្រះសីហនុ តំបន់ស្ទឹងហាវតំបន់សេដ្ឋកិច្ចពិសេស តំបន់បិតត្រាង និងអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ។

## ង- លើកកម្ពស់ការអប់រំ អភិវឌ្ឍធនធានមនុស្ស ទំនាក់ទំនងវិជ្ជាជីវៈ និងទីផ្សារពលកម្មដើម្បីទាក់ទាញការវិនិយោគនិងគាំទ្រដល់វិស័យឧស្សាហកម្ម

- ជំរុញនិងកសាងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈលើជំនាញអាទិភាព

- លើកកម្ពស់ការកសាងធនធានមនុស្សដើម្បីជំរុញការអភិវឌ្ឍឧស្សាហកម្មឱ្យមានភាពរឹងមាំដោយផ្តល់ការហ្វឹកហាត់លើជំនាញឯកទេសសម្រាប់ដោះស្រាយកង្វះខាតជំនាញលើវិស័យអាទិភាព
- ពង្រឹងសមត្ថភាពនិងសហគ្រិនភាពនៃសហគ្រាសធុនតូចនិងមធ្យមដើម្បីអាចផ្សារភ្ជាប់និងទាញយកផលប្រយោជន៍ពីសក្តានុពលសហគ្រាសនិងវិនិយោគបរទេសធំៗស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេស
- ជំរុញនិងជួយគាំទ្រដល់ការផ្ទេរបច្ចេកវិទ្យាតាមរយៈទស្សនកិច្ចសិក្សានិងការបណ្តុះបណ្តាលពីក្នុងប្រទេសនិងពីបណ្តាប្រទេសនានា
- ជំរុញនិងបន្តពង្រឹងយន្តការទំនាក់ទំនងរវាងត្រីភាគីរួមមានរាជរដ្ឋាភិបាល និយោជក និងនិយោជិតតាមរយៈគណៈកម្មាធិការប្រឹក្សាការងារដើម្បីបង្កើនការយោគយល់គ្នានិងការរៀបចំប្រព័ន្ធយន្តការមួយប្រកបដោយប្រសិទ្ធភាពសម្រាប់កំណត់ប្រាក់ឈ្នួលអប្បបរមាដែលស៊ីសង្វាក់ទៅនឹងផលិតភាពការងារសមស្របតាមលក្ខខណ្ឌសេដ្ឋកិច្ច សង្គម
- ពង្រឹងយន្តការជ្រើសរើសកម្លាំងពលកម្ម ការផ្តល់ព័ត៌មានពីទីផ្សារពលកម្ម និងការបណ្តុះបណ្តាលកម្មករឱ្យយល់ដឹងពីជីវភាពនិងសិទ្ធិស្របច្បាប់របស់ខ្លួន
- លើកកម្ពស់សុខុមាលភាពកម្មករតាមរយៈការជំរុញអនុវត្តគោលនយោបាយលំនៅឋានសម្រាប់កម្មករដែលអនុញ្ញាតឱ្យកម្មករអាចមានលទ្ធភាពធ្វើជាម្ចាស់កម្មសិទ្ធិលំនៅឋានសម្រាប់បង្កើតគ្រួសារ និងមិនធ្វើការផ្លាស់ប្តូរទីលំនៅញឹកញាប់ពេកដែលបង្កើតបញ្ហាខ្វះកម្លាំងពលកម្មក្នុងរយៈពេលខ្លី
- ពង្រឹងយន្តការគ្រប់គ្រងកម្មករជំនាញដើម្បីត្រៀមលក្ខណៈឱ្យបានល្អប្រសើរសម្រាប់ឧស្សាហកម្មនិងសហគ្រាសខ្នាតធំនិងសមាហរណកម្មអាស៊ាន
- ជំរុញការកសាងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីបណ្តុះបណ្តាលជំនាញឆ្លើយតបទៅនឹងតម្រូវការជំនាញមូលដ្ឋានផ្នែកកុំព្យូទ័រ ជំនាញព័ត៌មានវិទ្យា ជំនាញគ្រប់គ្រងជំនួញនិងធុរកិច្ច និងជំនាញផ្សេងៗទៀតដែលពាក់ព័ន្ធដើម្បីឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មទី៤
- ពង្រឹងផលិតភាពនិងការប្រកួតប្រជែងឧស្សាហកម្មតាមរយៈការផ្លាស់ប្តូរបន្តិចម្តងៗពីឧស្សាហកម្មដែលប្រើប្រាស់កម្លាំងពលកម្មច្រើនទៅជាឧស្សាហកម្មដែលប្រើបច្ចេកវិទ្យាព័ត៌មាន ទូរគមនាគមន៍និងបច្ចេកវិទ្យាទំនើបផ្សេងទៀត (ICT)
- ជំរុញ គាំទ្រ និងលើកទឹកចិត្តចំពោះការរៀបចំបង្កើតគោលនយោបាយអភិវឌ្ឍយុទ្ធសាស្ត្រដើម្បីជួយគាំទ្រដល់សហគ្រាសខ្នាតតូចនិងមធ្យម។

**ច- គោរពគោលការណ៍ណែនាំនិងបទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រដូចមានកំណត់នៅក្នុងចំណុច៤.១.២- យុទ្ធសាស្ត្រអភិរក្សនិងអភិវឌ្ឍនគរូបនីយកម្មតំបន់ឆ្នេរសមុទ្រ។**

### ៤.៤.៣- យុទ្ធសាស្ត្រអភិវឌ្ឍវិស័យកសិកម្ម

យុទ្ធសាស្ត្រអភិវឌ្ឍកសិកម្មនិងផ្សព្វផ្សាយផលិតផលក្នុងស្រុកនៅក្រុងព្រះសីហនុមានដូចខាងក្រោម៖

- ជំរុញ គាំទ្រ និងធានាដល់ការអភិរក្សធនធានជលផល កន្លែងត្រីពង និងផលិតផលកសិកម្ម
- ជំរុញរៀបចំឱ្យមានកន្លែងចិញ្ចឹមត្រីតាមបែបធម្មជាតិស្របតាមតម្រូវការទីផ្សារ

- បង្កើនគុណភាពផលិតផលនិងផ្សព្វផ្សាយអំពីផលិតផលផ្សេងៗដែលផលិតដោយកសិករនៅមូលដ្ឋាន ឬអ្នកជំនួញក្នុងស្រុកតាមរយៈភាពជាដៃគូរវាងរដ្ឋនិងឯកជន និងលក់ផលិតផលទាំងនេះទៅឱ្យភ្ញៀវទេសចរ
- បង្កបរិយាកាសល្អ លើកទឹកចិត្ត និងជំរុញការវិនិយោគក្នុងស្រុកនិងក្រៅស្រុកលើវិស័យកសិកម្មនិងវារីវប្បកម្មប្រកបដោយចំណេះដឹងដោយផ្អែកលើធនធានសមុទ្រដើម្បីគាំទ្រដល់វិស័យទេសចរណ៍ និងអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងក្រុង
- ពិនិត្យលទ្ធភាពក្នុងការកំណត់ទីតាំង រៀបចំ និងអភិវឌ្ឍតំបន់កសិកម្មតាមភូមិផ្សារភ្ជាប់ជាមួយទេសចរណ៍
- គាំទ្រ ពង្រឹង និងពង្រីកការកែច្នៃនិងវេចខ្ចប់ធនធានសមុទ្រសម្រាប់ទីផ្សារក្នុងស្រុកនិងការនាំចេញ
- ពង្រឹងនិងពង្រីកធនធានជលផលមានដូចជាធនាគារក្តាមនិងគ្រឿងសមុទ្រដទៃទៀត
- ធ្វើសមាហរណកម្មសេដ្ឋកិច្ចជនបទនៅក្នុងវិស័យទេសចរណ៍ដើម្បីលើកកម្ពស់ទំនិញសហគមន៍តាមរយៈភូមិមួយផលិតផលមួយនិងបង្កើតភូមិផលិតកម្មបម្រើភ្ញៀវទេសចរនិងរៀបចំដំណើរកម្សាន្ត
- អភិវឌ្ឍផលិតផលកសិកម្មតាមតម្រូវការទីផ្សារទេសចរណ៍
- សិក្សាទីផ្សារនិងផ្សព្វផ្សាយផលិតផលកសិកម្មដែលមានគុណភាពល្អក្នុងស្រុក
- រៀបចំមជ្ឈមណ្ឌលផ្សព្វផ្សាយនិងមណ្ឌលព័ត៌មានអំពីស្តង់ដាបច្ចេកទេសកសិកម្មដល់ប្រជាជន។

## ៤.៥-យុទ្ធសាស្ត្រអភិវឌ្ឍសង្គមកិច្ច

### ៤.៥.១-វិស័យអប់រំ

យុទ្ធសាស្ត្រអភិវឌ្ឍវិស័យអប់រំនៅក្រុងព្រះសីហនុមានដូចខាងក្រោម៖

- លើកកម្ពស់ការថែរក្សាបរិក្ខារនិងសេវាអប់រំដែលមានស្រាប់នៅតំបន់ទីប្រជុំជននិងកសាងបរិក្ខារអប់រំថ្មីនៅតំបន់ជុំវិញទីប្រជុំជន តំបន់ជាយក្រុង និងតំបន់ដែលខ្វះខាត
- ជំរុញនិងលើកកម្ពស់ដល់ការអប់រំធនធានមនុស្សទាំងបរិមាណនិងគុណភាព
- សិក្សាអំពីលទ្ធភាពបង្កើតសាលារៀនថ្មីសម្រាប់ចំណេះដឹងទូទៅដោយផ្អែកលើទំហំប្រជាសាស្ត្រនិងចំនួនសិស្សនៃតំបន់ដែលត្រូវបង្កើតសាលារៀនថ្មីនេះ
- រៀបចំនិងធ្វើផែនការបង្កើតបរិក្ខារអប់រំលើជំនាញបច្ចេកទេសនៅជុំវិញតំបន់ឧស្សាហកម្មដោយពិចារណាទៅលើកំណើនឧស្សាហកម្មគោលដៅឆ្នាំ២០៣៥
- សហការជាមួយវិស័យឯកជនទាំងក្នុងនិងក្រៅប្រទេសក្នុងការពង្រឹងវិស័យអប់រំទូទៅ ជំនាញវិជ្ជាជីវៈ ឧត្តមសិក្សា និងការសិក្សាស្រាវជ្រាវកម្រិតខ្ពស់
- លុបបំបាត់នូវអនក្ខរភាពនៅក្នុងក្រុងនិងតំបន់ជុំវិញ
- ធានានូវការទទួលបាននូវការអប់រំចំណេះដឹងទូទៅនិងកម្រិតជំនាញប្រកបដោយគុណភាពនៅក្នុងក្រុងនិងតំបន់ជុំវិញ។

### ៤.៥.២-វិស័យសុខាភិបាល

យុទ្ធសាស្ត្រអភិវឌ្ឍវិស័យសុខាភិបាលនៅក្រុងព្រះសីហនុមានដូចខាងក្រោម៖

- លើកកម្ពស់ការថែរក្សាបរិក្ខារនិងសេវាសុខាភិបាលដែលមានស្រាប់នៅតំបន់ទីប្រជុំជននិងកសាងបរិក្ខារសុខាភិបាលថ្មីនៅតំបន់ជុំវិញទីប្រជុំជន តំបន់ជាយក្រុង និងតំបន់ដែលខ្វះខាត
- ជំរុញនិងលើកកម្ពស់ដល់ការអប់រំផ្សព្វផ្សាយអំពីសុខភាពសាធារណៈដល់សាធារណជនឱ្យបានទូលំទូលាយទាំងនៅក្នុងទីក្រុង តំបន់ជាយក្រុង និងតំបន់ដាច់ស្រយាល
- ធានាបាននូវការផ្តល់សេវាសុខាភិបាលនៅទូទាំងក្រុង តំបន់ជុំវិញ និងតំបន់ដែលងាយរងគ្រោះ នៅដាច់ស្រយាល
- ជំរុញវិស័យឯកជនក្នុងការវិនិយោគនិងអភិវឌ្ឍមន្ទីរពេទ្យដែលមានគុណភាពនិងការប្រកួតប្រជែងខ្ពស់។

### ៤.៥.៣-ទីក្រុងគំរូក្នុងការគ្រប់គ្រងនិងអភិបាលកិច្ចល្អប្រកបដោយសេវាទីក្រុង ហេដ្ឋារចនាសម្ព័ន្ធទីក្រុង បរិក្ខារទីក្រុង និងផ្តល់ការងារសម្បូរបែប

យុទ្ធសាស្ត្រក្នុងការគ្រប់គ្រងនិងអភិបាលកិច្ចល្អប្រកបដោយសេវាទីក្រុង ហេដ្ឋារចនាសម្ព័ន្ធទីក្រុង បរិក្ខារទីក្រុង និងផ្តល់ការងារសម្បូរបែបនៅក្រុងព្រះសីហនុមានដូចខាងក្រោម៖

- បង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវារដ្ឋបាលសាធារណៈតាមរយៈអភិក្រមរបស់រាជរដ្ឋាភិបាលគឺទី១ឆ្លុះកញ្ចក់ ទី២ ងូតទឹក ទី៣ ដុសក្អែល ទី៤ ព្យាបាល និងទី៥ វះកាត់
- សម្រួលនិងរៀបចំការគ្រប់គ្រងនិងការផ្តល់សេវាប្រកបដោយប្រសិទ្ធភាពខ្ពស់តាមរយៈប្រព័ន្ធរដ្ឋបាលអេឡិចត្រូនិក
- ធ្វើជាគំរូល្អក្នុងការគ្រប់គ្រងនិងអភិបាលកិច្ចល្អ
- លើកកម្ពស់ការយល់ដឹងក្រមសីលធម៌ដល់មន្ត្រីគ្រប់កម្រិត
- ពង្រីកភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ
- ពង្រឹងប្រសិទ្ធភាពអនុវត្តការងារ
- ពង្រឹងអភិបាលកិច្ចវិស័យឯកជន
- ធានានូវការផ្តល់នូវបរិក្ខាររដ្ឋបាលឱ្យបានគ្រប់គ្រាន់នៅក្នុងទីក្រុងនិងតំបន់ជុំវិញដើម្បីឆ្លើយតបទៅនឹងកំណើនតម្រូវការនាពេលអនាគត។

### ៤.៥.៤-លម្ហសាធារណៈ សួនច្បារ និងខ្សែក្រវាត់តំបន់បៃតង

យុទ្ធសាស្ត្រអភិវឌ្ឍលម្ហសាធារណៈ សួនច្បារ និងខ្សែក្រវាត់តំបន់បៃតងនៅក្រុងព្រះសីហនុមានដូចខាងក្រោម៖

- គាំទ្រនិងធានាដល់ការរៀបចំបណ្តាញលម្ហសាធារណៈនិងផ្ទៃបៃតងនៅតាមបណ្តោយឆ្នេរសមុទ្រ ដៃសមុទ្រ ព្រែក ស្ទឹង អូរ និងបណ្តាញផ្លូវទឹកដែលតភ្ជាប់ទៅនឹងសមុទ្រ
- គាំទ្រ ការពារ និងផ្តល់លម្ហសាធារណៈនិងផ្ទៃបៃតងនៅតាមតំបន់ការពារធម្មជាតិនិងតំបន់វប្បធម៌

- គាំទ្រនិងជំរុញការរៀបចំបណ្តាញលម្ហសាធារណៈនិងផ្ទៃបៃតងតាមដងមហាវិថី វិថី អនុវិថី ផ្លូវជាតិលេខ៤ និងបណ្តាញផ្លូវផ្សេងៗទៀត
- គាំទ្រនិងជំរុញការរៀបចំអ័ក្សអភិវឌ្ឍន៍បណ្តាញបៃតងតភ្ជាប់ពីតំបន់ឆ្នេរសមុទ្រទៅតំបន់ការពារធម្មជាតិ តំបន់វប្បធម៌ សួន ឧទ្យាន និងបណ្តាញលម្ហសាធារណៈនៅក្នុងក្រុងប្រកបដោយសោភណភាពនិងភាពទាក់ទាញ
- គាំទ្រនិងជំរុញដល់ការរៀបចំបង្កើតឧទ្យានឬសួនច្បារនៅតំបន់មជ្ឈមណ្ឌលពាណិជ្ជកម្ម នៅតំបន់ឧស្សាហកម្ម និងភ្ជាប់ទៅនឹងតំបន់ឆ្នេរសមុទ្រ
- ថែរក្សានិងកែលម្អឧទ្យាននិងសួនដែលមានស្រាប់និងគិតគូរការបង្កើតសួនថ្មីដោយគិតគូរអំពីការរៀបចំសួនដែលនឹងបង្កើតថ្មីជាលម្ហសាធារណៈឱ្យស្របគ្នាជាមួយនឹងផែនការប្រើប្រាស់ដីបច្ចុប្បន្ន
- គាំទ្រនិងជំរុញដល់ការរៀបចំបង្កើតបណ្តាញខ្សែឬអ័ក្សផ្ទៃបៃតងសម្រាប់ការពារគ្រោះមហន្តរាយ និងលើកកម្ពស់ទេសភាពទីក្រុង
- គាំទ្រនិងជំរុញដល់ការរៀបចំបង្កើតសួនផ្សេងៗគ្នាដើម្បីលើកកម្ពស់និងជំរុញដល់បរិយាកាសនៃការលម្ហែកម្សាន្ត។

### ៤.៥.៥-បរិក្ខារវប្បវត្ថុនិងវប្បធម៌

យុទ្ធសាស្ត្រអភិវឌ្ឍនិងរៀបចំបរិក្ខារវប្បវត្ថុនិងវប្បធម៌នៅក្រុងព្រះសីហនុមានដូចខាងក្រោម៖

- ធានាដល់ការថែរក្សានិងការពារវត្តជោតញ្ញាណ (វត្តលើ) វត្តឥន្ទញ្ញាណ (វត្តក្រោម) វត្តអូរត្រេះ ព្រះរាជដំណាក់ និងកំណត់តំបន់គ្រប់គ្រងនគរូបនីយកម្មជុំវិញដែលមានកាំរង្វង់៥០០ម៉ែត្រ
- ធានាដល់ការបង្កើតហេដ្ឋារចនាសម្ព័ន្ធវប្បធម៌ដោយភ្ជាប់ទំនាក់ទំនងជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់នៅក្នុងក្រុងព្រះសីហនុ
- ធានាដល់ការពង្រីកនិងបង្កើតបរិក្ខារកីឡានិងវប្បធម៌ថ្មីដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់នាពេលអនាគត
- ធានា គាំទ្រ និងជំរុញដល់ការរៀបចំបង្កើតបរិក្ខារវប្បធម៌ដូចជាសារមន្ទីរឬមជ្ឈមណ្ឌលសិល្បៈនៅតំបន់ក្រុង តំបន់បិតត្រាង និងតំបន់ស្ទឹងហាវ
- ធានា គាំទ្រ និងជំរុញដល់ការរៀបចំបង្កើតបរិក្ខារសម្រាប់បម្រើដល់វិស័យកីឡាដូចជាពហុកីឡដ្ឋាននៅក្រុងព្រះសីហនុ នៅតំបន់បិតត្រាង និងនៅតំបន់ស្ទឹងហាវ។

### ៤.៥.៦-ការអភិវឌ្ឍសង្គមកិច្ច

យុទ្ធសាស្ត្រអភិវឌ្ឍសង្គមកិច្ចនៅក្រុងព្រះសីហនុមានដូចខាងក្រោម៖

- ជំរុញនិងដោះស្រាយសំណង់បណ្តោះអាសន្ននៅលើដីរដ្ឋ ដីចំណីឆ្នេរសមុទ្រ និងដីចំណីផ្លូវដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ
- យកចិត្តទុកដាក់ជួយដល់ប្រជាពលរដ្ឋក្រីក្រ និងជនងាយរងគ្រោះពិសេសប្រជាជនណាដែលទទួលរងការគំរាមកំហែងពីគ្រោះធម្មជាតិ
- គាំទ្រនិងជំរុញឱ្យសហគមន៍ទទួលបានការគាំទ្រនិងលើកទឹកចិត្តពីផ្នែកសាធារណៈនិងសង្គមស៊ីវិល

- ជំរុញការអភិវឌ្ឍសមត្ថភាពរបស់ប្រជាជននិងមានជំនាញវិជ្ជាជីវៈដែលអាចប្រកបមុខរបរបានតាមរយៈការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដើម្បីលើកកម្ពស់កម្រិតជីវភាពគ្រួសារ
- គាំទ្រនិងជំរុញការរៀបចំគម្រោងសម្បទានដីសង្គមកិច្ចសម្រាប់ប្រជាជនក្រីក្រក្នុងក្រុង  ប្រជាជនរស់នៅក្នុងសំណង់បណ្តោះអាសន្នគ្រប់កន្លែង ពិសេសក្នុងតំបន់ជាប់ព្រែកនិងឆ្នេរសមុទ្រ
- ជំរុញ គាំទ្រ និងធានាដល់ការរៀបចំផ្លូវថ្មើរជើង ផ្លូវជិះកង់ និងផ្លូវសម្រាប់ជនមានពិការភាព ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធ បរិក្ខារ និងសេវាសម្រាប់ជនមានពិការភាពមានជាអាទិ៍ផ្លូវជម្រាលសម្រាប់បម្លាស់ទីឧបករណ៍ផ្ទាក់ដៃ ជណ្តើរ បង្គន់អនាម័យ ចំណតយានយន្ត និងផ្លាកសញ្ញា ពិសេសសម្រាប់ជនមានពិការភាពនៅតាមដងផ្លូវ សួនសាធារណៈ និងទីសាធារណៈ។

## ៤.៦-យុទ្ធសាស្ត្រការពារបរិស្ថាននិងគ្រប់គ្រងសំណល់

### ៤.៦.១-យុទ្ធសាស្ត្រគ្រប់គ្រងសំណល់រឹង

ក្រុងព្រះសីហនុបាន និងកំពុងវិវត្តខ្លួនទៅជាទីក្រុងទេសចរណ៍កម្រិតអន្តរជាតិដោយសារតែកំណើនសេដ្ឋកិច្ចដ៏ឆាប់រហ័ស និងការអភិវឌ្ឍឧស្សាហកម្មទេសចរណ៍។ ដើម្បីគ្រប់គ្រង និងតម្រង់ទិសក្រុងព្រះសីហនុឱ្យក្លាយទៅជាទីក្រុងទេសចរណ៍កម្រិតអន្តរជាតិប្រកបដោយបរិស្ថានល្អប្រសើរ និងគ្មានសំរាម យុទ្ធសាស្ត្រសំខាន់ៗសម្រាប់ការគ្រប់គ្រងសំណល់រឹងត្រូវបានកំណត់ដូចខាងក្រោម៖

- ពង្រឹងមធ្យោបាយប្រមូលសំណល់រឹងនិងរៀបចំទីតាំងសម្រាប់ទុកដាក់សំណល់រឹងស្របតាមបទដ្ឋានបច្ចេកទេសនិងស្តង់ដាទីក្រុងស្អាត
- គាំទ្រនិងធានាដល់ការរៀបចំជាផ្នែកៗ កន្លែងសំអាតកំទេចកំទីសំរាម កន្លែងស្តុក តម្រូវដី និងការលុបសំណល់រឹង
- គាំទ្រនិងជំរុញដល់រៀបចំផែនការនិងធ្វើការកែលម្អប្រព័ន្ធដឹកជញ្ជូននិងការប្រមូលសំណល់រឹងតាមរយៈការធ្វើទំនើបកម្មប្រព័ន្ធប្រមូលសំណល់រឹងនិងមធ្យោបាយដឹកជញ្ជូន
- គាំទ្រដល់ការប្រើប្រាស់និងអភិវឌ្ឍបច្ចេកវិទ្យាទំនើបក្នុងការគ្រប់គ្រងសំណល់រឹងនិងកែលម្អប្រព័ន្ធគ្រប់គ្រងសំណល់រឹងតាមរយៈ៖
    - បង្កើតគោលនយោបាយនិងបទប្បញ្ញត្តិសម្រាប់ការប្រព្រឹត្តកម្មសំណល់រឹងប្រកបដោយអនាម័យនិងប្រសិទ្ធភាព
    - ធ្វើការផ្សព្វផ្សាយនិងផ្តោតយកចិត្តទុកដាក់លើការប្រព្រឹត្តកម្មសំណល់រឹងប្រកបដោយអនាម័យនិងប្រសិទ្ធភាព ការបំលែងថាមពល និងការកែច្នៃសំណល់រឹង។
- ជំរុញនិងលើកកម្ពស់ដល់ការត្រួតពិនិត្យ ការកែច្នៃឡើងវិញ និងការកាត់បន្ថយការផលិតសំណល់រឹងពីអ្នកប្រើប្រាស់
- ជំរុញនិងលើកទឹកចិត្តចំពោះការកែច្នៃសំណល់រឹងឡើងវិញដូចជាក្រដាស ប្លាស្ទិច និងដោយផ្ដើមក្នុងកម្រិតអតិបរមាដើម្បីកាត់បន្ថយកសំណល់រឹងចុងក្រោយទៅកប់ក្នុងដី
- ជំរុញឱ្យមានការអនុវត្តគោលការណ៍ការកាត់បន្ថយការប្រើប្រាស់ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃលើការគ្រប់គ្រងសំណល់រឹង និងបង្កើតជីកំប៉ុស្តិ៍

- ជំរុញនិងអនុវត្តនូវដំណើរការនៃការកាត់បន្ថយសំណល់រឹងតាមរយៈ៖




- រៀបចំបង្កើតបរិក្ខារប្រព្រឹត្តកម្មនិងធ្វើការកែច្នៃសំណល់រឹងស្របតាមបទដ្ឋានបច្ចេកទេស
- បង្កើនការផ្សព្វផ្សាយដល់ប្រជាជនពីការញែកសំរាមនៅតាមសាលារៀននិងទីសាធារណៈ
- ជំរុញការចូលរួមរបស់ប្រជាពលរដ្ឋនិងវិនិយោគិនឯកជននិងសាធារណៈ
- បង្កើតយន្តការនិងហេដ្ឋារចនាសម្ព័ន្ធក្នុងការគ្រប់គ្រងសំណល់រឹងក្នុងក្រុងនិងខេត្ត។

ទីលានចាក់សំរាមសម្រាប់ក្រុងព្រះសីហនុ ក៏ដូចជាសម្រាប់ខេត្តព្រះសីហនុគឺស្ថិតនៅលើទីតាំងទីលានចាក់សំរាមថ្មីដែលបានកំណត់នៅក្នុងផែនការរៀបចំដែនដីខេត្តព្រះសីហនុដែលបានសម្រេចជាផ្លូវការកាលពីថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០១៨។ ទីលានចាក់សំរាមថ្មីនេះមានទីតាំងស្ថិតនៅភូមិអូរតាសេក ឃុំអូរឧកញ៉ាហេង ស្រុកព្រៃនប់ មានចម្ងាយ២គីឡូម៉ែត្រខាងជើងផ្លូវជាតិលេខ៤ ដែលនឹងត្រូវរៀបចំអភិវឌ្ឍន៍ដោយប្រើបច្ចេកវិទ្យានិងប្រព័ន្ធដំណើរការទំនើបដើម្បីធានាបាននូវអនាម័យ សុវត្ថិភាព និងបរិស្ថានល្អ។

### ៤.៦.២- យុទ្ធសាស្ត្រគ្រប់គ្រងសំណល់រាវ

ដោយមានកំណើនវិនិយោគនិងការរីកចម្រើនផ្នែកឧស្សាហកម្មខ្លាំងនៅក្នុងក្រុង បរិមាណសំណល់រាវដែលចេញមកពីការប្រើប្រាស់និងសកម្មភាពផ្សេងៗមានការកើនឡើង។ ដើម្បីឆ្លើយតបទៅនឹងបញ្ហាគ្រប់គ្រងសំណល់រាវ ប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុបានកំណត់យុទ្ធសាស្ត្រនិងវិធានការសំខាន់ៗដើម្បីពង្រឹងការគ្រប់គ្រងសំណល់រាវនិងទឹកកខ្វក់ដើម្បីធានាគុណភាពបរិស្ថានរស់នៅល្អប្រសើរ និងការអភិវឌ្ឍប្រកបដោយចីរភាព។ គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជាបានសហការជាមួយរដ្ឋបាលខេត្តព្រះសីហនុះ

- សិក្សា រៀបចំ និងកសាងប្រព័ន្ធលូទឹកកខ្វក់និងលូទឹកភ្លៀងដាច់ដោយឡែកពីគ្នា ព្រមទាំងបានសិក្សារៀបចំ និងអភិវឌ្ឍស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ចំនួន៣ស្ថានីយ ដើម្បីធ្វើប្រព្រឹត្តកម្មទឹកកខ្វក់ស្របតាមកម្រិតកម្ពស់ភូមិសាស្ត្រនៅក្នុងគម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវក្រុងចំនួន៣៤ខ្សែ ក្នុងខេត្តព្រះសីហនុ ដោយបានដំណើរការសាងសង់បញ្ចប់ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ទី១ (PS1) មានសមត្ថភាពចម្រោះទឹកកខ្វក់ចំណុះ៥ ២០០ម៉ែត្រគូបក្នុងមួយថ្ងៃ ស្ថិតនៅឆ្នេរឯករាជ្យ និងស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ទី២ (PS2) មានសមត្ថភាពចម្រោះទឹកកខ្វក់ចំណុះ៧ ២០០ម៉ែត្រគូបក្នុងមួយថ្ងៃ ស្ថិតនៅអូរសម្ពាតនៃឆ្នេរសុខា និងកំពុងដំណើរការជំរុញរៀបចំសាងសង់ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ទី៣ (PS3) មានសមត្ថភាពចម្រោះទឹកកខ្វក់ចំណុះ២០ ០០០ម៉ែត្រគូបក្នុងមួយថ្ងៃ ស្ថិតនៅព្រែកអូរឈើទាល ដោយប្រើប្រាស់បច្ចេកវិទ្យាទំនើប MABR (Membrane Aerobic Biological Reactor) ដែលជាបច្ចេកវិទ្យាចុងក្រោយរបស់ប្រទេសអ៊ីស្រាអែលដែលមាន[illegible] និងដកយកនូវសារធាតុ BOD COD អាម៉ូញ៉ាក់ ($NH_3$-N) នីត្រាត ($NO_3$-N) ផូស្វ័រ (P) និងសារធាតុពុលផ្សេងទៀត និងជាបច្ចេកវិទ្យាមានស្ថេរភាព ប្រសិទ្ធភាព សន្សំសំចៃថាមពល [illegible]

និងគ្មានក្លិនប៉ះពាល់ដល់អ្នករស់នៅជុំវិញ និងបានអភិវឌ្ឍបណ្តាញលូទំនើបដោយញែកដាច់ពីគ្នារវាងទឹកកខ្វក់និងទឹកភ្លៀងនៅសងខាងផ្លូវ ដែលក្នុងនេះលូទឹកកខ្វក់មុខកាត់១ម៉ែត្រប្រវែង៧៤ ៩២៣,៦៣ម៉ែត្រ និងលូទឹកភ្លៀងមុខកាត់១ម៉ែត្រប្រវែង៨២ ៤៨៦,៥៦ម៉ែត្រ ដើម្បីឆ្លើយតបនឹងដំណោះស្រាយនៃការបំពុលបរិស្ថានឆ្នេរដោយទឹកកខ្វក់ និងបញ្ហាទឹកជំនន់និងការជន់លិចក្រុង

- បានអនុវត្តគម្រោងសាងសង់ស្ថានីយបូមទឹកកខ្វក់ទំនើបចំនួន៤កន្លែង នៅឆ្នេរឯករាជ្យ នៅឆ្នេរសុខា នៅអូរសម្មាត និងនៅឆ្នេរអូរឈើទាល, រៀបចំបណ្តាញលូបេតុងបានប្រវែង ៧៦០ម៉ែត្រនិងទុយោជ័រស្វិត HDPE បានប្រវែង ៥៧៨១ម៉ែត្រ, ស្តារព្រែកអូរឈើទាលបានប្រវែង ២៤០០ម៉ែត្រនិងអូរសម្មាតបានប្រវែង ១២២៤ម៉ែត្រ, ដាំដើមនាងនួនតាមដងវិថីចំនួន១០ បានចំនួន ២៤៥៨ដើម, និងដាំដើមកោងកាងនៅព្រែកអូរឈើទាលបានចំនួន ១០០០០ដើម
- ណែនាំគ្រប់ម្ចាស់សំណង់ឧស្សាហកម្ម ពាណិជ្ជកម្ម សេវាកម្មទេសចរណ៍ និងសំណង់សាធារណៈត្រូវមានអាងប្រព្រឹត្តកម្មនិងអាងបង្គន់អនាម័យត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស
- ផ្សព្វផ្សាយពីគោលការណ៍បរិស្ថាននិងអនាម័យដើម្បីធានាការអភិវឌ្ឍប្រកបដោយចីរភាព។

ទន្ទឹមនឹងនេះ បន្តរៀបចំយុទ្ធសាស្ត្រនិងផែនការមេសម្រាប់ការគ្រប់គ្រងសំណល់រាវនៅទូទាំងក្រុងព្រះសីហនុនិងតំបន់ជុំវិញរួមមាន៖

- សិក្សា រៀបចំ និងសាងសង់ពង្រីកបន្ថែមស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់នៅទីតាំងស្ថានីយចម្រោះទឹកកខ្វក់នៅតំបន់ទំនប់រលក តំបន់អូរត្រេះ ក្រុងព្រះសីហនុ តំបន់បឹងចំការខ្មែរ ស្រុកព្រៃនប់ តំបន់ស្ទឹងហាវ និងនៅតាមទីតាំងសំខាន់ៗមួយចំនួនទៀតនៅក្នុងក្រុងនិងតំបន់ជុំវិញ
- រៀបចំនិងពង្រីកបន្ថែមប្រព័ន្ធលូទឹកភ្លៀងនិងលូទឹកកខ្វក់ឱ្យដាច់ពីគ្នាដោយសមាហរណកម្មតភ្ជាប់គ្នានៅគ្រប់មហាវិថី វិថី អនុវិថី ផ្លូវ និងប្រព័ន្ធប្រឡាយមេសំខាន់ៗនៅទូទាំងក្រុងដោយភ្ជាប់ទៅនឹងស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ស្របតាមស្ថានភាពទីតាំងភូមិសាស្ត្រ និងត្រូវចម្រោះទឹកឱ្យបានស្អាតមុននឹងបង្ហូរចូលបំពង់លូសាធារណៈ និងទីតាំងសាធារណៈដោយត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេសកំណត់នៅក្នុងអនុក្រឹត្យលេខ២៣៥អនក្រ.បក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការគ្រប់គ្រងប្រព័ន្ធលូនិងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។

## ៤.៦.៣- ការបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថាន

កំណត់និងបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថានស្របតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដូចខាងក្រោម៖

- តំបន់ស្នូល
- តំបន់អភិរក្ស
- តំបន់ប្រើប្រាស់ច្រើនយ៉ាងប្រកបដោយចីរភាព
- តំបន់សហគមន៍។

### ៤.៦.៤-វិធានការចាំបាច់ក្នុងការការពារតំបន់សំខាន់ៗ

- ធានាដល់ការការពារនិងថែរក្សាភ្នំ ធនធានធម្មជាតិ ព្រៃឈើនៅតាមកោះ សមុទ្រ ឆ្នេរសមុទ្រ ព្រែក បឹង ស្ទឹង អូរ និងបណ្តាញផ្លូវទឹកស្របតាមបទប្បញ្ញត្តិជាធរមាន
- ធានាដល់ការការពារនិងថែរក្សាព្រៃកោងកាងដើម្បីធានាប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាងមានផលិតភាពខ្ពស់និងមានសារសំខាន់នៅក្នុងអាយុកាលនៃសារពាង្គកាយក្នុងសមុទ្រដូចជាមានតួនាទីសំខាន់ជាកន្លែងពងកូនឬកន្លែងរកចំណីសម្រាប់ធនធានវារីជាតនិងប្រភេទត្រីសមុទ្រ
- ធានាដល់ការការពារនិងថែរក្សាព្រៃតំបន់ប្រើប្រាស់ច្រើនយ៉ាងព្រែកទឹកសាបក្បាលឆាយនិងព្រៃក្នុងតំបន់ទីជម្រាលដើម្បីធានាការគ្រប់គ្រងបរិស្ថានប្រកបដោយចីរភាព។

## ៤.៧-យុទ្ធសាស្ត្របង្ការទប់ស្កាត់គ្រោះមហន្តរាយ

### ៤.៧.១-វិធានការបង្ការគ្រោះមហន្តរាយពីព្រែក អូរ ប្រឡាយ និងផ្លូវទឹកសំខាន់ៗ

ការរៀបចំផែនការស្នូលសម្រាប់ការគ្រប់គ្រងនិងប្រើប្រាស់ព្រែក អូរ ប្រឡាយ និងបណ្តាញផ្លូវទឹកសំខាន់ៗនៅក្រុងព្រះសីហនុស្របតាមគោលការណ៍ និងគោលបំណងនៃការការពារគ្រោះមហន្តរាយគឺមានសារៈសំខាន់ណាស់។ យុទ្ធសាស្ត្រសំខាន់ៗសម្រាប់ផែនការស្នូលនេះមានដូចខាងក្រោមៈ

- ជំរុញ គាំទ្រ និងធានាដល់ការថែរក្សា ការពារ និងស្តារពង្រីកបន្ថែមព្រែក អូរ ប្រឡាយ និងបណ្តាញផ្លូវទឹកទាំងអស់នៅក្នុងក្រុងព្រះសីហនុនិងតំបន់ជុំវិញដើម្បីធានាចីរភាពសម្រាប់អនាគត
- ធ្វើការពិនិត្យ អង្កេត និងវិភាគរាល់បញ្ហាដូចជាកម្ពស់ទឹក ចរន្តទឹកហូរ បរិស្ថាន និងស្ថានភាពប្រើប្រាស់ព្រែក អូរ ប្រឡាយ និងបណ្តាញផ្លូវទឹកទាំងអស់ដើម្បីរៀបចំផែនការចាំបាច់សម្រាប់ការគ្រប់គ្រងថែទាំ និងប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនិងបរិស្ថានល្អ
- រៀបចំកសាងខឿនការពារច្រាំងនៅតាមទីតាំងសំខាន់ៗនៃព្រែក អូរ ប្រឡាយ និងបណ្តាញផ្លូវទឹកសំខាន់ៗដើម្បីការពារការហូរច្រោះ ការបាក់ដី និងទឹកជំនន់
- ខឿនដែលបានរៀបចំហើយនៅផ្នែកខ្លះនៃបណ្តាញផ្លូវទឹកមានសភាពចាស់ទ្រុឌទ្រោមនិងខូចរចនាសម្ព័ន្ធដែលអាចមានការសឹករិចរិលនិងខូចខ្លាំងនៅរដូវវស្សា។ ដូច្នេះត្រូវរៀបចំបង្កើតផែនការការពារនិងគ្រប់គ្រងខឿនទំនប់ទឹកដើម្បីការពារការហូរច្រោះនិងការបាក់ដី
- រៀបចំវិធានការការពារស្រទាប់ដីខាងលើពីការហូរច្រោះស្របតាមបទដ្ឋានបច្ចេកទេសដូចជាការរៀបចំប្រព័ន្ធប្រឡាយការពារបីស្រទាប់ខាងលើ ការរៀបចំប្រព័ន្ធការពារទីជម្រាល និងតំបន់ចំណោតនិងការរៀបចំប្រព័ន្ធបៃតងជាដើម។

### ៤.៧.២-វិធានការការពារការស្ទះផ្លូវទឹកហូរ

#### ក-ការរៀបចំប្រព័ន្ធប្រឡាយនិងអណ្តូងលូ

ត្រូវរៀបចំឱ្យមានប្រព័ន្ធប្រឡាយនិងប្រព័ន្ធបង្ហូរទឹកភ្លៀងស្របតាមស្ថានភាពជាក់ស្តែងសម្រាប់រំដោះទឹកភ្លៀងដោយមានបំពាក់អណ្តូងលូដែលមានគម្របសំណាញ់ការពារការហូរនិងធ្លាក់ចូលដោយសំណល់រឹង។ អណ្តូងលូគួររៀបចំនិងបំពាក់នៅចន្លោះចិញ្ចើមផ្លូវនិងផ្លូវថ្នល់ឬទីតាំងសមស្របទៅតាមស្ថានភាពជាក់ស្តែង។

## ខ-បរិក្ខារបន្ថយល្បឿនទឹកភ្លៀងហូរ

ផ្ទៃបែតងមានការថយចុះដោយសារតែការអភិវឌ្ឍ ពិសេសការកសាងថ្មីៗនៅក្នុងក្រុង ដូច្នេះបរិមាណ និងល្បឿនទឹកហូរមានការកើនឡើង ហើយអាចលើសពីចំណុះរបស់លូនិងប្រឡាយទឹកដែលអាចនឹងបណ្តាលឱ្យ មានការលិចលង់។ ដើម្បីកាត់បន្ថយល្បឿនទឹកភ្លៀងហូរខ្លាំងនិងការពារការលិចលង់ ពិសេសនៅពេលដែលមាន ភ្លៀងព្យុះខ្លាំងត្រូវមានវិធានការនិងរៀបចំបំពាក់នូវបរិក្ខារបន្ថយល្បឿនទឹកភ្លៀងដែលបែងចែកជាបរិក្ខារផ្ទុក និង បរិក្ខារជម្រាបទឹកទៅតាមវិធីសាស្រ្តដូចខាងក្រោម៖

- បរិក្ខារផ្ទុកសំដៅដល់ការរៀបចំសម្រាប់ទឹកហូរចូលដើម្បីបន្ថយល្បឿនទឹកហូរនិងបរិមាណទឹកភ្លៀង ដូចជាអាងស្តុកទឹកនិងកន្លែងបង្ខូរទឹកដែលត្រូវបានរៀបចំឡើងជាបណ្តោះអាសន្នសម្រាប់ទប់មិនឱ្យ ទឹកភ្លៀងទាំងអស់ត្រូវហូរចូលព្រែក ប្រឡាយ ខ្សែទឹកផ្សេងៗ ឬសមុទ្រដោយផ្ទាល់។ បរិក្ខារទាំងនេះ អាចចាត់ទុកថាជាបរិក្ខារស្តុកទឹក ហើយក៏អាចចាត់ទុកថាជាកន្លែងស្តុកទឹកនៅខាងក្រៅឬនៅនឹង កន្លែងដោយអាស្រ័យទៅតាមទីតាំងជាក់ស្តែង
- បរិក្ខារជម្រាបទឹកចូលក្នុងដីសំដៅដល់បរិក្ខារដែលជួយដល់ជម្រាបទឹកចូលក្នុងដីដើម្បីបន្ថយល្បឿន ទឹកហូរ ហើយត្រូវបានដំឡើងដើម្បីបញ្ជ្រាបទឹកក្នុងដីដើម្បីបន្ថយការហូរដោយផ្ទាល់របស់ទឹកជំនន់។



រូបភាពទី៧៖ ការរៀបចំបរិក្ខារបន្ថយល្បឿនទឹកហូរតាមរយៈការជ្រាបទឹកចូលទៅក្នុងដី

## ៤.៧.៣-វិធានការការពារការកំណស្ទះខ្សែទឹកហូរដោយសារការអភិវឌ្ឍថ្មីៗ

ក្រុងព្រះសីហនុកំពុងមានការអភិវឌ្ឍយ៉ាងគំហុក ពិសេសការសាងសង់សំណង់ថ្មីៗដែលជាកត្តាដ៏សំខាន់ ក្នុងការបង្កើតសំណល់ផ្សេងៗចេញពីការដ្ឋានសំណង់ទាំងនោះ។ ដើម្បីគ្រប់គ្រងនិងការពារការខូចខាតដោយសារការ កកដីនិងការបង្អាក់ដល់ខ្សែទឹកហូរ រាល់គម្រោងអភិវឌ្ឍថ្មីត្រូវមានវិធានការចាំបាច់តម្រូវឱ្យរៀបចំអាងដីល្បាប់ និងប្រឡាយផ្លូវទឹកហូរភ្ជាប់ចេញពីទីតាំងគម្រោងអភិវឌ្ឍទៅអាងដីល្បាប់ដើម្បីហូរនាំយកសំណល់ផ្សេងៗចូល ទៅអាងដីល្បាប់។ ទីតាំងអាងដីល្បាប់គួរដំឡើងនៅត្រង់ផ្លូវទឹកហូរនៃរាល់គម្រោងអភិវឌ្ឍស្របតាមតម្រូវការ ជាក់ស្តែង។




រូបភាពទី៨៖ អាងដីល្បាប់




រូបភាពទី៩៖ អាងដីល្បាប់និងប្រឡាយបង្ហូរទឹក

### ៤.៧.៤-វិធានការបង្ការគ្រោះមហន្តរាយនៅទីចំណោត

បច្ចុប្បន្នក្រុងព្រះសីហនុមានចំណោតសិប្បនិម្មិតជាច្រើនដែលកើតឡើងដោយសារគម្រោងសាងសង់លំនៅឋាន គម្រោងអភិវឌ្ឍខ្នាតតូចនិងធំ ក៏ដូចជាការសាងសង់ផ្លូវថ្នល់។ល។ ចំណែកចំណោតដីធម្មជាតិក៏មានហានិភ័យចំពោះការបាក់គ្រប់ពេលវេលា។  ដើម្បីធ្វើការគ្រប់គ្រងនិងការពារគ្រោះមហន្តរាយពីការបាក់ដីនៅទីចំណោតប្រកបដោយប្រសិទ្ធភាពខ្ពស់ វិធានការសំខាន់ៗត្រូវបានកំណត់ដូចខាងក្រោម៖

- រាល់ការអភិវឌ្ឍឬការសាងសង់នៅតំបន់ចំណោតត្រូវធ្វើការរៀបចំប្លង់អភិវឌ្ឍន៍ជាមុន សណ្ឋានកំណាត់ដែលមានស្ថេរភាពឬលំនឹង បំពាក់ដោយបរិក្ខារទប់ដីបន្ថែម និងបរិក្ខារចាំបាច់ផ្សេងៗទៀតដែលជួយការពារពីការហូរច្រោះនិងបាក់ដី
- ការសាងសង់នៅតំបន់ចំណោតចាំបាច់ត្រូវសិក្សារក្សាលំនឹងរបស់សំណង់ដើម្បីការពារពីហានិភ័យផ្សេងៗដូចជាភ្លៀងខ្លាំង ខ្យល់ព្យុះ និងការប្រែប្រួលអាកាសធាតុជាដើម។

### ៤.៧.៥-វិធានការបង្ការគ្រោះមហន្តរាយតាមតំបន់ឆ្នេរសមុទ្រ

ក្រុងព្រះសីហនុមានកោះតូចធំនៅព័ទ្ធជុំវិញ ទោះបីយ៉ាងណាក៏ដោយកោះតូចធំទាំងនោះគឺមិនមានការខូចខាតដោយសារលំហូរទឹកសមុទ្រឬខ្យល់ព្យុះនោះទេ  ក៏ប៉ុន្តែក្រុងព្រះសីហនុក៏មិនអាចចៀសផុតពីគ្រោះមហន្តរាយដែលមិនអាចគិតទុកមុនដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុមិនប្រក្រតីនៅលើពិភពលោកដោយសារកំណើនកំដៅផែនដី។ ដូចនេះ រាល់ការអភិវឌ្ឍនៅតំបន់ឆ្នេរសមុទ្រត្រូវមានវិធានការការពារ ទប់ទល់បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ វិធានការសំខាន់ៗដើម្បីការពារគ្រោះមហន្តរាយតាមតំបន់ឆ្នេរសមុទ្រមានដូចខាងក្រោម៖

- រៀបចំបង្កើតអាងស្តុកទឹកដែលមានមុខងារច្រើនយ៉ាងជាកន្លែងស្តុកទឹក សួនឧទ្យានកម្សាន្ត និងកន្លែងកីឡា។ល។ នៅតំបន់ឆ្នេរសមុទ្រទំនាបដែលមានហានិភ័យទៅនឹងការលិចជន់ពីទឹកសមុទ្រដើម្បីជួយសម្រួលស្តុកទឹកនោះនៅពេលដែលទឹកសមុទ្រជោរឡើង និងជាអាងរងទឹកភ្លៀងនៅពេលដែលមានភ្លៀងខ្លាំងដើម្បីការពារការលិចលង់នៅតំបន់ទំនាបនេះ
- បរិក្ខារមួយចំនួននៅតំបន់ឆ្នេរសមុទ្រត្រូវបានបំពាក់ឡើងភ្លាមៗដើម្បីឆ្លើយតបទៅនឹងកំណើននៃការអភិវឌ្ឍនិងចំនួនអ្នកទេសចរដែលមានការកើនឡើងលើសពីការរំពឹងទុកឱ្យបានគ្រប់ជ្រុងជ្រោយដើម្បីការការពារបរិស្ថាននិងការពារគ្រោះមហន្តរាយ។ ដើម្បីឆ្លើយតបទៅនឹងបញ្ហារួមនៅតំបន់ឆ្នេរសមុទ្រត្រូវធ្វើការរៀបចំការអភិវឌ្ឍជាប្រព័ន្ធរួមមួយដែលមានការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់
- រាល់ការអភិវឌ្ឍនៅតំបន់ឆ្នេរសមុទ្រត្រូវគោរពតាមសារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជានិងបទប្បញ្ញត្តិជាធរមាន។






រូបភាពទី១០៖ គំនូរប្លង់បង្ហាញពីស្ទីលនៃការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា

ប្រភព៖ សារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា

### ៤.៨-យុទ្ធសាស្ត្រពង្រឹងអភិបាលកិច្ចល្អ គ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុនៅមូលដ្ឋាន

ការពង្រឹងលើកកម្ពស់សមត្ថភាព ស្ថាប័ន និងធនធានមនុស្សនៅរដ្ឋបាលខេត្តព្រះសីហនុ និងរដ្ឋបាលក្រុងព្រះសីហនុក្នុងការសម្របសម្រួលអនុវត្តប្លង់គោលប្រើប្រាស់ដីនេះ និងការគ្រប់គ្រងហិរញ្ញវត្ថុនៅមូលដ្ឋានជាកត្តាសំខាន់ចាំបាច់និងជាស្នូលនៃវិស័យទេសចរណ៍ សេដ្ឋកិច្ច អភិវឌ្ឍទីក្រុង និងបរិស្ថានដោយចាំបាច់ត្រូវ៖

- សម្របសម្រួលស្ថាប័នពាក់ព័ន្ធឱ្យចែករំលែកព័ត៌មានអំពីគម្រោងដែលត្រូវអនុវត្តនិងគម្រោងដែលត្រូវស្នើឡើងក្នុងខេត្តនិងក្រុង
- ពង្រឹងមូលដ្ឋានធនធានមនុស្សទាំងនៅថ្នាក់ខេត្តនិងថ្នាក់ក្រុង ពិសេសសម្រាប់ការគ្រប់គ្រងអភិវឌ្ឍនិងការត្រួតពិនិត្យគម្រោងសាធារណៈ ការគ្រប់គ្រងដីធ្លី ការប្រមូលពន្ធ។ល។
- ពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការប្រើប្រាស់ដីសាធារណៈ ការផ្តល់លិខិតអនុញ្ញាតសាងសង់ ការចុះបញ្ជីយានយន្ត ការចាក់ដី ការបូមទឹកក្រោមដី និងការគ្រប់គ្រងបរិស្ថាន
- ពង្រឹងហិរញ្ញវត្ថុនៅមូលដ្ឋានតាមរយៈការប្រមូលចំណូលនៅមូលដ្ឋាន ការបែងចែកចំណូលរដ្ឋពីវិស័យទេសចរណ៍ និងប្រភពផ្សេងៗទៀតដល់រដ្ឋបាលមូលដ្ឋានសម្រាប់ប្រើប្រាស់ជាប្រយោជន៍សាធារណៈ ពិសេសសម្រាប់ការជួសជុលនិងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងលើកកម្ពស់សោភណភាពនិងបរិស្ថានទីក្រុង។

## ៥-ផែនការសកម្មភាព

ផ្អែកតាមគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា ផែនការរៀបចំដែនដីខេត្តព្រះសីហនុដែលបានសម្រេចរួច និងប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុ រដ្ឋបាលខេត្តព្រះសីហនុ រដ្ឋបាលក្រុងព្រះសីហនុ និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធត្រូវអនុវត្តផែនការសកម្មភាពសំខាន់ៗចាំបាច់ដូចខាងក្រោម៖

### ៥.១-ការអភិរក្សនិងការអភិវឌ្ឍតំបន់នគរូបនីយកម្ម

- កំណត់ព្រំប្រទល់រដ្ឋបាលក្រុង សង្កាត់ និងភូមិស្របតាមបទប្បញ្ញត្តិជាធរមាន
- ដាក់ឈ្មោះឬលេខមហាវិថី វិថី អនុវិថី និងផ្លូវទាំងអស់នៅក្នុងក្រុងនិងតំបន់ជុំវិញ
- ដាក់លេខផ្ទះឱ្យបានគ្រប់ចំនួនខ្នងផ្ទះដើម្បីងាយស្រួលដល់ការគ្រប់គ្រង
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃតំបន់អភិវឌ្ឍទីក្រុងថ្មី (គម្រោងអភិវឌ្ឍទីក្រុងរាម)
- រៀបចំបណ្តាញអគ្គិសនី ឬបណ្តាញបញ្ជូនអគ្គិសនី ខ្សែកាប្លិ៍គ្រប់ប្រភេទ កប់ក្នុងដី ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពនិងរក្សាដល់សោភណភាពទីក្រុង
- រៀបចំវគ្គបណ្តុះបណ្តាលលើជំនាញគ្រប់គ្រងដីធ្លីនិងនគរូបនីយកម្មដល់គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ខេត្តនិងថ្នាក់ក្រុង ដែលមានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់និងសុរិយោដីខេត្តនិងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុងជាសេនាធិការក្នុងការគ្រប់គ្រងនិងការអនុវត្តការងាររៀបចំដែនដីនិងនគរូបនីយកម្ម
- កសាងផែនការអភិវឌ្ឍនិងអភិរក្សសំណង់អគារបេតិកភណ្ឌព្រះរាជដំណាក់ ផ្សារ និងសួនច្បារដែលមានស្រាប់ប្រកបដោយប្រសិទ្ធភាព ចីរភាព សុវត្ថិភាព សោភណភាព សណ្តាប់ធ្នាប់ និងបរិស្ថានរស់នៅល្អ

- រៀបចំកម្លាំងនិងកម្មវិធីសកម្មភាពកែលម្អនិងស្តារឆ្នេរសមុទ្រកម្សាន្ត សួនច្បារតាមមាត់បឹង ព្រែក និងផ្លូវ និងបំពាក់ភ្លើងបំភ្លឺឱ្យមានសោភណភាព គុណភាពបរិស្ថានល្អ និងសកម្មភាពរស់រវើកទាំងពេលយប់ និងពេលថ្ងៃសមស្របជាទីក្រុងទំនើបកម្រិតអន្តរជាតិនិងរមណីយដ្ឋានឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក
- កំណត់រចនាបថអគារ ពណ៌អគារ និងផ្លាកសញ្ញាផ្សព្វផ្សាយពាណិជ្ជកម្មតាមដងផ្លូវនិងតាមតំបន់ឱ្យមានសណ្តាប់ធ្នាប់និងសោភណភាពល្អស្របតាមទីតាំងភូមិសាស្ត្រជាក់ស្តែង
- កំណត់ទិសដៅនៃការពង្រីកក្រុងដើម្បីលើកកម្ពស់គុណភាពនិងសោភណភាពសម្រាប់ការស្នាក់នៅ ការធ្វើការងារ ការសិក្សា និងការកម្សាន្ត
- កសាងអ័ក្សបណ្តាញដឹកជញ្ជូនដោយភ្ជាប់ទំនាក់ទំនងរវាងតំបន់ស្នូលក្រុងព្រះសីហនុ កំពង់ផែស្រុកស្ទឹងហាវ តំបន់សេដ្ឋកិច្ចពិសេសបិតត្រាំង និងតំបន់អាកាសយានដ្ឋានអន្តរជាតិនៃស្រុកព្រៃនប់
- កែលម្អនិងរៀបចំមហាវិថី វិថី អនុវិថី ផ្លូវបម្រើការដឹកជញ្ជូនសំខាន់ៗ ផ្លូវថ្មើរជើង ផ្លូវជិះកង់ លម្ហសាធារណៈ សួនសាធារណៈ សួនកុមារ ទីលានកីឡា កន្លែងកម្សាន្ត កំណត់ប្រភេទដើមឈើ ដាំដើមឈើ និងអភិវឌ្ឍផ្ទៃបៃតងនៅក្រុងព្រះសីហនុស្របទៅតាមតំបន់ប្រើប្រាស់ដីឱ្យមានសោភណភាពរស់រវើក សណ្តាប់ធ្នាប់ល្អ និងបរិស្ថានរស់នៅប្រកបដោយផាសុកភាពសម្រាប់មនុស្សទាំងអស់គ្នា
- កសាងផែនការលម្អិតសម្រាប់ការគ្រប់គ្រងនិងថែរក្សាតំបន់ឧទ្យាន ភ្នំ ទេសភាពនិងតំបន់បៃតងជាយក្រុង និងអភិវឌ្ឍបណ្តាញបៃតងសមាហរណកម្មតភ្ជាប់ទីប្រជុំជន តំបន់ជុំវិញ និងតំបន់ជនបទ
- កសាងផែនការប្រើប្រាស់ដីដោយកំណត់បទប្បញ្ញត្តិនៃការប្រើប្រាស់ដី ការអភិវឌ្ឍដី ការសាងសង់ និងប្លង់លម្អិតនគរូបនីយកម្មតាមតំបន់នីមួយៗស្របតាមការចាំបាច់និងទីតាំងភូមិសាស្ត្រជាក់ស្តែង
- រៀបចំផែនការសកម្មភាពលម្អិតនិងជំរុញការអនុវត្តនូវយុទ្ធសាស្ត្រអភិវឌ្ឍក្រុងព្រះសីហនុជាទីក្រុងប្រកបដោយភាពឆ្លាត ចីរភាព និងបរិយាបន្នស្របតាមទស្សនវិស័យនៃការអភិវឌ្ឍទីក្រុងឆ្លាត ដូចកំណត់នៅក្នុងចំណុច៤.១.១-យុទ្ធសាស្ត្រអភិវឌ្ឍនិងទិសដៅនគរូបនីយកម្ម
- រៀបចំផែនការសកម្មភាពលម្អិតសម្រាប់ការអភិរក្សនិងការអភិវឌ្ឍតំបន់ឆ្នេរប្រកបដោយចីរភាពស្របតាមយុទ្ធសាស្ត្រអភិរក្សនិងអភិវឌ្ឍតំបន់ឆ្នេរដូចបានកំណត់នៅក្នុងចំណុច៤.១.២-យុទ្ធសាស្ត្រអភិរក្សនិងអភិវឌ្ឍនគរូបនីយកម្មតំបន់ឆ្នេរសមុទ្រ។

## ៥.២-ការគ្រប់គ្រងនិងការប្រើប្រាស់ដីប្រកបដោយចីរភាព

### ៥.២.១-ការគ្រប់គ្រងការអភិវឌ្ឍលើប្រភេទដីអាចសាងសង់បាននិងប្រភេទដីកម្រិតការសាងសង់

- បន្តចុះបញ្ជីដីធ្លីជាប្រព័ន្ធឱ្យបានគ្របដណ្តប់ទាំងក្រុងនិងតំបន់ជុំវិញ
- ធ្វើចំណាត់ថ្នាក់និងចុះបញ្ជីដីរដ្ឋឱ្យបានគ្របដណ្តប់ទាំងក្រុងនិងតំបន់ជុំវិញនិងកំណត់ព្រំប្រទល់ដីរដ្ឋនៅលើដីជាក់ស្តែងតាមរយៈការបោះបង្គោលបេតុងតាមព្រំប្រទល់ដែលបានកំណត់នៅក្នុងការចុះបញ្ជី
- បណ្តុះបណ្តាលនិងពង្រឹងសមត្ថភាពមន្ត្រីដែលមានសមត្ថកិច្ចនិងពាក់ព័ន្ធក្នុងដំណើរការផ្តល់លិខិតអនុញ្ញាតអភិវឌ្ឍដី លិខិតអនុញ្ញាតសាងសង់ និងលិខិតពាក់ព័ន្ធផ្សេងៗសម្រាប់ការអភិវឌ្ឍដីនិងការសាងសង់នូវបទប្បញ្ញត្តិប្រើប្រាស់ដីដែលបានកំណត់ក្នុងប្លង់គោលប្រើប្រាស់ដីសម្រាប់ប្រភេទដីអាច

សាងសង់បាននិងប្រភេទដីកម្រិតការសាងសង់មានជាអាទិ៍ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ សន្ទស្សន៍ប្រើប្រាស់ដី សួនច្បារជ្រាបទឹក ការដាំដើមឈើ ផ្លូវតម្រង់ ថ្នាតម្លាត ចំណតរថយន្ត អាងបង្គន់អនាម័យ អាងប្រព្រឹត្តកម្មទឹកកខ្វក់ ពណ៌អគារ សោភណភាព និងរចនាបថអគារ។ល។ ដើម្បីលើកកម្ពស់ការអនុវត្តប្លង់គោលប្រើប្រាស់ដីប្រកបដោយប្រសិទ្ធភាពខ្ពស់

- ពង្រឹងការត្រួតពិនិត្យនូវរាល់សកម្មភាពអភិវឌ្ឍន៍និងការសាងសង់លើប្រភេទដីដែលអាចសាងសង់បាននិងប្រភេទដីកម្រិតការសាងសង់តាមរយៈការចុះត្រួតពិនិត្យលើគម្រោងអភិវឌ្ឍជាក់ស្តែងនូវឯកសារដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនិងភាពត្រឹមត្រូវតាមផ្លូវច្បាប់ជាធរមានដូចជាលិខិតអនុញ្ញាតអភិវឌ្ឍដី លិខិតអនុញ្ញាតសាងសង់ជាដើម
- កំណត់ព្រំប្រទល់ប្រភេទដីកម្រិតការសាងសង់តាមរយៈការបោះបង្គោលឬសញ្ញាសំគាល់នៅលើដីជាក់ស្តែងដើម្បីគ្រប់គ្រងការអភិរក្ស ការអភិវឌ្ឍ និងការសាងសង់ផ្សេងៗ
- រៀបចំប្រជុំផ្សព្វផ្សាយប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុនិងតំបន់ជុំវិញដល់ក្រុមជំនាញវិនិយោគិន ប្រជាជន អង្គភាព និងស្ថាប័នពាក់ព័ន្ធតាមរយៈសិក្ខាសាលាផ្សព្វផ្សាយ ការបិទផ្សាយគម្រោងតាមប្រព័ន្ធឃោសនានានាដូចជាតាមវិទ្យុ ទូរទស្សន៍ កាសែត ទស្សនាវដ្តី និងបណ្តាញព័ត៌មាននិងគេហទំព័រឬតាមបណ្តាញសង្គមក្នុងប្រព័ន្ធអេឡិចត្រូនិករបស់រដ្ឋបាលខេត្តព្រះសីហនុនិងរដ្ឋបាលក្រុងព្រះសីហនុ។

## ៥.២.២-ការអភិវឌ្ឍលំនៅឋាន

នៅក្នុងការបែងចែកតំបន់ប្រើប្រាស់ដីនៃប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុ ចក្ខុវិស័យឆ្នាំ២០៣៥ តំបន់ដែលបម្រើដល់ការស្នាក់នៅនិងការតាំងលំនៅឋានមានតំបន់លំនៅឋាន តំបន់ពាណិជ្ជកម្ម និងតំបន់ចម្រុះ។ ដើម្បីជំរុញការអភិវឌ្ឍនិងការសាងសង់លំនៅឋាននៅក្នុងតំបន់ទាំងនេះនិងឆ្លើយតបទៅនឹងតម្រូវការលំនៅឋានជាក់ស្តែងនិងពេលអនាគត ផែនការសកម្មភាពសំខាន់ៗសម្រាប់អភិវឌ្ឍលំនៅឋានត្រូវបានកំណត់ដូចខាងក្រោម៖

- រៀបចំសិក្សា ចងក្រង និងកសាងទិន្នន័យប្រភេទ តម្រូវការ និងការផ្គត់ផ្គង់លំនៅឋានជាក់ស្តែង
- ផ្សព្វផ្សាយនិងផ្តល់ការណែនាំដល់ប្រជាជននូវវិធីសាស្រ្តសមស្របដែលជាលទ្ធភាពអាចទទួលបានលំនៅឋានសមរម្យតាមរយៈគ្រប់ខណ្ឌហិរញ្ញប្បទានផ្សេងៗក្នុងការសាងសង់ ជួសជុល និងកែលម្អលំនៅឋាន ពិសេសសម្រាប់គ្រួសារដែលមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាប និងក្រុមជនងាយរងគ្រោះ
- រៀបចំនិងជំរុញការអភិវឌ្ឍលំនៅឋានសាធារណៈនិងឯកជនសម្រាប់ជួលឬលក់ក្នុងតម្លៃសមរម្យតាមរយៈការបង់រំលស់ ពិសេសសម្រាប់គ្រួសារដែលមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាប និងក្រុមជនងាយរងគ្រោះ
- សហការជាមួយដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល សប្បុរសជន និងវិស័យឯកជនដើម្បីរៀបចំគម្រោងអភិវឌ្ឍលំនៅឋាន គម្រោងអភិវឌ្ឍសហគមន៍ គម្រោងស្ថាបនាមូលនិធិសន្សំសម្រាប់លំនៅឋាន ឬគម្រោងអភិវឌ្ឍដីសម្រាប់សាងសង់លំនៅឋាន និងគម្រោងសាងសង់លំនៅឋានមានតម្លៃសមរម្យសម្រាប់គ្រួសារដែលមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាប និងក្រុមជនងាយរងគ្រោះតាមរយៈការបង់រំលស់

- កៀរគរហិរញ្ញប្បទានអន្តរជាតិ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល វិស័យឯកជន សប្បុរសជន និងប្រភពហិរញ្ញប្បទានជាតិសម្រាប់ការងារលំនៅឋាននិងការតាំងលំនៅឋានថ្មី
- សហការនិងលើកទឹកចិត្តចំពោះការផ្តួចផ្តើមគំនិតនានារបស់សហគមន៍ឱ្យមានភាពម្ចាស់ការក្នុងការជួយខ្លួនឯង ការសន្សំប្រាក់ក្នុងសហគមន៍ និងការប្រើប្រាស់សហគមន៍សម្រាប់ការងារលំនៅឋាន
- ផ្សព្វផ្សាយនិងជំរុញការអនុវត្តគោលនយោបាយស្តីពីការលើកទឹកចិត្តនិងការបង្កើតកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ
- ផ្សព្វផ្សាយនិងអនុវត្តសារាចររបស់រាជរដ្ឋាភិបាលលេខ០៣ស.រ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់តាមរាជធានី ក្រុង និងទីប្រជុំជន
- ផ្សព្វផ្សាយនិងអនុវត្តគោលនយោបាយជាតិស្តីពីលំនៅឋាន។

## ៥.៣-ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ

### ៥.៣.១-ផ្លូវថ្នល់និងសេវាដឹកជញ្ជូនសាធារណៈ

#### ក-ផ្លូវថ្នល់

- កសាងផ្លូវល្បឿនលឿនសម្រាប់ការធ្វើដំណើរនិងការដឹកជញ្ជូនប្រកបដោយប្រសិទ្ធភាពនិងសុវត្ថិភាពរវាងក្រុងព្រះសីហនុនិងរាជធានីភ្នំពេញ
- ពង្រីកទទឹងទ្រូងផ្លូវជាតិលេខ៤ជាផ្លូវជាតិដ៏សំខាន់ដែលមានតួនាទីជាអ័ក្សអភិវឌ្ឍកសិកម្មឧស្សាហកម្មដើម្បីសម្រួលចរាចរណ៍និងឆ្លើយតបទៅនឹងតម្រូវការនៃការដឹកជញ្ជូនដែលកំពុងតែមានការកើនឡើង
- ពង្រីកកំណាត់ផ្លូវជាតិលេខ៤ចាប់ពីរង្វង់មូលអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុដើម្បីភ្ជាប់ជាមួយផ្លូវល្បឿនលឿនចូលមកក្រុងនិងអាកាសយានដ្ឋានអន្តរជាតិនេះឱ្យបាន៦គន្លងក្នុងនេះ៣គន្លងទៅនិង៣គន្លងមកដើម្បីសម្រួលចរាចរណ៍
- ជួសជុលនិងពង្រីកផ្លូវក្នុងក្រុងឡើងវិញចំនួន១១ខ្សែដែលមានប្រវែងសរុប៩៩ ១៦២ម៉ែត្រដែលក្នុងនោះមានកំណាត់ផ្លូវជាតិលេខ៤ ផ្លូវលេខ១៤៦បេ ផ្លូវក្រុងលេខ២០០ ផ្លូវក្រុងលេខ១០៤ និងផ្លូវក្រុងចំនួន៧ខ្សែផ្សេងទៀតដូចមាននិយាមកាកំណត់នៅក្នុងផែនទីយុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្រុងព្រះសីហនុដូចមាននុបសម្ព័ន្ធភ្ជាប់មកជាមួយ
- រៀបចំកសាងនិងកែលម្អផ្លូវស្របតាមបណ្តោយឆ្នេរសមុទ្រនិងបណ្តាញផ្លូវក្រុងឱ្យមានគុណភាពនិងសោភណភាពស្របតាមគោលការណ៍អភិវឌ្ឍបៃតង
- រៀបចំនិងកែលម្អចំណតរថយន្តសាធារណៈឱ្យស្របតាមបទដ្ឋានទីក្រុងស្អាត
- សាងសង់វិថីថ្មីចំនួន៣ខ្សែ ប្រវែង៣ ១៣៤ម៉ែត្រ ដើម្បីតភ្ជាប់ឆ្នេរសមុទ្រ[illegible] ប្រវែង១ ០៣៤ម៉ែត្រ វិថីពយ្ហួរឈើទាល ប្រវែង២៥០ម៉ែត្រ និងវិថីឆ្នេរ[illegible]ប្រវែង១ ៩៥០ម៉ែត្រ និងគោរពតាមបច្ចេកទេស
- កសាង ជួសជុល និងថែទាំមហាវិថី វិថី និងអនុវិថីចំនួន៣៤ខ្សែប្រវែង៨៤ ៩០៥ម៉ែត្រដូចមាននិយាមកាកំណត់ក្នុងផែនទីយុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្រុងព្រះសីហនុដូចមាននុបសម្ព័ន្ធ

ភ្ជាប់មកជាមួយនិងគោរពតាមបច្ចេកទេសសាងសង់រួមមានទំហំទ្រុងផ្លូវ ចំនួនគន្លងផ្លូវសម្រាប់រថយន្ត និងចំនួនគន្លងផ្លូវសម្រាប់មោចក្រយានយន្ត ទទឹងស្ទួនឡារ កម្រាស់បេតុង កម្រាស់កៅស៊ូ ទទឹងចិញ្ចើមផ្លូវ ចិញ្ចើមស្ទួន ចំណតតាមផ្លូវ ផ្លូវជិះកង់ ផ្លូវថ្មើរជើង លូទឹកភ្លៀង លូទឹកកខ្វក់ ប្រអប់ខ្សែកាប្លិ៍ បង្គោលភ្លើង។ល។ ដូចខាងក្រោម៖

១) មហាវិថីភមលេខ៤៥ មានប្រវែង៧ ២៥០ម៉ែត្រភ្ជាប់ពីផ្លូវជាតិលេខ៤មកអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុរហូតដល់មហាវិថីផ្សេះរាម មានទ្រុងផ្លូវទទឹង២៥,៧៥ម៉ែត្រ មាន៦គន្លងរថយន្តនិង២គន្លងមោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានស្ទួនកណ្តាលទទឹង១,៥០ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង១២,១៣ម៉ែត្រសងខាង និងមានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ។

២) មហាវិថីផ្សេះរាម ចាប់ពីរង្វង់មូលព្រះឧមាហេស្វរៈរហូតដល់រង្វង់មូលព្រះថោងព្រះនាងនាគមានប្រវែង៥ ៩៨១ម៉ែត្រ មានស្ពាន២កន្លែងដែលស្ពាននីមួយៗប្រវែង៧៥ម៉ែត្រនិងទទឹង២៥០ម៉ែត្រ មានទ្រុងផ្លូវទទឹង២៥,៧៥ម៉ែត្រ មាន៦គន្លងរថយន្តនិង២គន្លងមោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានស្ទួនកណ្តាលទទឹង១,៥០ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង១២,១៣ម៉ែត្រសងខាង និងមានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ។

៣) មហាវិថីជិទាវម៉ៅលេខ៤៧ ចាប់ពីផ្លូវជាតិលេខ៤រហូតដល់ចំណុចប្រសព្វវិថីសែនជ័យលេខ៤៩និងវិថីសែនត្រជាក់ចិត្តមានប្រវែង៩ ៥០០ម៉ែត្រ មានទ្រុងផ្លូវទទឹង២៥,៧៥ម៉ែត្រ មាន៦គន្លងរថយន្តនិង២គន្លងមោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានស្ទួនកណ្តាលទទឹង១,៥០ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង១២,១៣ម៉ែត្រសងខាង និងមានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ។

៤) វិថីលេខ៨៣៧-១ ចាប់ពីវិថីសែនជ័យលេខ៤៩រហូតដល់វិថីអូរគ្រេះមានប្រវែង១ ៧០៦ម៉ែត្រ មានទ្រុងផ្លូវទទឹង១៧,២៥ម៉ែត្រ មាន៤គន្លងរថយន្តនិង២គន្លងមោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង៦,៣៨ម៉ែត្រសងខាងដោយមានចិញ្ចើមស្ទួនទទឹង១,៥០ម៉ែត្រ មានផ្លូវជិះកង់១,៥០ម៉ែត្រ និងមានផ្លូវថ្មើរជើងទទឹង៣,៣៨ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ។

៥) វិថីអូរគ្រេះចាប់ពីស្ពានសែនត្រជាក់ចិត្តរហូតដល់វិថីមិត្តភាពមានប្រវែង៥ ៦៨៦ម៉ែត្រ

- កំណាត់ផ្លូវទី១ ចាប់ពីអូរត្រជាក់ចិត្តរហូតដល់សណ្ឋាគារម៉េងគ្រមានប្រវែង៩១៩ម៉ែត្រ មានទ្រុងផ្លូវទទឹង១០,២៥ម៉ែត្រ មាន២គន្លងរថយន្តនិង២គន្លងមោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង៤,៨៨ម៉ែត្រសងខាងដោយមានចិញ្ចើមស្ទួន១,៥០ម៉ែត្រ ផ្លូវជិះកង់១,៥០ម៉ែត្រ និងផ្លូវថ្មើរជើង១,៨៨ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ

- កំណាត់ផ្លូវទី២ ចាប់ពីសណ្ឋាគារម៉េងក្រូរហូតដល់ខ្លោងទ្វារឆ្នេរអូរព្រះមានប្រវែង២ ៥០៦ម៉ែត្រ មានទ្រូងផ្លូវទទឹង១៧,២៥ម៉ែត្រ មាន៤គន្លងរថយន្ត និងមាន២គន្លងទោចក្រយានយន្ត ដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង៦,៣៨ម៉ែត្រសងខាងដោយមានចិញ្ចើមស្មួន១,៥០ម៉ែត្រ ផ្លូវជិះកង់១,៥០ម៉ែត្រ និងផ្លូវថ្មើរជើង៣,៣៨ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ
- កំណាត់ផ្លូវទី៣ ចាប់ពីខ្លោងទ្វារឆ្នេរអូរព្រះរហូតដល់វិថីមិត្តភាពមានប្រវែង២ ២៦១ម៉ែត្រ មានទ្រូងផ្លូវទទឹង១៧,២៥ម៉ែត្រ មាន៤គន្លងរថយន្ត និងមាន២គន្លងទោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង១១,៣៨ម៉ែត្រសងខាងដោយមានចិញ្ចើមស្មួន១,៥០ម៉ែត្រ ផ្លូវជិះកង់១,៥០ម៉ែត្រ និងផ្លូវថ្មើរជើង៨,៣៨ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ។

៦) ផ្លូវកាត់ទទឹងវិថីអូរព្រះនិងវិថីឆ្នេរអូរព្រះមានប្រវែង៥៥២ម៉ែត្រ

- ប្រភេទទី១ ផ្លូវទទឹង៤០ម៉ែត្រមានប្រវែង៩២ម៉ែត្រ មានទ្រូងផ្លូវទទឹង១៧,២៥ម៉ែត្រ មាន៤គន្លងរថយន្តនិង២គន្លងទោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង១១,៣៨ម៉ែត្រសងខាងដោយមានចិញ្ចើមស្មួន១,៥០ម៉ែត្រ ផ្លូវជិះកង់១,៥០ម៉ែត្រ និងផ្លូវថ្មើរជើង៨,៣៨ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ
- ប្រភេទទី២ ផ្លូវទទឹង២០ម៉ែត្រមានប្រវែង៤៦០ម៉ែត្រ មានទ្រូងផ្លូវទទឹង១៧,២៥ម៉ែត្រ មាន២គន្លងរថយន្តនិង២គន្លងទោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង៤,៨៨ម៉ែត្រសងខាងដោយមានចិញ្ចើមស្មួន១,៥០ម៉ែត្រ និងផ្លូវថ្មើរជើង៣,៣៨ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ។

៧) វិថីអូរឈើទាលលេខ៥០០ចាប់ពីរង្វង់មូលគោពីររហូតដល់ស្ពានពយពាន់មានប្រវែង៣ ៧៤១ម៉ែត្រ

- កំណាត់ផ្លូវទី១ ចាប់ពីរង្វង់មូលគោពីររហូតដល់ផ្លូវលេខ៥០២មានប្រវែង២២៨ម៉ែត្រ មានទ្រូងផ្លូវទទឹង១២ម៉ែត្រ មាន២គន្លងរថយន្តនិង២គន្លងទោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង១៤ម៉ែត្រសងខាងដោយមានចិញ្ចើមស្មួន១,៥០ម៉ែត្រ ផ្លូវជិះកង់១,៥០ម៉ែត្រ និងផ្លូវថ្មើរជើង១១ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ
- កំណាត់ផ្លូវទី២ ចាប់ពីវិថីលេខ៥០២រហូតដល់ជីអាវីសុខមានប្រវែង១ ៣៦៤ម៉ែត្រ មានទ្រូងផ្លូវទទឹង១២ម៉ែត្រ មាន២គន្លងរថយន្តនិង២គន្លងទោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវ

ទទឹង១៩ម៉ែត្រសងខាងដោយមានចិញ្ចើមស្មូន១,៥០ម៉ែត្រ ផ្លូវជិះកង់១,៥០ម៉ែត្រ និងផ្លូវថ្មើរជើង១៦ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន១ខ្សែ

- កំណាត់ផ្លូវទី៣ ចាប់ពីឌីអារីស្តូនរហូតដល់ពយ៣៩មានប្រវែង២ ១៤៩ម៉ែត្រ មានទ្រូងផ្លូវទទឹង៨,២៥ម៉ែត្រ មាន២គន្លងរថយន្តនិង២គន្លងទោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង៤,៧៥ម៉ែត្រម្ខាងដោយមានចិញ្ចើមស្មូន១,៥០ម៉ែត្រ ម្ខាងមានផ្លូវជិះកង់២ម៉ែត្រ និងផ្លូវថ្មើរជើង៣ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន១ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន១ខ្សែ។

៨) វិថីពូឡូវ៉េលេខ៣០០ ចាប់ពីរង្វង់មូលតេជោពីររហូតដល់វិថីអូរឈើទាលលេខ៥០០មានប្រវែង ៣ ៣៧៤ម៉ែត្រ

- កំណាត់ផ្លូវទី១ ចាប់ពីរង្វង់មូលតេជោពីរទៅទល់ចំណុចប្រសព្វវិថីមិត្តភាពមានប្រវែង២ ៦១៩ម៉ែត្រ មានទ្រូងផ្លូវទទឹង១៧,២៥ម៉ែត្រ មាន៤គន្លងរថយន្តនិង២គន្លងទោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង១១,៣៨ម៉ែត្រសងខាងដោយមានចិញ្ចើមស្មូន១,៥០ម៉ែត្រ ផ្លូវជិះកង់១,៥០ម៉ែត្រ ផ្លូវថ្មើរជើង៨,៣៨ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ
- កំណាត់ផ្លូវទី២ ចាប់ពីចំណុចប្រសព្វវិថីមិត្តភាពរហូតដល់ផ្លូវកែងជិតព្រែកអូរឈើទាល មានប្រវែង៣៥២ម៉ែត្រ មានទ្រូងផ្លូវទទឹង១០,២៥ម៉ែត្រ មាន២គន្លងរថយន្តនិង២គន្លងទោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង៩,៨៨ម៉ែត្រសងខាងដោយមានចិញ្ចើមស្មូន១,៥០ម៉ែត្រ ផ្លូវថ្មើរជើង៨,៣៨ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ
- កំណាត់ផ្លូវទី៣ ចាប់ពីផ្លូវកែងជិតព្រែកអូរឈើទាលរហូតដល់ចំណុចប្រសព្វផ្លូវបំបែក មានប្រវែង២៨០ម៉ែត្រ មានទ្រូងផ្លូវទទឹង១០,២៥ម៉ែត្រ មាន២គន្លងរថយន្តនិង២គន្លងទោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង៤,៨៨ម៉ែត្រសងខាងដោយមានចិញ្ចើមស្មូន១,៥០ម៉ែត្រ ផ្លូវថ្មើរជើង៣,៣៨ម៉ែត្រ មានសាងសង់លូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ
- កំណាត់ផ្លូវទី៤ ចាប់ពីចំណុចប្រសព្វផ្លូវបំបែករហូតដល់វិថីអូរឈើទាលមានប្រវែង១២៥ម៉ែត្រ មានទ្រូងផ្លូវទទឹង១០,២៥ម៉ែត្រ មាន២គន្លងរថយន្តនិង២គន្លងទោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង៤,៨៨ម៉ែត្រសងខាងដោយមានចិញ្ចើមស្មូន១,៥០ម៉ែត្រ និងផ្លូវថ្មើរជើង៣,៣៨ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ។

៩) វិថីឯករាជ្យលេខ១១០០ ចាប់ពីរង្វង់មូលតេជោពិររហូតដល់ចំណុចប្រសព្វវិថីមិត្តភាពកម្ពុជា-រុស្ស៊ីលេខ៧០៥និងវិថីថៃព្រះសីហនុមានប្រវែង៥ ៣៦៥ម៉ែត្រ

- កំណាត់ផ្លូវទី១ ចាប់ពីរង្វង់មូលតេជោពិររហូតដល់រង្វង់មូលត្រីផ្លូហ៊ឺនមានប្រវែង៣ ៤០៨ម៉ែត្រ មានទទ្រុងផ្លូវទទឹង១៧,២៥ម៉ែត្រ មាន៤គន្លងរថយន្តនិង២គន្លងមោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង១១,៣៨ម៉ែត្រសងខាងដោយមានចិញ្ចើមសួន២,៥០ម៉ែត្រ ចំណតតាមផ្លូវ២,៥០ម៉ែត្រ ផ្លូវថ្មើរជើង៤,៨៨ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ
- កំណាត់ផ្លូវទី២ ចាប់ពីរង្វង់មូលត្រីផ្លូហ៊ឺនរហូតដល់សួនច្បារ (ភូនសោរ) មុខមន្ទីរអប់រំ យុវជន និងកីឡាខេត្តមានប្រវែង៥៥៣ម៉ែត្រ មានទទ្រុងផ្លូវទទឹង១៧,២៥ម៉ែត្រ មាន៤គន្លងរថយន្តនិង២គន្លងមោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង១៦,៣៨ម៉ែត្រសងខាងដោយមានចិញ្ចើមសួន២,៥០ម៉ែត្រ ចំណតតាមផ្លូវ២,៥០ម៉ែត្រ ផ្លូវថ្មើរជើង១៣,៨៨ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ
- កំណាត់ផ្លូវទី៣ ចាប់ពីសួនច្បារ (ភូនសោ) មុខមន្ទីរអប់រំ យុវជន និងកីឡាខេត្តរហូតដល់ស្តូបចាក់វិមានវិថីមិត្តភាពកម្ពុជា-រុស្ស៊ីមុខវេទិកាមានប្រវែង២៥០ម៉ែត្រ មានទទ្រុងផ្លូវទទឹង១៧,២៥ម៉ែត្រ មាន៤គន្លងរថយន្តនិង២គន្លងមោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង ១៦,៣៨ម៉ែត្រសងខាងដោយមានផ្លូវថ្មើរជើង១៦,៣៨ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ
- កំណាត់ផ្លូវទី៤ ចាប់ពីស្តូបចាក់វិមានវិថីមិត្តភាពកម្ពុជា-រុស្ស៊ីរហូតដល់វិថីមិត្តភាពកម្ពុជា-រុស្ស៊ីមុខវេទិកា(ត្រង់ចំណុចសណ្ឋាគារឆ្នេរថ្មី) មានប្រវែង១ ១៥៤ម៉ែត្រ មានទទ្រុងផ្លូវទទឹង១០,២៥ម៉ែត្រ មាន៤គន្លងរថយន្តនិង២គន្លងមោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់ ០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹងពី៧,៨៧ដល់ ១៤,៨៧ម៉ែត្រសងខាងដោយមានចិញ្ចើមសួន១,៥០ម៉ែត្រ ផ្លូវថ្មើរជើងពី៦,៣៧ដល់១៣,៣៧ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ។

១០) វិថី២ធ្នូលេខ៦០០ ចាប់ពីរង្វង់មូលតេជោពិររហូតដល់វិថីមិត្តភាពកម្ពុជា-រុស្ស៊ីលេខ៧០៥មានប្រវែង៦ ២៨៧ម៉ែត្រ មានស្ពាន១កន្លែងប្រវែង៥០ម៉ែត្រនៅចំណុចបឹងព្រែកទប់ មានទទ្រុងផ្លូវទទឹង១៧,២៥ម៉ែត្រ មាន៤គន្លងរថយន្តនិង២គន្លងមោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង១១,៣៨ម៉ែត្រសងខាងដោយមានចិញ្ចើមសួន១,៥០ម៉ែត្រ ផ្លូវជិះកង់១,៥០ម៉ែត្រ និងផ្លូវថ្មើរជើង៨,៣៨ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ។

១១)វិថីលម្អែព្រះភូមិន្ទលេខ៤០០ ចាប់ពីរង្វង់មូលតោពីរហូតដល់ផ្លូវលេខ៥០៧ស្របបឹងអារីស្ទូន មានប្រវែង១ ៣៤៦ម៉ែត្រ មានទ្រូងផ្លូវទទឹង១៧,២៥ម៉ែត្រ មាន៤គន្លងរថយន្តនិង២គន្លងទោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង១៦,៣៨ម៉ែត្រដោយមានចិញ្ចើមស្មួន១,៥០ម៉ែត្រ ផ្លូវជិះកង់១,៥០ម៉ែត្រ និងផ្លូវថ្មើរជើង១៣,៣៨ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ

១២)វិថីឆ្នេរអូរគ្រេះ ចាប់ពីជើងភ្នំពយ៣៩រហូតដល់ស្ពានសែនត្រជាក់ចិត្តមានប្រវែង៤ ៤៥០ម៉ែត្រ

- កំណាត់ផ្លូវទី១ ចាប់ពីជើងភ្នំពយ៣៩រហូតដល់អូរត្រជាក់ចិត្តមានប្រវែង៣ ៧៦៥ម៉ែត្រ មានទ្រូងផ្លូវទទឹង៨,២៥ម៉ែត្រ មាន២គន្លងរថយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រ និងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង៤,៧៥ម៉ែត្រ ដោយម្ខាងមានចិញ្ចើមស្មួន១,៥០ម៉ែត្រ ម្ខាងមានផ្លូវជិះកង់២ម៉ែត្រ និងផ្លូវថ្មើរជើង៣ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន១ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន១ខ្សែ
- ផ្លូវតាមជើងភ្នំពយ៣៩ មានប្រវែង៦៨៥ម៉ែត្រ មានទ្រូងផ្លូវទទឹង៨,២៥ម៉ែត្រ មាន២គន្លងរថយន្ត ដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ ម្ខាងមានចិញ្ចើមផ្លូវទទឹង៣ម៉ែត្រ និងមានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន១ខ្សែ។

១៣)វិថីប៉ុរីកម្មករលេខ១១២ ចាប់ពីវិថីមិត្តភាពកម្ពុជា-រុស្ស៊ីលេខ៧០៥រហូតដល់វិថីឯករាជ្យលេខ១០០មានប្រវែង១ ៩៤៦ម៉ែត្រ មានទ្រូងផ្លូវទទឹង១០,២៥ម៉ែត្រ មាន២គន្លងរថយន្តនិង២គន្លងទោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង៩,៨៨ម៉ែត្រសងខាងដោយមានចិញ្ចើមស្មួន១,៥០ម៉ែត្រ និងផ្លូវថ្មើរជើង៨,៣៨ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ។

១៤)វិថីជោតញ្ញាណលេខ៧០១ ចាប់ពីរង្វង់មូលរាជសីហមុខបីរហូតដល់កែងផ្លូវលេខ៨០១មានប្រវែង១ ០០៥ម៉ែត្រ មានទ្រូងផ្លូវទទឹង១០,២៥ម៉ែត្រ មាន២គន្លងរថយន្តនិង២គន្លងទោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹងចាប់ពី៤,៨៨ដល់៩,៨៨ម៉ែត្រសងខាងដោយមានផ្លូវថ្មើរជើងចាប់ពី៩,៧៥ដល់១៩,៧៥ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ។

១៥)ផ្លូវលេខ៨០១ ចាប់ពីវិថីជោតញ្ញាណលេខ៧០១រហូតដល់ទល់វិថីមិត្តភាពមានប្រវែង៩៦៤ម៉ែត្រ

- កំណាត់ផ្លូវទី១ ចាប់ពីផ្លូវលេខ៧០១រហូតដល់ក្បាលដីលេខ18010103-1031 មានប្រវែង៤៦៥ម៉ែត្រ មានទ្រូងផ្លូវទទឹង១០,២៥ម៉ែត្រ មាន២គន្លងរថយន្តនិង២គន្លងទោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង៤,៨៨ម៉ែត្រសងខាងដោយមានផ្លូវថ្មើរជើង៤,៨៨ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ

- កំណាត់ផ្លូវទី២ ចាប់ពីក្បាលដីលេខ18010103-1011រហូតដល់ក្បាលដីលេខ18010202-0452មានប្រវែង៣៩៦ម៉ែត្រ មានទទ្រឹងផ្លូវទទឹង១០,២៥ម៉ែត្រ មាន២គន្លងរថយន្តនិង២គន្លងទោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង២,៣៨ម៉ែត្រសងខាង ដោយមានផ្លូវថ្មើរជើង២,៣៨ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ
- កំណាត់ផ្លូវទី៣ ចាប់ពីក្បាលដីលេខ18010202-0452រហូតដល់វិថីមិត្តភាពមានប្រវែង១០៣ម៉ែត្រ មានទទ្រឹងផ្លូវទទឹង៧ម៉ែត្រ មាន២គន្លងរថយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង១,៥០ម៉ែត្រសងខាងដោយមានផ្លូវថ្មើរជើង១,៥០ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ។

១៦)វិថី២៨មិថុនាលេខ១២៣ ចាប់ពីរង្វង់មូលត្រីភ្នំហ៊ិនរហូតដល់វិថី២ធ្នូលេខ៦០០មានប្រវែង២ ០០០ម៉ែត្រ មានទទ្រឹងផ្លូវទទឹង១៧,២៥ម៉ែត្រ មាន៤គន្លងរថយន្តនិង២គន្លងទោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រ និងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង៨,១៣ម៉ែត្រសងខាងដោយមានចិញ្ចើមសួន២,៥០ម៉ែត្រ ផ្លូវជិះកង់២,០០ម៉ែត្រ និងផ្លូវថ្មើរជើង៦,១៣ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ។

១៧)ផ្លូវលេខ៥០១ ចាប់ពីវិថីអូរឈើទាលលេខ៥០០រហូតដល់វិថីពូឡូវ៉ៃលេខ៣០០មានប្រវែង២៥០ម៉ែត្រ មានទទ្រឹងផ្លូវទទឹង១០,២៥ម៉ែត្រ មាន២គន្លងរថយន្តនិង២គន្លងទោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង១៧,៣៨ម៉ែត្រសងខាងដោយមានចិញ្ចើមសួន១,៥០ម៉ែត្រ ផ្លូវជិះកង់១,៥០ម៉ែត្រ និងផ្លូវថ្មើរជើង១៤,៣៨ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ។

១៨)ផ្លូវលេខ៥០៣ ចាប់ពីវិថីអូរឈើទាលលេខ៥០០រហូតដល់វិថីលម្ហែព្រះភូមិន្ទលេខ៤០០មានប្រវែង១៣០ម៉ែត្រ មានទទ្រឹងផ្លូវទទឹង១០,២៥ម៉ែត្រ មាន២គន្លងរថយន្តនិង២គន្លងទោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង៩,៨៨ម៉ែត្រសងខាងដោយមានចិញ្ចើមសួន១,៥០ម៉ែត្រ ផ្លូវជិះកង់១,៥០ម៉ែត្រ និងផ្លូវថ្មើរជើង៦,៨៨ ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ។

១៩)ផ្លូវលេខ៥០៥ ចាប់ពីវិថីអូរឈើទាលលេខ៥០០រហូតដល់វិថីលម្ហែព្រះភូមិន្ទលេខ៤០០មានប្រវែង១៣០ម៉ែត្រ មានទទ្រឹងផ្លូវទទឹង១០,២៥ម៉ែត្រ មាន២គន្លងរថយន្តនិង២គន្លងទោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង៩,៨៨ម៉ែត្រសងខាងដោយមានចិញ្ចើមសួន១,៥០ម៉ែត្រ ផ្លូវជិះកង់១,៥០ម៉ែត្រ និងផ្លូវថ្មើរជើង៦,៨៨ម៉ែត្រ មានទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ។

២០)ផ្លូវលេខ៥០៧ ចាប់ពីវិថីអូរឈើទាលលេខ៥០០រហូតដល់វិថីពូឡូវៃលេខ៣០០មានប្រវែង២៦៧ម៉ែត្រ មានទ្រូងផ្លូវទទឹង១០,២៥ម៉ែត្រ មាន២គន្លងរថយន្តនិង២គន្លងទោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង៩,៨៨ម៉ែត្រសងខាងដោយមានចិញ្ចើមស្មៅ១,៥០ម៉ែត្រ ផ្លូវជិះកង់១,៥០ម៉ែត្រ និងផ្លូវថ្មើរជើង៦,៨៨ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ។

២១)វិថីមិត្តភាពកម្ពុជា-រុស្ស៊ីលេខ៧០៥ ចាប់ពីវិថីផែព្រះសីហនុរហូតដល់ចំណុចប្រសព្វវិថីឯករាជ្យលេខ១០០និងវិថីផែព្រះសីហនុមានប្រវែង៤ ៣៥៣ម៉ែត្រ

- កំណាត់ផ្លូវទី១ ចាប់ពីវិថីផែព្រះសីហនុរហូតដល់វិថីបុរីកម្មករមានប្រវែង៦២៨ម៉ែត្រ មានទ្រូងផ្លូវទទឹង១៧,២៥ម៉ែត្រ មាន៤គន្លងរថយន្តនិង២គន្លងទោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង១៦,៣៨ម៉ែត្រសងខាងដោយមានចិញ្ចើមស្មៅ១,៥០ម៉ែត្រនិងផ្លូវថ្មើរជើង១៤,៨៨ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ
- កំណាត់ផ្លូវទី២ ចាប់ពីវិថីបុរីកម្មកររហូតដល់ស្តួនច្រមុះជ្រូកព្រះនរាយណ៍មានប្រវែង៨៦០ម៉ែត្រ មានទ្រូងផ្លូវទទឹង១៧,២៥ម៉ែត្រ មាន៤គន្លងរថយន្តនិង២គន្លងទោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង១១,៣៨ម៉ែត្រសងខាងដោយមានចិញ្ចើមស្មៅ១,៥០ម៉ែត្រនិងផ្លូវថ្មើរជើង៩,៨៨ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ
- កំណាត់ផ្លូវទី៣ ចាប់ពីស្តួនច្រមុះជ្រូកព្រះនរាយណ៍រហូតដល់ស្តុបចរាចរណ៍ទល់នឹងវិថីឯករាជ្យ មានប្រវែង៦៤០ម៉ែត្រ មានទ្រូងផ្លូវទទឹង១០,២៥ម៉ែត្រ មាន២គន្លងរថយន្តនិង២គន្លងទោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង៩,៨៨ម៉ែត្រសងខាងដោយមានចិញ្ចើមស្មៅ១,៥០ម៉ែត្រនិងផ្លូវថ្មើរជើង៨,៣៨ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ
- កំណាត់ផ្លូវទី៤ ចាប់ពីស្តុបចរាចរណ៍រហូតដល់វិថី២ធ្នូលេខ៦០០មានប្រវែង៦៦៦ម៉ែត្រ មានទ្រូងផ្លូវទទឹង១០,២៥ម៉ែត្រ មាន២គន្លងរថយន្តនិង២គន្លងទោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង១៤,៨៨ម៉ែត្រសងខាងដោយមានចិញ្ចើមស្មៅ១,៥០ម៉ែត្រ និងផ្លូវថ្មើរជើង១៣,៣៨ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ
- កំណាត់ផ្លូវទី៥ ចាប់ពីវិថី២ធ្នូរហូតដល់ចំណុចប្រសព្វវិថីឯករាជ្យនិងវិថីផែមានប្រវែង១ ៥៥៩ម៉ែត្រ មានទ្រូងផ្លូវទទឹង១០,២៥ម៉ែត្រ មាន២គន្លងរថយន្តនិង២គន្លងទោចក្រយានយន្តដោយក្រាល

បេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង៩,៨៨ម៉ែត្រសងខាងដោយចិញ្ចើមស្មៅ១,៥០ម៉ែត្រ និងផ្លូវថ្មើរជើង៨,៣៨ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ។

២២)វិថីសែនជ័យលេខ៤៩ ចាប់ពីចំណុចប្រសព្វផ្លូវជាតិលេខ៤រហូតដល់មហាវិថីជ័យជំនះហ៊ុនសែន មានប្រវែង៦ ៥០៦ម៉ែត្រ មានស្ពានប្រអប់២កន្លែងដែលស្ពាននីមួយៗមានប្រវែង១៥ម៉ែត្រ មានទ្រូងផ្លូវទទឹង១៧,២៥ម៉ែត្រ មាន៤គន្លងរថយន្តនិង២គន្លងមោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវ ១១,៣៨ម៉ែត្រសងខាង មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ។

២៣)ផ្លូវគុជអាស៊ីលេខ១២៣៧ ចាប់ពីផ្លូវលេខ១១៥រហូតដល់វិថី២៨មិថុនាមានប្រវែង១០៦០ម៉ែត្រ មានទទឹងទ្រូងផ្លូវ១០,២៥ម៉ែត្រ មាន២គន្លងរថយន្តនិង២គន្លងមោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង៩,៨៨ម៉ែត្រសងខាងដោយមានផ្លូវថ្មើរជើង៩,៨៨ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ។

២៤)ផ្លូវលេខ១១៥ ចាប់ពីវិថី២ធ្នូលេខ៦០០រហូតដល់វិថីឯករាជ្យលេខ១០០មានប្រវែង១ ៤១៥ម៉ែត្រ

- កំណាត់ផ្លូវទី១ ចាប់ពីវិថី២ធ្នូរហូតដល់ចំណុចប្រសព្វរវាងវិថីគុជអាស៊ីនិងផ្លូវលេខ១១៥ មានប្រវែង៨០០ម៉ែត្រ មានទ្រូងផ្លូវទទឹង១០,២៥ម៉ែត្រ មាន២គន្លងរថយន្តនិង២គន្លងមោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង៩,៨៨ម៉ែត្រសងខាងដោយមានផ្លូវថ្មើរជើង៩,៨៨ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ
- កំណាត់ផ្លូវទី២ ចាប់ពីចំណុចប្រសព្វរវាងវិថីគុជអាស៊ីនិងផ្លូវលេខ១១៥រហូតដល់វិថីឯករាជ្យ មានប្រវែង៦១៥ម៉ែត្រ មានទ្រូងផ្លូវទទឹង១០,២៥ម៉ែត្រ មាន២គន្លងរថយន្តនិង២គន្លងមោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង៤,៨៨ម៉ែត្រសងខាងដោយមានផ្លូវថ្មើរជើង៤,៨៨ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ។

២៥)ផ្លូវលេខ៦០២ ចាប់ពីវិថី២ធ្នូលេខ៦០០រហូតដល់វិថី២៨មិថុនាលេខ១២៣មានប្រវែង៥៦៧ម៉ែត្រ មានទ្រូងផ្លូវទទឹង១០,២៥ មាន២គន្លងរថយន្តនិង២គន្លងមោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹងចាប់ពី៩,៧៥ដល់១៩,៧៥ម៉ែត្រសងខាងដោយមានផ្លូវថ្មើរជើងចាប់ពី៩,៧៥ដល់១៩,៧៥ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ។

២៦)វិថីសែនត្រជាក់ចិត្តចាប់ពីស្ពានសែនត្រជាក់ចិត្តរហូតដល់នឹងចំណុចប្រសព្វវិថីសែនជ័យលេខ ៤៩និងមហាវិថីជិតាវរម៉ៅលេខ៤៧មានប្រវែង៨០០ម៉ែត្រ មានទ្រូងផ្លូវទទឹង៨,២៥ម៉ែត្រនិងមាន២គន្លងរថយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់ ០,០៧ម៉ែត្រ។

២៧)វិថីឆ្នេរពេយជិតាវរម៉ៅ ចាប់ពីវិថីស្ពានសែនត្រជាក់ចិត្តរហូតដល់មហាវិថីជិតាវរម៉ៅលេខ៤៧មានប្រវែង៤ ៥៥០ម៉ែត្រ មានទ្រូងផ្លូវទទឹង៨,២៥ម៉ែត្រនិងមាន២គន្លងរថយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ។

២៨)ផ្លូវលេខ៥០២ ចាប់ពីវិថីអូរឈើទាលលេខ៥០០រហូតដល់កំពង់ផែទេសចរណ៍ឆ្នេរអូរឈើទាល មានប្រវែង៣២០ម៉ែត្រ មានទ្រូងផ្លូវទទឹង១០,២៥ម៉ែត្រ មាន២គន្លងរថយន្តនិង២គន្លងទោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់ ០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង១៤,៨៨ម៉ែត្រសងខាងដោយមានផ្លូវថ្មើរជើង១៤,៨៨ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ។

២៩)ផ្លូវលេខ៨១០ ចាប់ពីវិថីមិត្តភាពលេខ៨០០រហូតដល់ផ្លូវលេខ៨១៨មានប្រវែង១ ២៣៥ម៉ែត្រ មានទ្រូងផ្លូវទទឹង១០,២៥ម៉ែត្រ មាន២គន្លងរថយន្តនិង២គន្លងទោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង៤,៨៨ម៉ែត្រសងខាងដោយមានផ្លូវថ្មើរជើង៤,៨៨ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ។

៣០)ផ្លូវលេខ៨១៨ ចាប់ពីផ្លូវលេខ៨១០រហូតដល់ផ្លូវលេខ៨១៨មានប្រវែង៨០៥ម៉ែត្រ មានទ្រូងផ្លូវទទឹង១០,២៥ម៉ែត្រ មាន២គន្លងរថយន្តនិង២គន្លងទោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង៤,៨៨ម៉ែត្រសងខាងដោយមានផ្លូវថ្មើរជើង៤,៨៨ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ។

៣១)ផ្លូវលេខ១០២ ចាប់ពីវិថីព្ញូវៃរហូតដល់វិថីឯករាជ្យមានប្រវែង១ ៣១៧ម៉ែត្រ មានទ្រូងផ្លូវទទឹង១០,២៥ម៉ែត្រ មាន២គន្លងរថយន្តនិង២គន្លងទោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង៤,៨៨ម៉ែត្រសងខាងដោយមានផ្លូវថ្មើរជើង៤,៨៨ម៉ែត្រ ប្រវែង១ ៣១៧ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ។

៣២)ផ្លូវលេខ៨០៦ ចាប់ពីវិថីមិត្តភាពលេខ៨០០រហូតដល់ផ្លូវលេខ១០៦មានប្រវែង៧៣០ម៉ែត្រ មានទ្រូងផ្លូវទទឹង១០,២៥ម៉ែត្រ មាន២គន្លងរថយន្តនិង២គន្លងទោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង៩,៧៥ម៉ែត្រសងខាងដោយមានផ្លូវថ្មើរជើង៩,៧៥ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន១ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន១ខ្សែ។

៣៣)ផ្លូវលេខ១០៦ ចាប់ពីផ្លូវលេខ៨០៦រហូតដល់វិថីឯករាជ្យលេខ១១០០មានប្រវែងសរុប៤២៥ម៉ែត្រ មានទ្រុងផ្លូវទទឹង១០,២៥ម៉ែត្រ មាន២គន្លងរថយន្តនិង២គន្លងមោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង៤,៧៥ម៉ែត្រសងខាងដោយមានផ្លូវថ្មើរជើង៤,៧៥ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ។

៣៤)ផ្លូវលេខ១២៦ ចាប់ពីវិថីមិត្តភាពកម្ពុជា-រុស្ស៊ីលេខ៧០៥រហូតដល់វិថីឯករាជ្យលេខ១១០០មានប្រវែង៣៥០ម៉ែត្រ មានទ្រុងផ្លូវទទឹង១០,២៥ម៉ែត្រ មាន២គន្លងរថយន្តនិង២គន្លងមោចក្រយានយន្តដោយក្រាលបេតុងសរសៃដែកកម្រាស់០,២៥ម៉ែត្រនិងចាក់ក្រាលកៅស៊ូកម្រាស់០,០៧ម៉ែត្រ មានចិញ្ចើមផ្លូវទទឹង២,០៣ម៉ែត្រសងខាងដោយមានផ្លូវថ្មើរជើង២,០៣ម៉ែត្រ មានលូទឹកភ្លៀងមុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ និងមានលូទឹកកខ្វក់មុខកាត់ទំហំ១ម៉ែត្រចំនួន២ខ្សែ។

**ខ-សេវាដឹកជញ្ជូនសាធារណៈ**

- សិក្សាខ្សែដឹកជញ្ជូនសាធារណៈដោយគិតគូរអំពីការភ្ជាប់ទំនាក់ទំនងរវាងតំបន់ទេសចរណ៍សំខាន់ៗ នៅក្នុងក្រុង តំបន់កម្សាន្តមាត់សមុទ្រ តំបន់បេតិកភណ្ឌវប្បធម៌ និងតំបន់ដឹកជញ្ជូនមានជាអាទិ៍ ស្ថានីយអយស្ម័យយាននិងអាកាសយានដ្ឋានអន្តរជាតិ
- បង្កើតនិងដាក់ឱ្យដំណើរការនូវប្រព័ន្ធដឹកជញ្ជូនសាធារណៈទៅតាមគម្រោងបង្កើតសេវាដឹកជញ្ជូនសាធារណៈឱ្យបានគ្រប់តាមផែនការដូចបានកំណត់ក្នុងផែនទីយុទ្ធសាស្ត្រអភិវឌ្ឍវិស័យដឹកជញ្ជូនសាធារណៈដូចមានឧបសម្ព័ន្ធភ្ជាប់មកជាមួយ។ សេវាដឹកជញ្ជូនសាធារណៈត្រូវរៀបចំឡើងទៅតាមប្រព័ន្ធមួយដែលមានភាពទៀងទាត់ ភាពងាយស្រួលប្រកបដោយទំនុកចិត្ត គ្របដណ្តប់បានទូលំទូលាយក្នុងនិងក្រៅក្រុង មានចំណតគ្រប់គ្រាន់ និងមានតម្លៃសមរម្យដើម្បីបង្កើនប្រសិទ្ធភាពនិងទាក់ទាញសាធារណជនប្រើប្រាស់
- រៀបចំផែនការអប់រំនិងផ្សព្វផ្សាយដល់ប្រជាជនអំពីការទទួលសេវាដឹកជញ្ជូនសាធារណៈនិងអត្ថប្រយោជន៍ពីការប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈ។

**៥.៣.២-ផ្លូវដែក**

- បង្កើតស្ថានីយអយស្ម័យយានក្នុងក្រុងដោយភ្ជាប់ជាមួយនឹងបរិក្ខារសេវាកម្មផ្សេងៗ អគារពាណិជ្ជកម្ម អគារបម្រើសេវាដឹកជញ្ជូន និងភ្ជាប់ជាមួយនឹងសេវាដឹកជញ្ជូនផ្សេងៗទៀតដូចជារថយន្តក្រុង យានយន្តឯកជន និងយានយន្តដឹកអ្នកដំណើរផ្សេងៗទៀត
- បង្កើនប្រសិទ្ធភាពនៃការដឹកទំនិញចេញពីកំពង់ផែតាមរយៈការតភ្ជាប់ផ្លូវដែកទៅកាន់កំពង់ផែ។

**៥.៣.៣-ផ្លូវទឹកនិងកំពង់ផែ**

យោងតាមស្ថិតិពីកំពង់ផែស្វយ័តក្រុងព្រះសីហនុឆ្នាំ២០១៧ និងការផ្តល់អនុសាសន៍របស់ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) គម្រោងពង្រីកនិងអភិវឌ្ឍកំពង់ផែចែកចេញជា៖

- សាងសង់សំណង់ថ្មីដែលមានមុខងារច្រើនយ៉ាង ពង្រីកមុខងារចែកចាយ និងបំពាក់បរិក្ខារសម្រាប់ការចរាចរណ៍ទំនិញ (ផែនការរយៈពេលខ្លីឆ្នាំ២០២៣)

- កសាងស្ថានីយថ្មីសម្រាប់កុងតឺន័រដំណាក់កាលទី១ (ផែនការរយៈពេលមធ្យមឆ្នាំ២០៣០)
- កសាងស្ថានីយថ្មីសម្រាប់កុងតឺន័រដំណាក់កាលទី២និងទី៣ (ផែនការរយៈពេលវែងឆ្នាំ២០៤០)
- អភិវឌ្ឍផ្នែកខាងក្នុងនៃទំនប់ទឹកដែលមានស្រាប់ដំណាក់កាលទី១និងអភិវឌ្ឍផ្នែកខាងក្រៅទំនប់ទឹកដែលមានស្រាប់ដំណាក់កាលទី២ (ផែនការបន្ទាប់ពីឆ្នាំ២០៤០)។

### ៥.៣.៤-អាកាសចរស៊ីវិល

ដើម្បីឆ្លើយតបទៅនឹងកំណើនអ្នកធ្វើដំណើរមកកាន់ខេត្តព្រះសីហនុ រួមជាមួយការដឹកជញ្ជូនភស្តុភារកម្មសម្រាប់គោលដៅឆ្នាំ២០៣៨ ក្រុមហ៊ុន Cambodia Airports (VINCI) មានផែនការសកម្មភាពអភិវឌ្ឍវិស័យអាកាសចរស៊ីវិលក្រុងព្រះសីហនុតាមរយៈការពង្រីកស្ថានីយអ្នកដំណើរទៅទិសខាងត្បូងនៃស្ថានីយអ្នកដំណើរដែលមានស្រាប់សម្រាប់បំពេញមុខងារជាអាកាសយានដ្ឋានអន្តរជាតិ និងឆ្លើយតបទៅនឹងចំនួនអ្នកធ្វើដំណើរដែលត្រូវបានរំពឹងទុកថានឹងមានការកើនឡើងនាពេលអនាគត។ ទន្ទឹមនឹងនេះ ដើម្បីធ្វើឱ្យផែនការកែលម្អអាកាសយានដ្ឋានអន្តរជាតិកាន់តែមានភាពល្អប្រសើរឡើង ក្រុមហ៊ុនក៏មានគម្រោងកសាងសេវាដឹកជញ្ជូនសាធារណៈភ្ជាប់ពីអាកាសយានដ្ឋានអន្តរជាតិទៅកាន់ក្រុងព្រះសីហនុនាពេលអនាគតដើម្បីសម្រួលការធ្វើដំណើររវាងទីក្រុងនិងអាកាសយានដ្ឋាន។

### ៥.៣.៥-ការផ្គត់ផ្គង់ថាមពលនិងអគ្គិសនី

- ស្តារនិងអភិវឌ្ឍថាមពលនិងអគ្គិសនីដើម្បីគាំទ្រដល់ការអភិវឌ្ឍឧស្សាហកម្ម ទេសចរណ៍ សេដ្ឋកិច្ចនិងពាណិជ្ជកម្មដោយធានាបាននូវគុណភាពបរិស្ថានរស់នៅល្អ
- ពង្រីកបន្ថែមបណ្តាញអគ្គិសនីឱ្យដល់គ្រប់ភូមិនិងគ្រប់លំនៅឋាន
- រៀបចំបណ្តាញអគ្គិសនី ឬបណ្តាញបញ្ជូនអគ្គិសនី ខ្សែកាប្លិ៍គ្រប់ប្រភេទ កប់ក្នុងដី ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពនិងរក្សាដល់សោភណភាពទីក្រុង
- រៀបចំផែនការផ្សព្វផ្សាយនិងជំរុញលើកទឹកចិត្តឱ្យប្រើប្រាស់អគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យនិងថាមពលធម្មជាតិ
- រៀបចំផែនការផ្សព្វផ្សាយនិងជំរុញលើកទឹកចិត្តឱ្យប្រើប្រាស់ប្រព័ន្ធថាមពលឆ្លាត ដូចជាយានយន្តប្រើអាគុយ អំពូលឆ្លាត និងឧបករណ៍អគ្គិសនី និងសម្ភារៈឆ្លាត។

### ៥.៣.៦-ការផ្គត់ផ្គង់ទឹកស្អាតនិងធនធានទឹក

- ត្រួតពិនិត្យតាមដានការផ្គត់ផ្គង់និងការប្រើប្រាស់ទឹកដើម្បីធានានូវបរិមាណទឹកស្អាតប្រើប្រាស់ឱ្យបានគ្រប់គ្រាន់និងមានប្រសិទ្ធភាព
- សិក្សាប្រភពទឹកផ្សេងៗដើម្បីផ្គត់ផ្គង់ទឹកស្អាតសម្រាប់តំបន់កណ្តាលក្រុងនិងតំបន់ជាយក្រុង
- កសាងបទប្បញ្ញត្តិនិងចាត់វិធានការផ្សេងៗដើម្បីការពារប្រភពផ្គត់ផ្គង់ទឹកក្នុងក្រុងនិងតំបន់ជុំវិញ
- ស្តារឡើងវិញនិងដោះដូរបំពង់ទឹកចាស់ៗដើម្បីកាត់បន្ថយការលេចធ្លាយនិងបង្កើនគុណភាពទឹក
- ពង្រីកបន្ថែមនិងរក្សាការពារទីតាំងប្រភពទឹកស្អាតដើម្បីធានាការផ្គត់ផ្គង់ទឹកស្អាតរួមមានតំបន់ប្រើប្រាស់ច្រើនយ៉ាងក្បាលឆាយ អាងស្តុកទឹកកច្ចដា អាងស្តុកទឹកឃុំព្រៃនប់ ឃុំកំពេញ ស្ទឹងហាវ អាងស្តុក

ទឹកចង្កេះភ្នំបូកគោ អាងស្តុកទឹកទំនប់រលក អាងស្តុកទឹកទំនប់បង្កៀរឃុំអូរត្រេះ អាងស្តុកទឹករោងចក្រប្រេងកាតឃុំអូរត្រេះ អាងស្តុកទឹកឃុំកែវផុស ប្រភពទឹកស្អាតស្ទឹងអ៊ីនៃឃុំកំពង់សីលា អាងស្តុកទឹកបឹងកញ្ចែប និងអាងស្តុកទឹកមួយចំនួនទៀតនៅក្នុងខេត្តព្រះសីហនុ

- ពង្រឹងសមត្ថភាពនិងគ្រប់គ្រងដំណើរការថែទាំ ជួសជុល និងការពារបណ្តាញចែកចាយទឹកស្អាតស្របតាមបទដ្ឋានបច្ចេកទេស
- ការពារនិងថែរក្សាប្រភពទឹកធម្មជាតិពីតំបន់ប្រើប្រាស់ច្រើនយ៉ាងព្រៃកទឹកសាបក្បាលឆាយដែលជាប្រភពទឹកមានស្ថេរភាពបំផុតទាំងរដូវប្រាំងនិងវស្សាក្នុងការផ្គត់ផ្គង់ទឹកនៅក្រុងព្រះសីហនុនិងតំបន់ជុំវិញ។ នៅក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងព្រែកទឹកសាបក្បាលឆាយកំពុងធ្វើការសាងសង់ទំនប់ទឹកមានមុខងារច្រើនយ៉ាងនិងមានសមត្ថភាពស្តុកទឹកប្រមាណ៩ ៣៧៥ ០០០ម៉ែត្រគូបប្រកបដោយស្ថេរភាពទោះបីជានៅក្នុងរដូវប្រាំងក៏ដោយ។

## ៥.៤-ការអភិវឌ្ឍសេដ្ឋកិច្ច

### ៥.៤.១-ការអភិវឌ្ឍវិស័យទេសចរណ៍

#### ក-តំបន់សំណង់ស្ថាបត្យកម្មបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្រ្ត

- ការពារសំណង់និងទ្រព្យសម្បត្តិដែលមានស្រាប់នៅក្នុងព្រះរាជដំណាក់
- រៀបចំផែនការគ្រប់គ្រងឲ្យច្បាស់លាស់និងធ្វើការជួសជុល កែលម្អ និងរៀបចំសោភណភាពឡើងវិញដោយរក្សានូវទ្រង់ទ្រាយដើម
- កំណត់និងធ្វើផែនការប្រើប្រាស់ដីលម្អិតតំបន់ជុំវិញព្រះរាជដំណាក់ ដោយបែងចែកជាតំបន់ស្នូលនិងតំបន់ទ្រនាប់ក្នុងកាំរង្វង់៥០០ម៉ែត្រនិងត្រូវសិក្សាពីការបោមឃាត់ ការការពារ និងការកែលម្អ
- រៀបចំផែនការអភិវឌ្ឍទេសចរណ៍វប្បធម៌ប្រវត្តិសាស្រ្តព្រះរាជដំណាក់ ដោយចាប់ផ្តើមពីយន្តការនិងការគ្រប់គ្រងរហូតដល់ការបង្កើតហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍គាំទ្រ និងការផ្សព្វផ្សាយដល់ភ្ញៀវទេសចរជាតិនិងអន្តរជាតិ
- រៀបចំបង្កើតឱ្យមានក្រុមតន្ត្រីនិងក្រុមរបាំប្រពៃណី ដើម្បីសម្តែងជូនភ្ញៀវទេសចរទស្សនា។

#### ខ-តំបន់ទេសចរណ៍ធម្មជាតិ

- រៀបចំកែលម្អ និងគ្រប់គ្រងឆ្នេរសមុទ្រស្របតាមស្តង់ដារបច្ចេកទេសទាំងនៅលើដីគោក និងលើដីកោះ ដើម្បីទាក់ទាញភ្ញៀវទេសចរគ្រប់ប្រភេទ និងគ្រប់ជាតិសាសន៍មកសម្រាកកម្សាន្ត
- កំណត់តំបន់ប្រើប្រាស់ដីឱ្យបានច្បាស់លាស់ នៅឆ្នេរខ្សាច់ ព្រែក អូរ ព្រៃកោងកាង ស្មៅក្រោមទឹក តំបន់ឧទ្យានជាតិ និងតំបន់ប្រជុំកោះនានា ដើម្បីមានជាមូលដ្ឋានរឹងមាំគាំទ្រដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍សម្រាប់បង្កើតនិងអភិវឌ្ឍផលិតផលទេសចរណ៍ប្រកបដោយភាពទាក់ទាញ
- រៀបចំចងក្រងនិងបង្កើតសហគមន៍ទេសចរណ៍ដើម្បីជាយន្តការប្រកបដោយប្រសិទ្ធភាព ក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍមូលដ្ឋាន។

**គ-ការអភិវឌ្ឍផលិតផលទេសចរណ៍**

- អភិវឌ្ឍផលិតផលទេសចរណ៍ឆ្នេរខ្សាច់ សមុទ្រ និងកោះ ក្នុងនោះរួមទាំងការអភិវឌ្ឍទេសចរណ៍ក្រោមទឹកសមុទ្រ និងមុខទឹកសមុទ្រ ព្រមទាំងទេសចរណ៍ធម្មជាតិ ដូចកំណត់ក្នុងចំណុច (ខ)
- អភិវឌ្ឍផលិតផលទេសចរណ៍កីឡាលើទឹកសមុទ្រ ពិសេសហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ការរៀបចំព្រឹត្តិការណ៍កីឡាទេសចរណ៍លើទឹកសមុទ្រ
- លើកទឹកចិត្តដល់ការវិនិយោគអភិវឌ្ឍទេសចរណ៍ផ្ទះទី២ និងទេសចរណ៍សុខភាព
- កែលម្អនិងអភិវឌ្ឍកំពង់ផែទេសចរណ៍ខ្នាតអន្តរជាតិ ដែលអាចទទួលកប៉ាល់ប្រវែងលើសពី១០០ម៉ែត្រ ចំណតយន្តហោះលើទឹក និងម៉ារីណាទេសចរណ៍ស្របតាមស្តង់ដាអន្តរជាតិ ដើម្បីទាក់ទាញភ្ញៀវទេសចរតាមកប៉ាល់និងតាមទូកឯកជន
- លើកទឹកចិត្តដល់ការអភិវឌ្ឍបង្កើតតំបន់ទេសចរណ៍ពិសិដ្ឋស្របតាមអនុក្រឹត្យលេខ៤០អនក្រ.បក ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៩
- រៀបចំផលិតផលកសិ-ទេសចរណ៍ ពិសេសការដាំដុះបន្លែ ផ្លែឈើសុវត្ថិភាពតាមបែបទំនើប និងការចិញ្ចឹមសត្វសម្រាប់ផ្គត់ផ្គង់ភ្ញៀវទេសចរ ដើម្បីចូលរួមកាត់បន្ថយការធ្លាក់ចុះការធ្លាយសេដ្ឋកិច្ចក្នុងវិស័យទេសចរណ៍
- អភិវឌ្ឍផលិតផលទេសចរណ៍កម្រិតខ្ពស់ ដូចជាទេសចរណ៍វាយកូនហ្គោល និងប្រភេទទេសចរណ៍ MICE ជាដើម
- រៀបចំព្រឹត្តិការណ៍ទេសចរណ៍ជាតិនិងអន្តរជាតិ
- រៀបចំផែនការអភិវឌ្ឍតំបន់រមណីយដ្ឋានទេសចរណ៍សំខាន់ៗដែលមានស្រាប់ក្នុងក្រុងព្រះសីហនុ។

**ឃ-ខ្សែទស្សនកិច្ចទេសចរណ៍និងហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍**

- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍គាំទ្រដល់ការអភិវឌ្ឍផលិតផលទេសចរណ៍និងការតភ្ជាប់ជាកញ្ចប់ទស្សនកិច្ចទេសចរណ៍ពីតំបន់កម្សាន្តមួយទៅតំបន់កម្សាន្តមួយ
- កំណត់និងបង្កើតតំបន់ដែលអាចអភិវឌ្ឍចំណតរថយន្តទូទៅ និងចំណតសម្រាប់រថយន្តការ៉ាវ៉ាន់
- តភ្ជាប់ច្រករបៀងទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជានិងភាគខាងត្បូងតំបន់អាស៊ានតាមផ្លូវសមុទ្រ
- ធ្វើទំនើបកម្មបណ្តាញតភ្ជាប់ផ្លូវដែកពីក្រុងព្រះសីហនុ ទៅខេត្តតំបន់ឆ្នេរសមុទ្រផ្សេងៗទៀត និងភ្ជាប់ទៅរាជធានីភ្នំពេញ។

**ង-ការសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍**

- សិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍ឱ្យបានសកម្ម និងសហការជាមួយវិស័យឯកជនក្នុងការផលិតឯកសារផ្សព្វផ្សាយនិងសកម្មភាពផ្សព្វផ្សាយទាំងក្នុងនិងក្រៅប្រទេស
- អភិវឌ្ឍមជ្ឈមណ្ឌលផ្សព្វផ្សាយ មណ្ឌលព័ត៌មានទេសចរណ៍ និងគេហទំព័រតំបន់ឆ្នេរសមុទ្រដោយតភ្ជាប់ជាមួយគេហទំព័ររបស់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល អនុតំបន់ និងតំបន់។ល។
- អភិវឌ្ឍទីផ្សារទេសចរណ៍បៃតងនិងបង្កើតឱ្យមានផ្សាររាត្រី

- ផ្សព្វផ្សាយនិងទាក់ទាញឱ្យមានការហោះហើរត្រង់និងតាមនាវាទេសចរណ៍មកក្រុងព្រះសីហនុឱ្យបានច្រើន
- រៀបចំខ្សែទស្សនកិច្ចនៅក្នុងតំបន់ឆ្នេរសមុទ្រកម្ពុជាតភ្ជាប់ទៅប្រទេសជិតខាងនិងជំរុញការផ្សព្វផ្សាយ

**ច-សុវត្ថិភាពទេសចរណ៍**

- បន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយគ្រប់ភាគីពាក់ព័ន្ធ ដើម្បីពង្រឹងសន្តិសុខ និងសុវត្ថិភាពនៅក្នុងទីក្រុងក៏ដូចជាគោលដៅកម្សាន្តនានាទាំងនៅលើដីគោក និងនៅលើទឹក ដោយមានយន្តការបង្ការនិងឆ្លើយតបទាន់ពេលវេលា
- បន្តពង្រឹងដល់សុវត្ថិភាពចំណីអាហារ និងអនាម័យនៅតាមបណ្តាភោជនីយដ្ឋាន និងអាហារដ្ឋាន
- បន្តពង្រឹងការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ឱ្យបានម៉ឺងម៉ាត់នៅគ្រប់គោលដៅកម្សាន្ត និងគ្រប់មូលដ្ឋានអាជីវកម្មទេសចរណ៍។

**ឆ-ការអភិវឌ្ឍធនធានមនុស្ស**

- លើកទឹកចិត្តដល់ការបង្កើតមហាវិទ្យាល័យទេសចរណ៍ស្តង់ដាអន្តរជាតិ សម្រាប់ការបណ្តុះបណ្តាលកម្រិតឧត្តមសិក្សានិងក្រោយឧត្តមសិក្សា
- បង្កើតសាលាជំនាញវិជ្ជាជីវៈទេសចរណ៍តំបន់ឆ្នេរសមុទ្រគ្រប់ជំនាញ ដោយផ្សារភ្ជាប់ទ្រឹស្តីជាមួយនឹងការអនុវត្តជំនាញផ្ទាល់
- លើកទឹកចិត្តដល់មូលដ្ឋានអាជីវកម្មទេសចរណ៍ដើម្បីផ្តល់ឱកាសដល់បុគ្គលិកក្នុងការបណ្តុះបណ្តាលបន្ថែមពង្រឹងនិងអភិវឌ្ឍសមត្ថភាពជំនាញជាប្រចាំតាមរយៈអនឡាញនិងការបណ្តុះបណ្តាលផ្ទាល់
- ពង្រឹងដល់ការសិក្សាជំនាញវិជ្ជាជីវៈទេសចរណ៍នៅតាមវិទ្យាល័យ។

### ៥.៤.២-ការអភិវឌ្ឍវិស័យឧស្សាហកម្ម

**ក-លើកកម្ពស់ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសនិងវិស័យឧស្សាហកម្មបច្ចេកវិទ្យាទំនើបសម្រាប់ការនាំចេញ**

- កែលម្អនិងការពង្រឹងគម្រោងតំបន់សេដ្ឋកិច្ចពិសេសរួមមាន៖
  - គាំទ្រនិងលើកកម្ពស់ការវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេស
  - លើកទឹកចិត្តសម្រាប់ក្រុមហ៊ុនដែលបោះទីតាំងនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសសម្រាប់ទាំងក្រុមហ៊ុនបរទេស ក្រុមហ៊ុនក្នុងស្រុក និងសហគ្រាសធុនតូចនិងមធ្យម
  - ផ្សព្វផ្សាយនិងជំរុញការអនុវត្តច្បាប់ស្តីពីការវិនិយោគ និងផែនការរៀបចំដែនដីខេត្តព្រះសីហនុដល់ក្រុមហ៊ុនវិនិយោគ
  - លើកទឹកចិត្តចំពោះគម្រោងវិនិយោគដែលរួមចំណែកក្នុងការបណ្តុះបណ្តាលជំនាញ និងការសិក្សាស្រាវជ្រាវនិងអភិវឌ្ឍ
  - ជំរុញអនុវត្តឱ្យបានម៉ឺងម៉ាត់នូវលក្ខខណ្ឌនិងភារកិច្ចរបស់អ្នកអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស
  - កំណត់តំបន់កែច្នៃសម្រាប់ធ្វើការនាំចេញ

    - ចាត់វិធានការនិងជំរុញឱ្យមានការចូលរួមកាន់តែសកម្មថែមទៀតពីវិស័យឯកជនក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅតាមបណ្តាតំបន់សេដ្ឋកិច្ច សំដៅធានាឱ្យមានភាពទាក់ទាញនិងការចាប់អារម្មណ៍ពីសំណាក់វិនិយោគិនដែលកំពុងស្វែងរកទីតាំងបង្កើតមូលដ្ឋានផលិតកម្ម។
- ជ្រើសរើសយកប្រភេទនៃឧស្សាហកម្មដែលមានសក្តានុពលសម្រាប់ទិសដៅនាំចេញ
- លើកកម្ពស់ការប្រកួតប្រជែងរវាងតំបន់សេដ្ឋកិច្ចពិសេស តំបន់ឧស្សាហកម្មនានានៅក្នុងខេត្ត
- បង្កើតសួនឧស្សាហកម្មសម្រាប់សហគ្រាសធុនតូចនិងមធ្យមសំដៅជំរុញការតភ្ជាប់រវាងសហគ្រាសធំបរទេសនិងសហគ្រាសក្នុងស្រុក ពិសេសការចូលរួមក្នុងខ្សែច្រវាក់តម្លៃនិងច្រវាក់ផលិតកម្ម។

**ខ- លើកកម្ពស់ការអភិវឌ្ឍវិស័យឧស្សាហកម្មកែច្នៃផលិតផលក្នុងស្រុកនិងពង្រីកហេដ្ឋារចនាសម្ព័ន្ធដើម្បីបង្កើនចំណូលដល់អ្នកនៅជនបទ**

- បង្កើតបណ្តាញទំនាក់ទំនងរវាងតំបន់ទេសចរណ៍ ពង្រីកបច្ចេកវិទ្យា ហេដ្ឋារចនាសម្ព័ន្ធ និងផលិតផលកសិកម្មសម្រាប់ធ្វើការកែច្នៃនិងចែកចាយ
- ជំរុញវិនិយោគនៅក្នុងច្រវាក់ផលិតកម្មនិងការផ្គត់ផ្គង់ធំណាំឧស្សាហកម្មដែលមានតម្លៃខ្ពស់និងវិនិយោគទៅលើផលិតផលនិងធនធាននៅតាមតំបន់តាមរយៈឧស្សាហកម្មកែច្នៃចំណីអាហារ
- អភិវឌ្ឍនូវឧស្សាហកម្មកែច្នៃអាហារសម្រាប់ផលិតផលកសិកម្មនិងផលិតកម្មផ្សេងៗនិងការបន្ថែមតម្លៃបន្ថែមលើផលិតផលដើម្បីពង្រឹងការប្រកួតប្រជែងសម្រាប់ការនាំចេញ
- ជំរុញបង្កើតនូវតំបន់កែច្នៃកសិផលដូចជាតំបន់កែច្នៃផលិតសង្ហារឹម តំបន់កែច្នៃផលិតម្ហូបអាហារពីសមុទ្រ តំបន់កែច្នៃចំណីអាហារសម្រាប់គោលដៅប្រើប្រាស់ក្នុងស្រុកផងនិងនាំចេញផងដោយប្រើប្រាស់យន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន ព្រមទាំងផ្តល់ការលើកទឹកចិត្តចំពោះក្រុមហ៊ុនណាដែលបោះទីតាំងក្នុងតំបន់ទាំងនោះ
- បង្កើតមូលនិធិសម្រាប់ជំរុញការអភិវឌ្ឍផលិតផល បច្ចេកទេសកែច្នៃកសិផល និងអភិវឌ្ឍបច្ចេកទេសដោយភ្ជាប់ទៅនឹងសក្តានុពលនាំចេញ
- ជំរុញកំណត់មុខទំនិញអាទិភាពដែលមានសក្តានុពលកែច្នៃសម្រាប់នាំចេញ ហើយរៀបចំផែនការសកម្មភាពដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយដោយផ្អែកលើខ្សែច្រវាក់តម្លៃដើម្បីកំណត់មូលដ្ឋានគាំទ្រជាក់លាក់ដល់ការអភិវឌ្ឍវិស័យទាំងនោះ
- ធ្វើកសិកម្មសរីរាង្គដែលមានការកាត់បន្ថយការប្រើប្រាស់ជីគីមីសម្រាប់រយៈពេលវែង
- ចងក្រងសៀវភៅសម្រាប់កសិករនិងផ្សព្វផ្សាយអំពីការប្រើប្រាស់ជីគីមីកសិកម្ម
- ចងក្រងគោលការណ៍ណែនាំស្តីពីបរិស្ថាន។

**គ- ពង្រឹងនិងលើកស្ទួយរចនាសម្ព័ន្ធឧស្សាហកម្មនិងតម្លៃបន្ថែមលើផលិតកម្ម**

- រៀបចំតំបន់រោងចក្រដែលមានស្រាប់ឡើងវិញដោយធ្វើការកែប្រែទៅជាឧស្សាហកម្មដែលបន្ថែមតម្លៃបន្ថែមខ្ពស់លើផលិតផលតាមរយៈការពង្រឹងនិងកែលម្អឡើងវិញនូវរចនាសម្ព័ន្ធឧស្សាហកម្មដែលមានស្រាប់តាមរយៈ៖
    - ការបង្កើតប្រព័ន្ធសហប្រតិបត្តិការសមាហរណកម្មរវាងតំបន់ផលិតកម្មឧស្សាហកម្មនិងតំបន់សេដ្ឋកិច្ចពិសេស

▪ ការធ្វើការផ្លាស់ប្តូរពីវិធីសាស្ត្រនៃផលិតកម្មដែលពឹងផ្អែកលើកម្លាំងពលកម្មដែលគ្មានជំនាញទៅជាវិធីសាស្ត្រនៃផលិតកម្មតាមបច្ចេកវិទ្យាទំនើប

▪ លើកស្ទួយការប្រកួតប្រជែងតាមរយៈការផ្លាស់ប្តូរពីឧស្សាហកម្មដែលប្រើប្រាស់កម្លាំងពលកម្មច្រើនទៅជាឧស្សាហកម្មដែលប្រើប្រាស់បច្ចេកវិទ្យាទំនើបនិងប្រើប្រាស់វត្ថុធាតុដើមនៅក្នុងតំបន់។

– លើកស្ទួយការប្រកួតប្រជែងផ្នែកកាត់ដេរនិងវាយនភណ្ឌ តាមរយៈការពង្រឹងបច្ចេកវិទ្យានៃការផលិតនិងការប្រើប្រាស់វត្ថុធាតុដើមនៅក្នុងតំបន់ឧស្សាហកម្មព្រោះវិស័យវាយនភណ្ឌបានចូលរួមយ៉ាងសំខាន់នៅក្នុងកំណើនសេដ្ឋកិច្ចប្រទេសកម្ពុជា ប៉ុន្តែវិស័យនេះពឹងផ្អែកទៅលើការនាំចូលនូវវត្ថុធាតុដើម ដែលជាកត្តានាំឱ្យមានផលប៉ះពាល់ដល់សេដ្ឋកិច្ចនៅក្នុងស្រុក

– សហការនិងទាក់ទាញការវិនិយោគទាំងក្នុងស្រុកនិងក្រៅប្រទេសចូលមកវិនិយោគជាពិសេសនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ដើម្បីទាញយកនូវបច្ចេកវិទ្យាទំនើបនិងការគ្រប់គ្រងតាមបែបបច្ចេកវិទ្យាទំនើប។

### ឃ-ថែទាំនិងពង្រីកហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្មនិងអភិវឌ្ឍប្រព័ន្ធភស្តុភារកម្ម

– អភិវឌ្ឍប្រព័ន្ធដឹកជញ្ជូននិងភស្តុភារកម្មក្នុងគោលដៅបង្កើតប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយនិងប្រព័ន្ធភស្តុភារកម្មដែលមានសមាហរណកម្មនិងប្រសិទ្ធភាពខ្ពស់ ពិសេសផ្តោតលើការតភ្ជាប់ប៉ូលអភិវឌ្ឍនិងអ័ក្សនៃការអភិវឌ្ឍភ្នំពេញ-ព្រះសីហនុឱ្យក្លាយទៅជាអ័ក្សនៃការអភិវឌ្ឍគន្លឹះរបស់ជាតិតាមរយៈការកសាងផ្លូវល្បឿនលឿន និងការបង្កើតប្រព័ន្ធភស្តុភារកម្មប្រកបដោយប្រសិទ្ធភាព

– កសាងប្រព័ន្ធភស្តុភារកម្មតាមរយៈការតភ្ជាប់និងសមាហរណកម្មជាមួយនឹងបរិក្ខារដែលមានស្រាប់

– រៀបចំផែនការផ្គត់ផ្គង់អគ្គិសនីនិងទឹកស្អាតទៅកាន់តំបន់ឧស្សាហកម្ម និងផលិតកម្មសំខាន់ៗនៅក្នុងក្រុងនិងខេត្តដោយធានាឱ្យបានតាមតម្រូវការនិងស្មេរភាពជាមួយតម្លៃសមរម្យដែលអនុញ្ញាតឱ្យរោងចក្រអាចដំណើរការផលិតកម្មរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព

– រៀបចំនិងអនុវត្តផែនការបញ្ចុះថ្លៃអគ្គិសនីសម្រាប់វិស័យឧស្សាហកម្មនិងពាណិជ្ជកម្មរួមទាំងការពង្រឹងភាពទុកចិត្តនិងការពង្រីកវិសាលភាពគ្របដណ្តប់នៃការផ្គត់ផ្គង់អគ្គិសនី

– ពង្រីកបណ្តាញបច្ចេកវិទ្យាព័ត៌មាន ទូរគមនាគមន៍ និងបច្ចេកវិទ្យាទំនើបដទៃទៀត (ICT) ដើម្បីត្រៀមឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មទី៤

– ពង្រឹងមុខងារនៃការដឹកជញ្ជូនរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុជាកំពង់ផែទឹកជ្រៅដែលជាច្រកសំខាន់បំផុតសម្រាប់ការនាំចេញនាំចូលទំនិញក្នុងប្រទេស និងពង្រឹងការប្រកួតប្រជែងជាមួយនឹងកំពង់ផែអន្តរជាតិនៃប្រទេសជិតខាង

– ភ្ជាប់ទំនាក់ទំនងសមាហរណកម្មផ្លូវទាំងអស់ជាមួយគ្នានិងភ្ជាប់ទៅតំបន់សំខាន់ៗដទៃទៀត មានកំពង់ផែក្រុងព្រះសីហនុ តំបន់ស្ទឹងហាវតំបន់សេដ្ឋកិច្ចពិសេស តំបន់បិតត្រាំង និងអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ។

**ង-លើកកម្ពស់ការអប់រំ អភិវឌ្ឍធនធានមនុស្ស ទំនាក់ទំនងវិជ្ជាជីវៈ និងទីផ្សារពលកម្មដើម្បីទាក់ទាញការវិនិយោគនិងគាំទ្រដល់វិស័យឧស្សាហកម្ម**

– កសាងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈលើជំនាញអាទិភាពនិងជំនាញឯកទេសដើម្បីជំរុញការអភិវឌ្ឍឧស្សាហកម្មឱ្យមានភាពរឹងមាំ
– បណ្តុះបណ្តាលសមត្ថភាពនិងសហគ្រិនភាពនៃសហគ្រាសធុនតូចនិងមធ្យមដើម្បីអាចផ្សារភ្ជាប់និងទាញយកផលប្រយោជន៍ពីសក្តានុពលសហគ្រាសនិងវិនិយោគបរទេសធំៗស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេស
– គាំទ្រដល់ការផ្ទេរបច្ចេកវិទ្យាតាមរយៈទស្សនកិច្ចសិក្សានិងការបណ្តុះបណ្តាលពីក្នុងប្រទេសនិងពីបណ្តាប្រទេសនានា
– ពង្រឹងយន្តការទំនាក់ទំនងវិជ្ជាជីវៈត្រីភាគីរវាងរាជរដ្ឋាភិបាល និយោជក និងនិយោជិតតាមរយៈគណៈកម្មាធិការប្រឹក្សាការងារដើម្បីបង្កើតការយោគយល់គ្នានិងការរៀបចំប្រព័ន្ធយន្តការមួយប្រកបដោយប្រសិទ្ធភាពសម្រាប់កំណត់ប្រាក់ឈ្នួលអប្បបរមាដែលស៊ីសង្វាក់ទៅនឹងផលិតភាពការងារសមស្របតាមលក្ខខណ្ឌសេដ្ឋកិច្ច សង្គម
– ផ្តល់ព័ត៌មានពីទីផ្សារពលកម្មនិងការបណ្តុះបណ្តាលកម្មករឱ្យយល់ដឹងពីជីវភាពនិងសិទ្ធិស្របច្បាប់របស់ខ្លួន
– អនុវត្តគោលនយោបាយលំនៅឋានសម្រាប់កម្មករដែលអនុញ្ញាតឱ្យកម្មករអាចមានលទ្ធភាពធ្វើជាម្ចាស់កម្មសិទ្ធិលំនៅឋានសម្រាប់បង្កើតគ្រួសារ និងមិនធ្វើការផ្លាស់ប្តូរទីលំនៅញឹកញាប់ពេក ដែលបង្កើតបញ្ហាខ្វះកម្លាំងពលកម្មក្នុងរយៈពេលខ្លី
– ត្រៀមលក្ខណៈឱ្យបានល្អប្រសើរសម្រាប់ឧស្សាហកម្ម និងសហគ្រាសខ្នាតធំនិងសមាហរណកម្មអាស៊ានតាមរយៈការពង្រឹងយន្តការបណ្តុះបណ្តាលនិងគ្រប់គ្រងកម្មករជំនាញ
– កៀរគរកម្លាំងពលកម្មតាមរយៈទីភ្នាក់ងារជាតិមុខរបរនិងការងារ
– កសាងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីបណ្តុះបណ្តាលជំនាញឆ្លើយតបទៅនឹងតម្រូវការជំនាញមូលដ្ឋានផ្នែកកុំព្យូទ័រ ជំនាញព័ត៌មានវិទ្យា ជំនាញគ្រប់គ្រងជំនួញនិងធុរកិច្ច និងជំនាញផ្សេងៗទៀតដែលពាក់ព័ន្ធដើម្បីឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មទី៤
– រៀបចំផែនការផ្លាស់ប្តូរបន្តិចម្តងៗពីឧស្សាហកម្មដែលប្រើប្រាស់កម្លាំងពលកម្មច្រើនទៅជាឧស្សាហកម្មដែលប្រើបច្ចេកវិទ្យាព័ត៌មាន ទូរគមនាគមន៍ និងបច្ចេកវិទ្យាទំនើបផ្សេងទៀត
– បង្កើតគោលនយោបាយអភិវឌ្ឍយុទ្ធសាស្ត្រដើម្បីជួយគាំទ្រដល់សហគ្រាសខ្នាតតូចនិងមធ្យម។

**៥.៤.៣-ការអភិវឌ្ឍវិស័យកសិកម្ម**

– កសាងផែនការសកម្មភាពអភិរក្សធនធានជលផល កន្លែងត្រពាំង និងផលិតផលកសិកម្ម
– រៀបចំឱ្យមានកន្លែងចិញ្ចឹមត្រីតាមបែបធម្មជាតិស្របតាមតម្រូវការទីផ្សារ
– ផ្សព្វផ្សាយ លើកទឹកចិត្ត និងជំរុញការវិនិយោគក្នុងស្រុកនិងក្រៅស្រុកលើវិស័យកសិកម្មនិងកសិឧស្សាហកម្មប្រកបដោយចំណេះដឹងដោយផ្អែកលើធនធានសមុទ្រដើម្បីគាំទ្រដល់វិស័យទេសចរណ៍និងអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងក្រុង

- កំណត់ទីតាំងសម្រាប់អភិរក្សធនធានជលផល កន្លែងត្រីពង និងផលិតផលកសិកម្មដើម្បីលើកស្ទួយផលិតកម្មកសិកម្ម
- កំណត់ទីតាំង រៀបចំ និងអភិវឌ្ឍតំបន់កសិកម្មតាមភូមិផ្សារភ្ជាប់ជាមួយទេសចរណ៍
- ពង្រីកការកែច្នៃនិងវេចខ្ចប់ធនធានសមុទ្រដើម្បីលក់ជូនភ្ញៀវទេសចរ
- ពង្រីកធនធានជលផលមានដូចជាធនាគារក្ដាមនិងគ្រឿងសមុទ្រដទៃទៀត
- សិក្សានិងអភិវឌ្ឍផលិតផលកសិកម្មតាមតម្រូវការទីផ្សារទេសចរណ៍
- ផ្សព្វផ្សាយផលិតផលកសិកម្មដែលមានគុណភាពល្អក្នុងស្រុក
- បង្កើតមជ្ឈមណ្ឌលផ្សព្វផ្សាយនិងមណ្ឌលព័ត៌មានអំពីស្តង់ដាបច្ចេកទេសកសិកម្មដល់ប្រជាជន។

## ៥.៥-ការអភិវឌ្ឍសង្គមកិច្ច

### ៥.៥.១-វិស័យអប់រំ

- ថែរក្សាបរិក្ខារនិងសេវាអប់រំដែលមានស្រាប់
- កសាងបរិក្ខារអប់រំថ្មីនៅតំបន់ជុំវិញទីប្រជុំជន តំបន់ជាយក្រុង និងតំបន់ដែលខ្វះខាត
- បង្កើតសាលារៀនថ្មីដោយផ្អែកលើទំហំប្រជាសាស្ត្រនិងចំនួនសិស្សនៃតំបន់ដែលត្រូវបង្កើតសាលារៀនថ្មីនេះ
- រៀបចំកសាងបរិក្ខារអប់រំទូទៅនៅជុំវិញតំបន់លំនៅឋានរបស់ប្រជាពលរដ្ឋ
- បង្កើតសាលាបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈលើវិស័យទេសចរណ៍នៅទីប្រជុំជនក្រុង
- បង្កើតឱ្យមានសាលាបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈសម្រាប់វិស័យនុស្សាហកម្មនិងបណ្ដុះបណ្ដាលធនធានមនុស្សមានជំនាញកម្រិតខ្ពស់នៅតំបន់ស្នឹងហាវ
- បង្កើតឱ្យមានសាលាបណ្ដុះបណ្ដាលពហុបច្ចេកវិទ្យាជំនាញ
- បង្កើតវិទ្យាស្ថានស្រាវជ្រាវ អភិវឌ្ឍ បច្ចេកវិទ្យា និងនវានុវត្តន៍
- កសាងសាលាមត្តេយ្យសិក្សានិងបឋមសិក្សាដែលមានចម្ងាយយ៉ាងច្រើនត្រឹមកាំរង្វង់៥០០ម៉ែត្រឬភូមិមួយត្រូវមានសាលាមត្តេយ្យសិក្សានិងបឋមសិក្សាមួយយ៉ាងតិចឬស្របតាមបទដ្ឋានបច្ចេកទេសនិងស្ថានភាពភូមិសាស្ត្រនៃទីតាំងជាក់ស្តែង
- កសាងសាលាអនុវិទ្យាល័យដែលមានចម្ងាយយ៉ាងច្រើនត្រឹមកាំរង្វង់៣ ០០០ម៉ែត្រឬឃុំ សង្កាត់មួយត្រូវមានសាលាអនុវិទ្យាល័យមួយយ៉ាងតិចឬស្របតាមបទដ្ឋានបច្ចេកទេសនិងស្ថានភាពភូមិសាស្ត្រនៃទីតាំងជាក់ស្តែង។

### ៥.៥.២-វិស័យសុខាភិបាល

- ថែរក្សានិងកែលម្អបរិក្ខារបម្រើដល់វិស័យសុខភាពដែលមានស្រាប់
- កសាងបរិក្ខារសុខាភិបាលថ្មីនៅតំបន់ជុំវិញទីប្រជុំជន តំបន់ជាយក្រុង និងតំបន់ដែលខ្វះខាតនៅតំបន់ដាច់ស្រយាល
- រៀបចំបង្កើតពេទ្យបង្អែកចំនួនមួយឬពីរផ្សេងៗទៀត មួយនៅតំបន់បឹងព្រែកទប់ និងមួយទៀតនៅតំបន់ស្ទឹងហាវដោយគិតគូរទៅលើចំនួនប្រជាជននាពេលអនាគតនៅតំបន់នោះដែលមានចំនួនកើនឡើងដល់ទៅ៥០០ ០០០នាក់

- រៀបចំបង្កើតមណ្ឌលសុខភាពថ្មីចំនួនពាផ្សេងគ្នានៅក្រុងព្រះសីហនុមួយកន្លែង នៅតំបន់បិតត្រាងមួយកន្លែង និងមួយកន្លែងទៀតនៅតំបន់ស្ទឹងហាវដោយសិក្សាពីតុល្យភាពតំបន់ជុំវិញនិងការទទួលបានសេវាកម្មពីមណ្ឌលសុខភាពទាំងនោះ
- សម្របសម្រួលដល់វិស័យឯកជនដែលមានវិជ្ជាជីវៈក្នុងវិស័យសុខាភិបាលច្បាស់លាស់ ក្នុងការវិនិយោគនិងអភិវឌ្ឍមន្ទីរពេទ្យដែលមានគុណភាពនិងការប្រកួតប្រជែងខ្ពស់។

### ៥.៥.៣- ទីក្រុងឆ្លាតវៃក្នុងការគ្រប់គ្រងនិងអភិបាលកិច្ចល្អប្រកបដោយសេវាទីក្រុង ហេដ្ឋារចនាសម្ព័ន្ធទីក្រុង បរិក្ខារទីក្រុង និងផ្ដល់ការងារសម្បូរបែប

- អនុវត្តនិងលើកកម្ពស់ប្រសិទ្ធភាពក្នុងការផ្ដល់សេវារដ្ឋបាលសាធារណៈតាមរយៈអភិក្រមរបស់រាជរដ្ឋាភិបាលគឺទី១ ឆ្លុះកញ្ចក់ ទី២ ងូតទឹក ទី៣ ដុសក្អែល ទី៤ ព្យាបាល និងទី៥ វះកាត់
- បង្កើតប្រព័ន្ធរដ្ឋបាលអេឡិចត្រូនិកឆ្លាតក្នុងការគ្រប់គ្រងនិងផ្ដល់សេវា
- បណ្ដុះបណ្ដាលនិងអប់រំក្រមសីលធម៌ដល់មន្ត្រីគ្រប់កម្រិត
- កែលម្អ កែទម្រង់ និងលើកកម្ពស់ស្ថាប័ន
- តាមដាននិងត្រួតពិនិត្យការងារអនុវត្តទូទៅរបស់រដ្ឋបាលសាធារណៈ
- ថែរក្សា កែលម្អ និងជួសជុលអគារនិងបរិក្ខាររដ្ឋបាលដែលមានស្រាប់
- បំពាក់បរិក្ខាររដ្ឋបាលថ្មីដើម្បីឆ្លើយតបទៅនឹងកំណើនតម្រូវការនាពេលអនាគត
- ផ្ដល់នូវបរិក្ខាររដ្ឋបាលនៅតំបន់ស្ទឹងហាវដែលជាតំបន់ឧស្សាហកម្ម។

### ៥.៥.៤- លម្ហសាធារណៈ សួនច្បារ និងខ្សែក្រវាត់តំបន់បៃតង

- បង្កើតបណ្ដាញលម្ហសាធារណៈនិងផ្ទៃបៃតងនៅតាមបណ្ដោយឆ្នេរសមុទ្រ ដៃសមុទ្រ ព្រែក ស្ទឹង អូរ និងបណ្ដាញផ្លូវទឹកដែលតភ្ជាប់ទៅនឹងសមុទ្រ
- បង្កើតបណ្ដាញលម្ហសាធារណៈនិងផ្ទៃបៃតងនៅតាមតំបន់ការពារធម្មជាតិនិងតំបន់វប្បធម៌
- បង្កើតបណ្ដាញលម្ហសាធារណៈនិងផ្ទៃបៃតងតាមដងមហាវិថី វិថី អនុវិថី ផ្លូវជាតិលេខ៤ និងបណ្ដាញផ្លូវផ្សេងៗទៀត
- បង្កើតអ័ក្សអភិវឌ្ឍន៍បណ្ដាញបៃតងតភ្ជាប់ពីតំបន់ឆ្នេរសមុទ្រទៅតំបន់ការពារធម្មជាតិ តំបន់វប្បធម៌ សួន ឧទ្យាន និងបណ្ដាញលម្ហសាធារណៈនៅក្នុងក្រុងប្រកបដោយសោភណភាពនិងភាពទាក់ទាញ
- ថែរក្សានិងកែលម្អឧទ្យាននិងសួនដែលមានស្រាប់និងគិតគូរការបង្កើតសួនថ្មីដោយគិតគូរអំពីការរៀបចំសួនដែលនឹងបង្កើតថ្មីជាលម្ហសាធារណៈឱ្យស្របគ្នាជាមួយនឹងផែនការប្រើប្រាស់ដីបច្ចុប្បន្ន
- បង្កើតសួនផ្សេងៗគ្នាដើម្បីលើកកម្ពស់និងជំរុញដល់បរិយាកាសនៃការលម្ហែកម្សាន្ត៖
  - សួនច្បារភូមិសម្រាប់បម្រើដល់ប្រជាជនក្នុងសហគមន៍ឬតំបន់លំនៅឋានដែលមួយៗដែលអាចប្រើប្រាស់ដោយផ្ទាល់និងមិនផ្ទាល់។ សួននេះអាចមានទំហំ៥ ០០០ម៉ែត្រក្រឡា និងត្រូវមានចម្ងាយពីសួនមួយទៅសួនមួយយ៉ាងច្រើន២គីឡូម៉ែត្រ
  - សួនច្បារសង្កាត់សម្រាប់បម្រើដល់ប្រជាជនក្នុងសង្កាត់និងតំបន់ជិតខាងនូវសកម្មភាពសម្រាកកម្សាន្ត លម្ហែ និងកីឡា។ សួននេះអាចមានទំហំ៥ហិកតា

- សួនច្បារទីក្រុងសម្រាប់បម្រើដល់ប្រជាជនក្នុងទីក្រុងនូវសកម្មភាពសម្រាកកម្សាន្ត លម្ហែ និងកីឡា។ សួននេះអាចមានទំហំ១០ហិកតា
- សួនតំបន់ជាសួនខ្នាតធំដែលប្រើប្រាស់សម្រាប់តំបន់ឬទីក្រុងច្រើនក្នុងគោលបំណងថែរក្សាទេសភាពនិងសោភណភាពធម្មជាតិដែលប្រើប្រាស់សម្រាប់ការធ្វើដំណើរនិងការបោះជំរុំទេសចរណ៍និងកម្សាន្តរបស់ប្រជាជនក្នុងទីក្រុង។ សួននេះអាចមានទំហំ៥០ហិកតា។

### ៥.៥.៥-បរិក្ខារវប្បធម៌និងវប្បធម៌

- កសាងផែនការថែរក្សានិងការពារវត្តជោតញ្ញាណ (វត្តលើ) វត្តឥន្ទញ្ញាណ (វត្តក្រោម) វត្តអូរព្រះព្រះរាជដំណាក់ និងកំណត់តំបន់គ្រប់គ្រងនគរូបនីយកម្មជុំវិញដែលមានកាំរង្វង់៥០០ម៉ែត្រ
- បង្កើតហេដ្ឋារចនាសម្ព័ន្ធវប្បធម៌ដោយភ្ជាប់ទំនាក់ទំនងជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់នៅក្នុងក្រុងព្រះសីហនុ
- បង្កើតបរិក្ខារកីឡានិងវប្បធម៌ថ្មីដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់នាពេលអនាគត
- បង្កើតបរិក្ខារវប្បធម៌ដូចជាសារមន្ទីរឬមជ្ឈមណ្ឌលសិល្បៈនៅតំបន់ក្រុង តំបន់បិតត្រាង និងតំបន់ស្ទឹងហាវ
- បង្កើតបរិក្ខារសម្រាប់បម្រើដល់វិស័យកីឡាដូចជាពហុកីឡដ្ឋាននៅក្រុងព្រះសីហនុ នៅតំបន់បិតត្រាង និងនៅតំបន់ស្ទឹងហាវ។

### ៥.៥.៦-ការអភិវឌ្ឍសង្គមកិច្ច

- ដោះស្រាយសំណង់បណ្តោះអាសន្ននៅលើដីរដ្ឋ ដីចំណីឆ្នេរសមុទ្រ និងដីចំណីផ្លូវដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ
- បណ្តុះបណ្តាលជំនាញនិងអភិវឌ្ឍសមត្ថភាពរបស់ប្រជាជននៅជនបទឱ្យមានជំនាញវិជ្ជាជីវៈដែលអាចប្រកបមុខរបរបានដើម្បីលើកកម្ពស់កម្រិតជីវភាពគ្រួសារ
- សិក្សាលទ្ធភាពនិងរៀបចំគម្រោងសម្បទានដីសង្គមកិច្ចសម្រាប់ប្រជាជនក្រីក្រក្នុងក្រុង ប្រជាជនរស់នៅក្នុងសំណង់បណ្តោះអាសន្នគ្រប់កន្លែង ពិសេសក្នុងតំបន់ជាប់ព្រៃកនិងឆ្នេរសមុទ្រ
- រៀបចំបង្កើតផ្លូវថ្មើរជើង ផ្លូវជិះកង់ និងផ្លូវសម្រាប់ជនមានពិការភាព ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធបរិក្ខារ និងសេវាសម្រាប់ជនមានពិការភាពមានជាអាទិ៍ផ្លូវជម្រាលសម្រាប់បម្លាស់ទី ឧបករណ៍ថ្នាក់ដៃ ជណ្តើរ បង្គន់អនាម័យ ចំណតយានយន្ត និងផ្លាកសញ្ញា ពិសេសសម្រាប់ជនមានពិការភាពនៅតាមដងផ្លូវ សួនសាធារណៈ និងទីសាធារណៈ។

## ៥.៦-ការការពារបរិស្ថាននិងការគ្រប់គ្រងសំណល់

### ៥.៦.១-ការគ្រប់គ្រងសំណល់រឹង

- ធ្វើការកែលម្អប្រព័ន្ធដឹកជញ្ជូននិងការប្រមូលសំណល់រឹងតាមរយៈការធ្វើទំនើបកម្មប្រព័ន្ធប្រមូលសំណល់រឹងនិងមធ្យោបាយដឹកជញ្ជូន
- ប្រើប្រាស់និងអភិវឌ្ឍបច្ចេកវិទ្យាទំនើបក្នុងការគ្រប់គ្រងសំណល់រឹងនិងកែលម្អប្រព័ន្ធគ្រប់គ្រងសំណល់រឹងតាមរយៈ៖

- បង្កើតគោលនយោបាយនិងបទប្បញ្ញត្តិសម្រាប់ការប្រព្រឹត្តកម្មសំណល់រឹងប្រកបដោយអនាម័យ និងប្រសិទ្ធភាព
- ធ្វើការផ្សព្វផ្សាយនិងផ្តោតយកចិត្តទុកដាក់លើការប្រព្រឹត្តកម្មសំណល់រឹងប្រកបដោយអនាម័យ និងប្រសិទ្ធភាព ការបំលែងថាមពល និងការកែច្នៃសំណល់រឹង។

- រៀបចំផែនការត្រួតពិនិត្យ ការកែច្នៃឡើងវិញ និងការកាត់បន្ថយការផលិតសំណល់រឹងពីអ្នកប្រើប្រាស់
- កែច្នៃសំណល់រឹងឡើងវិញដូចជាក្រដាស ប្លាស្ទិច និងលោហធាតុក្នុងកម្រិតអតិបរមាដើម្បីកាត់បន្ថយការយកសំណល់រឹងចុងក្រោយទៅកប់ក្នុងដី
- បង្កើតបរិក្ខារប្រព្រឹត្តកម្មនិងធ្វើការកែច្នៃសំណល់រឹងស្របតាមបទដ្ឋានបច្ចេកទេស៖
  - សំណល់រឹងត្រូវយកទៅបោះចោលចុងក្រោយប្រកបដោយអនាម័យដូចជាកន្លែងប្រព្រឹត្តកម្មដែលមានស្ថេរភាពនិងការពារចំពោះការបំពុលបរិស្ថានដល់តំបន់ជុំវិញ
  - កន្លែងចាក់សំរាមត្រូវមានការប្រព្រឹត្តកម្មគម្របដីគ្របពីលើនិងរៀបចំប្រព័ន្ធបរិក្ខារបង្ហូរទឹកដែលហូរច្រោះពីសំរាមដើម្បីការពារក្លិនមិនល្អ ការពារទឹកក្រោមដី និងការបំពុលដី។
- ផ្តល់សម្ភារៈធ្វើការប្រកបដោយសុវត្ថិភាពនិងទុនសម្រាប់ការបណ្តុះបណ្តាល
- ផ្សព្វផ្សាយនិងអប់រំប្រជាជនពីការញែកសំរាមនៅតាមសាលារៀននិងទីសាធារណៈនិងជំរុញដល់ការអនុវត្តគោលការណ៍ការកាត់បន្ថយការប្រើប្រាស់ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃលើការគ្រប់គ្រងសំណល់រឹងនិងបង្កើតជីកំប៉ុស្តិ៍។

## ៥.៦.២-ការគ្រប់គ្រងសំណល់រាវ

### ក-ផែនការចំពោះមុខ

### ក.១-សាងសង់ស្ថានីយបូមទឹកកខ្វក់ចំនួន៤កន្លែង

- ស្ថានីយបូមទឹកកខ្វក់ទី១ ស្ថិតនៅឆ្នេរឯករាជ្យចន្លោះសណ្ឋាគារសោខាសាញបេនិងសណ្ឋាគារហូលីដេ មានទំហំ១១ម៉ែត្រ x ១៥ម៉ែត្រ ជម្រៅ៥ម៉ែត្រ ប្រើម៉ូទ័រចំនួន២គ្រឿង និងមានសមត្ថភាពបូម៣៦០ម៉ែត្រគូបក្នុងមួយម៉ោង
- ស្ថានីយបូមទឹកកខ្វក់ទី២ ស្ថិតនៅអូរសុខាចន្លោះសណ្ឋាគារសុខានិងសណ្ឋាគារស៊ីហ្វ មានទំហំ៨ម៉ែត្រ x ១៥ម៉ែត្រ ជម្រៅ៥,៥ម៉ែត្រ ប្រើម៉ូទ័របូមចំនួន២គ្រឿង និងមានសមត្ថភាពបូម៧២០ម៉ែត្រគូបក្នុងមួយម៉ោង
- ស្ថានីយបូមទឹកកខ្វក់ទី៣ ស្ថិតនៅអូរសម្លាតមានទំហំ១០ម៉ែត្រ x ២០ម៉ែត្រ ជម្រៅ៥,៥ម៉ែត្រ ប្រើម៉ូទ័របូមចំនួន៤គ្រឿង និងមានសមត្ថភាពបូម៧២០ម៉ែត្រគូបក្នុងមួយម៉ោង
- ស្ថានីយបូមទឹកកខ្វក់ទី៤ ស្ថិតនៅឆ្នេរអូរឈើទាល មានទំហំ១០,៨ម៉ែត្រ x ១៥ម៉ែត្រ ជម្រៅ៥,២ម៉ែត្រ ប្រើម៉ូទ័របូមចំនួន២គ្រឿង និងមានសមត្ថភាពបូម៧២០ម៉ែត្រគូបក្នុងមួយម៉ោង។

### ក.២-រៀបចំអណ្តូងល្ង

- អណ្តូងល្ង (MH-1) ស្ថិតនៅទីតាំងខាងកើតសណ្ឋាគារស៊ីហ្វមានទីខ្ពស់ +១៤ម៉ែត្រ
- អណ្តូងល្ង (MH-1a) ស្ថិតនៅទីតាំងផ្លូវប្រសព្វកែងបុរីគុជអាស៊ី

– អណ្តូងលូ (MH-2) ស្ថិតនៅទីតាំងទីខ្ពស់ +២៨ម៉ែត្រ
– អណ្តូងលូ (MH-3) ស្ថិតនៅទីតាំងជ្រុងខាងកើតនៃរង្វង់មូលតោពីរ
– អណ្តូងលូ (MH-3a) ស្ថិតនៅចន្លោះអណ្តូងលូ (MH-3) និង (MH-4)
– អណ្តូងលូ (MH-4) ស្ថិតនៅទីតាំងចុងខុយោរជំរស្មិតនិងលូបេតុង
– អណ្តូងលូ (MH-4a) ស្ថិតនៅទីតាំងកែងផ្លូវប្រសព្វអតីតអារីសុន
– អណ្តូងលូ (MH-5) ស្ថិតនៅទីតាំងអណ្តូងចាស់នៃមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តព្រះសីហនុ។

**ក.៣-រៀបចំដាក់បណ្តាញខុយោរជំរស្មិតនិងលូបេតុង**

– ពីស្ថានីយទី១ (PS-1) ទៅស្ថានីយទី៣ (PS-3) ប្រវែង២ ៧៩១ម៉ែត្រ
– ពីស្ថានីយទី១ (PS-1) ទៅអណ្តូងលូ (MH-1) ប្រវែង៩៦៩ម៉ែត្រ
– ពីស្ថានីយទី១ (PS-3) ទៅអណ្តូងលូ (MH-1) ប្រវែង១ ៨២២ម៉ែត្រ
– ពីស្ថានីយទី១ (PS-2) ទៅស្ថានីយទី៣ (PS-3) ប្រវែង៦៧០ម៉ែត្រ
– ពីស្ថានីយទី៣ (PS-3) ទៅអណ្តូងលូ (MH-2) និង (MH-3) រង្វង់មូលតោពីរ ប្រវែង៩២៥ម៉ែត្រ
– ពីស្ថានីយទី៣ (PS-4) ទៅអណ្តូងលូ (MH-4) ប្រវែង៤២៦ម៉ែត្រ
– លូបេតុងមុខកាត់១ម៉ែត្រពីអណ្តូងលូ (MH-3) ជ្រុងរង្វង់មូលតោពីរទៅអណ្តូងលូ (MH-4) កែងជីអារីសុន ប្រវែង៧៦០ម៉ែត្រនិង៧៤៨ម៉ែត្រ។

**ក.៤-ស្ពានប្រឡាយ**

– ស្ពានប្រឡាយអូរសុខាពីផ្លូវស្ពានថ្មរហូតដល់ឆ្នេរមាត់សមុទ្រប្រវែង១ ២២៤ម៉ែត្រ
– ស្ពានព្រែកអូរឈើទាលប្រវែង២ ៤០០ម៉ែត្រ
– ស្ពានប្រឡាយផ្សេងៗទៀតទៅតាមលំដាប់អាទិភាពដែលមាននៅក្នុងក្រុង។

**ខ-ផែនការរយៈពេលមធ្យមនិងរយៈពេលវែង**

**ខ.១-ប្រព័ន្ធលូទឹកភ្លៀងនិងលូទឹកកខ្វក់ដាច់ដោយឡែកពីគ្នា**

រៀបចំបំពាក់ប្រព័ន្ធលូតាមសងខាងមហាវិថី វិថី អនុវិថី និងផ្លូវបម្រើឱ្យការដឹកជញ្ជូនសំខាន់ៗដោយរៀបចំឱ្យមាន៖ ១)លូប្រមូលទឹកភ្លៀង ២)អណ្តូងលូសាធារណៈ ៣)លូទឹកភ្លៀង និង ៤)លូទឹកកខ្វក់។ លូទឹកភ្លៀងនិងលូទឹកកខ្វក់ត្រូវរៀបចំដាច់ពីគ្នា។

**ខ.២-ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់**

បញ្ចប់ការសាងសង់ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ទី១ (PS1) មានសមត្ថភាពចម្រោះទឹកកខ្វក់ចំណុះ ៥ ២០០ម៉ែត្រគូបក្នុងមួយថ្ងៃ ស្ថិតនៅឆ្នេរឯករាជ្យចន្លោះសណ្ឋាគារសាន់សាញបេនិងសណ្ឋាគារបេលីវ៉ូ និងស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ទី២ (PS2) មានសមត្ថភាពចម្រោះទឹកកខ្វក់ចំណុះ៣ ២០០ម៉ែត្រគូបក្នុងមួយថ្ងៃ ស្ថិតនៅអូរសម្លាញចន្លោះសណ្ឋាគារសុខានិងសណ្ឋាគារស៊ីហ្វូ និងកំពុងដំណើរការរៀបចំសាងសង់ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ទី៣ (PS3) មានសមត្ថភាពចម្រោះទឹកកខ្វក់ចំណុះ២០ ០០០ម៉ែត្រគូបក្នុងមួយថ្ងៃ ស្ថិតនៅ

ព្រែកអូរឈើទាល ដោយប្រើប្រាស់បច្ចេកវិទ្យាទំនើប MABR (Membrane Aerobic Biological Reactor) ដែលជាបច្ចេកវិទ្យាចុងក្រោយរបស់ប្រទេសអ៊ីស្រាអែលដែលមានលទ្ធភាពកម្ចាត់ពួកបាក់តេរីនិងដកយកនូវសារធាតុ BOD COD អាម៉ូញ៉ាក់ ($NH_3$-N) នីត្រាត ($NO_3$-N) ផូស្វរ (P) និងសារធាតុពុលផ្សេងទៀតដែលត្រូវបានទទួលស្គាល់ថាជាបច្ចេកវិទ្យាមានស្ថេរភាព ប្រសិទ្ធភាព សន្សំសំចៃថាមពល គ្មានសំឡេងរំខាន និងគ្មានក្លិនប៉ះពាល់ដល់អ្នករស់នៅជុំវិញ។

### ៥.៦.៣- ការបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថាន

កំណត់និងបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថានស្របតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលចែកចេញជាតំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ច្រើនយ៉ាងប្រកបដោយចីរភាព និងតំបន់សហគមន៍។

### ៥.៦.៤- វិធានការចាំបាច់ក្នុងការការពារតំបន់សំខាន់ៗ

- ការពារនិងថែរក្សាភ្នំ ធនធានធម្មជាតិ ព្រៃឈើនៅតាមកោះ សមុទ្រ ឆ្នេរសមុទ្រ ព្រែក បឹង ស្ទឹង អូរ និងបណ្តាញផ្លូវទឹកស្របតាមបទប្បញ្ញត្តិជាធរមាន
- ការពារនិងថែរក្សាព្រៃកោងកាងដើម្បីធានាប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាងមានផលិតភាពខ្ពស់និងមានសារសំខាន់នៅក្នុងអាយុកាលនៃសារពាង្គកាយក្នុងសមុទ្រដូចជាមានតួនាទីសំខាន់ជាកន្លែងពងកូន ឬកន្លែងរកចំណីសម្រាប់ធនធានវារីជាតនិងប្រភេទត្រីសមុទ្រ
- ការពារនិងថែរក្សាព្រៃតំបន់ប្រើប្រាស់ច្រើនយ៉ាងព្រែកទឹកសាបក្បាលឆាយនិងព្រៃក្នុងតំបន់ទីជម្រាល ដើម្បីធានាការគ្រប់គ្រងបរិស្ថានប្រកបដោយចីរភាព។

## ៥.៧- ការបង្ការទប់ស្កាត់គ្រោះមហន្តរាយ

### ៥.៧.១- ការបង្ការគ្រោះមហន្តរាយពីព្រែក អូរ ប្រឡាយ និងផ្លូវទឹកសំខាន់ៗ

- ថែរក្សា ការពារ និងស្តារពង្រីកបន្ថែមព្រែក អូរ ប្រឡាយ និងបណ្តាញផ្លូវទឹកទាំងអស់នៅក្នុងក្រុងព្រះសីហនុនិងតំបន់ជុំវិញដើម្បីធានាចីរភាពសម្រាប់អនាគត
- រៀបចំផែនការសកម្មភាពពិនិត្យ អង្កេត និងវិភាគរាល់បញ្ហាដូចជាកម្ពស់ទឹក ចរន្តទឹកហូរ បរិស្ថាន និងស្ថានភាពប្រើប្រាស់ព្រែក អូរ ប្រឡាយ និងបណ្តាញផ្លូវទឹកទាំងអស់ដើម្បីរៀបចំផែនការចាំបាច់សម្រាប់ការគ្រប់គ្រង ថែទាំ និងប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនិងបរិស្ថានល្អ
- កសាងខឿនការពារច្រាំងនៅតាមទីតាំងសំខាន់ៗនៃព្រែក អូរ ប្រឡាយ និងបណ្តាញផ្លូវទឹកសំខាន់ៗ ដើម្បីការពារការហូរច្រោះ ការបាក់ដី និងទឹកជំនន់ ពិសេសទីតាំងដែលអាចកំណើតខ្លាំង
- រៀបចំប្រព័ន្ធការពារទីជម្រាលនិងតំបន់ចំណោតស្របតាមបទដ្ឋានបច្ចេកទេសដើម្បីការពារស្រទាប់ដីខាងលើពីការហូរច្រោះនិងការបាក់ដីដូចជាការរៀបចំប្រព័ន្ធប្រឡាយការពារដីស្រទាប់ខាងលើ និងការរៀបចំប្រព័ន្ធបៃតងជាដើម។

### ៥.៧.២- ការការពារការស្ទះផ្លូវទឹកហូរ

- រៀបចំប្រព័ន្ធប្រឡាយនិងអណ្ដូងលូត្រងទឹកភ្លៀងពីផ្លូវចូលប្រព័ន្ធលូសាធារណៈមុននឹងហូរចាក់ចូលទៅប្រភពទឹកផ្សេងៗ
- រៀបចំផែនការកាត់បន្ថយល្បឿនទឹកភ្លៀងហូរតាមរយៈការបំពាក់បរិក្ខារផ្ទុកទឹកដូចជាអាងស្តុកទឹកនិងកន្លែងបង្ហូរទឹកដែលត្រូវបានរៀបចំបណ្ដោះអាសន្នសម្រាប់ទប់មិនឱ្យទឹកភ្លៀងទាំងអស់ត្រូវហូរចូលអាងស្តុកទឹកដោយផ្ទាល់ និងបរិក្ខារជម្រាបទឹកចូលក្នុងដីដើម្បីបន្ថយល្បឿនទឹកហូរនិងត្រូវបានដំឡើងដើម្បីបញ្ជ្រាបទឹកចូលក្នុងដីដើម្បីបន្ថយការហូរដោយផ្ទាល់នៃទឹកជំនន់។

### ៥.៧.៣- ការការពារការរាំងស្ទះខ្សែទឹកហូរដោយសារការអភិវឌ្ឍថ្មីៗ

- រៀបចំបង្កើតអាងដីល្បាប់និងប្រឡាយដែលភ្ជាប់ជាមួយនឹងអាងដីល្បាប់នោះនៅតំបន់អភិវឌ្ឍន៍ដើម្បីគ្រប់គ្រងនិងការពារការខូចដីតាមរយៈការកកដីនិងការបង្ហាក់ដល់ខ្សែទឹកហូរ
- ចាត់វិធានការតាមដានត្រួតពិនិត្យទីតាំងអភិវឌ្ឍន៍និងតម្រូវឱ្យមានការសាងសង់អាងដីល្បាប់និងប្រឡាយដែលភ្ជាប់ជាមួយនឹងអាងដីល្បាប់នៅកំឡុងពេលសាងសង់។

### ៥.៧.៤- ការបង្ការគ្រោះមហន្តរាយនៅទីចំណោត

- ចាត់វិធានការត្រួតពិនិត្យនិងតម្រូវឱ្យរៀបចំគួរប្លង់អភិវឌ្ឍន៍និងសំណង់ដែលមានស្ថេរភាពឬលំនឹងបំពាក់ដោយបរិក្ខារទប់ដីបន្ថែមនិងបរិក្ខារធានាសុវត្ថិភាពដើម្បីការពារគ្រោះមហន្តរាយពីការបាក់ដីនៅទីចំណោត
- តម្រូវឱ្យធ្វើការសិក្សាក្បាលំនឹងរបស់សំណង់សម្រាប់រាល់ការសាងសង់នៅតំបន់ចំណោតដើម្បីធ្វើការគ្រប់គ្រងសំណង់ប្រកបដោយប្រសិទ្ធភាព ការពារពីកត្តាហានិភ័យផ្សេងៗដូចជាភ្លៀងខ្លាំង ខ្យល់ព្យុះ និងការប្រែប្រួលអាកាសធាតុ។

### ៥.៧.៥- ការបង្ការគ្រោះមហន្តរាយតាមតំបន់ឆ្នេរសមុទ្រ

- សិក្សាលម្អិតនិងផ្តល់នូវគោលការណ៍ណែនាំស្តីពីការទប់ទល់ទៅនឹងខ្យល់ព្យុះ និងហានិភ័យផ្សេងៗនៅតំបន់ឆ្នេរសមុទ្រសម្រាប់រាល់ការអភិវឌ្ឍនៅតំបន់ឆ្នេរសមុទ្រ
- បង្កើតអាងស្តុកទឹកដែលមានមុខងារច្រើនយ៉ាងជាកន្លែងស្តុកទឹក សួនឧទ្យានកម្សាន្ត និងកន្លែងកីឡា ។ល។ នៅតំបន់ឆ្នេរសមុទ្រទំនាបដែលមានហានិភ័យទៅនឹងការជន់លិចដីទឹកសមុទ្រដើម្បីជួយសម្រួលស្តុកទឹកនោះនៅពេលដែលទឹកសមុទ្រជោរឡើងនិងជាអាងរងទឹកភ្លៀងនៅពេលដែលមានភ្លៀងខ្លាំងដើម្បីការពារការលិចលង់នៅតំបន់ទំនាបនេះ
- តាមដាននិងត្រួតពិនិត្យនូវរាល់ការអភិវឌ្ឍនៅតំបន់ឆ្នេរសមុទ្រត្រូវគោរពតាមសារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជានិងបទប្បញ្ញត្តិជាធរមាន។

## ៦-គម្រោងអាទិភាព

### ៦.១-ការអភិរក្សនិងការអភិវឌ្ឍតំបន់នគរូបនីយកម្ម

- រៀបចំវគ្គបណ្តុះបណ្តាលលើជំនាញគ្រប់គ្រងដីធ្លី និងនគរូបនីយកម្មដល់គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ខេត្តនិងថ្នាក់ក្រុងដែលមានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុងជាលេខាធិការក្នុងការគ្រប់គ្រងនិងការអនុវត្តការងាររៀបចំដែនដីនិងនគរូបនីយកម្ម
- កំណត់ព្រំប្រទល់រដ្ឋបាលក្រុង សង្កាត់ និងភូមិស្របតាមបទប្បញ្ញត្តិជាធរមាន
- ដាក់ឈ្មោះឬលេខមហាវិថី វិថី អនុវិថី និងផ្លូវទាំងអស់នៅក្នុងក្រុងនិងតំបន់ជុំវិញ
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃតំបន់អភិវឌ្ឍទីក្រុងថ្មី (គម្រោងអភិវឌ្ឍទីក្រុងរាម)
- រៀបចំបណ្តាញអគ្គិសនី ឬបណ្តាញបញ្ជូនអគ្គិសនី ខ្សែកាប្លិ៍គ្រប់ប្រភេទ កប់ក្នុងដី ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពនិងរក្សាដល់សោភណភាពទីក្រុង
- កែលម្អនិងស្តារបណ្តាញហេដ្ឋារចនាសម្ព័ន្ធមានផ្លូវ បណ្តាញទឹកស្អាត បណ្តាញអគ្គិសនី ការប្រមូលសំណល់រឹងនិងរាវឱ្យមានលក្ខណៈសមស្របនិងមានគុណភាពដើម្បីលើកកម្ពស់គុណភាពរស់នៅនិងសោភណភាពក្រុង
- កំណត់រចនាបថអគារ ពណ៌អគារ និងផ្លាកសញ្ញាផ្សព្វផ្សាយពាណិជ្ជកម្មតាមដងផ្លូវនិងតាមតំបន់ឱ្យមានសណ្តាប់ធ្នាប់និងសោភណភាពល្អស្របតាមទីតាំងភូមិសាស្ត្រជាក់ស្តែង
- រៀបចំផែនការប្រើប្រាស់ដីដោយកំណត់បទប្បញ្ញត្តិនៃការប្រើប្រាស់ដី ការអភិវឌ្ឍដី ការសាងសង់ និងប្លង់លម្អិតនគរូបនីយកម្មតាមតំបន់នីមួយៗស្របតាមការចាំបាច់និងទីតាំងភូមិសាស្ត្រជាក់ស្តែង។

### ៦.២-ការគ្រប់គ្រងនិងការប្រើប្រាស់ដីប្រកបដោយចីរភាព

#### ៦.២.១-ការគ្រប់គ្រងការអភិវឌ្ឍលើប្រភេទដីអាចសាងសង់បាននិងប្រភេទដីកម្រិតការសាងសង់

- បន្តចុះបញ្ជីដីធ្លីជាប្រព័ន្ធឱ្យបានចប់ទូទាំងក្រុងនិងតំបន់ជុំវិញ
- បណ្តុះបណ្តាលនិងពង្រឹងសមត្ថភាពមន្ត្រីដែលមានសមត្ថកិច្ចនិងពាក់ព័ន្ធក្នុងដំណើរការផ្តល់លិខិតអនុញ្ញាតអភិវឌ្ឍដី លិខិតអនុញ្ញាតសាងសង់ និងលិខិតពាក់ព័ន្ធផ្សេងៗសម្រាប់ការអភិវឌ្ឍដី និងការសាងសង់នូវបទប្បញ្ញត្តិប្រើប្រាស់ដីដែលបានកំណត់ក្នុងប្លង់គោលប្រើប្រាស់ដីសម្រាប់ប្រភេទដីអាចសាងសង់បាននិងប្រភេទដីកម្រិតការសាងសង់មានជាអាទិ៍ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ សន្ទស្សន៍ប្រើប្រាស់ដី សួនច្បារជ្រាបទឹក ការដាំដើមឈើ ផ្លូវតម្រង់ ឆ្លាតម្លាត ចំណតរថយន្ត អាងបង្គន់អនាម័យ អាងប្រព្រឹត្តកម្មទឹកកខ្វក់ ពណ៌អគារ សោភណភាព និងរចនាបថអគារ។ល។ ដើម្បីលើកកម្ពស់ការអនុវត្តប្លង់គោលប្រើប្រាស់ដីប្រកបដោយប្រសិទ្ធភាពខ្ពស់
- ផ្សព្វផ្សាយប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុនិងតំបន់ជុំវិញដល់គ្រប់និន្នាការវិនិយោគិន ប្រជាជន អង្គភាព និងស្ថាប័នពាក់ព័ន្ធតាមរយៈសិក្ខាសាលាផ្សព្វផ្សាយ ការបិទផ្សាយគម្រោងតាមប្រព័ន្ធឃោសនានានាដូចជាតាមវិទ្យុ ទូរទស្សន៍ កាសែត ទស្សនាវដ្តី និងបណ្តាញព័ត៌មាននិងគេហទំព័រឬតាមបណ្តាញសង្គមក្នុងប្រព័ន្ធអេឡិចត្រូនិករបស់រដ្ឋបាលខេត្តព្រះសីហនុនិងរដ្ឋបាលក្រុងព្រះសីហនុ។

### ៦.២.២-ការអភិវឌ្ឍលំនៅឋាន

- រៀបចំសិក្សា ចងក្រង និងកសាងទិន្នន័យប្រភេទ តម្រូវការ និងការផ្គត់ផ្គង់លំនៅឋានជាក់ស្តែង
- ផ្សព្វផ្សាយនិងផ្តល់ការណែនាំដល់ប្រជាជននូវវិធីសាស្ត្រសមស្របដែលជាលទ្ធភាពអាចទទួលបានលំនៅឋានសមរម្យតាមរយៈក្របខណ្ឌហិរញ្ញប្បទានផ្សេងៗក្នុងការសាងសង់ ជួសជុល និងកែលម្អលំនៅឋាន ពិសេសសម្រាប់គ្រួសារដែលមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាប និងក្រុមជនងាយរងគ្រោះ
- សហការជាមួយដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល សប្បុរសជន និងវិស័យឯកជនដើម្បីរៀបចំគម្រោងអភិវឌ្ឍលំនៅឋាន គម្រោងអភិវឌ្ឍសហគមន៍ គម្រោងស្ថាបនាមូលនិធិសង្គមសម្រាប់លំនៅឋាន ឬគម្រោងអភិវឌ្ឍដីសម្រាប់សាងសង់លំនៅឋាន និងគម្រោងសាងសង់លំនៅឋានមានតម្លៃសមរម្យសម្រាប់គ្រួសារដែលមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាប និងក្រុមជនងាយរងគ្រោះតាមរយៈការបង់រំលស់
- សហការនិងលើកទឹកចិត្តចំពោះការផ្តួចផ្តើមគំនិតនានារបស់សហគមន៍ឱ្យមានភាពម្ចាស់ការក្នុងការជួយខ្លួនឯង ការសន្សំប្រាក់ក្នុងសហគមន៍ និងការប្រើប្រាស់សហគមន៍សម្រាប់ការងារលំនៅឋាន។

## ៦.៣-ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ

### ៦.៣.១-ផ្លូវថ្នល់ សេវាដឹកជញ្ជូនសាធារណៈ និងថាមពល

- កសាងផ្លូវល្បឿនលឿនសម្រាប់ការធ្វើដំណើរនិងការដឹកជញ្ជូនប្រកបដោយប្រសិទ្ធភាពនិងសុវត្ថិភាពរវាងក្រុងព្រះសីហនុនិងរាជធានីភ្នំពេញ
- កសាង ជួសជុល និងថែទាំមហាវិថី វិថី និងអនុវិថីចំនួន៣៧ខ្សែប្រវែង៨៧ ៦៣៥ម៉ែត្រដោយកំណត់ចក្ខុវិស័យផ្លូវមិនត្រឹមតែសម្រាប់ធ្វើដំណើរប្រកបដោយប្រសិទ្ធភាពប៉ុណ្ណោះទេ ថែមទាំង៖ ១)ផ្លូវជាលម្ហសាធារណៈប្រកបដោយមេត្រីភាព សុវត្ថិភាព និងសមធម៌ ២)ផ្លូវដើម្បីកំណើនសេដ្ឋកិច្ចនិងអភិវឌ្ឍធុរកិច្ច ៣)ផ្លូវដើម្បីលើកកម្ពស់គុណភាពនគរូបនីយកម្ម ភាពធន់នឹងអាកាសធាតុ និងបរិស្ថានប្រកបដោយចីរភាព ដូចមាននិយាមកាកំណត់ក្នុងផែនទីយុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្រុងព្រះសីហនុដូចមានឧបសម្ព័ន្ធភ្ជាប់មកជាមួយ
- ជួសជុលនិងពង្រីកផ្លូវក្នុងក្រុងឡើងវិញចំនួន១១ខ្សែដែលមានប្រវែងសរុប៥៩ ១៦២ម៉ែត្រដែលក្នុងនោះមានកំណាត់ផ្លូវជាតិលេខ៤ ផ្លូវលេខ១៤៦បេ ផ្លូវក្រុងលេខ២០០ ផ្លូវក្រុងលេខ១០៤ និងផ្លូវក្នុងក្រុងចំនួន៧ខ្សែផ្សេងទៀតដូចមាននិយាមកាកំណត់នៅក្នុងផែនទីយុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្រុងព្រះសីហនុដូចមានឧបសម្ព័ន្ធភ្ជាប់មកជាមួយ
- បង្កើតនិងដាក់ឱ្យដំណើរការនូវប្រព័ន្ធដឹកជញ្ជូនសាធារណៈទៅតាមគម្រោងបង្កើតសេវាដឹកជញ្ជូនសាធារណៈឱ្យបានគ្រប់តាមផែនការដូចបានកំណត់ក្នុងផែនទីយុទ្ធសាស្ត្រអភិវឌ្ឍវិស័យដឹកជញ្ជូនសាធារណៈដូចមានឧបសម្ព័ន្ធភ្ជាប់មកជាមួយ។ សេវាដឹកជញ្ជូនសាធារណៈត្រូវរៀបចំឡើងទៅតាមប្រព័ន្ធមួយដែលមានភាពទៀងទាត់ ភាពងាយស្រួលប្រកបដោយទំនុកចិត្ត ត្រូវមណ្ឌលចំណតទូលំ

ទូលាយក្នុងនិងក្រៅក្រុង មានចំណតគ្រប់គ្រាន់ និងមានតម្លៃសមរម្យដើម្បីបង្កើនប្រសិទ្ធភាពនិងទាក់ទាញសាធារណជនប្រើប្រាស់

- ពង្រីកបន្ថែមបណ្ដាញអគ្គិសនីឱ្យដល់គ្រប់ភូមិនិងគ្រប់លំនៅឋាន
- បន្តនិងជំរុញលើកទឹកចិត្តឱ្យប្រើប្រាស់អគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យនិងថាមពលធម្មជាតិ។

### ៦.៣.២-ការផ្គត់ផ្គង់ទឹកស្អាត

- ស្ដារឡើងវិញនិងដោះដូរបំពង់ទឹកចាស់ៗដើម្បីកាត់បន្ថយការលេចធ្លាយនិងបង្កើនគុណភាពទឹក
- រក្សា កំណត់ ការពារ និងពង្រីកបន្ថែមទីតាំងប្រភពទឹកស្អាតដើម្បីធានាការផ្គត់ផ្គង់ទឹកស្អាតរួមមានតំបន់ប្រើប្រាស់ច្រើនយ៉ាងក្បាលឆាយ អាងស្តុកទឹកថ្មដា អាងស្តុកទឹកឃុំព្រៃនប់ ឃុំសំរុង ឃុំអណ្ដូងថ្ម អាងស្តុកទឹកចង្កេះភ្នំប្លុកគោ អាងស្តុកទឹកទំនប់រលក អាងស្តុកទឹកទំនប់បង្អៀរឃុំអូរព្រះ អាងស្តុកទឹករោងចក្រប្រេងកាតឃុំអូរព្រះ អាងស្តុកទឹកឃុំកែវផុស ប្រភពទឹកស្អាតស្ទឹងអ៊ីនៃឃុំកំពង់សីលា អាងស្តុកទឹកបឹងកង្កែប និងអាងស្តុកទឹកមួយចំនួនទៀតនៅក្នុងខេត្តព្រះសីហនុ
- ការពារនិងថែរក្សាប្រភពទឹកធម្មជាតិពីតំបន់ប្រើប្រាស់ច្រើនយ៉ាងព្រែកទឹកសាបក្បាលឆាយដែលជាប្រភពទឹកមានស្ថេរភាពបំផុតទាំងរដូវប្រាំងនិងវស្សាក្នុងការផ្គត់ផ្គង់ទឹកនៅក្រុងព្រះសីហនុនិងតំបន់ជុំវិញ។ នៅក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងព្រែកទឹកសាបក្បាលឆាយកំពុងធ្វើការសាងសង់ទំនប់ទឹកមានមុខងារច្រើនយ៉ាងនិងមានសមត្ថភាពស្តុកទឹកប្រមាណ៩ ៣៧៥ ០០០ម៉ែត្រគូបប្រកបដោយស្ថេរភាពទោះបីជានៅក្នុងរដូវប្រាំងក៏ដោយ។

## ៦.៤-ការអភិវឌ្ឍសេដ្ឋកិច្ច

### ៦.៤.១-ការអភិវឌ្ឍវិស័យទេសចរណ៍

#### ក-តំបន់សំណង់ស្ថាបត្យកម្មបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ

- ការពារសំណង់និងទ្រព្យសម្បត្តិដែលមានស្រាប់នៅក្នុងព្រះរាជដំណាក់
- រៀបចំផែនការគ្រប់គ្រងច្បាស់លាស់និងធ្វើការជួសជុល កែលម្អ និងរៀបចំសោភណភាពឡើងវិញដោយរក្សានូវទ្រង់ទ្រាយដើម
- កំណត់និងធ្វើផែនការប្រើប្រាស់ដីលម្អិតតំបន់ជុំវិញព្រះរាជដំណាក់ ដោយបែងចែកជាតំបន់ស្នូលនិងតំបន់ទ្រនាប់ក្នុងកាំរង្វង់៥០០ម៉ែត្រនិងត្រូវសិក្សាពីការហាមឃាត់ ការការពារ និងការកែលម្អ
- បង្កើតឱ្យមានក្រុមមន្ត្រីនិងក្រុមរបាំប្រពៃណី ដើម្បីសម្ដែងជូនភ្ញៀវទេសចរទស្សនា។

#### ខ-តំបន់ទេសចរណ៍ធម្មជាតិ

- រៀបចំកែលម្អ និងគ្រប់គ្រងឆ្នេរសមុទ្រស្របតាមស្តង់ដារបច្ចេកទេសទេសចរណ៍នៅលើដីគោក និងលើដីកោះ ដើម្បីទាក់ទាញភ្ញៀវទេសចរគ្រប់ប្រភេទ និងគ្រប់ជាតិសាសន៍មកសម្រាកកម្សាន្ត

- កំណត់តំបន់ប្រើប្រាស់ដីឱ្យបានច្បាស់លាស់ នៅឆ្នេរខ្សាច់ ព្រៃក អូរ ព្រៃកោងកាង ព្រៃលិចទឹក តំបន់ឧទ្យានជាតិ និងតំបន់ប្រជុំកោះនានា ដើម្បីមានជាមូលដ្ឋានរឹងមាំគាំទ្រដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍សម្រាប់បង្កើតនិងអភិវឌ្ឍផលិតផលទេសចរណ៍ប្រកបដោយភាពទាក់ទាញ
- រៀបចំចងក្រងនិងបង្កើតសហគមន៍ទេសចរណ៍ដើម្បីជាយន្តការប្រកបដោយប្រសិទ្ធភាព ក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍមូលដ្ឋាន។

**គ-ការអភិវឌ្ឍផលិតផលទេសចរណ៍**

- អភិវឌ្ឍផលិតផលទេសចរណ៍ឆ្នេរខ្សាច់ សមុទ្រ និងកោះ ក្នុងនោះរួមទាំងការអភិវឌ្ឍទេសចរណ៍ក្រោមទឹកសមុទ្រ និងមុជទឹកសមុទ្រ ព្រមទាំងទេសចរណ៍ធម្មជាតិ ដូចកំណត់ក្នុងចំណុច (ខ)
- អភិវឌ្ឍផលិតផលទេសចរណ៍កីឡាលើទឹកសមុទ្រ ពិសេសហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ការរៀបចំព្រឹត្តិការណ៍កីឡាទេសចរណ៍លើទឹកសមុទ្រ
- លើកទឹកចិត្តដល់ការអភិវឌ្ឍបង្កើតតំបន់ទេសចរណ៍ពិសិដ្ឋស្របតាមអនុក្រឹត្យលេខ៤០អនក្រ.បក ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៩
- រៀបចំផែនការអភិវឌ្ឍតំបន់រមណីយដ្ឋានទេសចរណ៍សំខាន់ៗដែលមានស្រាប់ក្នុងក្រុងព្រះសីហនុ។

**ឃ-ខ្សែចង្វាក់ទេសចរណ៍និងហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍**

- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍គាំទ្រដល់ការអភិវឌ្ឍផលិតផលទេសចរណ៍និងការតភ្ជាប់ជាកញ្ចប់ទស្សនកិច្ចទេសចរណ៍ពីតំបន់កម្សាន្តមួយទៅតំបន់កម្សាន្តមួយ
- កំណត់និងបង្កើតតំបន់ដែលអាចអភិវឌ្ឍចំណតរថយន្តទូទៅ និងចំណតសម្រាប់រថយន្តការ៉ាវ៉ាន់
- តភ្ជាប់ច្រករបៀងទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជានិងភាគខាងត្បូងតំបន់អាស៊ានតាមផ្លូវសមុទ្រ
- ធ្វើទំនើបកម្មបណ្តាញតភ្ជាប់ផ្លូវដែកពីក្រុងព្រះសីហនុ ទៅខេត្តតំបន់ឆ្នេរសមុទ្រផ្សេងៗទៀត និងភ្ជាប់ទៅរាជធានីភ្នំពេញ។

**ង-ការសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍**

- សិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍ឱ្យបានសកម្ម និងសហការជាមួយផ្នែកឯកជនក្នុងការផលិតឯកសារផ្សព្វផ្សាយនិងសកម្មភាពផ្សព្វផ្សាយទាំងក្នុងនិងក្រៅប្រទេស
- រៀបចំមណ្ឌលព័ត៌មានទេសចរណ៍ និងគេហទំព័រតំបន់ឆ្នេរសមុទ្រដោយតភ្ជាប់ជាមួយគេហទំព័ររបស់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល អនុតំបន់ និងតំបន់។ល។

**ច-សុវត្ថិភាពទេសចរណ៍**

- បន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយគ្រប់ភាគីពាក់ព័ន្ធ ដើម្បីពង្រឹងសន្តិសុខ និងសុវត្ថិភាពនៅក្នុងទីក្រុងក៏ដូចជាគោលដៅកម្សាន្តនានាទាំងនៅលើដីគោក និងនៅលើទឹក ដោយមានយន្តការសង្គ្រោះនិងឆ្លើយតបទាន់ពេលវេលា
- បន្តពង្រឹងដល់សុវត្ថិភាពចំណីអាហារ និងអនាម័យនៅតាមបណ្តាភោជនីយដ្ឋាន និងអាហារដ្ឋាន
- បន្តពង្រឹងការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ឱ្យបានម៉ឺងម៉ាត់នៅគ្រប់គោលដៅកម្សាន្ត និងគ្រប់មូលដ្ឋានអាជីវកម្មទេសចរណ៍។

### ឆ-ការអភិវឌ្ឍធនធានមនុស្ស

- លើកទឹកចិត្តដល់ការបង្កើតមហាវិទ្យាល័យទេសចរណ៍ស្តង់ដាអន្តរជាតិ សម្រាប់ការបណ្តុះបណ្តាលកម្រិតឧត្តមសិក្សានិងក្រោយឧត្តមសិក្សា
- បង្កើតសាលាជំនាញវិជ្ជាជីវៈទេសចរណ៍តំបន់ឆ្នេរសមុទ្រគ្រប់ជំនាញ ដោយផ្សារភ្ជាប់ទ្រឹស្តីជាមួយនឹងការអនុវត្តជំនាញផ្ទាល់
- លើកទឹកចិត្តដល់មូលដ្ឋានអាជីវកម្មទេសចរណ៍ដើម្បីផ្តល់ឱកាសដល់បុគ្គលិកក្នុងការបណ្តុះបណ្តាលបន្ថែមពង្រឹងនិងអភិវឌ្ឍសមត្ថភាពជំនាញជាប្រចាំតាមរយៈអនឡាញនិងការបណ្តុះបណ្តាលផ្ទាល់
- ពង្រឹងដល់ការសិក្សាជំនាញវិជ្ជាជីវៈទេសចរណ៍នៅតាមវិទ្យាល័យ។

## ៦.៤.២-ការអភិវឌ្ឍវិស័យឧស្សាហកម្ម

### ក-លើកកម្ពស់ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសនិងវិស័យឧស្សាហកម្មបច្ចេកវិទ្យាទំនើបសម្រាប់ការនាំចេញ

- គាំទ្រនិងលើកកម្ពស់ការវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេស
- ផ្សព្វផ្សាយច្បាប់ស្តីពីការវិនិយោគ និងផែនការរៀបចំដែនដីខេត្តព្រះសីហនុដល់ក្រុមហ៊ុនវិនិយោគ
- លើកកម្ពស់ការប្រកួតប្រជែងរវាងតំបន់សេដ្ឋកិច្ចពិសេស តំបន់ឧស្សាហកម្មនានានៅក្នុងខេត្តដោយសិក្សានូវសូចនាករស្នូលសម្រាប់វាស់ស្ទង់សមិទ្ធិកម្មនៃកិច្ចដំណើរការនៃតំបន់សេដ្ឋកិច្ចពិសេស និងឧស្សាហកម្មទាំងនោះសម្រាប់ជាលក្ខណៈវិនិច្ឆ័យក្នុងការផ្តល់ការលើកទឹកចិត្ត។

### ខ-លើកកម្ពស់ការអភិវឌ្ឍវិស័យឧស្សាហកម្មកែច្នៃផលិតផលក្នុងស្រុកនិងពង្រីកហេដ្ឋារចនាសម្ព័ន្ធដើម្បីបង្កើនចំណូលដល់អ្នកនៅជនបទ

- បង្កើតបណ្តាញទំនាក់ទំនងរវាងតំបន់នគរូបនីយកម្ម ពង្រីកបច្ចេកវិទ្យា ហេដ្ឋារចនាសម្ព័ន្ធ និងផលិតផលកសិកម្មសម្រាប់ធ្វើការកែច្នៃនិងចែកចាយ
- វិនិយោគនៅក្នុងច្រវាក់ផលិតកម្មនិងការផ្គត់ផ្គង់ដំណាំឧស្សាហកម្មដែលមានតម្លៃខ្ពស់និងវិនិយោគទៅលើផលិតផលនិងធនធាននៅតាមតំបន់តាមរយៈឧស្សាហកម្មកែច្នៃចំណីអាហារ
- បង្កើតនូវតំបន់កែច្នៃកសិផលដូចជាតំបន់កែច្នៃផលិតសង្ហារឹម តំបន់កែច្នៃផលិតម្ហូបអាហារពីសមុទ្រ តំបន់កែច្នៃចំណីអាហារសម្រាប់គោលដៅប្រើប្រាស់ក្នុងស្រុកផងនិងនាំចេញផងដោយប្រើប្រាស់យន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន ព្រមទាំងផ្តល់ការលើកទឹកចិត្តចំពោះក្រុមហ៊ុនណាដែលបោះទីតាំងក្នុងតំបន់ទាំងនោះ
- បង្កើតមូលនិធិសម្រាប់ជំរុញការអភិវឌ្ឍផលិតផល បច្ចេកទេសកែច្នៃកសិផល និងអភិវឌ្ឍបច្ចេកទេសដោយភ្ជាប់ទៅនឹងសក្តានុពលនាំចេញ។

### គ-ពង្រឹងនិងលើកស្ទួយរចនាសម្ព័ន្ធឧស្សាហកម្មនិងតម្លៃបន្ថែមលើផលិតកម្ម

- ពង្រឹងផលិតភាពនិងការប្រកួតប្រជែងឧស្សាហកម្មនៅក្នុងស្រុកដោយធ្វើការផ្លាស់ប្តូរវិធីសាស្ត្រនៃផលិតកម្មដែលពឹងផ្អែកលើកម្លាំងពលកម្មដែលគ្មានជំនាញទៅជាវិធីសាស្ត្រនៃផលិតកម្មតាមបច្ចេកវិទ្យាទំនើបនិងប្រើប្រាស់វត្ថុធាតុដើមនៅក្នុងតំបន់

- ពង្រឹងការប្រកួតប្រជែងផ្នែកកាត់ដេរនិងវាយនភណ្ឌ តាមរយៈការពង្រឹងបច្ចេកវិទ្យានៃការផលិតនិងការប្រើប្រាស់វត្ថុធាតុដើមនៅក្នុងតំបន់ឧស្សាហកម្មព្រោះវិស័យវាយនភណ្ឌបានចូលរួមយ៉ាងសំខាន់នៅក្នុងកំណើនសេដ្ឋកិច្ចប្រទេសកម្ពុជា ប៉ុន្តែវិស័យនេះពឹងផ្អែកទៅលើការនាំចូលនូវវត្ថុធាតុដើមដែលជាកត្តានាំឱ្យមានផលប៉ះពាល់ដល់សេដ្ឋកិច្ចនៅក្នុងស្រុក។

**ឃ- ថែទាំនិងពង្រីកហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្មនិងអភិវឌ្ឍប្រព័ន្ធភស្តុភារកម្ម**

- អភិវឌ្ឍប្រព័ន្ធដឹកជញ្ជូននិងភស្តុភារកម្មក្នុងគោលដៅបង្កើតប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយនិងប្រព័ន្ធភស្តុភារកម្មដែលមានសមាហរណកម្មនិងប្រសិទ្ធភាពខ្ពស់ ពិសេសផ្តោតលើការតភ្ជាប់ប៉ូលអភិវឌ្ឍនិងអ័ក្សនៃការអភិវឌ្ឍភ្នំពេញ-ព្រះសីហនុឱ្យក្លាយទៅជាអ័ក្សនៃការអភិវឌ្ឍគន្លឹះរបស់ជាតិតាមរយៈការកសាងផ្លូវល្បឿនលឿន និងការបង្កើតប្រព័ន្ធភស្តុភារកម្មប្រកបដោយប្រសិទ្ធភាព
- រៀបចំផែនការផ្គត់ផ្គង់អគ្គិសនីនិងទឹកស្អាតទៅកាន់តំបន់ឧស្សាហកម្ម និងផលិតកម្មសំខាន់ៗនៅក្នុងក្រុងនិងខេត្តដោយធានាឱ្យបានតាមតម្រូវការនិងស្ថេរភាពជាមួយតម្លៃសមរម្យដែលអនុញ្ញាតឱ្យរោងចក្រអាចដំណើរការផលិតកម្មរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព
- ពង្រីកបណ្តាញបច្ចេកវិទ្យាព័ត៌មាន ទូរគមនាគមន៍ និងបច្ចេកវិទ្យាទំនើបផ្សេងទៀត (ICT) ដើម្បីត្រៀមឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មទី៤។

**ង- លើកកម្ពស់ការអប់រំ អភិវឌ្ឍធនធានមនុស្ស ទំនាក់ទំនងវិជ្ជាជីវៈ និងទីផ្សារពលកម្មដើម្បីទាក់ទាញការវិនិយោគនិងគាំទ្រដល់វិស័យឧស្សាហកម្ម**

- បណ្តុះបណ្តាលសមត្ថភាពនិងសហគ្រិនភាពនៃសហគ្រាសធុនតូចនិងមធ្យមដើម្បីអាចផ្សារភ្ជាប់និងទាញយកផលប្រយោជន៍ពីសក្តានុពលសហគ្រាសនិងវិនិយោគបរទេសធំៗ ស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេស
- អនុវត្តគោលនយោបាយលំនៅឋានសម្រាប់កម្មករដែលអនុញ្ញាតឱ្យកម្មករអាចមានលទ្ធភាពធ្វើជាម្ចាស់កម្មសិទ្ធិលំនៅឋានសម្រាប់បង្កើតគ្រួសារ និងមិនធ្វើការផ្លាស់ប្តូរទីលំនៅញឹកញាប់ពេកដែលបង្កើតបញ្ហាខ្វះកម្លាំងពលកម្មក្នុងរយៈពេលខ្លី
- កសាងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីបណ្តុះបណ្តាលជំនាញឆ្លើយតបទៅនឹងតម្រូវការជំនាញមូលដ្ឋានផ្នែកកុំព្យូទ័រ ជំនាញព័ត៌មានវិទ្យា ជំនាញគ្រប់គ្រងជំនួញនិងធុរកិច្ច និងជំនាញផ្សេងៗទៀតដែលពាក់ព័ន្ធដើម្បីឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មទី៤
- រៀបចំផែនការផ្លាស់ប្តូរបន្តិចម្តងៗពីឧស្សាហកម្មដែលប្រើប្រាស់កម្លាំងពលកម្មច្រើនទៅជាឧស្សាហកម្មដែលប្រើបច្ចេកវិទ្យាព័ត៌មាន ទូរគមនាគមន៍ និងបច្ចេកវិទ្យាទំនើបផ្សេងទៀត។

**៦.៤.៣- ការអភិវឌ្ឍវិស័យកសិកម្ម**

- ផ្សព្វផ្សាយ លើកទឹកចិត្ត និងជំរុញការវិនិយោគក្នុងស្រុកនិងក្រៅស្រុកលើវិស័យកសិកម្មនិងកសិឧស្សាហកម្មប្រកបដោយចំណេះដឹងដោយផ្អែកលើធនធានសមុទ្រដើម្បីគាំទ្រដល់វិស័យទេសចរណ៍និងអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងក្រុង

- រៀបចំឱ្យមានកន្លែងចិញ្ចឹមត្រីតាមបែបធម្មជាតិស្របតាមតម្រូវការទីផ្សារ
- កំណត់ទីតាំង រៀបចំ និងអភិវឌ្ឍតំបន់កសិកម្មតាមភូមិផ្សារភ្ជាប់ជាមួយទេសចរណ៍
- សិក្សាទីផ្សារនិងផ្សព្វផ្សាយផលិតផលកសិកម្មដែលមានគុណភាពល្អក្នុងស្រុក។

## ៦.៥-ការអភិវឌ្ឍសង្គមកិច្ច

### ៦.៥.១-វិស័យអប់រំ

- រៀបចំកសាងបរិក្ខារអប់រំខ្ទៅនៅជុំវិញតំបន់លំនៅឋានរបស់ប្រជាពលរដ្ឋ
- បង្កើតឱ្យមានសាលាបណ្តុះបណ្តាលពហុបច្ចេកវិទ្យាជំនាញ
- បង្កើតវិទ្យាស្ថានស្រាវជ្រាវ អភិវឌ្ឍ បច្ចេកវិទ្យា និងនវានុវត្តន៍
- បង្កើតឱ្យមានសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសម្រាប់វិស័យឧស្សាហកម្មនិងបណ្តុះបណ្តាលធនធានមនុស្សមានជំនាញកម្រិតខ្ពស់នៅតំបន់ស្ទឹងហាវ។

### ៦.៥.២-វិស័យសុខាភិបាល

- ថែរក្សានិងកែលម្អបរិក្ខារបម្រើដល់វិស័យសុខភាពដែលមានស្រាប់
- រៀបចំបង្កើតមណ្ឌលសុខភាពថ្មីចំនួន៣ផ្សេងគ្នានៅក្រុងព្រះសីហនុមួយកន្លែង នៅតំបន់បិតត្រាងមួយកន្លែង និងមួយកន្លែងទៀតនៅតំបន់ស្ទឹងហាវដោយសិក្សាពីតុល្យភាពតំបន់ជុំវិញនិងការទទួលបានសេវាកម្មពីមណ្ឌលសុខភាពទាំងនោះ។

### ៦.៥.៣-ទីក្រុងគំរូក្នុងការគ្រប់គ្រងនិងអភិបាលកិច្ចល្អប្រកបដោយសេវាទីក្រុង ហេដ្ឋារចនាសម្ព័ន្ធទីក្រុង បរិក្ខារទីក្រុង និងផ្តល់ការងារសម្បូរបែប

- បង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវារដ្ឋបាលសាធារណៈតាមរយៈអភិក្រមរបស់រាជរដ្ឋាភិបាលគឺទី១ ឆ្លុះកញ្ចក់ ទី២ ងូតទឹក ទី៣ ដុសក្អែល ទី៤ ព្យាបាល និងទី៥ វះកាត់
- បង្កើតប្រព័ន្ធរដ្ឋបាលអេឡិចត្រូនិកឆ្លាតក្នុងការគ្រប់គ្រងនិងផ្តល់សេវា
- បណ្តុះបណ្តាលនិងអប់រំក្រមសីលធម៌ដល់មន្ត្រីគ្រប់កម្រិត
- ថែរក្សា កែលម្អ និងជួសជុលអគារនិងបរិក្ខាររដ្ឋបាលដែលមានស្រាប់
- បំពាក់បរិក្ខាររដ្ឋបាលថ្មីដើម្បីឆ្លើយតបទៅនឹងកំណើនតម្រូវការនាពេលអនាគត។

### ៦.៥.៤-លម្ហសាធារណៈ សួនច្បារ និងខ្សែក្រវាត់តំបន់បៃតង

- បង្កើតបណ្តាញលម្ហសាធារណៈនិងផ្ទៃបៃតងនៅតាមបណ្តោយឆ្នេរសមុទ្រ ដៃសមុទ្រ ព្រែក ស្ទឹង អូរ និងបណ្តាញផ្លូវទឹកដែលតភ្ជាប់ទៅនឹងសមុទ្រ
- បង្កើតបណ្តាញលម្ហសាធារណៈនិងផ្ទៃបៃតងនៅតាមតំបន់ការពារធម្មជាតិនិងព្រៃកោងកាង
- បង្កើតបណ្តាញលម្ហសាធារណៈនិងផ្ទៃបៃតងតាមដងមហាវិថី វិថី អនុវិថី ផ្លូវជាតិលេខ៤ និងបណ្តាញផ្លូវផ្សេងៗទៀត
- បង្កើតអ័ក្សអភិវឌ្ឍន៍បណ្តាញបៃតងតភ្ជាប់ពីតំបន់ឆ្នេរសមុទ្រទៅតំបន់ការពារធម្មជាតិ តំបន់វប្បធម៌ សួន ឧទ្យាន និងបណ្តាញលម្ហសាធារណៈនៅក្នុងក្រុងប្រកបដោយសោភណភាពនិងភាពទាក់ទាញ។

### ៦.៥.៥-បរិក្ខារប្បបវត្ថុនិងវប្បធម៌

- កសាងផែនការថែរក្សានិងការពារវត្តជោតញ្ញាណ (វត្តលើ) វត្តឥន្ទញ្ញាណ (វត្តក្រោម) វត្តអូរព្រះ ព្រះរាជដំណាក់ និងកំណត់តំបន់គ្រប់គ្រងធនធានរូបនីយកម្មជុំវិញដែលមានកាំរង្វង់៥០០ម៉ែត្រ
- បង្កើតបរិក្ខារកីឡានិងវប្បធម៌ថ្មីដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់នាពេលអនាគត
- បង្កើតបរិក្ខារសម្រាប់បម្រើដល់វិស័យកីឡាដូចជាពហុកីឡដ្ឋាននៅក្រុងព្រះសីហនុ នៅតំបន់បិតត្រាង និងនៅតំបន់ស្ទឹងហាវ។

### ៦.៥.៦-ការអភិវឌ្ឍសង្គមកិច្ច

- រៀបចំផែនការសិក្សានិងដោះស្រាយសំណង់បណ្ដោះអាសន្ននៅលើដីរដ្ឋ ដីចំណីឆ្នេរសមុទ្រ និងដីចំណីផ្លូវដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ
- បណ្ដុះបណ្ដាលជំនាញនិងអភិវឌ្ឍសមត្ថភាពរបស់ប្រជាជននៅជនបទឱ្យមានជំនាញវិជ្ជាជីវៈដែលអាចប្រកបមុខរបរបានដើម្បីលើកកម្ពស់កម្រិតជីវភាពគ្រួសារ។

## ៦.៦-ការការពារបរិស្ថាននិងការគ្រប់គ្រងសំណល់

### ៦.៦.១-ការគ្រប់គ្រងសំណល់រឹង

- អភិវឌ្ឍបច្ចេកវិទ្យាទំនើបក្នុងការគ្រប់គ្រងសំណល់រឹងនិងកែលម្អប្រព័ន្ធគ្រប់គ្រងសំណល់រឹងតាមរយៈ
  - បង្កើតគោលនយោបាយនិងបទប្បញ្ញត្តិសម្រាប់ការប្រព្រឹត្តកម្មសំណល់រឹងប្រកបដោយអនាម័យ និងប្រសិទ្ធភាព
  - ធ្វើការផ្សព្វផ្សាយនិងផ្ដោតយកចិត្តទុកដាក់លើការប្រព្រឹត្តកម្មសំណល់រឹងប្រកបដោយអនាម័យ និងប្រសិទ្ធភាព ការបំបែងថាមពល និងការកែច្នៃសំណល់រឹង។
- រៀបចំផែនការត្រួតពិនិត្យ ការកែច្នៃឡើងវិញ និងការកាត់បន្ថយការផលិតសំណល់រឹងពីអ្នកប្រើប្រាស់
- បង្កើតបរិក្ខារប្រព្រឹត្តកម្មនិងធ្វើការកែច្នៃសំណល់រឹងស្របតាមបទដ្ឋានបច្ចេកទេស។

### ៦.៦.២-ការគ្រប់គ្រងសំណល់រាវ

- រៀបចំផែនការតាមដាន ត្រួតពិនិត្យ និងថែទាំស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ដែលបានសាងសង់រួច និងដំរុញដំណើរការ
- រៀបចំផែនការតាមដាន ត្រួតពិនិត្យ និងថែទាំស្ថានីយបូមទឹកកខ្វក់ អណ្ដូងលូ ទុយោរជំរុញ លូបេតុង ប្រឡាយ និងទំនប់បង្ហៀរទឹកដែលបានសាងសង់រួចនិងកំពុងដំណើរការ
- រៀបចំនិងពង្រីកបន្ថែមប្រព័ន្ធលូទឹកភ្លៀងនិងលូទឹកកខ្វក់ឱ្យដាច់ពីគ្នាដោយឡែកនៅទីស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ស្របតាមស្ថានភាពទីតាំងភូមិសាស្ត្រនិងត្រូវចម្រោះទឹកឱ្យបានស្អាតស្របតាមបទដ្ឋានបច្ចេកទេសអនាម័យមុននឹងបង្ហូរចូលលូសាធារណៈ
- ណែនាំគ្រប់ម្ចាស់សំណង់លំនៅឋាន ឧស្សាហកម្ម ពាណិជ្ជកម្ម សេវាកម្មទេសចរណ៍ និងសំណង់សាធារណៈត្រូវមានអាងប្រព្រឹត្តកម្មនិងអាងបង្គន់អនាម័យត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស។

## ៦.៧-ការបង្ការទប់ស្កាត់គ្រោះមហន្តរាយ

### ៦.៧.១-ការបង្ការគ្រោះមហន្តរាយពីព្រៃក អូរ ប្រឡាយ និងផ្លូវទឹកសំខាន់ៗ

- កសាងខឿនការពារច្រាំងនៅតាមទីតាំងសំខាន់ៗនៃព្រែក អូរ ប្រឡាយ និងបណ្តាញផ្លូវទឹកសំខាន់ៗ ដើម្បីការពារការហូរច្រោះ ការបាក់ដី និងទឹកជំនន់ ពិសេសទីតាំងដែលមានចំណោតខ្លាំង
- រៀបចំវិធានការការពារស្រទាប់ដីខាងលើពីការហូរច្រោះស្របតាមបទដ្ឋានបច្ចេកទេសដូចជាការរៀបចំប្រព័ន្ធប្រឡាយការពារដីស្រទាប់ខាងលើ ការរៀបចំប្រព័ន្ធការពារទីជម្រាល និងតំបន់ចំណោត និងការរៀបចំប្រព័ន្ធបៃតងជាដើម។

### ៦.៧.២-ការការពារការស្ទះផ្លូវទឹកហូរ

- រៀបចំប្រព័ន្ធប្រឡាយនិងអណ្តូងលូត្រងទឹកភ្លៀងពីផ្លូវចូលប្រព័ន្ធលូសាធារណៈមុននឹងហូរចាក់ចូលទៅប្រភពទឹកផ្សេងៗ
- រៀបចំផែនការកាត់បន្ថយល្បឿនទឹកភ្លៀងហូរតាមរយៈការបំពាក់បរិក្ខារផ្ទុកទឹកដូចជាអាងស្តុកទឹក និងកន្លែងបង្ហូរទឹកដែលត្រូវបានរៀបចំបណ្តោះអាសន្នសម្រាប់ទប់មិនឱ្យទឹកភ្លៀងទាំងអស់ត្រូវហូរចូលអាងស្តុកទឹកដោយផ្ទាល់ និងបរិក្ខារជម្រាបទឹកចូលក្នុងដីដើម្បីបន្ថយល្បឿនទឹកហូរនិងត្រូវបានដំឡើងដើម្បីបញ្ជ្រាបទឹកចូលក្នុងដីដើម្បីបន្ថយការហូរដោយផ្ទាល់នៃទឹកជំនន់។

### ៦.៧.៣-ការការពារការរាំងស្ទះខ្សែទឹកហូរដោយសារការអភិវឌ្ឍថ្មីៗ

- រៀបចំបង្កើតអាងដីល្បាប់និងប្រឡាយដែលភ្ជាប់ជាមួយនឹងអាងដីល្បាប់នោះនៅតំបន់អភិវឌ្ឍន៍ដើម្បីគ្រប់គ្រងនិងការពារការខូចដីតាមរយៈការកកដីនិងការបង្ហាក់ដល់ខ្សែទឹកហូរ
- ចាត់វិធានការតាមដានត្រួតពិនិត្យទីតាំងអភិវឌ្ឍន៍និងតម្រូវឱ្យមានការសាងសង់អាងដីល្បាប់និងប្រឡាយដែលភ្ជាប់ជាមួយនឹងអាងដីល្បាប់នៅកំឡុងពេលសាងសង់។

### ៦.៧.៤-ការបង្ការគ្រោះមហន្តរាយនៅទីចំណោត

- ចាត់វិធានការត្រួតពិនិត្យនិងតម្រូវឱ្យរៀបចំគូរប្លង់អភិវឌ្ឍន៍និងសំណង់ដែលមានស្ថេរភាពឬលំនឹងបំពាក់ដោយបរិក្ខារទប់ដីបន្ថែមនិងបរិក្ខារធានាសុវត្ថិភាពដើម្បីការពារគ្រោះមហន្តរាយពីការបាក់ដីនៅទីចំណោត។

### ៦.៧.៥-ការបង្ការគ្រោះមហន្តរាយតាមតំបន់ឆ្នេរសមុទ្រ

- សិក្សាលម្អិតនិងផ្តល់នូវគោលការណ៍ណែនាំស្តីពីការទប់ទល់ទៅនឹងខ្យល់ព្យុះ និងហានិភ័យផ្សេងៗ នៅតំបន់ឆ្នេរសមុទ្រសម្រាប់រាល់ការអភិវឌ្ឍនៅតំបន់ឆ្នេរសមុទ្រ
- បង្កើតអាងស្តុកទឹកដែលមានមុខងារច្រើនយ៉ាងជាកន្លែងស្តុកទឹក សួនឧទ្យានកម្សាន្ត និងកន្លែងកីឡា ។ល។ ដើម្បីជួយសម្រួលស្តុកទឹកនោះនៅពេលដែលទឹកសមុទ្រជោរឡើង។

## ៧-ធនធានហិរញ្ញវត្ថុ

ប្រភពធនធានហិរញ្ញវត្ថុសម្រាប់ការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុមានជាអាទិ៍៖

- ថវិកាជាតិ
- ថវិកាអភិវឌ្ឍន៍និងវិនិយោគដោយវិស័យឯកជន
- ថវិកាវិនិយោគរវាងរដ្ឋនិងឯកជន
- ថវិកាហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍និងកិច្ចសហប្រតិបត្តិការអន្តរជាតិ
- ថវិកាពីការចូលរួមរបស់ប្រជាពលរដ្ឋ សហគមន៍ និងសប្បុរសជន។

## ៨-ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ

### ៨.១-យន្តការ

យន្តការថ្នាក់ជាតិដើម្បីតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុ ចក្ខុវិស័យឆ្នាំ២០៣៥ មាន៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា និងក្រសួង ស្ថាប័នតាមវិស័យរបស់រដ្ឋ។

យន្តការថ្នាក់ក្រោមជាតិសម្រាប់អនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុ ចក្ខុវិស័យឆ្នាំ២០៣៥ មាន៖ រដ្ឋបាលខេត្តព្រះសីហនុ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តព្រះសីហនុ រដ្ឋបាលក្រុងព្រះសីហនុ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងព្រះសីហនុ គណៈកម្មាធិការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជាខេត្តព្រះសីហនុ មន្ទីរ អង្គភាពជុំវិញខេត្ត និងអាជ្ញាធរសង្កាត់ និងភូមិ។

### ៨.២-ច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត

ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុ ចក្ខុវិស័យឆ្នាំ២០៣៥ ត្រូវបានធ្វើឡើងដោយផ្អែកទៅលើគោលនយោបាយ ច្បាប់ និងក្របខណ្ឌគតិយុត្តមានជាអាទិ៍គោលនយោបាយដីធ្លី "សៀវភៅសដីធ្លី" គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយជាតិស្តីពីលំនៅឋាន គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍទេសចរណ៍ លិខិតបទដ្ឋានគតិយុត្តសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងការរៀបចំដែនដីនិងនគរូបនីយកម្មនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដូចជាច្បាប់ស្តីពីសំណង់ ច្បាប់ស្តីពីភូមិបាល ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីអស្សាមិករណ៍ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ អនុក្រឹត្យស្តីពីតំបន់ទេសចរណ៍ពិសិដ្ឋ អនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ សារាចរណែនាំស្តីពីការអភិវឌ្ឍ

តំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេចស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំអភិវឌ្ឍន៍រមណីយដ្ឋានឆ្នេរសមុទ្រ ប្រកាសអន្តរក្រសួងស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងឆ្នេរខ្សាច់កម្សាន្ត និងសេចក្តីសម្រេចស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

## ៨.៣-ភារកិច្ច នីតិវិធី និងគោលការណ៍

រដ្ឋបាលក្រុងព្រះសីហនុដោយមានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុងព្រះសីហនុជាសេនាធិការមានភារកិច្ចៈ

- ទទួលខុសត្រូវក្នុងការរៀបចំផែនការសកម្មភាពលម្អិតសម្រាប់ការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុដោយមានការចូលរួមពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាព វិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងសហគមន៍មូលដ្ឋាន។ ផែនការសកម្មភាពលម្អិតខាងលើត្រូវកំណត់នូវគោលបំណង គោលដៅសកម្មភាព ពេលវេលា ធនធានហិរញ្ញវត្ថុ ការទទួលខុសត្រូវ និងសូចនាករសំខាន់ៗសម្រាប់ការត្រួតពិនិត្យនិងការវាយតម្លៃ ព្រមទាំងត្រូវមានសង្គតិភាពជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍ៥ឆ្នាំ កម្មវិធីវិនិយោគ៣ឆ្នាំរំកិល ប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្មថ្នាក់ក្រុង សង្កាត់
- ត្រូវធ្វើបច្ចុប្បន្នភាពប្លង់គោលប្រើប្រាស់ដីនេះ ក្នុងរយៈពេល៥ឆ្នាំម្តងស្របតាមគោលការណ៍ និងនីតិវិធីដែលបានកំណត់ឬតាមពេលវេលា និងតម្រូវការចាំបាច់ជាក់ស្តែងសំដៅបម្រើផលប្រយោជន៍សាធារណៈឬផលប្រយោជន៍ជាតិ
- ត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំស្តីពីការអនុវត្តប្លង់គោលប្រើប្រាស់ដីនេះជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តព្រះសីហនុ រដ្ឋបាលខេត្តព្រះសីហនុ ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិដើម្បីធ្វើការបូកសរុបនិងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល។

គោលការណ៍នៃការត្រួតពិនិត្យនិងវាយតម្លៃត្រូវផ្អែកលើសូចនាករនៃការរៀបចំដែនដីនិងនគរូបនីយកម្ម និងសូចនាករតាមវិស័យ ដើម្បីបញ្ជាក់អំពីប្រសិទ្ធភាពនៃការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមប្រកបដោយចីរភាព។

## ៩-សេចក្តីសន្និដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ទទួលបាននូវសុខសន្តិភាពពេញលេញ ស្ថេរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ព្រមទាំងការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យតាមរយៈការអនុវត្តគោលនយោបាយ ឈ្នះ-ឈ្នះ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។ ប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុត្រូវបានរៀបចំឡើងលម្អិតបន្ថែមបន្តពីផែនការរៀបចំដែនដីខេត្តព្រះសីហនុ និងសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការគឺជា

ឧបករណ៍គតិយុត្តគោលដ៏មានសារៈសំខាន់សម្រាប់ការអនុវត្តនិងសម្របសម្រួលស្ថាប័នពាក់ព័ន្ធតាមវិស័យដើម្បីធានាសម្រេចបានចក្ខុវិស័យដល់ឆ្នាំ២០៣៨ គឺ "**ក្រុងព្រះសីហនុជាទីក្រុងស្នូលនៃប៉ូលអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាពនៅតំបន់ឆ្នេរសមុទ្រកម្ពុជាក្នុងការជំរុញកំណើនសេដ្ឋកិច្ច អភិវឌ្ឍន៍ធុរកិច្ច ពាណិជ្ជកម្ម និងទេសចរណ៍ប្រកបដោយភាពរស់រវើក ស្អាត និងបរិយាបន្ន**" តាមរយៈការអភិវឌ្ឍ៖ ១)ទីក្រុងទំនើបបៃតងប្រកបដោយភាពច្នៃប្រឌិតរស់រវើកនិងបរិស្ថានរស់នៅល្អប្រសើរបំផុត ២)តំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង មជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិ និងមជ្ឈមណ្ឌលកំណើនជាតិ ៣)រមណីយដ្ឋានឆ្នេរសមុទ្រនិងកោះដែលស្អាតបំផុតលើសកលលោកសម្រាប់ការស្នាក់នៅ លម្ហែកាយ និងការកម្សាន្ត ៤)មជ្ឈមណ្ឌលគាំទ្រឧស្សាហកម្មផលិតកម្មបែបបច្ចេកវិទ្យាទំនើប នវានុវត្តន៍ ៥)ច្រកចេញចូលអន្តរជាតិនិងភស្តុភារកម្មជាតិដែលមានទំនាក់ទំនងជាមួយទីផ្សារអាស៊ាននិងសកលលោក ៦)ទីក្រុងគំរូក្នុងការគ្រប់គ្រងនិងអភិបាលកិច្ចល្អប្រកបដោយសេវាទីក្រុង ហេដ្ឋារចនាសម្ព័ន្ធទីក្រុង បរិក្ខារទីក្រុង និងផ្តល់ការងារសមរម្យបែប ដើម្បីរួមចំណែកសម្រេចចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍខេត្តព្រះសីហនុជាប៉ូលអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាព និងជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង និងប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

ថ្ងៃពុធ ២កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជា**
**ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

**ជា សុផារ៉ា**

**អនុសាសន៍**

ដើម្បីឱ្យប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុអនុវត្តមានប្រសិទ្ធភាព រដ្ឋបាលក្រុងព្រះសីហនុនិងរដ្ឋបាលខេត្តព្រះសីហនុត្រូវយកចិត្តទុកដាក់៖

ទី១. អនុវត្តបទប្បញ្ញត្តិប្រើប្រាស់ដីតាមតំបន់នីមួយៗ និងត្រូវបន្តរៀបចំផែនការប្រើប្រាស់ដី ព្រមទាំងប្លង់លម្អិតនគរូបនីយកម្ម ចុះបញ្ជីដីធ្លីឱ្យបានច្បាស់លាស់ និងរៀបចំបទប្បញ្ញត្តិនានាក្នុងការគ្រប់គ្រងប្រើប្រាស់ដីនិងសំណង់ឱ្យមានប្រសិទ្ធភាព។

ទី២. រៀបចំផែនការសកម្មភាពនិងគម្រោងវិនិយោគតាមលំដាប់អាទិភាពដើម្បីធ្វើការផ្សព្វផ្សាយស្វែងរកដៃគូអភិវឌ្ឍន៍និងអ្នកវិនិយោគទុនស្របតាមច្បាប់វិនិយោគនិងបទដ្ឋានគតិយុត្តជាធរមាន។

ទី៣. លើកកម្ពស់សមត្ថភាពមន្ត្រីនិងបណ្តុះបណ្តាលធនធានមនុស្សថ្នាក់ខេត្ត និងថ្នាក់ក្រុងដើម្បីធានាការគ្រប់គ្រងនិងអភិបាលកិច្ចល្អ។

ទី៤. តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ព្រមទាំងរៀបចំធ្វើបច្ចុប្បន្នភាពប្លង់គោលប្រើប្រាស់ដីដើម្បីស្នើសុំការសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការស្របតាមនីតិវិធីជាធរមាន។

ទី៥. រៀបចំកញ្ចប់ថវិកាថ្នាក់ខេត្តនិងថ្នាក់ក្រុងសម្រាប់អនុវត្តគម្រោងផែនការជួសជុល ថែទាំ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សំណង់ផ្តល់សេវាជូនសាធារណជន និងលម្អសាធារណៈ។

ទី៦. ស្នើសុំកិច្ចសហការនិងគាំទ្រពីគ្រប់ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដើម្បីធានាការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុឱ្យមានប្រសិទ្ធភាព ចីរភាព តុល្យភាព និងសមាហរណកម្មល្អប្រសើរ។

២០២០៨៤៩

## សទ្ទានុក្រម

**ទីក្រុង** សំដៅដល់រាជធានី ក្រុង និងទីប្រជុំជន។ ទីក្រុងត្រូវបានធ្វើចំណាត់ថ្នាក់ជាទីក្រុងប្រភេទធំ ប្រភេទមធ្យម និងប្រភេទតូច ស្របតាមលក្ខខណ្ឌនៃចំនួនប្រជាជន ដង់ស៊ីតេប្រជាជន សមាមាត្រអ្នកធ្វើការមិនមែនជាកសិករ មុខងារទីក្រុង និងរចនាសម្ព័ន្ធរូបវន្តទីក្រុង។ល។

**នគរូបនីយកម្ម** សំដៅដល់សិល្បៈ វិទ្យាសាស្ត្រ និងបច្ចេកទេសនៃការធ្វើផែនការរូបវន្តទីក្រុង ការអភិវឌ្ឍ ការអភិរក្ស ការគ្រប់គ្រងការអភិវឌ្ឍ ការសាងសង់ និងការកែលម្អនៅក្នុងទីក្រុងនិងតំបន់ជុំវិញ ព្រមទាំង តំបន់ទទួលឥទ្ធិពល ក្នុងគោលបំណងទទួលបាននូវចីរភាព តុល្យភាព សុខុមាលភាព សោភណភាព សមធម៌ និងសមាហរណកម្ម។

**ផែនការរៀបចំដែនដីថ្នាក់ជាតិ តាមតំបន់ និងថ្នាក់ខេត្ត** សំដៅដល់ផែនការដែលកំណត់ចក្ខុវិស័យនិងយុទ្ធសាស្ត្រតម្រង់ទិសការប្រើប្រាស់ដី និងការអភិវឌ្ឍផ្នែករូបវន្ត ដោយផ្អែកលើសក្ដានុពលនៃភូមិសាស្ត្រ និងតំបន់នីមួយៗក្នុងក្របខណ្ឌថ្នាក់ជាតិ តាមតំបន់ និងថ្នាក់ខេត្ត។

**ប្លង់គោលប្រើប្រាស់ដីឬប្លង់គោល** សំដៅដល់ផែនការដែលកំណត់អំពីចក្ខុវិស័យនិងយុទ្ធសាស្ត្រសរុប សម្រាប់ការអភិវឌ្ឍរូបវន្តនិងកំណត់ពីប្រភេទនៃការប្រើប្រាស់ដី (ប្រភេទដីអាចសាងសង់បាន និងប្រភេទដីកម្រិតការសាងសង់) ព្រមទាំងបង្ហាញអំពីទម្រង់ទីក្រុង បណ្ដាញហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងគមនាគមន៍សំខាន់ៗនៃទីក្រុងព្រមទាំងការធ្វើសមាហរណកម្ម។ ប្លង់គោលប្រើប្រាស់ដីត្រូវភ្ជាប់មកជាមួយនូវផែនការសកម្មភាពសម្រាប់អភិវឌ្ឍន៍និងអភិរក្សទីក្រុង ទៅតាមលំដាប់អាទិភាពសម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង។ ប្លង់គោលប្រើប្រាស់ដីគឺជាប្លង់ដែលត្រូវបានសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយស្ថាប័នរដ្ឋមានសមត្ថកិច្ច។

**ផែនការប្រើប្រាស់ដី** សំដៅដល់ផែនការលម្អិតចេញពីប្លង់គោលប្រើប្រាស់ដីដែលកំណត់អំពីប្រភេទប្រើប្រាស់ដី តំបន់ប្រើប្រាស់ដី និងកំណត់អំពីបទបញ្ជានៃការប្រើប្រាស់ដីជាក់ស្ដែង ការសាងសង់ ការអភិវឌ្ឍដីនិងរយៈពេលការអភិរក្សក្នុងតំបន់នីមួយៗ ព្រមទាំងកំណត់អំពីបណ្ដាញគមនាគមន៍ និងការធ្វើសមាហរណកម្ម។ ផែនការប្រើប្រាស់ដី គឺជាផែនការដែលត្រូវបានសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយស្ថាប័នរដ្ឋមានសមត្ថកិច្ច។

**ប្លង់លម្អិតនគរូបនីយកម្ម** សំដៅដល់ប្លង់វិលេចទីតាំងនៃតំបន់ណាមួយក្នុងទីក្រុង ឬជាគម្រោងអភិវឌ្ឍទីក្រុង ដើម្បីបង្ហាញអំពីយុទ្ធសាស្ត្ររូបវន្តលម្អិតនៃការរៀបចំផ្នែក ទីតាំង ឬតំបន់ប្រើប្រាស់ដីណាមួយ ឬច្រើនទីក្រុងដែលរួមមានការបង្ហាញអំពីការរៀបចំការរចនាទម្រង់ រូបរាង និងសោភណភាពនៃរចនាសម្ព័ន្ធរូបវន្តសម្រាប់ការអភិវឌ្ឍ ការអភិរក្សនិងការសាងសង់ តាមរយៈគំនូរ ឬរូបសំណាក។ ប្លង់លម្អិតនគរូបនីយកម្មត្រូវគោរពតាមផែនការប្រើប្រាស់ដី។

**ផែនការប្រើប្រាស់ដីថ្នាក់ឃុំ សង្កាត់** សំដៅដល់ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ទាំងមូល ទាំងដីរដ្ឋ ទាំងដីឯកជន ដោយប៉ាន់ប្រមាណពីសក្ដានុពលដីនិងធនធានទឹក លទ្ធភាពផ្សេងៗក្នុងការប្រើប្រាស់ដី ព្រមទាំងលក្ខខណ្ឌសេដ្ឋកិច្ចនិងសង្គមកិច្ច ដើម្បីធ្វើការជ្រើសរើសនូវជម្រើសសមស្របក្នុងការប្រើប្រាស់ដី។

**ប្រភេទដីអាចសាងសង់បាន** សំដៅដល់ប្រភេទដីដែលជំរុញឱ្យមានការអភិវឌ្ឍ និងការសាងសង់លើគ្រប់វិស័យ។ ប្រភេទដីនេះ ត្រូវបានបែងចែកជាតំបន់លំនៅឋាន តំបន់ពាណិជ្ជកម្ម តំបន់ឧស្សាហកម្ម តំបន់ចម្រុះ តំបន់ដឹកជញ្ជូន តំបន់សេវាកម្មទេសចរណ៍ តំបន់រដ្ឋបាលនិងសេវាសាធារណៈ តំបន់លម្ហសាធារណៈ និងផ្ទៃបៃតង តំបន់វប្បធម៌និងសាសនា និងតំបន់ផ្សេងៗមួយចំនួនទៀតស្របតាមភូមិសាស្ត្រជាក់ស្តែង។

**ប្រភេទដីកម្រិតការសាងសង់** សំដៅដល់ប្រភេទដីដែលត្រូវគ្រប់គ្រងពិសេសចំពោះការសាងសង់។ ប្រភេទដីនេះ ត្រូវបានបែងចែកជាតំបន់កសិកម្ម តំបន់ព្រៃឈើ តំបន់ធនធានទឹក តំបន់ការពារ និងតំបន់ផ្សេងៗមួយចំនួនទៀតស្របតាមភូមិសាស្ត្រជាក់ស្តែង។

**ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍** សំដៅដល់អនុបាតរវាងផ្ទៃក្រឡាបាតសំណង់ជាន់ផ្ទាល់ដី និងផ្ទៃក្រឡាដីឡូត៍គិតជាភាគរយ។

**សន្ទស្សន៍ប្រើប្រាស់ដី** សំដៅដល់អនុបាតរវាងផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ និងផ្ទៃក្រឡាដីឡូត៍ដែលសំណង់នោះតាំងនៅ។

**តំបន់ស្នូលនៃការអភិវឌ្ឍ** សំដៅដល់តំបន់ដែលមានសក្តានុពលខ្ពស់ ឬតំបន់ដែលមានការអភិវឌ្ឍខ្ពស់ សម្រាប់គាំទ្រដល់តំបន់ដែលមានសក្តានុពលទាប។

**អ័ក្សនៃការអភិវឌ្ឍ** សំដៅដល់បណ្តាញផ្លូវគមនាគមន៍ ឬច្រករបៀងតភ្ជាប់ពីតំបន់អភិវឌ្ឍន៍មួយទៅតំបន់អភិវឌ្ឍន៍មួយទៀត ដែលអាចឱ្យតំបន់ជាប់ជិតខាងតាមអ័ក្សទាញយកប្រយោជន៍ពីការអភិវឌ្ឍតាមអ័ក្សនេះបាន។

**ប៉ូលអភិវឌ្ឍន៍** សំដៅដល់តំបន់ដែលមានសក្តានុពលខ្ពស់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច។

**តំបន់លម្ហសាធារណៈនិងផ្ទៃបៃតង** សំដៅដល់តំបន់ដែលមានមុខងារសម្រាប់បម្រើដល់ការសម្រាក ការលម្ហែ ការកម្សាន្ត និងពិធីសាធារណៈនានាដូចជាឧទ្យាន សួនច្បារ សួនសត្វ សួនកុមារ កន្លែងក្មេងលេង សួនយុវជន សួនមនុស្សចាស់។ល។ ដែលត្រូវបានរៀបចំនិងសាងសង់សម្រាប់បម្រើដល់សាធារណជន។

**បណ្តាញបៃតង** សំដៅដល់សួនសាធារណៈ និងដើមឈើដែលរៀបចំប្រទាក់ក្រឡាគ្នាតាមចិញ្ចើមផ្លូវភ្ជាប់ទៅសួនទីក្រុង។

**ការត្រួតពិនិត្យការអភិវឌ្ឍ** សំដៅដល់ការត្រួតពិនិត្យការអនុវត្តស្របតាមប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងស្របតាមបទប្បញ្ញត្តិជាធរមាន។

**ឆ្នេរសមុទ្រ** សំដៅដល់ចំណែកដី ឬខ្សាច់ដែលមានសណ្ឋានជម្រាល និងលិចទឹកម្តងម្កាល។ ឆ្នេរសមុទ្រត្រូវកំណត់ចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតនៃទឹកសមុទ្រឡើងមកលើ រហូតដល់ខ្សែបន្ទាត់ដែលមិនមានការកាន់កាប់ ឬសាងសង់នានាជាថ្មី ដី ឬខ្សាច់ដែលបានកំណត់ទុកជាតំបន់សម្រាប់ប្រើប្រាស់ជាសាធារណៈ និងត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ។ ទំហំឆ្នេរសមុទ្រត្រូវកំណត់ដូចខាងក្រោម៖

- ឆ្នេរជម្រាលត្រូវកំណត់យ៉ាងតិច៣០ (សាមសិប) ម៉ែត្រ ចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតទៅខាងដីគោក
- ឆ្នេរចោតត្រូវកំណត់យ៉ាងតិច២០ (ម្ភៃ) ម៉ែត្រ ចាប់ពីចំណុចកំពូលនៃផ្ទៃចោតមកខាងដីគោក។

ក្នុងករណីដែលស្ថានភាពទីតាំងជាក់ស្តែងនៃឆ្នេរជម្រាលមិនអាចកំណត់តាមទំហំខាងលើបាន ទំហំឆ្នេរសមុទ្រត្រូវកែច្នៃ ឬពង្រីកបន្ថែមដើម្បីបង្កើតជាឆ្នេរសម្រាប់ដើរលេងកម្សាន្តប្រសិនបើអាចធ្វើទៅបាន។

**ដីចំណីឆ្នេរសមុទ្រ** សំដៅដល់ផ្ទៃដីដែលចាប់រាប់ពីខ្សែបន្ទាត់ឆ្នេរខាងលើមកទិសខាងដីគោក។ ដីចំណីឆ្នេរសមុទ្រជាដីសាធារណៈរបស់រដ្ឋ លើកលែងតែមានការកាន់កាប់ស្របច្បាប់។ ប្រវែង ឬទំហំដីចំណីឆ្នេរសមុទ្រត្រូវកំណត់ដូចខាងក្រោម៖

- ប្រវែងទទឹងដីចំណីឆ្នេរសមុទ្រត្រូវកំណត់យ៉ាងតិច៥០ (ហាសិប) ម៉ែត្រគិតពីខ្សែបន្ទាត់ឆ្នេរខាងលើទៅខាងដីគោក
- ក្នុងករណីដែលតាមបណ្តោយឆ្នេរសមុទ្រមានផ្លូវសាធារណៈរួចហើយ ដីចំណីឆ្នេរសមុទ្រអាចកំណត់មកទល់នឹងផ្លូវសាធារណៈនេះ។

**តំបន់រណប** សំដៅដល់តំបន់មួយឬកស្ថិតនៅចន្លោះផ្លូវសាធារណៈតាមបណ្តោយឆ្នេរសមុទ្រ និងផ្លូវស្របបន្ទាប់មួយទៀតដែលស្ថិតក្នុងទិសខាងដីគោក។

**ផ្លូវសាធារណៈតាមបណ្តោយដីចំណីឆ្នេរសមុទ្រ** សំដៅដល់ផ្លូវដែលសាងសង់ឡើងនៅជាប់ខ្សែបន្ទាត់ខាងក្រៅនៃដីចំណីឆ្នេរសមុទ្រដែលខណ្ឌចែកដីចំណីឆ្នេរសមុទ្រជាមួយតំបន់រណប។ ផ្លូវនេះជារបាំងទប់ស្កាត់ការរំលោភបំពានកាន់កាប់ដីចំណីឆ្នេរសមុទ្រ។

**ផ្លូវសាធារណៈតាមបណ្តោយដីចំណីដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹក ដែលនាវាឬក្បូនចេញចូលបាន បណ្តែតបាន** សំដៅដល់ផ្លូវដែលសាងសង់ឡើងនៅជាប់ខ្សែបន្ទាត់ខាងក្រៅនៃដីចំណីដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបានទាំងនោះ ដែលខណ្ឌចែកដីចំណីដៃ សមុទ្រ ស្ទឹង ព្រែក ផ្លូវទឹក ដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបានជាមួយតំបន់រណប។ ផ្លូវនេះជារបាំងទប់ស្កាត់ការរំលោភបំពានកាន់កាប់ដីចំណីដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបាន។

**ដៃសមុទ្រ** សំដៅដល់ផ្ទៃទឹកដែលតភ្ជាប់ទៅនឹងផ្ទៃទឹកសមុទ្រ។ ទំហំផ្ទៃដៃសមុទ្រ ត្រូវកំណត់យកត្រឹមខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុត។ ទំហំដីចំណីដៃសមុទ្រត្រូវកំណត់ចម្ងាយ៣០ (សាមសិប) ម៉ែត្រយ៉ាងតិចពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុត។

**ផ្លូវទឹកដែលតភ្ជាប់ទៅនឹងផ្ទៃទឹកសមុទ្រ** សំដៅដល់ស្ទឹង ព្រែក ផ្លូវទឹកដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបាន។ ទំហំទទឹងស្ទឹង ព្រែក ផ្លូវទឹកដែលនាវាឬក្បូនចេញចូលបាន បណ្តែតបាន ត្រូវកំណត់ត្រឹមខ្សែបន្ទាត់កម្រិតទឹកខ្ពស់បំផុតទាំងសងខាងនៅរដូវវស្សា លើកលែងតែមានទឹកជំនន់ខុសធម្មតា។ ទំហំដីចំណីស្ទឹង ព្រែក ផ្លូវទឹកដែលនាវាឬក្បូនចេញចូលបាន បណ្តែតបាន ត្រូវកំណត់ចម្ងាយ២០ (ម្ភៃ) ម៉ែត្រយ៉ាងតិចពីខ្សែបន្ទាត់ទឹកខ្ពស់បំផុតនៅរដូវវស្សា។

**កោះ** សំដៅដល់ផ្ទៃដីដែលហ៊ុមព័ទ្ធដោយទឹកសមុទ្រ។ ព្រំប្រទល់ដីកោះក្នុងសមុទ្រ ត្រូវកំណត់ត្រឹមខ្សែទឹកជោរអតិបរមាឡើងលើ។ កោះអាចមានទំហំតូចធំខុសៗគ្នា ដែលអាចប្រើប្រាស់ក្នុងគោលដៅផ្សេងៗ លើកលែងតែមានការកំណត់ដោយឡែក។ កោះអាចជាកម្មវត្ថុសម្រាប់ការរស់នៅនិងការអភិវឌ្ឍ ស្របតាមគោលដៅនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ការពារជាតិ និងទេសចរណ៍។

**ដែនទឹកសមុទ្រ** សំដៅដល់ផ្ទៃទឹកខាងលើនិងក្នុងទឹក។ នៅក្នុងទឹកមានធនធានសមុទ្រ ប្រព័ន្ធអេកូឡូស៊ីនិងជីវចម្រុះគ្រប់ប្រភេទ។

**អាងទន្លេ** សំដៅដល់តំបន់ភូមិសាស្ត្រដែលកំណត់ដោយព្រំប្រទល់ទីជម្រាលនៃប្រព័ន្ធទឹកហូរដោយរាប់បញ្ចូលទាំងទឹកលើដី និងទឹកក្រោមដី។

**ទឹកក្រោមដី** សំដៅដល់ទឹកដែលហូរនៅក្រោមដីក្នុងចន្លោះថ្មតូចធំ និងភាគល្អិតនៃដីដែលផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត។

**សមុទ្រ** សំដៅដល់ប្រភពធនធានទឹកប្រៃ និងជាកន្លែងទទួលរំហូរទឹកមកពីទន្លេ ស្ទឹង ព្រែក ជ្រោះ អូរ ទឹកក្រោមដី និងតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ។

**ទន្លេ** សំដៅដល់ផ្លូវទឹកធម្មជាតិ ដែលទទួលប្រភពទឹកមកពីស្ទឹង ព្រែក ជ្រោះ អូរ ទឹកក្រោមដី និងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ ហើយហូរចាក់ទៅសមុទ្រ។

**ស្ទឹង** សំដៅដល់ផ្លូវទឹកធម្មជាតិ ដែលទទួលប្រភពទឹកមកពីជ្រោះ អូរ ទឹកក្រោមដី និងពីតំបន់ផ្ទៃរង ទឹកភ្លៀងនៅផ្នែកខាងលើ ហើយហូរចាក់ទៅបឹង ទន្លេ និងសមុទ្រ។

**ព្រែក** សំដៅដល់ផ្លូវទឹកធម្មជាតិ ឬសិប្បនិម្មិតដែលនាំទឹកចេញឬចូលពីទន្លេ ឬស្ទឹង និងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ។

**អូរ** សំដៅដល់ផ្លូវទឹកធម្មជាតិដែលទទួលប្រភពទឹកមកពីជ្រោះ និងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ ហើយហូរចូលព្រែក ស្ទឹង ទន្លេ ឬបឹង។

**ជ្រោះ** សំដៅដល់ជ្រលង ឬល្បាក់ទឹកធម្មជាតិដែលកើតឡើងដោយសារបាតុភូតធម្មជាតិនៃការហូរច្រោះ ដោយសារចរន្តទឹកពីតំបន់ភ្នំ ឬតំបន់ខ្ពង់រាប។

**បឹងបួ** សំដៅដល់ល្ហលទឹកធំល្វឹងល្វើយកើតពីទីជម្រាល ឬជម្រៅធម្មជាតិដែលអាចមានទឹក ឬគ្មានទឹកទៅតាមរដូវកាល និងមានប្រភពមកពីទន្លេ ស្ទឹង ព្រែក ឬពីតំបន់ផ្ទៃរងទឹកភ្លៀង។

**អាងទឹក** សំដៅដល់ទីតម្កល់ទឹកដែលកើតឡើងដោយធម្មជាតិ ឬសិប្បនិម្មិតសម្រាប់ប្រើតាមតម្រូវការ។

**ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់** សំដៅដល់ប្រឡាយចំហ អាងស្តុក ស្ថានីយបូមលូ ឬទឹកភ្លៀង បណ្តាញលូរួម បណ្តាញលូមេរង ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់រួមមានតាមលក្ខណៈបច្ចេកវិទ្យា ឬលក្ខណៈធម្មជាតិ។

**ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់រួម** សំដៅដល់រោងចក្រសម្អាតទឹកកខ្វក់រួមរបស់ទីប្រជុំជន រាជធានី ខេត្ត ក្រុង ស្រុក ឬខណ្ឌ។

**ទឹកកខ្វក់** សំដៅដល់ទឹកដែលបានប្រែប្រួលចរិតលក្ខណៈដើមរបស់វា ក្រោយពីការប្រើប្រាស់រួចមានដូចជាទឹកសំណល់ពីផ្ទះបាយ បន្ទប់ទឹក ការបោកគក់ ឬការលាងសម្អាតនានា និងទឹកសំណល់ពីបង្គន់អនាម័យរួមទាំងទឹកនោម និងលាមកដែលបញ្ចេញពីលំនៅឋាន បុរីលំនៅឋាន ទីក្រុងរណប អគារអាជីវកម្ម អគារពាណិជ្ជកម្ម សេវាកម្ម និងតំបន់ទីរមនីយដ្ឋាន ឬមជ្ឈមណ្ឌលកម្សាន្ត។

**សំណល់រាវ** សំដៅដល់ទឹកសំណល់មានផ្ទុកសារធាតុបំពុលបរិស្ថានដែលបញ្ចេញពីសកម្មភាព ឬដំណើរការផ្ទាល់នៃផលិតកម្ម អាជីវកម្ម ឬសេវាកម្ម។

**ប្រព័ន្ធលូ** សំដៅដល់បណ្ដាញប្រមូល និងបង្ហូរទឹកកខ្វក់រួមមានតំណភ្ជាប់ អណ្ដូងលូ និងបណ្ដាញលូ (បណ្ដាញលូរួមបណ្ដាញលូដាច់ដោយឡែក បណ្ដាញលូមេ បណ្ដាញលូមេរង បណ្ដាញលូខ្នែង និងបណ្ដាញលូខ្នែងរង)។

**អាងបង្គន់អនាម័យ** សំដៅដល់អាងទទួលទឹកកខ្វក់ពីបង្គន់អនាម័យ និងបន្ទប់ទឹក ដើម្បីស្តុក និងបំបែកសំណល់សរីរាង្គក្នុងទឹកកខ្វក់ មុនការបង្ហូរចេញទៅក្នុងប្រព័ន្ធលូសាធារណៈ។

៦២៦០៩៥

**ឯកសារឧបសម្ព័ន្ធ**

- ផែនទីប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុនិងតំបន់ជុំវិញ ចក្ខុវិស័យឆ្នាំ២០៣៨
- ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូនសាធារណៈក្រុងព្រះសីហនុនិងតំបន់ជុំវិញ ចក្ខុវិស័យឆ្នាំ ២០៣៨
- ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍប្រព័ន្ធទឹកស្អាតក្រុងព្រះសីហនុនិងតំបន់ជុំវិញ ចក្ខុវិស័យឆ្នាំ២០៣៨
- ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍសង្គមសេដ្ឋកិច្ចក្រុងព្រះសីហនុនិងតំបន់ជុំវិញ ចក្ខុវិស័យឆ្នាំ២០៣៨
- ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍវិស័យវប្បធម៌និងកីឡាដ្ឋានក្រុងព្រះសីហនុនិងតំបន់ជុំវិញ ចក្ខុវិស័យឆ្នាំ ២០៣៨
- ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍវិស័យអប់រំក្រុងព្រះសីហនុនិងតំបន់ជុំវិញ ចក្ខុវិស័យឆ្នាំ២០៣៨
- ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍវិស័យសុខាភិបាលក្រុងព្រះសីហនុនិងតំបន់ជុំវិញ ចក្ខុវិស័យឆ្នាំ២០៣៨
- ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍវិស័យទេសចរណ៍ ផ្ទៃបៃតង និងលម្ហសាធារណៈក្រុងព្រះសីហនុនិងតំបន់ជុំវិញ ចក្ខុវិស័យឆ្នាំ២០៣៨
- ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍបណ្ដាញហេដ្ឋារចនាសម្ព័ន្ធក្រុងព្រះសីហនុនិងតំបន់ជុំវិញ ចក្ខុវិស័យឆ្នាំ ២០៣៨
- ប្លង់បទប្បញ្ញត្តិប្រើប្រាស់ដីតំបន់ឆ្នេរអូរត្រេះ
- ប្លង់បទប្បញ្ញត្តិប្រើប្រាស់ដីតំបន់ឆ្នេរពយជីទាវម៉ៅ
- ប្លង់បទប្បញ្ញត្តិប្រើប្រាស់ដីតំបន់ឆ្នេរព្រែកព្រែង។

២២០៩៤៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនទីប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុនិងតំបន់ជុំវិញ ចក្ខុវិស័យឆ្នាំ ២០៣៥



ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូនសាធារណៈ ក្រុងព្រះសីហនុនិងតំបន់ជុំវិញ ចក្ខុវិស័យឆ្នាំ ២០៣៥




Projection: UTM
Datum: WGS84
Zone: 48 North
Unit: Meter
Scale: 1:115,000
Paper Size: A3 Landscape

# ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍសង្គមសេដ្ឋកិច្ច ក្រុងព្រះសីហនុនិងតំបន់ជុំវិញ ចក្ខុវិស័យឆ្នាំ ២០៣៥



# ផែនទីយុទ្ធសាស្ត្រគ្រប់គ្រងប្រើប្រាស់ដីកម្រិតតំបន់ ក្រុងព្រះសីហនុនិងតំបន់ជុំវិញ ចក្ខុវិស័យឆ្នាំ ២០៣៥



| | | | |
|---|---|---|---|
| Projection: | UTM | Unit: | Meter |
| Datum: | WGS84 | Scale: | 1:115,000 |
| Zone: | 48 North | Paper Size: | A3 Landscape |

# ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍវិស័យធំៗ ក្រុងព្រះសីហនុនិងតំបន់ជុំវិញ ចក្ខុវិស័យឆ្នាំ ២០៣៥



ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍវិស័យសុខាភិបាល ក្រុងព្រះសីហនុនិងតំបន់ជុំវិញ ចក្ខុវិស័យឆ្នាំ ២០៣៨





| | | | |
|---|---|---|---|
| Projection: | UTM | Unit: | Meter |
| Datum: | WGS84 | Scale: | 1:115,800 |
| Zone: | 48 North | Paper Size: | A3 Landscape |

# ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ក្រុងព្រះសីហនុនិងតំបន់ជុំវិញ ចក្ខុវិស័យឆ្នាំ ២០៣៥



# បទបញ្ញត្តិប្រើប្រាស់ដីតំបន់ឆ្នេរអូរត្រេះ



# បទបញ្ញត្តិប្រើប្រាស់ដីតំបន់ឆ្នេរពាមជំនាងម៉ៅ



# បទប្បញ្ញត្តិប្រើប្រាស់ដីតំបន់ឆ្នេរព្រែកក្រោង



# ប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុ

## ចក្ខុវិស័យឆ្នាំ ២០៣៨



**រៀបចំដោយ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

អាសយដ្ឋានៈ ដីឡូត៍លេខ ២០០៥ ផ្លូវលេខ ៣០៧ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរសព្ទ (៨៥៥) ២៣ ៨៨៦ ៩៩៩
គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

ប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុ ចក្ខុវិស័យឆ្នាំ ២០៣៨